ឯកសារព័ត៌មាន

ផ្សាយនៅលើគេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គម

របស់អាជ្ញាធរជាតិអប្សរា

ឆ្នាំ ២០២០ ប្រចាំឆមាសទី២

ភូមិបង្គោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
០៦៣ ៧៦៥ ៥៧៧ ០៦៣ ៧៦៥ ៥៧៦
info@apsaraauthority.gov.kh apsaraautorite
www.apsaraauthority.gov.kh apsara authority

នាយកដ្ឋានផ្សព្វផ្សាយ នៃអាជ្ញាធរជាតិអប្សរា បានកត់ត្រា និងផ្សព្វផ្សាយជាប្រចាំនូវរាល់សកម្មភាពរបស់ថ្នាក់ដឹកនាំ និង សកម្មភាពការងារនៃអាជ្ញាធរជាតិអប្សរា តាមរយៈគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គម របស់អាជ្ញាធរជាតិអប្សរា និងចែកចាយទៅតាមបណ្តាញសារព័ត៌មានជាដៃគូជាច្រើនទៀត ។ ឯកសារទាំងនេះ បានជូនជ្រាបដល់មហាជនទាំងក្នុងឧទ្យានអង្គរ និងមហាជនទូទៅ និងបានបង្កើនការយល់ដឹងអំពីកិច្ចការអភិរក្សបេតិកភណ្ឌ។

រាល់ព្រឹត្តិការណ៍ព័ត៌មាន ដែលមាននៅក្នុងឯកសារនេះ ត្រូវបានដកស្រង់ទាំងស្រុងចេញពីគេហទំព័ររបស់អាជ្ញាធរជាតិអប្សរា សម្រាប់រក្សាទុកតែប៉ុណ្ណោះ។

មាតិកា

ប្រចាំខែកក្កដា

- ទោចមុដគូទី៣បានព្រលែងនៅក្នុងព្រៃរមណីយដ្ឋានអង្គរក្រោយបន្សាំអស់រយៈពេលមួយឆ្នាំកន្លះ ១
- អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យរៀបចំការងារមួយចំនួនក្នុងតំបន់រមណីយដ្ឋានអង្គរ ២
- នាយកដ្ឋានរៀបចំដែនដីនៃអាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យប្រជាពលរដ្ឋ
  ធ្វើលំនៅដ្ឋាននិងជួសជុលចំនួន៤៩ករណី ក្នុងអំឡុងសប្តាហ៍ទី៤នៃខែមិថុនា ៣
- ៦ខែ ដើមឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាផ្តល់ការអនុញ្ញាតជួសជុលកែលម្អលំនៅដ្ឋាន
  សាងសង់សំណង់ស្រាលដល់អ្នកស្រុកអង្គរចំនួន១៩៥៩គ្រួសារ ៤
- អាជ្ញាធរជាតិអប្សរានឹងចូលរួមសហការជាមួយអគ្គិសនីកម្ពុជារៀបចំតាំងបង្ហាញ
  នៅសារមន្ទីរថាមពលកកើតឡើងវិញ និងឧទ្យានជាតិសម្តេច ហ៊ុន សែន កំពត ៥
- អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា៖ រាល់សំណង់ ឬអគារនានា ដែលមានភាពស្របច្បាប់
  គឺអាជ្ញាធរជាតិអប្សរា មិនដែលបដិសេធនោះទេ ៦
- អាជីវករ៤នាក់ទៀតបានស្ម័គ្រចិត្តរុះរើសំណង់ភោជនីយដ្ឋានរបស់ខ្លួននៅមុខប្រាសាទអង្គរវត្ត ៧
- សេចក្តីសម្រេចស្តីពី ការលុបឈ្មោះបុគ្គលិក នៃអាជ្ញាធរជាតិអប្សរា.. ៨
- ស្ថានីយបណ្តុះកូនឈើ៨ហិកតារបស់អាជ្ញាធរជាតិអប្សរាបណ្តុះប្រភេទពូជឈើកម្រ៥ប្រភេទនៅកម្ពុជា ៩
- លោកជំទាវ ភឿង សកុណា ដឹកនាំកិច្ចប្រជុំពិនិត្យការងារពាក់ព័ន្ធផែនការមេវិស័យទេសចរណ៍ ១០
- លោកជំទាវ ភឿង សកុណា ប្រគេនទៀនព្រះវស្សានិងទេយ្យទានព្រះគ្រូចៅអធិការវត្តរាជបូណ៌ ១១
- លោកជំទាវ ភឿង សកុណា ចូលរួមកិច្ចប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើពង្រាងផែនការមេ
  វិស័យទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២០-២០៣៥ .... ១២
- ដើមឈើមួយចំនួនដែលមានហានិភ័យខ្ពស់ក្នុងរមណីយដ្ឋានអង្គរនឹងត្រូវដកហូតនិងកាត់ក្រី ១៣
- អាជ្ញាធរជាតិអប្សរាបន្តជួយសម្រួលដល់ការងារសាងសង់របស់ប្រជាពលរដ្ឋ ១៤
- សេចក្តីអំពាវនាវស្តីពី ការស្ម័គ្រចិត្តរុះរើតូបលក់ដូរអចិន្ត្រៃយ៍របស់របស់អាជីវករ
  នៅបរិវេណខាងលិចមុខប្រាសាទអង្គរវត្ត ១៥
- អាជ្ញាធរជាតិអប្សរាចូលរួមដាំកូនឈើឡើងវិញនៅទីបញ្ជាការដ្ឋានយោធភូមិភាគទី៤ .... ១៦
- អាជ្ញាធរជាតិអប្សរា បានចែកចាយកូនឈើជូនសាធារណជនបានចំនួនជិត៥ម៉ឺនដើមហើយ ១៧
- លោកជំទាវ ភឿង សកុណា បើកកិច្ចប្រជុំផ្ទៃក្នុងពិភាក្សាលើពង្រាងផែនការមេវិស័យទេសចរណ៍
  ខេត្តសៀមរាបឆ្នាំ២០២០-២០៣៥.. ១៨
- ដើមឈើប្រណីតនិងឈើផ្កាព្រៃចំនួន៤០០ដើមត្រូវបានដាំក្នុងបរិវេណប្រាសាទអង្គរវត្ត
  ក្រោមប្រធានបទ "សន្តិភាព យុត្តិធម៌ សាសនា បេតិកភណ្ឌ បរិស្ថាន".. ១៩
- អគ្គនាយកអាជ្ញាធរជាតិអប្សរា៖ ដើមឈើមានតួនាទីសំខាន់ក្នុងការងារថែរក្សាអភិរក្សប្រាសាទ
  បុរាណ នៅក្នុងតំបន់អង្គរ.. ២០
- អាជ្ញាធរជាតិអប្សរាផ្តល់កូនឈើជូនមន្ទីរបរិស្ថានខេត្តសៀមរាបចំនួន២៥០០ដើមបន្ថែមទៀត ២១
- បាឋកថាស្តីអំពី របនាសម្ពន្ធសំណង់ឈើនៅស្រះអង្គរ.. ២២
- អាជ្ញាធរជាតិអប្សរាបន្តកិច្ចប្រជុំពិភាក្សាលើពង្រាងផែនការមេវិស័យទេសចរណ៍ខេត្តសៀមរាប
  ឆ្នាំ២០២០-២០៣៥.. ២៣
- អាជ្ញាធរជាតិអប្សរាសហការជាមួយអគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ
  នៃក្រសួងផែនការដាំកូនឈើ៧៥០ដើមក្នុងរមណីយដ្ឋានអង្គរ.. ២៤
- អាជ្ញាធរជាតិអប្សរាសហការជាមួយមន្ត្រីនៃរាជបណ្ឌិតសភាកម្ពុជាដាំកូនឈើ២០០០ដើម
  នៅខាងកើតប្រាសាទប្រី ២៥

- សិលាចារឹកដែលរកឃើញនៅប្រាសាទទន្លេស្ងួតត្រូវបានចុះលេខ K.1459 ក្នុងបញ្ជីសារពើភណ្ឌសិលាចារឹកកម្ពុជា ..២៦
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា អាជ្ញាធរមូលដ្ឋាន ពិនិត្យ និងអនុញ្ញាត សំណើសុំជួសជុលសំណង់តូចតាចរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៣៦ សំណើ ២៧
- បាឋកថាស្តីអំពី ‹ព្រះពុទ្ធបដិមានៅអង្គរវត្ត› ២៨
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ចុះពិនិត្យ និងដោះស្រាយ សំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៨សំណើ ២៩
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ ៣០
- លិខិតអបអរសាទរលោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ៣១
- លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា អញ្ជើញចុះពិនិត្យរូបចម្លាក់ ឧបករណ៍ភ្លេងបុរាណនៅតាមប្រាសាទក្នុងរមណីយដ្ឋានអង្គរ ៣២
- អ្នកជំនាញអាជ្ញាធរជាតិអប្សរាបង្ហាញថា បដិមាដែលប្រទះឃើញនៅប្រាសាទអង្គរវត្ត គឺមិនមែនជាការកប់ចោលទេ ៣៣
- អាជ្ញាធរជាតិអប្សរាផ្តល់កូនឈើ៣០០ដើមដល់ព្រះសង្ឃតំណាងសមាគមជីវិតនិងក្តីសង្ឃឹម ៣៤
- ផ្ទៃដីដែលធ្លាប់ទន្ទ្រានខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរត្រូវបានដាំកូនឈើឡើងវិញ ៣៥
- មន្ត្រី-បុគ្គលិកចំនួន៤០រូបនៃអាជ្ញាធរជាតិអប្សរាទទួលការបណ្តុះបណ្តាល អំពី របបសារព័ត៌មាន ការផ្តល់ព័ត៌មាន ទទួលព័ត៌មានក្នុងរង្វង់ មន្ត្រី-បុគ្គលិក ៣៦
- អ្នកជំនាញអាជ្ញាធរជាតិអប្សរារួមគ្នាបង្ហាញពី‹អាថ៌កំបាំងសំណង់ប្រាសាទនៅក្រោមកុដិវត្តលលៃ› ៣៧
- អាជ្ញាធរជាតិអប្សរាផ្តល់កូនឈើ៥០ដើមដល់ពលរដ្ឋនៅភូមិជ្រាវ ៣៨
- ក្នុងខែកក្កដាឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យនិងផ្តល់នូវប្រឹក្សាយោបល់បច្ចេកទេស សាងសង់លំនៅដ្ឋានដល់អ្នកស្រុកអង្គរចំនួន៣៨៧គ្រួសារ ៣៩
- អាជ្ញាធរជាតិអប្សរានឹងប្រើពេល៤ខែអភិរក្សនិងជួសជុលប្រាសាទដំរីក្រាបនៅលើភ្នំគូលែន ៤០
- កូនឈើ១,២០០ ត្រូវបានផ្តល់ជូនអ្នកភូមិក្នុងខេត្តសៀមរាប ៤១
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន២១២ ករណីក្នុងខែកក្កដា ឆ្នាំ២០២០ ....៤២
- អាជ្ញាធរជាតិអប្សរាបន្តជួយសម្រួលដល់ការងារសាងសង់របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ៤៣

ប្រចាំខែសីហា

- អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យសកម្មភាពគម្រោងផ្សេងៗ ក្នុងតំបន់រមណីយដ្ឋានអង្គរ ៤៧
- ឯកឧត្តម ឃិត ចាន់ដារដ្ឋ៖ ព្រៃឈើជាសម្បត្តិរួមដ៏មានសារៈសំខាន់បំផុតរបស់មនុស្ស បរិស្ថាន និងបុរាណដ្ឋាន.....៤៨
- រយៈពេល២ថ្ងៃដើមខែសីហា អាជ្ញាធរជាតិអប្សរាចែកជូនកូនឈើជិត២ពាន់ដើម ដល់សាធារណជន..........៤៩
- លិខិតអបអរសាទរក្នុងឱកាសខួបកំណើតគម្រប់៦៨ឆ្នាំឈានចូល៦៩ឆ្នាំ ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ៥០
- កូនឈើចំនួន១,៤០០ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាផ្តល់ជូនដល់ស្ថាប័នក្នុង ខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ ៥១
- ប្រាសាទបាយក្អែកនឹងរៀបចំឱ្យក្លាយជាសារមន្ទីរលម្ហ ៥២
- ត្រឹម២ថ្ងៃ អាជ្ញាធរជាតិអប្សរាចែកកូនឈើជាង៤ពាន់ដើមទៀតដល់សាធារណជន..........៥៣
- អាជ្ញាធរជាតិអប្សរានឹងបន្តចែកកូនឈើដល់សាធារណជនទូទៅឲ្យបាន១១ម៉ឺនដើម ៥៤
- អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំប្រជុំពិភាក្សាតាមដានការអនុវត្តការងារភ្នាក់ងារទេសចរណ៍ ៥៥

- អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលាស្ដីអំពី ‹ប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ សម្រាប់ឆ្នាំ២០២០›........................ ៥៦
- អាជ្ញាធរជាតិអប្សរាជួសជុលនិងស្ដារប្រព័ន្ធបង្ហូរទឹកចាស់នៅលើស្ពានហាលខាងលិច
  ប្រាសាទអង្គរវត្តឱ្យដំណើរការឡើងវិញ ៥៧
- កូនឈើចំនួន ៣,៤០០ដើមបន្ថែមទៀត បានចែកជូនសាធារណជន ៥៨
- ភ្ញៀវទេសចរជាច្រើន ទស្សនាប្រាសាទអង្គរវត្តអំឡុងថ្ងៃឈប់សម្រាក... ៥៩
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមពិធីបួងសួងសុំសេចក្ដីសុខរៀបចំព្រឹត្តិការណ៍ សម្រាកសៀមរាប ៦០
- ប្រជាពលរដ្ឋបន្តដើរកម្សាន្តក្នុងរមណីយដ្ឋានអង្គរនាថ្ងៃឈប់សម្រាក ៦១
- អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើជិត៤ពាន់ដើមបន្ថែមទៀតដល់សាធារណជន.................................... ៦២
- ដើមឈើចំនួន៨,៦០០ដើម បានដាំនៅតំបន់ជុំវិញខេត្តសៀមរាប ៦៣
- អាជីវករលក់ដូរនៅមុខប្រាសាទអង្គរវត្តបន្តការរុះរើតូបលក់ដូររបស់ខ្លួនដើម្បីត្រៀមទៅលក់ដូរនៅកន្លែងថ្មី............ ៦៤
- សេចក្ដីជូនដំណឹងស្ដីពីការបិទជាបណ្ដោះអាសន្នសម្រាប់ការទស្សនាថ្ងៃលិចនៅប្រាសាទប្រែរូប ៦៥
- អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើជិត២ពាន់ដើមទៀតទៅសាធារណជន ៦៦
- នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គររៀបចំផ្លាស់ប្ដូរទីតាំងបំពេញការងារ
  របស់ប្រធាន-អនុប្រធានភ្នាក់ងារទេសចរណ៍ប្រចាំឆ្នាំ.. ៦៧
- គម្រោងផលិតឯកសារវីដេអូ ‹អង្គរ និងលើសពីនេះ› បានចាប់ផ្ដើម ៦៨
- សំណង់ភោជនីយដ្ឋាន តូបលក់ដូរ អាគាររដ្ឋសរុបប្រមាណ១៥០ខ្នងត្រូវបានរុះរើរួចរាល់ទាំងស្រុង
  នៅមុខបរិវេណខាងលិចប្រាសាទអង្គរវត្ត.. ៦៩
- រួមគ្នាដាំកូនឈើដើម្បីលើកកម្ពស់គម្របព្រៃឈើ បរិស្ថាន និងការអភិរក្សប្រាសាទក្នុងរមណីយដ្ឋានអង្គរ.............. ៧០
- អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា៖ ទិដ្ឋភាពខាងលិចប្រាសាទអង្គរវត្តទាំងស្រុងកំពុងតែកែប្រែឱ្យ
  កាន់តែមានសម្រស់ស្រស់ស្អាត.. ៧១
- បាឋកថាស្ដីអំពី ‹វឌ្ឍនភាពនៃការជួសជុលស្ពានហាលអង្គរ›.. ៧២
- សំណើចំនួន២២ករណីត្រូវបានអាជ្ញាធរជាតិអប្សរាចុះពិនិត្យនៅសប្ដាហ៍ទី៤នៃខែសីហា ៧៣
- អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើជាង៣ពាន់ដើមបន្ថែមទៀតដល់សាធារណជន ៧៤

ប្រចាំខែកញ្ញា

- អាជ្ញាធរជាតិអប្សរាសហការជាមួយរដ្ឋបាលក្រុងសៀមរាប ចុះរុះរើសំណង់ខុសច្បាប់
  នៅទីបុរាណដ្ឋានត្រពាំងហៃផ្កាជាលើកទី២ .... ៧៧
- ចម្លាក់ប្រអប់ព្រះហស្តឆ្វេងព្រះពុទ្ធបដិមាដ៏ធំមួយបានប្រទះឃើញនៅខាងត្បូងនៃប្រាសាទបាយ័ន្ត ៧៨
- សកម្មភាពដាំកូនឈើរបស់ក្រុមភ្នាក់ងារព្រៃឈើរបស់អាជ្ញាធរជាតិអប្សរា.. ៧៩
- អគ្គនាយកអាជ្ញាធរជាតិអប្សរានិងសហការីចុះពិនិត្យតាមដានវឌ្ឍនភាពការងារ
  នៅតាមការដ្ឋាននានាក្នុងតំបន់អង្គរ ៨០
- អាជ្ញាធរជាតិអប្សរាស្វាគមន៍ការចូលរួមរបស់ធនាគារ CIMB ក្នុងការដាំកូនឈើក្នុងរមណីយដ្ឋានអង្គរ ៨១
- ក្រុមហ៊ុន Minebea ចូលរួមដាំកូនឈើជាមួយអាជ្ញាធរជាតិអប្សរា ចំនួន៣០០ដើម
  នៅខាងត្បូងប្រាសាទបន្ទាយក្ដី.. ៨២
- កូនឈើជិត២ពាន់ដើមដែលទទួលបានពីអាជ្ញាធរជាតិអប្សរា បានយកទៅដាំដើម្បីអភិវឌ្ឍន៍មូលដ្ឋាន................. ៨៣
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ................ ៨៤
- ទូតឥណ្ឌាចប់អាណត្តិជួបសម្ដែងការគួរសមនិងជម្រាបលាថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ៨៥
- ភ្នាក់ងារទេសចរណ៍ទទួលការបណ្ដុះបណ្ដាលពីការគ្រប់គ្រងហានិភ័យប្រាសាទ... ៨៦
- វិទ្យាស្ថានបារាំងចុងបូព៌ាប្រគល់ឯកសារស្រាវជ្រាវតាំងពីជំនាន់បារាំងឱ្យអាជ្ញាធរជាតិអប្សរាថែរក្សាទុក ៨៧
- អ្នកជំនាញធ្វើបទបង្ហាញពីដំណើរការជួសជុលស្ពានហាលខាងលិចអង្គរវត្ត.. ៨៨

- សេចក្តីប្រកាសព័ត៌មាន ៨៩
- សំណង់ព្រះវិហារបុរាណនៅវត្តរាជបូណ៌ប្តូរសោភ័ណភាពថ្មីដ៏ស្រស់ស្អាតបន្ទាប់ពីជួសជុលហើយ ៩០
- ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមពិភាក្សាជាមួយសមាគមសណ្ឋាគារ
  អំពីវិស័យទេសចរណ៍នៅខេត្តសៀមរាប ៩១
- អាជ្ញាធរជាតិអប្សរាស្វាគមន៍គ្រប់ស្ថាប័នដើម្បីចូលរួមដាំកូនឈើក្នុងរមណីយដ្ឋានអង្គរ ៩២
- ក្នុងពាក់កណ្តាលខែកញ្ញានេះ អាជ្ញាធរជាតិអប្សរាបានចែកកូនឈើជាង ១៥,០០០ដើម
  បន្ថែមទៀតដល់សាធារណជន ៩៣
- ការប្រកាន់ទម្លាប់នៃការចូលប្រាសាទដូចពីបុរាណកាល គឺរក្សាបានទាំងតម្លៃអភិរក្សប្រាង្គប្រាសាទ ៩៤
- អាជ្ញាធរជាតិអប្សរាបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ជាមួយរមណីយដ្ឋានហ័ងសាន ៩៦
- ក្រុមការងារនៃនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការចូលរួមដាំកូនឈើនៅតំបន់ប្រាសាទព្រះខ័ន ៩៧
- ក្រុមការងារសណ្តាប់ធ្នាប់សាធារណៈនៃអាជ្ញាធរជាតិអប្សរាចុះណែនាំអ្នកលក់ដូរតាមប្រាសាទ ៩៨
- ក្រុមការងារគ្រប់គ្រងទឹករបស់អាជ្ញាធរជាតិអប្សរាប្រមូលទឹកស្តុកទុកមិនឱ្យជន់លិច
  រមណីយដ្ឋានអង្គរនាអំឡុងពេលមានភ្លៀងធ្លាក់ខ្លាំងក្រោមឥទ្ធិពលរបស់ព្យុះនូល ៩៩
- ក្រុមការងារសណ្តាប់ធ្នាប់សាធារណៈនៃអាជ្ញាធរជាតិអប្សរាចុះរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវ
  ក្នុងរមណីយដ្ឋានអង្គរ ១០០
- ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម បំផុសគំនិតឱ្យពលរដ្ឋខ្មែរដាំដើមព្នៅឡើងវិញ ១០១
- ប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន៣០៩គ្រួសារ ត្រូវបានអាជ្ញាធរជាតិអប្សរាចុះពិនិត្យលក្ខណៈ
  បច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន ១០២
- កូនឈើចំនួន៥០០ដើម ត្រូវបានដាំនៅបរិវេណវត្តតាំងតុក្នុងក្រុងអង្គរធំ ១០៣
- អ្នកជួសជុលប្រាសាទភ្នំបាខែងមានមោទនភាពចំពោះការងារអភិរក្សប្រាង្គប្រាសាទ ១០៤
- បរិវេណមុខប្រាសាទអង្គរវត្តបានប្រែមុខមាត់ថ្មីក្រោយមានការអភិវឌ្ឍជាបន្តបន្ទាប់ ១០៥
- អាជ្ញាធរជាតិអប្សរា បានកាត់សម្អាតដើមឈើដែលដួលរលំដោយសារភ្លៀង និងខ្យល់កន្ត្រាក់
  ក្នុងរដូវវស្សាឆ្នាំនេះបានចំនួន៩៨ដើម ១០៦
- ភាគីបារាំងប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរក្នុងការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច ១០៧
- អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើដល់សាធារណជនជាង៣ពាន់ដើមនៅចុងខែកញ្ញានេះ ១០៨

ប្រចាំខែតុលា

- ការជួសជុលផ្ទះ និងសាងសង់សំណង់តូចតាចចំនួន២៥០៧សំណើ
  ត្រូវបានអនុញ្ញាតក្នុងរយៈពេល៩ខែ ដោយអាជ្ញាធរជាតិអប្សរា ១១១
- លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន អញ្ជើញទស្សនកិច្ចការងារនៅរមណីយដ្ឋានអង្គរ ១១២
- ក្រុមកម្មករកំពុងមមាញឹកជួសជុលប្រាសាទមេបុណ្យខាងលិច ១១៣
- អាជ្ញាធរជាតិអប្សរាបញ្ចប់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពភ្នាក់ងារទេសចរណ៍នៅតាមប្រាសាទក្នុងតំបន់អង្គរ. ១១៤
- សត្វព្រៃ២ប្រភេទផ្សេងទៀត គ្រោងដោះលែងបន្ថែមក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ ១១៥
- បន្ទប់ទឹកសាធារណៈកម្រិតស្តង់ដារអន្តរជាតិនឹងដាក់ឱ្យដំណើរការនៅបរិវេណមុខប្រាសាទអង្គរវត្ត ១១៦
- រចនាសម្ព័ន្ធកំពែងទី៣ប្រាសាទបន្ទាយស្រីត្រូវបានជួសជុលឱ្យផុតពីហានិភ័យ ១១៧
- កូនឈើចម្រុះចំនួន៤៥០ដើមត្រូវបានដាំឡើងវិញនៅទីតាំងកាប់ទន្ទ្រាននៃតំបន់ការពារប្រាសាទបន្ទាយអំពិល ១១៨
- រចនាសម្ព័ន្ធកំពែងទី៣ប្រាសាទបន្ទាយស្រីត្រូវបានជួសជុលឱ្យផុតពីហានិភ័យ ១១៩
- ចរាចរណ៍ចេញចូលប្រាសាទអង្គរវត្តតាមស្ពានហាលខាងលិច នឹងអាចចាប់ផ្តើមឡើងវិញ
  នៅខែសីហា ឆ្នាំ២០២១ .... ១២០

- អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋមដល់សិក្ខាកាមចំនួន១២០នាក់ ១២១
- អាជ្ញាធរជាតិអប្សរា គ្រោងដាំប្រភេទផ្កាព្រៃនៅតាមផ្លូវក្នុងតំបន់រមណីយដ្ឋានអង្គរ ១២២
- លិខិតជូនពរលោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា
  នាឱកាសខួបកំណើតគម្រប់៦០ឆ្នាំឈានចូល៦១ឆ្នាំ ១២៣
- អាជ្ញាធរជាតិអប្សរាសម្រេចបញ្ឈប់បុគ្គលិកដែលប្រព្រឹត្តិខុសនឹងច្បាប់ចេញពីស្ថាប័ន ១២៤
- អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យការដ្ឋានមួយចំនួនក្នុងតំបន់រមណីយដ្ឋានអង្គរ ១២៥
- អាជ្ញាធរជាតិអប្សរារៀបចំផ្លូវចូលរមណីយដ្ឋានភ្នំក្បាលស្ពានដែលរងការបំផ្លាញដោយសារទឹកភ្លៀង ១២៦
- រយៈពេល២ថ្ងៃ ក្រុមសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល
  ផ្ទះប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៦០សំណើ ១២៧
- ក្រុមការងាររៀបចំទីលានបដិសណ្ឋារកិច្ចមុខអង្គរវត្តបន្តរៀបចំអគារផ្តល់ព័ត៌មាន និងបកស្រាយវប្បធម៌ ១២៨
- អាជីវករសម្តែងការរីករាយនឹងកន្លែងលក់ដូរថ្មីនៅទីលានបដិសណ្ឋារកិច្ចប្រាសាទអង្គរវត្ត ១២៩
- ទឹកជាច្រើនលានម៉ែត្រគូបត្រូវបានប្រមូលរក្សាទុក ១៣០
- សកម្មភាពកម្មករដឹកជញ្ជូនថ្មទៅជួសជុលប្រាសាទកណ្តាលស្រះស្រង់ ១៣១
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យប្រព័ន្ធទ្វាររំដោះទឹកក្នុងតំបន់រមណីយដ្ឋានអង្គរ ១៣២
- ព្រះចៅអធិការវត្តព្រះឥន្ទ្រទេពប្រគល់បំណែកបដិមាចំនួន៤១ដុំជូនអាជ្ញាធរជាតិអប្សរារក្សាទុក ១៣៣
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងដោះស្រាយសំណើ
  សុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៥សំណើ ១៣៤
- រដ្ឋមន្ត្រីក្រសួងព័ត៌មានចុះសិក្សាស្វែងយល់ពីការងារអភិវឌ្ឍន៍នៅបរិវេណមុខប្រាសាទអង្គរវត្ត ១៣៥
- សូមថ្វាយមហាព្រះរាជកុសល ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាវីរក្សត្រ
  ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" ១៣៦
- អាជ្ញាធរជាតិអប្សរាចូលរួមគោរពព្រះវិញ្ញាណក្ខន្ធថ្វាយព្រះរាជកុសល
  ព្រះបរមរតនកោដ្ឋខួបសោយទិវង្គត៨ព្រះវស្សា ១៣៧
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ប្រចាំក្រុងសៀមរាបចុះពិនិត្យ
  និងដោះស្រាយសំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋបាន៨សំណើ ១៣៨
- អាជ្ញាធរជាតិអប្សរាបណ្តុះនិងដាំដើមត្នោតរាប់ពាន់ដើមក្នុងរមណីយដ្ឋានអង្គរ ១៣៩
- របៀបផ្តិតសិលាចារឹក ១៤០
- អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ ១៤២
- ស្ថានភាពទឹកក្នុងរមណីយដ្ឋានអង្គរស្ថិតក្រោមការគ្រប់គ្រង ១៤៣
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងដោះស្រាយសំណើសុំ
  ជួសជុលផ្ទះប្រជាជនក្នុងឧទ្យានអង្គរបាន១០សំណើ ១៤៤
- អាជ្ញាធរជាតិអប្សរាសហការជាមួយសារព័ត៌មានអេឡិចត្រូនិកថ្មីៗដើម្បីរៀបចំឯកសារស្តីពីអង្គរ ១៤៥
- ក្រុមការងារគ្រប់គ្រងព្រៃឈើ កំពុងកាត់ដកហូតដើមឈើ
  ដែលមានហានិភ័យខ្ពស់ក្នុងបរិវេណប្រាសាទបន្ទាយស្រី ១៤៦
- កុលាលភាជន៍ដែលបានពីការស្តារប្រឡាយនៅបរិវេណប្រាសាទព្រះខ័ន
  ត្រូវបានយកមករក្សាទុកដើម្បីជួសជុល ១៤៧
- សិក្ខាកាមចំនួន២៥រូប ទទួលបានការបណ្តុះបណ្តាលស្តីពី ‹ការអភិរក្ស និងគ្រប់គ្រងបេតិកភណ្ឌ› ១៤៨
- អាជ្ញាធរជាតិអប្សរា បានដាំដើមត្នោតចំនួន៧៣០ដើមបន្ថែមទៀតនៅតាមទំនប់បុរាណនៃរមណីយដ្ឋានអង្គរ ១៤៩
- អាជ្ញាធរជាតិអប្សរាសហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍របស់ប្រទេសស៊ុយអែត
  រៀបចំសិក្ខាសាលាស្តីពី ‹ការអភិវឌ្ឍទឹកស្អាត និងអនាម័យនៅទីក្រុងប្រកបដោយចីរភាព SUWAS› ១៥០

- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៩សំណើ....១៥១
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅបានចុះពិនិត្យ និងដោះស្រាយ សំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៤សំណើ....១៥២
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល
- ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៨សំណើ ១៥៣
- សារលិខិតថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនីព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសព្រះរាជពិធិខួបលើកទី១៦នៃការយាងគ្រងរាជសម្បត្តិ....១៥៤
- មន្ត្រីស្ថានទូតប្រទេសជប៉ុនចុះពិនិត្យនិងសិក្សាស្វែងយល់ពីការអភិរក្សនិងអភិវឌ្ឍន៍ ប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរ ១៥៥

ប្រចាំខែវិច្ឆិកា

- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៥សំណើ ១៥៩
- ខែតុលា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើជួសជុលផ្ទះ និងសាងសង់សំណង់តូចតាចចំនួន២៥៧សំណើ....១៦០
- ក្រុមការងារសហគមន៍ប្រចាំស្រុកបន្ទាយស្រី ចុះពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះបានចំនួន៥សំណើ ១៦១
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាប្រចាំស្រុកពួក និងក្រុងសៀមរាប ចុះពិនិត្យដោះស្រាយសំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋបាន១២សំណើ....១៦២
- អាជ្ញាធរជាតិអប្សរាបើកសិក្ខាសាលាស្តីអំពីដំណើរការគ្រប់គ្រងបរិស្ថានអង្គរ ១៦៣
- ភាជន៍ដីដុតពណ៌បៃតងមួយត្រូវបានប្រទះឃើញក្នុងដំណើរការជួសជុលប្រាសាទលលៃ....១៦៤
- អាជ្ញាធរជាតិអប្សរានិងអង្គការមូលនិធិប្រាសាទពិភពលោកពិភាក្សាបច្ចេកទេសជួសជុលប្រាសាទតាសោម ១៦៥
- សិក្ខាកាមចំនួន២៥រូបនៃវគ្គបណ្តុះបណ្តាល ‹ការអភិរក្សនិងគ្រប់គ្រងបេតិកភណ្ឌ› ចុះសិក្សាដោយផ្ទាល់ពីប្រវត្តិសាស្ត្រក្រុងអង្គរធំ ១៦៦
- អាជ្ញាធរជាតិអប្សរាបិទវគ្គបណ្តុះបណ្តាលស្តីពីជំនាញ បច្ចេកទេសសង្គ្រោះបឋម បន្ទាប់ពីបានបណ្តុះបណ្តាលរយៈពេលមួយខែរួចមក....១៦៧
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា៣គោលដៅ ពិនិត្យ និងដោះស្រាយសំណើសុំ ជួសជុលផ្ទះប្រជាពលរដ្ឋបាន១៥សំណើ....១៦៨
- អាជ្ញាធរជាតិអប្សរាចូលរួមគោរពទិវាឯករាជ្យជាតិលើកទី៦៧ ....១៦៩
- ពលរដ្ឋបង្ហាញអារម្មណ៍គាំទ្រនិងរីករាយចំពោះការរៀបចំបរិវេណមុខប្រាសាទអង្គរវត្ត ១៧០
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ ប្រជាពលរដ្ឋបានចំនួន១៤សំណើ ១៧១
- អ្នករៀបចំសួនមុខប្រាសាទអង្គរវត្តបង្ហាញពីចំណាប់អារម្មណ៍ដែលបានបំពេញការងារសម្រាប់អង្គរ ១៧២
- ព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោសាប្រគល់ថ្មបុរាណចំនួន៣ដុំជូនអាជ្ញាធរជាតិអប្សរារក្សាទុកជាសម្បត្តិជាតិ ១៧៣
- អាជ្ញាធរជាតិអប្សរាសម្អាតប្រព័ន្ធលូនៅក្នុងរមណីយដ្ឋានអង្គរ....១៧៤
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសុំជួសជុលផ្ទះរបស់ ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៥សំណើ....១៧៥

- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៧សំណើ ១៧៦
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១២សំណើ ១៧៧
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៨សំណើ......................... ១៧៨
- ប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គររៀបរាប់ពីនិតិវិធីស្នើសុំការសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់............................ ១៧៩
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៨សំណើ ១៨០
- អាជ្ញាធរជាតិអប្សរាបើកកិច្ចប្រជុំសវនកម្មផ្ទៃក្នុងគ្រប់នាយកដ្ឋាន និងអង្គភាពចំណុះដើម្បីបញ្ជាក់ នូវភាពអនុលោមជាប្រចាំនៃប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ.. ១៨១
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១២សំណើ ១៨២
- អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលព្រះពុទ្ធបដិមាមួយអង្គនៅរួតបាកាណកំពូលប្រាសាទអង្គរវត្ត ១៨៣
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៨៤
- លិខិតចូលរួមរំលែកមរណទុក្ខ ឯកឧត្តម អ៊ឹង ហឿន ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប ១៨៥
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធឯកឧត្តម អ៊ឹង ហឿន ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប ១៨៦
- សវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ របស់អាជ្ញាធរជាតិអប្សរា បង្ហាញថាមានភាពល្អប្រសើរលើសឆ្នាំកន្លងមក ១៨៧
- យុវជននិងគ្រូបង្រៀនចំនួន១៥០នាក់នៃក្រសួងអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ស្វែងយល់អំពីការគ្រប់គ្រងបេតិកភណ្ឌក្នុងរមណីយដ្ឋានអង្គរ... ១៨៨
- អ្នកជំនាញអាជ្ញាធរជាតិអប្សរាធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យារកឃើញឡដុតភាជន៍ នៅខាងជើងខ្លោងទ្វារដីឆ្នាំងនៃក្រុងអង្គរធំ ១៨៩
- អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន ជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរ៣៩១គ្រួសារ ១៩០

ប្រចាំខែធ្នូ

- ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់ អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១៨០ករណី ១៩៣
- ស្ពានឈើចាស់នៅរមណីយដ្ឋានក្បាលស្ពានត្រូវបានរុះរើដើម្បីជួសជុលពង្រឹងសាឡើងវិញ ១៩៤
- ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយ សំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ... ១៩៥
- អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការងារតាមការដ្ឋានជួសជុលនៅក្នុងរមណីយដ្ឋានអង្គរ......................... ១៩៦
- អាជ្ញាធរជាតិអប្សរាបានចេញផ្សាយទស្សនាវដ្តីឈ្មោះថា ‹ព្រះនគរ›... ១៩៧
- សកម្មភាពថែទាំទ្រនល់ឈើការពារសត្វល្អិតនៅប្រាសាទភ្នំក្រោម... ១៩៨
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយ សំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ... ១៩៩

- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយ សំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ១៩៩
- អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើលំនៅដ្ឋាន និងជួសជុលតូចតាចចំនួន ២៨៤គ្រួសារក្នុងអំឡុង៦ខែចុងឆ្នាំ២០២០............ ២០០
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២០១
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២០២
- កិច្ចប្រជុំរបស់គណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ ត្រូវបានលើកពេល............ ២០៣
- អាជ្ញាធរជាតិអប្សរានិងស្ថាប័នពាក់ព័ន្ធចូលរួមបោះបង្គោលព្រំការពារបុរាណដ្ឋាននៅស្រុកវ៉ារិន............ ២០៤
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២០៥
- សារលិខិតជូនពរ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា............ ២០៦
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២០៧
- ខ្លោងទ្វារខាងកើតប្រាសាទតានៃនឹងបញ្ចប់ការជួសជុលជាស្ថាពរពីអ្នកជំនាញខ្មែរនាចុងឆ្នាំ២០២០............ ២០៨
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២០៩
- សត្វទោចមកុដ១គូចុងក្រោយ គ្រោងដោះលែងក្នុងព្រៃធម្មជាតិនៃក្រុងអង្គរធំ............ ២១០
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២១១
- អាជ្ញាធរជាតិអប្សរាកំពុងកាត់ដកហូតដើមឈើមានហានិភ័យខ្ពស់នៅប្រាសាទក្រោលរមាស លើភ្នំគូលែន............ ២១២
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២១៣
- អាជ្ញាធរជាតិអប្សរាកំពុងកាត់ដកហូតដើមឈើមានហានិភ័យខ្ពស់នៅប្រាសាទក្រោលរមាស លើភ្នំគូលែន............ ២១៤
- អាជ្ញាធរជាតិអប្សរា គ្រោងនឹងបញ្ចប់គម្រោងជួសជុលប្រាសាទកណ្តាលស្រះស្រង់នៅបំណាច់ឆ្នាំ២០២០............ ២១៥
- ក្រុមជំនាញផ្នែកព្រៃឈើនៃអាជ្ញាធរជាតិអប្សរា បានជួយកាត់ក្រី និងដកហូតដើមឈើ បង្ការគ្រោះថ្នាក់តាមការស្នើសុំពីប្រជាពលរដ្ឋ............ ២១៦
- ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំ នៃអាជ្ញាធរជាតិអប្សរាបរិច្ចាគថវិកា ជូនសម្តេចតេជោដើម្បីទិញវ៉ាក់សាំងកូវីដ-១៩............ ២១៧
- អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតការជួសជុលផ្ទះនិងសាងសង់សំណង់តូចតាចបាន ចំនួន៣០៨២គ្រួសារក្នុងឆ្នាំ២០២០............ ២១៨
- អាជ្ញាធរជាតិអប្សរាជួសជុលផ្លូវវង់ធំ ចាប់ពីចំណុចមុខប្រាសាទប្រែរូប រហូតដល់ខាងលិចប្រាសាទមេបុណ្យខាងកើត............ ២១៩
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២២០
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ............ ២២១
- អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលប្រាសាទដំរីក្រាបនៅលើខ្នងភ្នំគូលែន............ ២២២
- ក្រុមការងារព្រៃឈើនឹងចុះកាត់ដកហូតដើមឈើហានិភ័យ២ដើមនៅប្រាសាទអង្គរវត្ត............ ២២៣

- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល
ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២២៤
- សត្វស្វាកាចៗមួយចំនួននៅប្រាសាទបាយ័ននឹងត្រូវយកចេញទៅព្រលែងនៅក្នុងព្រៃក្រៅឧទ្យានអង្គរ ២២៥
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល
ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២២៦
- អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន
ជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន៨២៣គ្រួសារ ២២៧
- ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បណ្តុះបណ្តាលអ្នកជំនាញអាជ្ញាធរជាតិអប្សរា
ទាក់ទងនឹងការពង្រឹងសមត្ថភាពព្យាបាលនិងជួសជុលវត្ថុបុរាណតាមបែបវិទ្យាសាស្ត្រ ២២៨
- អាជ្ញាធរជាតិអប្សរាដាក់ឱ្យដំណើរការនូវប្រព័ន្ធស្រោចស្រពស្មៅនៅបរិវេណប្រាសាទអង្គរវត្ត ២២៩
- ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ
របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ២៣០
- ទិដ្ឋភាពផ្លូវមុខប្រាសាទអង្គរវត្ត ក្រោយស្លាបនារួច ២៣១
- សេចក្តីប្រកាសព័ត៌មានស្តីពីករណីចាប់សត្វស្វាកាចមួយចំនួនចេញពីតំបន់ឧទ្យានអង្គរ
យកទៅព្រលែងឲ្យរស់នៅបែបធម្មជាតិនៅតំបន់ក្រៅឧទ្យានអង្គរ ២៣២
- ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋ
ក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១៩១ករណី ២៣៣
- សារលិខិតថ្វាយព្រះពរ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ២៣៤
- សារលិខិតជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ២៣៥
- លិខិតជូនពរ លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណារដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ២៣៦

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែកក្កដា



ទោចម្កុដគូទី៣បានព្រលែងនៅក្នុងព្រៃរមណីយដ្ឋានអង្គរក្រោយបន្សាំអស់រយៈពេលមួយឆ្នាំកន្លះ

ផ្សាយនៅថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០២០

អង្គការសម្ពន្ធមិត្តសត្វព្រៃនិងរដ្ឋបាលព្រៃឈើក្រុងភ្នំពេញ ក្រោមកិច្ចសហការពីអាជ្ញាធរជាតិអប្សរា បានព្រលែងទោចម្កុដមួយគូបន្ថែមទៀតឱ្យរស់នៅតាមបែបធម្មជាតិនៅក្នុងព្រៃម្តុំខ្លោងទ្វារតាកាវ នៅព្រឹកថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ក្រោយបន្សាំក្នុងទ្រុងអស់រយៈពេលមួយឆ្នាំកន្លះ។

តាមការបញ្ជាក់របស់លោក និច ម៉ាក នាយកសង្គ្រោះសត្វព្រៃនៃអង្គការសម្ពន្ធមិត្តសត្វព្រៃថា នេះជាទោចម្កុដគូទី៣ ហើយដែលក្រុមការងារបានព្រលែងនៅក្នុងព្រៃរមណីយដ្ឋានអង្គរ។ យើងបានបន្សាំវាឱ្យនៅក្នុងទ្រុងសិន ដើម្បីឱ្យវាស្រឡាញ់គ្នា ពិនិត្យសុខភាពថាគ្មានជំងឺ ឱ្យវាចេះសម្របខ្លួននឹងធម្មជាតិ អាកាសធាតុ បរិយាកាស ស្គាល់កន្លែងខ្លាចមនុស្សតិចតួច ទើបអាចដោះលែងវាឱ្យរស់នៅក្នុងព្រៃបាន។ សម្រាប់លោក និច យល់ថា ទោចម្កុដជាប្រភេទសត្វស្លូត ហើយចំពោះការជ្រើសយកព្រៃក្នុងឧទ្យានអង្គរដើម្បីព្រលែងសត្វទោចម្កុដ ព្រោះព្រៃអង្គរមានសុវត្ថិភាពមានព្រៃស្អាត ធម្មជាតិល្អ មានអាហារគ្រប់គ្រាន់។
លក្ខណៈពិសេសរបស់ទោចម្កុដ ជាសត្វប្រកាន់ដៃគូ ស្មោះត្រង់នឹងដៃគូរស់នៅជាគ្រួសារ គម្លាតពីគ្រួសារ១ទៅគ្រួសារ១ប្រហែល១គីឡូម៉ែត្រកន្លះ អាយុ៦ឆ្នាំពេញវ័យ និងមានផ្ទៃពោះរយៈពេល៨ខែ មានកូនម្តង១ ហើយជាសត្វមិនបង្ករគ្រោះថ្នាក់ដល់មនុស្សឡើយ។

លោក ជូរ៉ា ឌីណា អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានឱ្យដឹងថា យើងបានសហការជាមួយរដ្ឋបាលព្រៃឈើ អង្គការសម្ពន្ធមិត្តសត្វព្រៃ តាំងពីឆ្នាំ២០១៣ ក្នុងការព្រលែងសត្វព្រៃជាច្រើនប្រភេទក្នុងព្រៃរមណីយដ្ឋានអង្គរ។ ក្នុងនោះ ទោចម្កុដ គឺយើងអាចព្រលែងបានតែ៤គ្រួសារទេ។ ចំពោះការថែទាំទាំងទោចម្កុដនិងសត្វផ្សេងៗ គឺមុនព្រលែងក្នុងព្រៃមានក្រុមការងារបន្សាំ ឱ្យចំណី តាមដានសុខភាព និងសុវត្ថិភាពផងដែរ។ អាជ្ញាធរជាតិអប្សរាក៏បានបង្កប់កាមេរ៉ានៅតាមទីតាំងមួយចំនួនឃើញថា សត្វព្រៃដែលក្រុមការងារព្រលែង គឺមានវត្តមានទាំងអស់។

កន្លងមក អាជ្ញាធរជាតិអប្សរារួមនឹងអង្គការសម្ពន្ធមិត្តសត្វព្រៃរដ្ឋបាលព្រៃឈើបានព្រលែងសត្វទោចម្កុដបានចំនួន៣ទីតាំងហើយ គឺនៅប្រាសាទតានៃ១គូ មានកូន៣ ខ្លោងទ្វារខ្មោច១គូ មានកូន២ និងគូទី៣ នៅខ្លោងទ្វារតាកាវ ហើយគ្រោងនឹងដាក់គូទី៤ គឺនៅបឹងសន្ធមា។ បន្ថែមពីនោះ ក៏មានព្រលែងសត្វឈ្លូស៤ក្បាល ស្វាព្រាហ្មណ៍១២ក្បាល សំពោចក្រអូប៥ក្បាល និងកេខ្លួនរលោង៥ក្បាល បច្ចុប្បន្នភេបង្កើតបានកូន២ហើយ។

ជាគោលដៅទៅអនាគតអាជ្ញាធរជាតិអប្សរាដោយសហការជាមួយអង្គការសម្ពន្ធមិត្តសត្វព្រៃ រដ្ឋបាលព្រៃឈើ នឹងយកសត្វប្រើស សត្វក្ងោក និងសត្វកេងកងមកព្រលែងនៅក្នុងរមណីយដ្ឋានអង្គរបន្ថែមទៀតដែរ៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យរៀបចំការងារ មួយចំនួនក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០១ ខែ កក្កដា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១ ខែកក្កដា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារចុះពិនិត្យ និងត្រៀមរៀបចំការងារមួយចំនួន នៅតាមប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ។ សកម្មភាពនេះ ជាយន្តការក្នុងការជំរុញឱ្យការងារទាំងឡាយប្រព្រឹត្តដោយរលូន និងមានប្រសិទ្ធភាពខ្ពស់។

ដោយចាប់ផ្តើមពិនិត្យនៅបរិវេណខាងមុខប្រាសាទអង្គរវត្ត ឯកឧត្តម អគ្គនាយក បានស្នើដល់ក្រុមការងារពាក់ព័ន្ធនានាសិក្សាពីគម្រោងសង់បង្គន់អនាម័យមួយកន្លែងទៀតក្បែរចំណតរថយន្តបច្ចុប្បន្ន ដើម្បីឆ្លើយតបតាមតម្រូវការរបស់ភ្ញៀវទេសចរនាពេលអនាគត។ ជាមួយគ្នានោះដែរ ឯកឧត្តមអគ្គនាយក ក៏បានណែនាំឱ្យក្រុមការងាររៀបចំ និងលើកតម្លៃឡើងវិញនៅទីទួលបុរាណដ្ឋានប្រាសាទបាយក្អែក (វាលខាងស្តាំដៃមុខប្រាសាទអង្គរវត្ត) ឱ្យក្លាយជាសារមន្ទីរលំហរ ដោយមានដាក់ស្លាកផ្ទាំងព័ត៌មាន ការរៀបចំផ្លូវចូលជាដើម បំណងឱ្យទេសចរ និងអ្នកសិក្សាស្រាវជ្រាវបានដឹងពីប្រវត្តិទីតាំងនោះ។

ឯកឧត្តមអគ្គនាយក ក៏បានចុះពិនិត្យមើលការដ្ឋានជួសជុលស្ពានហាល ដែលស្ថិតក្នុងដំណាក់កាលជិតរួចរាល់នាពេលដ៏ខ្លីខាងមុខនេះ ក្នុងនោះ **ឯកឧត្តម ហង់ ពៅ** បានផ្តល់នូវអនុសាសន៍បន្ថែមដើម្បីឱ្យការងារនេះកាន់តែមានប្រសិទ្ធភាពខ្ពស់។ ក្នុងបរិវេណប្រាសាទឯណោះវិញ ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា ក៏បានបន្តសិក្សា និងផ្តល់អនុសាសន៍បន្ថែមលើការងាររៀបចំសួនបៃតង ការពង្រីកការដាំកូនឈើ និងគម្រោងសិក្សាលើកបង្គន់អនាម័យខាងត្បូងប្រាសាទឱ្យមានគំលាតឆ្ងាយបន្តិចពីប្រាសាទ ដើម្បីឱ្យស័ក្តិសមជាទីសក្ការដ៏ខ្ពង់ខ្ពស់របស់មនុស្សជាតិ។

ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានបញ្ចប់ការចុះត្រួតពិនិត្យការងារក្នុងតំបន់រមណីយដ្ឋានអង្គរនៅប្រាសាទព្រះខ័ន ដែលនៅទីនោះក្រុមការងារក៏សិក្សាពីការរៀបចំកែលម្អបង្គន់អនាម័យ និងការងារអភិរក្សសំណង់ប្រាសាទផងដែរ។ល។

នាយកដ្ឋានរៀបចំដែនដីនៃអាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើលំនៅដ្ឋាននិងជួសជុលចំនួន៤៩ករណី ក្នុងអំឡុងសប្តាហ៍ទី៤នៃខែមិថុនា

ផ្សាយនៅថ្ងៃទី០២ ខែ កក្កដា ឆ្នាំ២០២០

ក្រុមការងារនៃនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ ប្រចាំប្រកទាំង៦របស់អាជ្ញាធរជាតិអប្សរា បានអនុញ្ញាត ឱ្យប្រជាពលរដ្ឋធ្វើលំនៅដ្ឋាននិងជួសជុលតិចតួចចំនួន២១ករណី ក្នុងចំណោម ពាក្យស្នើសុំទាំងអស់ចំនួន៤៩ករណី នាក្នុងអំឡុងសប្តាហ៍ទី៤ នៃខែមិថុនាឆ្នាំ ២០២០។



ការអនុញ្ញាតនោះ គឺនៅក្រុងសៀមរាបចំនួន៥ករណី នៅស្រុកពួកចំនួន៨ករណីនៅស្រុកបន្ទាយស្រីចំនួន៥ករណី នៅស្រុកអង្គរធំចំនួន២ករណីនិងនៅស្រុកប្រាសាទបាគងចំនួន១ករណី។ ទាក់ទងនឹងការអនុញ្ញាតឱ្យធ្វើលំនៅដ្ឋាននិងជួសជុលតិចតួចនេះដែរ ចំពោះប្រជាពលរដ្ឋណាដែលមានលក្ខខណ្ឌគ្រប់គ្រាន់លើការអនុញ្ញាតគឺក្រុមការងារផ្នែកស្ថាបត្យកម្ម ក៏បានជួយរៀបចំគំនូសប្លង់ លំនៅដ្ឋានបែបខ្មែរជូនចំនួន១៣ករណីផ្សេងទៀត ដូចជា៖ នៅក្រុងសៀមរាបចំនួន៤ករណី នៅស្រុកបន្ទាយស្រីចំនួន៤ករណី នៅស្រុកពួកចំនួន៣ករណី នៅស្រុកប្រាសាទបាគងចំនួន១ករណី និងនៅស្រុកអង្គរធំចំនួន១ករណីដែរ។

ចំណែក ការត្រួតពិនិត្យផ្នែកលក្ខណៈបច្ចេកទេសវិញ អាជ្ញាធរជាតិអប្សរា ក៏បានចុះទៅពិនិត្យ និងជួយប្រជាពលរដ្ឋបានចំនួនគ្រួសារ១២៧ករណី ដោយក្នុងនោះ មាននៅក្រុងសៀមរាបចំនួន៤៣ករណីនៅ ស្រុកប្រាសាទបាគងចំនួន១៩ករណី នៅស្រុកបន្ទាយស្រីចំនួន១៥ករណី ស្រុកពួកចំនួន៥០ករណី៕

៦ខែ ដើមឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាផ្តល់ការអនុញ្ញាតជួសជុលកែលម្អលំនៅដ្ឋាន សាងសង់សំណង់ស្រាលដល់អ្នកស្រុកអង្គរចំនួន១៩៥៩គ្រួសារ

ផ្សាយនៅថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០២០

យោងតាមរបាយការណ៍៦ខែដំបូងនៃឆ្នាំ២០២០ ក្រុមការងារលេខាធិការដ្ឋានសហគមន៍ទាំង៥ក្រុមនៃអាជ្ញាធរជាតិអប្សរាបានបន្តការងារចុះពិនិត្យ ការជួសជុលកែលម្អលំនៅដ្ឋាននិងសាងសង់សំណង់ស្រាលតូចតាចក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរចំនួន២៦៣៩គ្រួសារ ក្នុងនោះបានអនុញ្ញាតមានចំនួន១៩៥៩គ្រួសារ ។

ប្រភេទនៃការជួសជុលកែលម្អលំនៅដ្ឋាន និងសាង់សង់សំណង់ស្រាលដែលទទួលបានការអនុញ្ញាតរួមមាន ជួសជុល ឬប្តូរដំបូល ជួសជុលជញ្ជាំង ប្តូរសសរ ប្តូរជណ្តើរ តសំយ៉ាប កត់ដ្ឋក្រោមផ្ទះ សាងសង់បង្គន់អនាម័យ ទ្រុងមាន់ ចាក់ដីក្រោលគោ ទ្រុងជ្រូក ។ល។ និងតម្រូវការផ្សេងៗទៀតដែលចាំបាច់ក្នុងការរស់នៅប្រចាំថ្ងៃ។

ក្នុងចំណោមអ្នកស្រុក១៩៥៩គ្រួសារដែលទទួលបានការអនុញ្ញាតមាន ស្រុកប្រាសាទបាគងទទួលបានការអនុញ្ញាតចំនួន២១១គ្រួសារ ស្រុកអង្គរធំទទួលបានការអនុញ្ញាតចំនួន៣០៥គ្រួសារ ស្រុកពួកទទួលបានការអនុញ្ញាតចំនួន៤៤២ករណី ក្រុងសៀមរាបទទួលបានការអនុញ្ញាតចំនួន៣៥១គ្រួសារ និងស្រុកបន្ទាយស្រីទទួលបានការអនុញ្ញាតបានចំនួន៦៥០គ្រួសារ។

ការអនុញ្ញាតនេះ ធ្វើឡើងបន្ទាប់ពីក្រុមការងារសហគមន៍បានចុះពិនិត្យទៅដល់ខ្នងផ្ទះដាក់ស្តែងនិងឯកសារចាំបាច់ពាក់ព័ន្ធមួយចំនួនទៀត ដើម្បីជាមូលដ្ឋានបច្ចេកទេសក្នុងការវាយតម្លៃថាពួកគាត់គឺជាប្រជាពលរដ្ឋរស់នៅក្នុងតំបន់អង្គរពិតប្រាកដតាំងពីយូរយារ មានការបញ្ជាក់យ៉ាងច្បាស់លាស់ពីអាជ្ញាធរមូលដ្ឋានភូមិ-ឃុំ-សង្កាត់ និងមានតម្រូវការជាក់ស្តែងក្នុងការកែលម្អការរស់នៅឱ្យបានល្អប្រសើរ។

គួរបញ្ជាក់ដែរថា អាជ្ញាធរជាតិអប្សរាបានបង្កើតក្រុមការងារសហគមន៍នេះឡើង គឺដើម្បីសម្រួលដល់ការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់អង្គរដែលគ្របដណ្តប់លើផ្ទៃដី៤០១គីឡូម៉ែត្រការ៉េ ស្ថិតនៅក្នុងក្រុង/ស្រុកចំនួន៥ ឃុំចំនួន២១ និងភូមិចំនួន១១២ លើការជួសជុលផ្ទះចាស់ និងសាងសង់សំណង់ស្រាល ការដោះស្រាយបញ្ហាប្រឈមនានា ការជួយសង្គ្រោះពេលប្រជាជនមានទុក្ខលំបាក រួមទាំងផ្សព្វផ្សាយការយល់ដឹងអំពីបេតិកភណ្ឌដល់ប្រជាជនគ្រប់ៗគ្នា។ ពិសេសជាងនេះទៀតនោះ សកម្មភាពទាំងនេះគឺជាចូលរួមចំណែករបស់អាជ្ញាធរជាតិអប្សរាក្នុងការបង្ខិតសេវាសាធារណៈរបស់រដ្ឋឲ្យចូលទៅជិតបងប្អូនប្រជាពលរដ្ឋ និងកាត់បន្ថយរាល់ការចំណាយទាំងពេលវេលានិងការធ្វើដំណើរទៅមក៕

អាជ្ញាធរជាតិអប្សរានឹងចូលរួមសហការជាមួយអគ្គិសនីកម្ពុជារៀបចំតាំងបង្ហាញ នៅសារមន្ទីរថាមពលកកើតឡើងវិញ និងឧទ្យានជាតិសម្តេច ហ៊ុន សែន កំពត

ផ្សាយនៅថ្ងៃទី០៣ ខែ កក្កដា ឆ្នាំ២០២០

ព្រឹកថ្ងៃទី៣ខែកក្កដា ឆ្នាំ២០២០ នៅទីស្នាក់ការនៃអាជ្ញាធរជាតិអប្សរា មានជំនួបពិភាក្សាការងាររវាង **ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា និងលោក ជា ពិសិដ្ឋ នាយករងផលិតកម្មនៃអគ្គិសនីកម្ពុជា អំពីការចូលរួមរបស់អាជ្ញាធរជាតិអប្សរាក្នុងការបង្កើតវត្ថុដាក់តាំងបង្ហាញនៅក្នុងសារមន្ទីរថាមពលកកើតឡើងវិញ និងឧទ្យានជាតិសម្តេច ហ៊ុន សែន កំពត។

នៅក្នុងជំនួបពិភាក្សាការងារនេះ លោក ជា ពិសិដ្ឋ បានធ្វើបទបង្ហាញនូវគោលបំណងនៃការបង្កើតសារមន្ទីរ នៅទីតាំងស្ថានីយ៍វារីអគ្គិសនីទំនប់ធំកំចាយនិងចែករំលែកបទសោធន៍ល្អៗ ព្រមទាំងបានអញ្ជើញអ្នកជំនាញនៃអាជ្ញាធរជាតិអប្សរាចូលរួមតាំងបង្ហាញកិច្ចការរៀបចំ និងគ្រប់គ្រងទឹកនៅក្នុងរមណីយដ្ឋានអង្គរ នៅសារមន្ទីរខាងលើ។

ឯកឧត្តម ហង់ ពៅ បានកោតសរសើរចំពោះគម្រោងដ៏ល្អមួយនេះដែលមានទីតាំងសមស្រប ព្រមទាំងរចនាបថខ្មែរ និងបង្កើតវត្ថុដាក់តាំងបង្ហាញ ការចងក្រងឯកសារប្រវត្តិសាស្ត្រនិងវិទ្យាសាស្ត្រពាក់ព័ន្ធវិស័យថាមពលអគ្គិសនី ជាផ្នែកមួយក្នុងការទាក់ទាញដល់ភ្ញៀវទេសចរ និងផ្តល់ចំណេះដឹងដល់សាធារណជន។

អាជ្ញាធរជាតិអប្សរាមានក្តីរីករាយនឹងផ្តល់ជាគំនិត និងសហការជាមួយគ្នាដើម្បីឱ្យការបង្កើតសារមន្ទីរនេះសម្រេចបាន ដោយភាពជោគជ័យប្រកបដោយប្រណីតភាព និងទុកជាកេរដំណែលប្រវត្តិសាស្ត្រសម្រាប់កូនចៅជំនាន់ក្រោយ៕

អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា៖ រាល់សំណង់ ឬអគារនានា ដែលមានភាពស្របច្បាប់ គឺអាជ្ញាធរជាតិអប្សរា មិនដែលបដិសេធនោះទេ

ផ្សាយនៅថ្ងៃទី០៦ ខែ កក្កដា ឆ្នាំ២០២០

លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា នាព្រឹកថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០ បានអះអាងថា អាជ្ញាធរជាតិអប្សរាមិនដែលបដិសេធចំពោះសំណង់ឬអគារណាដែលមានភាពស្របច្បាប់ ហើយស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនទេ។ នេះគឺជាការឆ្លើយបំភ្លឺទាក់ទិនទៅនឹងការផ្សព្វផ្សាយនៅលើបណ្តាញព័ត៌មានសង្គមហ្វេសប៊ុកនៅថ្ងៃទី៤ ខែកក្កដា ដែលមិនមានមូលដ្ឋានច្បាស់លាស់ ឈ្មោះ វិទ្យុ នគររាជ្យ ថា "អាស្រមពើងតាអេរ ស្ថិតនៅលើភ្នំគូលេន ខេត្តសៀមរាប ត្រូវភ្លើងឆេះអស់ ព្រះសង្ឃឆាន់នៅក្រោមដើមឈើ ពុទ្ធបរិស័ទសុំច្បាប់សាងសង់ឡើងវិញតែអជ្ញាធរជាតិអប្សរា មិនអនុញ្ញាត ចង់សួរថាមូលហេតុអ្វី?"

លោក ឡុង កុសល បានសង្កត់ធ្ងន់យ៉ាងដូច្នេះថា៖ "ពេលនេះយើងពុំទាន់បានបដិសេធឬអនុញ្ញាតនៅឡើយទេ ព្រោះក្រុមការងារកំពុងតែពិនិត្យលើការងារនេះ ដោយមើលឯកសារគតិយុត្តិនានាស្តីពីភាពស្របច្បាប់នៃទីតាំងរបស់សំណង់អាស្រមនោះ ព្រោះថាជាគោលការណ៍របស់អាជ្ញាធរជាតិអប្សរា គឺមិនបដិសេធនោះទេចំពោះសំណង់ឬអគារនានា ដែលមានភាពស្រពច្បាប់ និងបម្រើឱ្យផលប្រយោជន៍ជាសាធារណៈ។"

បន្ថែមពីនេះ តាមការបញ្ជាក់ពីអ្នកនាំពាក្យ បច្ចុប្បន្នក្រុមការងាររបស់អាជ្ញាធរជាតិអប្សរា និងរដ្ឋបាលស្រុកស្វាយលើកំពុងធ្វើការជុំវិញរឿងនេះ នឹងគ្រោងទៅពិនិត្យទីតាំងនេះជាក់ស្តែងដោយផ្ទាល់នៅលើខ្នងភ្នំគូលេនតែម្តង ៕

អាជីវករ៤នាក់ទៀតបានស្ម័គ្រចិត្តរុះរើសំណង់ភោជនីយដ្ឋានរបស់ខ្លួននៅមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៦ ខែ កក្កដា ឆ្នាំ២០២០

ក្នុងស្មារតីចូលរួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ពន្ធនិងសម្បទានទេសចរណ៍នៅបរិវេណមុខប្រាសាទអង្គរវត្តជាមួយអាជ្ញាធរជាតិអប្សរា ម្ចាស់ភោជនីយដ្ឋានចំនួន៤ខ្នងបានរុះរើដោយស្ម័គ្រចិត្ត នាព្រឹកថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២០។

លោក ញៀន ទឿម ម្ចាស់ភោជនីយដ្ឋាន «នារីខ្មែរអង្គរ» ដែលបានបើកបម្រើសេវាកម្មម្ហូបអាហារនិងភេសជ្ជៈជូនភ្ញៀវទេសចរជាតិ-អន្តរជាតិជាង១០ឆ្នាំមកនោះ បានយល់ស្រប ពេញចិត្តចូលរួមរុះរើទីតាំងជូនអាជ្ញាធរជាតិអប្សរារៀបចំសណ្ដាប់ធ្នាប់ ហេដ្ឋារចនាសម្ពន្ធ និងកែលម្អមុខប្រាសាទអង្គរវត្តឱ្យស្រស់ស្អាតជាងមុន។ លោក ក៏បានសម្ដែងការសោកស្ដាយដែរ តែដើម្បីប្រយោជន៍រួម គឺត្រូវលះបង់ព្រោះអាជ្ញាធរជាតិអប្សរាក៏បានប្រគល់ទីតាំងថ្មីមួយសម្រាប់លោកលក់ដូរនៅក្នុងទីលានបដិសណ្ឋារកិច្ចវិញដែរ។

ម្ចាស់ភោជនីយដ្ឋាន «នគររាជ» អ្នកស្រី លី សាវេត ដែលបានប្រកបរបរភោជនីយដ្ឋានជាង២០ឆ្នាំមកហើយបានលើកឡើងថា ខ្ញុំសោកស្ដាយក៏សោកស្ដាយ ព្រោះធ្លាប់ជាទីតាំងរកចំណូលចិញ្ចឹមជីវិត ធ្លាប់មានអនុស្សាវរីយ៍ច្រើន តែជាកាតព្វកិច្ចខ្ញុំត្រូវចូលរួមលះបង់ដើម្បីអង្គរម្ដង ព្រោះអង្គរក៏បានផ្ដល់ស្នាមញញឹម ផលកម្រៃ សុភមង្គលសម្រាប់ការរស់នៅរបស់ខ្ញុំច្រើនមកដែរ។ អ្នកស្រីក៏ត្រេកអរចំពោះការរៀបចំសោភ័ណភាពមុខអង្គរវត្ត និងការអនុវត្តច្បាប់រុះរើដោយស្មើភាពគ្នា ហើយលោកស្រីសង្ឃឹមថា ក្រោយការរៀបចំអង្គរវត្ត កាន់តែស្រស់ស្អាតប្លែក ហើយភ្ញៀវទេសចរនឹងកើនឡើងច្រើនពេលជំងឺកូវីដ១៩បានបញ្ចប់។

ឯកឧត្តម យិត ចាន់ដារដ្ឋ អគ្គនាយករងអាជ្ញាធរជាតិអប្សរា

បានថ្លែងអំណរគុណដល់ម្ចាស់អាជីវកម្មទាំងអស់ដែលបានយល់ដឹងនិងចូលរួមសហការជាមួយអាជ្ញាធរជាតិអប្សរាឱ្យដំណើរការការងារយ៉ាងរលូន។ នៅចុងខែសីហានេះ អាជីវករនឹងអាចចូលទៅលក់ដូរនៅក្នុងទីលានបដិសណ្ឋារកិច្ចដែលកំពុងសាងសង់បាន៧០% ហើយក្រុមការងារក៏នឹងបន្តការរុះរើសំណង់ផ្សេងៗទៀតដែលមានការស្ម័គ្រចិត្តពីម្ចាស់រហូតដល់អស់ពីមុខក្នុងពេលដ៏ខ្លី។ ឯកឧត្តម បញ្ជាក់ទៀតថា តាំងពីដើមឆ្នាំ២០២០ រហូតមកដល់ខែកក្កដានេះមានតូបលក់ដូរភោជនីយដ្ឋានធំៗចំនួន១១ខ្នង ហើយដែលម្ចាស់បានស្ម័គ្រចិត្តរុះរើ៕

សេចក្តីសម្រេចស្តីពី ការលុបឈ្មោះបុគ្គលិក នៃអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ឈ្មោះ ឡាយ ពិសិដ្ឋ ត្រូវបានលុបឈ្មោះចេញពីបុគ្គលិករបស់នាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរា ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០តទៅ ដោយមូលហេតុប្រព្រឹត្តកំហុសធ្ងន់ធ្ងរ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ.១៣៥/រប-អសរ/២០

សេចក្តីសម្រេច

ស្តីពី

ការលុបឈ្មោះបុគ្គលិក នៃអាជ្ញាធរជាតិអប្សរា

អគ្គនាយកអាជ្ញាធរជាតិអប្សរា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៣ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន នៃអាជ្ញាធរអប្សរា
- លិខិតលេខ ២៣២/២០ ន.ស.ស ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ របស់នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ

សម្រេច

ប្រការ១ ៖ លុបឈ្មោះលោក ឡាយ ពិសិដ្ឋ ចេញពីបុគ្គលិករបស់នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ នៃអាជ្ញាធរជាតិអប្សរា ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ តទៅដោយប្រព្រឹត្តកំហុសធ្ងន់ធ្ងរ។

ប្រការ២ ៖ រាល់សេចក្តីសម្រេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

ប្រការ៣ ៖ នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ នាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច ១ រោច ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

សៀមរាបថ្ងៃទី ខែកក្កដា ឆ្នាំ២០២០

អគ្គនាយក

ហង់ ពៅ

ចម្លងជូន៖
- ដូចប្រការ៣ - ដើម្បីអនុវត្ត
- ឯកសារ -កាលប្បវត្តិ

ស្ថានីយបណ្ដុះកូនឈើ៨ហិកតារបស់អាជ្ញាធរជាតិអប្សរា បណ្ដុះប្រភេទពូជឈើកម្រ៥ប្រភេទនៅកម្ពុជា

ផ្សាយនៅថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០២០

ព្រៃឈើ គឺផ្នែកមួយដ៏សំខាន់ក្នុងរមណីយដ្ឋានអង្គរ និងបានបំពេញតួនាទីស្នូលក្នុងការបង្កើនគម្របព្រៃឈើ បរិស្ថាន និងអភិរក្សក្នុងរមណីយដ្ឋានអង្គរ។ ក្នុងន័យនេះ ស្ថានីយបណ្ដុះកូនឈើ៨ហិកតា ជាស្ថានីយមួយក្នុងចំណោមស្ថានីយទាំង៤ របស់អាជ្ញាធរជាតិអប្សរាក្នុងការងារបណ្ដុះកូនឈើសម្រាប់ដាំដុះទាំងក្នុងតំបន់រមណីយដ្ឋានអង្គរ និងចែកចាយជូនទៅដាំនៅខាងក្រៅរមណីយដ្ឋានអង្គរ។

លោក ស៊ិន សុផាណារ៉េត បុគ្គលិកទទួលបន្ទុកនៅស្ថានីយបណ្ដុះកូនឈើ៨ហិកតា ឱ្យដឹងថាក្នុងចំណោមប្រភេទកូនឈើជាច្រើន ស្ថានីយនេះបានបណ្ដុះប្រភេទឈើប្រណិតកម្រចំនួន៥ប្រភេទនៅកម្ពុជា ដូចជាឈើបេង ឈើគ្រញូង ឈើធ្នង់ ឈើច្រេះ និងឈើនាងនួន។ ស្ថានីយបណ្ដុះប្រភេទកូនឈើទាំងនោះដោយធ្វើការប្រមូលគ្រាប់ពូជពីព្រៃក្នុងរមណីយដ្ឋានអង្គរ ការផ្ដល់ដោយវិស័យឯកជន និងទិញពីផ្សារ ដូចជាឈើនាងនួនជាដើម។

លោកបន្តថា ក្នុងមួយឆ្នាំៗស្ថានីយបណ្ដុះកូនឈើ៨ហិកតាអាចមានលទ្ធភាពបណ្ដុះកូនឈើជាមធ្យមជាង២ម៉ឺនដើម តែសម្រាប់ឆ្នាំមុន ស្ថានីយបានបណ្ដុះរហូតដល់ជិត៥ម៉ឺនដើម។ ប៉ុន្តែការបណ្ដុះកូនឈើទាំងនេះមានការលំបាកបន្តិចដោយសារពូជខ្លះដូចជាបេង ត្រូវការស្រុះទឹកក្ដៅ និងកាប់ច្រៀកវាសិន ទើបកូនឈើទាំងនោះឆាប់ដុះ និងដុះក្នុងបរិមាណច្រើន៕

លោកជំទាវ ភឿង សកុណា ដឹកនាំកិច្ចប្រជុំពិនិត្យគ្រោងពាក់ព័ន្ធផែនការមេវិស័យទេសចរណ៍

ផ្សាយនៅថ្ងៃទី០៧ ខែ កក្កដា ឆ្នាំ២០២០

នារសៀលថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២០ នៅស្នាក់ការអាជ្ញាធរជាតិអប្សរា ក្រោមអធិបតីភាព **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា និងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា បានបើកកិច្ចប្រជុំពិភាក្សានិងពិនិត្យពង្រាងផែនការមេវិស័យទេសចរណ៍។

លោកជំទាវ បានឱ្យដឹងថា ការរៀបចំសៀវភៅផែនការមេសម្រាប់អភិវឌ្ឍន៍វិស័យទេសចរណ៍ពិតជាមានសារៈសំខាន់ណាស់សម្រាប់ខេត្តសៀមរាបនិងតំបន់រមណីយដ្ឋានអង្គរដែលអាចទាក់ទាញទេសចរណ៍បានកាន់តែច្រើនមកតំបន់ប្រវត្តិសាស្ត្រដ៏ល្បីល្បាញលើពិភពលោក និងអាចបញ្ចៀសវាល់ផលប៉ះពាល់នានាលើផ្នែកបេតិកភណ្ឌ៕

លោកជំទាវ ភឿង សកុណា ប្រគេនទៀនព្រះវស្សានិងទេយ្យទានព្រះគ្រូចៅអធិការវត្តរាជបូណ៌

ផ្សាយនៅថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ២០២០

នាល្ងាចថ្ងៃទី៧ ខែកក្កដា ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា បានអញ្ជើញចូលក្រាបបង្គំសួរសុខទុក្ខនិងប្រគេនទៀនព្រះវស្សាព្រមទាំងទេយ្យទានមួយចំនួនដល់ព្រះមហាវិមលធម្មពិនសែមរាជាគណៈថ្នាក់ទោ និងជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្តរាជបូណ៌ និងជាព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាវត្តអារាម។

ក្នុងឱកាសនោះ **លោក ជំទាវ ភឿង សកុណា** ក៏បានគូសបញ្ជាក់ថា ទៀនព្រះវស្សានិងទេយ្យវត្ថុដែលនាំមកប្រគេនព្រះសង្ឃនាពេលនេះ គឺសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់ព្រះសង្ឃក្នុងរយៈពេលគង់ចាំព្រះវស្សាអស់ត្រីមាសនៅតាមទីវត្តអារាមនានា ដែលព្រះសង្ឃមិនអាចនិមន្តចេញទៅបិណ្ឌបាត្របាន ដោយរដូវវស្សាមានភ្លៀងធ្លាក់ជោគជាំ ហើយក៏ដើម្បីឧទ្ទិសកុសលដល់វិញ្ញាណក្ខន្ធអ្នកដែលបានចែកឋានទៅកាន់បរលោកខាងមុខនោះផងដែរ៕

លោកជំទាវ ភឿង សកុណា ចូលរួមកិច្ចប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើពង្រាងផែនការមេ វិស័យទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២០-២០៣៥

ផ្សាយនៅថ្ងៃទី០៨ ខែ កក្កដា ឆ្នាំ២០២០

នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០២០ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា រួមនឹងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាបានចូលរួមប្រជុំអន្តរក្រសួងដើម្បីពិភាក្សាលើពង្រាងផែនការមេវិស័យទេសចរណ៍ខេត្តសៀមរាបឆ្នាំ ២០២០-២០៣៥ នាសណ្ឋាគាររ៉ូយ៉ាល់ជីនសុីអង្គរ។

កិច្ចប្រជុំអន្តរក្រសួងនេះបានប្រព្រឹត្តទៅដោយមានវត្តមានដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ថោង ខុន** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ឯកឧត្តម សាយ សំអាល់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន **ឯកឧត្តម ទៀ សីហា** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប និងការចូលរួមពីបណ្តាថ្នាក់ដឹកនាំ មន្ត្រីជំនាញនៅតាមបណ្តាស្ថាប័ននិងអង្គភាពពាក់ព័ន្ធនានា។

គោលបំណងនៃកិច្ចប្រជុំអន្តរក្រសួងនេះដើម្បីឆ្លងសេចក្តីព្រាងបឋមផែនការមេខាងលើ និងផ្លាស់ប្តូរយោបល់ឱ្យល្អិតល្អន់ មានលក្ខណៈស៊ីជម្រៅនិងស៊ីចង្វាក់គ្នាលើគ្រប់ផ្នែកពាក់ព័ន្ធទាំងអស់។ ពិសេសធ្វើយ៉ាងណាជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ដ៏សំខាន់នៅក្នុងខេត្តសៀមរាបឱ្យកាន់តែមានភាពទាក់ទាញ ផ្តល់ផលប្រយោជន៍ពីវិស័យនេះឱ្យបានដល់គ្រប់ផ្នែកទាំងអស់នៃសង្គមប្រកបដោយសមធម៌៕

ដើមឈើមួយចំនួនដែលមានហានិភ័យខ្ពស់ក្នុងរមណីយដ្ឋានអង្គរនឹងត្រូវដកហូតនិងកាត់ក្រី

ផ្សាយនៅថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០២០

ដើម្បីធានាដល់សុវត្ថិភាពប្រាសាទ ភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាព នៅតាមបរិវេណប្រាសាទក្នុងតំបន់រមណីយដ្ឋានអង្គរ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ ដែលមានហានិភ័យខ្ពស់។ ព័ត៌មានលំអិតសូមអានសេចក្តីជូនដូចដែលមានភ្ជាប់ខាងក្រោម៖



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ០៤៤២/អ.សហ/៧
២០

សេចក្តីជូនដំណឹង
ស្តីពី
ការកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ
ដែលមានហានិភ័យខ្ពស់ នៅតាមបរិវេណប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

អាជ្ញាធរជាតិអប្សរា សូមជូនដំណឹងដល់មន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបថា ដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ សាធារណជន ក៏ដូចជាដើម្បីលើកកម្ពស់សោភ័ណភាព នៅតាមដងផ្លូវ និងតាមបរិវេណប្រាសាទ ក្នុងតំបន់រមណីយដ្ឋានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា នឹងកាត់ដកហូតដើមឈើ និងកាត់ក្រីមែកឈើ នៅតាមទីតាំងនានា ដូចខាងក្រោម៖

- កាត់ដកហូតដើមឈើងាប់ចំនួន ០៣ដើម (ដើមគគីរ០១ដើម និងដើមអាកាស្យា០២ដើម) ដែលមាន ហានិភ័យខ្ពស់ស្ថិតនៅតាមដងផ្លូវពីប្រាសាទអង្គរវត្តទៅព្រលានយន្តហោះ ស្ថិតក្នុងភូមិខ្វៀន សង្កាត់គោកចក ក្រុងសៀមរាប។
- កាត់ដកហូតដើមអំពិលបារាំង ០១ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅភូមិនគរក្រៅ សង្កាត់គោកចក ក្រុងសៀមរាប។
- កាត់ដកហូតដើមឈើងាប់ចំនួន ០៧ដើម (ដើមស្វាយ០២ដើម ដើមទឹកដោះ០១ដើម ដើមពុទ្រា០១ដើម ដើមអាកាស្យា ០១ដើម ដើមគគីរ០១ដើម និងដើមអំពិល០១ដើម) ដែលមានហានិភ័យខ្ពស់ ស្ថិតនៅបរិវេណប្រាសាទបាគង។
- កាត់ដកហូតដើមឈើចំនួន ០២ដើម (ដើមឈើទាល និងដើមស្វាយ) ដែលមានហានិភ័យខ្ពស់ ស្ថិតនៅប្រាសាទមេបុណ្យខាងលិច។
- កាត់ក្រីមែកឈើទាលចំនួន ០៨ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅក្នុងសាលាបឋមសិក្សាស្រះស្រង់។
- កាត់ដកហូតដើមត្នោតងាប់ចំនួន ០២ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅភូមិត្រពាំងសេះ។
- កាត់ក្រីមែកអំពិលបារាំង ០១ដើម ដែលមានហានិភ័យខ្ពស់ ស្ថិតនៅក្នុងភូមិត្រពាំងសេះ។
- កាត់ដកហូតដើមឈើងាប់ចំនួន ៤ដើម (ដើមឈើទាល ១ដើម ដើមដកព ១ដើម ដើមក្រាច ១ដើម និងដើមចំបក់ ១ដើម) ដែលមានហានិភ័យខ្ពស់ ស្ថិតនៅតាមផ្លូវចំណុចច្រកចូលខាងកើតប្រាសាទអង្គរវត្ត រហូតដល់ខាងត្បូងប្រាសាទបន្ទាយក្តី ។

ក្រុមការងារនៃអាជ្ញាធរជាតិអប្សរា នឹងចាប់ផ្តើមអនុវត្តការងារខាងលើចាប់ពីថ្ងៃទី១៤ ខែកក្កដាឆ្នាំ២០២០ តទៅ រហូតដល់ចប់ភារកិច្ច។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមមន្ទីរ ស្ថាប័ន សមត្ថកិច្ចពាក់ព័ន្ធ ភ្ញៀវជាតិ-អន្តរជាតិ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ៤ រោច ខែ ... ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ២០២០

APSARA

Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

អាជ្ញាធរជាតិអប្សរាបន្តជួយសម្រួលដល់ការទាមទារសាងសង់របស់ប្រជាពលរដ្ឋ

ផ្សាយនៅថ្ងៃទី១០ ខែ កក្កដា ឆ្នាំ២០២០

តាមរបាយការណ៍នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងតំបន់អង្គរនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា សប្តាហ៍ទី១ ខែកក្កដា ឆ្នាំ២០២០ ក្រុមការងារនៃនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរប្រចាំច្រកទាំង៦របស់អាជ្ញាធរជាតិអប្សរា បានទទួលពាក្យស្នើសុំធ្វើលំនៅដ្ឋាននិងជួសជុលតិចតួចចំនួន៦៥ ករណីក្នុងចំណោមសំណើទាំងនោះ។

មន្ត្រី-បុគ្គលិកជំនាញបានចុះពិនិត្យដល់ទីតាំងស្នើសុំជាក់ស្តែង ដើម្បីពិនិត្យមើលលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់ទីតាំងស្នើសុំរបស់ប្រជាពលរដ្ឋម្ចាស់សំណើដល់ទីតាំងផ្ទាល់បានចំនួន៤៣ករណី។ការពិនិត្យនោះគឺនៅក្រុងសៀមរាបចំនួន១៧ករណី ស្រុកពួកចំនួន៥ករណី ស្រុកបន្ទាយស្រីចំនួន៦ករណី ស្រុកអង្គរធំចំនួន៥ករណី ស្រុកប្រាសាទបាគង ចំនួន៩ករណី និងស្រុកសូទ្រនិគម ចំនួន១ករណី។

ទាក់ទងនឹងការអនុញ្ញាតឱ្យធ្វើលំនៅដ្ឋាននិងជួសជុលតិចតួចនេះដែរ ចំពោះប្រជាពលរដ្ឋណាដែលមានលក្ខខណ្ឌគ្រប់គ្រាន់លើការអនុញ្ញាត គឺក្រុមការងារផ្នែកស្ថាបត្យកម្មក៏បានជួយរៀបចំគំនូសប្លង់លំនៅដ្ឋានបែបខ្មែរជូនចំនួន៣៣ករណីផ្សេងទៀត ដូចជា៖

នៅក្រុងសៀមរាបចំនួន១០ករណី
នៅស្រុកបន្ទាយស្រីចំនួន៦ករណី
នៅស្រុកពួកចំនួន២ករណី
នៅស្រុកប្រាសាទបាគងចំនួន៩ករណី
និងនៅស្រុកអង្គរធំចំនួន៦ករណីដែរ។

ក្រោយពីទទួលបានការអនុញ្ញាតហើយ អាជ្ញាធរជាតិអប្សរានៅតែបន្តជួយលក្ខណៈបច្ចេកទេសដល់ប្រជាពលរដ្ឋដែលសាងសង់លំនៅដ្ឋាន។ ជាក់ស្តែងក្នុងរយៈពេលដូចគ្នា ក្រុមការងារនេះបានចុះពិនិត្យចំនួន១១៤គ្រួសារ គឺនៅក្រុងសៀមរាបចំនួន៣០គ្រួសារ ស្រុកប្រាសាទបាគងចំនួន៣២គ្រួសារ ស្រុកបន្ទាយស្រីចំនួន២៩គ្រួសារ ស្រុកអង្គរធំចំនួន២០គ្រួសារនិងស្រុកពួកបានចំនួន០៣គ្រួសារ។

សូមបញ្ជាក់ថា ក្រុមការងារនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរាតែងតែចុះជាប្រចាំដើម្បីសម្របសម្រួលករណីសំណើផ្សេងៗ និងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា៕



សេចក្ដីអំពាវនាវស្ដីពី ការស្ម័គ្រចិត្តរុះរើតូបលក់ដូរអេចិន្ត្រៃយ៍របស់របស់អាជីវករ នៅបរិវេណខាងលិចមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១១ ខែ កក្កដា ឆ្នាំ២០២០

ក្នុងគោលបំណងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍ ទេសភាព បរិស្ថាន ខាងលិចមុខប្រាសាទអង្គរវត្តឱ្យមានភាពល្អប្រសើរ និងលើកតម្លៃអង្គរឱ្យសមជាបេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរា ដោយមានការចូលរួមស្ម័គ្រចិត្តពីបងប្អូនអាជីវករ សំណង់ភោជនីយដ្ឋាន អាគាររដ្ឋ និងតូបលក់ដូរមួយចំនួនត្រូវបានរុះរើ។

ដើម្បីបន្តកិច្ចការនេះ អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមអំពាវនាវដល់អាជីវករដែលមានតូបលក់ដូរអចិន្ត្រៃយ៍នៅបរិវេណខាងលិចមុខប្រាសាទអង្គរវត្ត និងត្រពាំងសេសមេត្តាចូលរួមសហការនិងរុះរើសំណង់អាជីវកម្មរបស់ខ្លួនដោយស្ម័គ្រចិត្ត ហើយប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរាអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទានទេសចរណ៍ឱ្យបានមុនថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ដើម្បីជានាទទួលបានតូបលក់ដូរថ្មីដែលសាងសង់ជិតរួចរាល់ហើយ។

ផុតកំណត់នៃរយៈពេលនេះ អាជ្ញាធរជាតិអប្សរាមិនទទួលខុសត្រូវចំពោះការបាត់បង់ ការខូចខាតទ្រព្យសម្បត្តិរបស់បងប្អូនអាជីវករឡើយ៕ ព័ត៌មានលំអិត សូមអានសេចក្ដីអំពាវនាវដូចខាងក្រោម៖



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ......../រជ.អអន/២០

សេចក្ដីអំពាវនាវ
ស្ដីពី
ការស្ម័គ្រចិត្តរុះរើតូបលក់ដូរអចិន្ត្រៃយ៍របស់អាជីវករនៅបរិវេណខាងលិចមុខប្រាសាទអង្គរវត្ត

អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនដំណឹង និងអំពាវនាវដល់អាជីវករទាំងអស់ដែលមានតូបលក់ដូរអចិន្ត្រៃយ៍នៅបរិវេណខាងលិចមុខប្រាសាទអង្គរវត្ត និងត្រពាំងសេស ឱ្យបានជ្រាបថា៖ តាមរយៈលិខិតលេខ ០០៨៤/២០ រប.សជណ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា បានជូនដំណឹងស្ដីពីការអនុវត្តគម្រោងនានា នៅបរិវេណប្រាសាទអង្គរវត្ត ដើម្បីចូលរួមចំណែកធ្វើឱ្យហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍ ទេសភាព និងបរិស្ថាន នៅបរិវេណមុខខាងលិចប្រាសាទអង្គរវត្ត មានភាពល្អប្រសើរ ព្រមទាំងលើកតម្លៃរមណីយដ្ឋានអង្គរ ដែលជានិមិត្តរូបនៃព្រលឹងជាតិខ្មែរ ឱ្យកាន់តែល្បីល្បាញ និងស័ក្តិសមជាសម្បត្តិបេតិកភណ្ឌពិភពលោក។

ក្នុងរយៈពេលអនុវត្តគម្រោងនាពេលកន្លងមក បងប្អូនអាជីវករដែលជាម្ចាស់ភោជនីយដ្ឋានធំៗ ជាច្រើនបានស្ម័គ្រចិត្តជាបន្តបន្ទាប់ រុះរើតូបលក់ដូររបស់ខ្លួនចេញ និងប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរា។ អាជ្ញាធរជាតិអប្សរា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរដោយស្មោះចំពោះការលះបង់នេះ ដើម្បីជាប្រយោជន៍រួម។

ឆ្លៀតក្នុងឱកាសនេះ អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់បងប្អូនអាជីវករដែលមានតូបលក់ដូរអចិន្ត្រៃយ៍នៅបរិវេណខាងលិចមុខប្រាសាទអង្គរវត្ត និងត្រពាំងសេសផ្សេងទៀត(ភោជនីយដ្ឋាន តូបលក់វត្ថុអនុស្សាវរីយ៍ លក់ភេសជ្ជៈ លក់មាន់អាំង...) មេត្តាចូលរួមសហការ និងស្ម័គ្រចិត្តរុះរើតូបលក់ដូររបស់ខ្លួន ហើយប្រគល់ទីតាំងជូនអាជ្ញាធរជាតិអប្សរា ឱ្យបានមុនថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២០ ដើម្បីជានាទទួលបានទីតាំងលក់ដូរថ្មី ដែលនឹងសាងសង់រួចរាល់នាពេលខាងមុខនេះ។ ផុតកំណត់រយៈពេលអំពាវនាវនេះ អាជ្ញាធរជាតិអប្សរា នឹងមិនទទួលខុសត្រូវរាល់ការបាត់បង់ប្រយោជន៍ជាយថាហេតុ របស់បងប្អូនអាជីវករឡើយ។

ក្នុងន័យនេះ ប្រសិនបើបងប្អូនអាជីវករមានបំណងស្ម័គ្រចិត្តរុះរើ សូមអញ្ជើញទំនាក់ទំនងដោយផ្ទាល់ទៅ **ឯកឧត្តម យឹត ចាន់ដារដ្ឋ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា តាមរយៈទូរស័ព្ទលេខ ០១២ ៨៨៣ ១៣៨ ដើម្បីទទួលបានព័ត៌មានបន្ថែមពាក់ព័ន្ធនឹងលក្ខខណ្ឌនានា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនអាជីវករទាំងអស់ មេត្តាជ្រាប និងចូលរួមសហការតាមការគួរ។

ថ្ងៃ........ ខែ........ ឆ្នាំជូត ទោស័ក ព.ស២៥៦៤
សៀមរាប ថ្ងៃទី........ ខែ........ ឆ្នាំ២០២០
អាជ្ញាធរជាតិអប្សរា

Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

អាជ្ញាធរជាតិអប្សរាចូលរួមដាំកូនឈើឡើងវិញនៅទីបញ្ជាការដ្ឋានយោធភូមិភាគទី៤

ផ្សាយនៅថ្ងៃទី១១ ខែ កក្កដា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២០នេះ លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា និងជាប្រធាននាយកដ្ឋានផ្សព្វផ្សាយ បានដឹកនាំក្រុមការងារចូលរួមដាំកូនឈើឡើងវិញនៅបញ្ជាការដ្ឋានយោធភូមិភាគទី៤។ ពិធីប្រព្រឹត្តិទៅក្រោមអធិបតីភាព **ឯកឧត្តមឧត្តមសេនីយឯក ពៅ ហេង** មេបញ្ជាការដ្ឋានយោធភូមិភាគទី៤ **ឯកឧត្តម នាក់ ឈាវ៉ុន** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប តំណាងកងឯកភាពកំចាត់មីនទី៤ ព្រមទាំងមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរា និងពលទាហានប្រមាណជាង៤០០នាក់។

កូនឈើដែលបានដាំនៅពេលនោះសរុបចំនួន ៥០០០ដើម មាន១៨ប្រភេទ ដែលជាការឧបត្ថម្ភដោយអាជ្ញាធរជាតិអប្សរា៕

អាជ្ញាធរជាតិអប្សរា បានចែកចាយកូនឈើជូនសាធារណជនបានចំនួនជិត៥ម៉ឺនដើមហើយ

ផ្សាយនៅថ្ងៃទី១៣ ខែ កក្កដា ឆ្នាំ២០២០

ក្នុងរយៈពេលជាងមួយខែនៃយុទ្ធនាការដាំ និងចែកចាយកូនឈើក្នុងរដូវវស្សាឆ្នាំ២០២០នេះ អាជ្ញាធរជាតិអប្សរាបានចែកចាយកូនឈើគ្រប់ប្រភេទដូចជា គ្រញូង ធ្នង់

បេង ប្រេស ឈើទាល គគីរ កកោះ រំដួល គុយ សិរមាន់ ផ្កាក្រៀក ផ្កាឥន្ទនេលជាដើម ជូនដល់ស្ថាប័នរដ្ឋ អង្គការសហគមន៍ សាលារៀន វត្តអារាម វិស័យឯកជន និងសាធារណជនទូទៅបានចំនួនជិត៥ម៉ឺនដើម ដើម្បីចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការស្តារ និងបង្កើនគម្របព្រៃឈើឲ្យប្រសើរឡើងវិញ ទាំងក្នុងតំបន់សៀមរាប អង្គរ និងតាមបណ្តាខេត្តនានា។ ការផ្តល់ជូនទាំងនោះមានដូចជា៖

- មន្ទីរបរិស្ថានខេត្តសៀមរាប ចំនួន៣,០០០ដើម
- ទីបញ្ជាការយោធភូមិភាគ៤ ចំនួន៥,០០០ដើម
- រដ្ឋបាលស្រុកបន្ទាយស្រី ចំនួន១,៥០០ដើម
- រដ្ឋបាលស្រុកក្រឡាញ់ ចំនួន៣,០០០ដើម
- សាលាសង្កាត់គោកចក ចំនួន១,៥០០ដើម
- មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ចំនួន៣,៣០០ដើម
- ធនាគារជាតិនៃកម្ពុជា ចំនួន៨៥០ដើម
- ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប ចំនួន១០,៧០០ដើម
- ក្រុមហ៊ុនគូឡារ៉ាំជើរ(ទឹកអូគូលែន)ចំនួន២,០០០ដើម

ក្រៅពីនោះមានសាលារៀន វត្តអារាម ក្រុមហ៊ុន អង្គការសហគមន៍ និងប្រជាពលរដ្ឋចំនួន១៦,៩៨០ដើមទៀត៕

លោកជំទាវ ភឿង សកុណា បើកកិច្ចប្រជុំផ្ទៃក្នុងពិភាក្សាលើពង្រាងផែនការមេវិស័យទេសចរណ៍ខេត្តសៀមរាបឆ្នាំ២០២០-២០៣៥

ផ្សាយនៅថ្ងៃទី១៤ ខែ កក្កដា ឆ្នាំ២០២០

នាថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០ តាមរយៈកិច្ចប្រជុំវីដេអូ **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិ

អប្សរា បានដឹកនាំកិច្ចប្រជុំជាមួយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា និងអ្នកជំនាញពាក់ព័ន្ធ ពិភាក្សាលើពង្រាងផែនការមេវិស័យទេសចរណ៍នៅក្នុងខេត្តសៀមរាបឆ្នាំ២០២០-២០៣៥ ដែលក្រុមការងារអន្តរក្រសួងបានព្រាងនិងដាក់ឆ្លងកាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០កន្លងមក។

គោលបំណងនៃអង្គប្រជុំ គឺដើម្បីពិភាក្សាឱ្យស៊ីជម្រៅក្នុងការជំរុញឱ្យផែនការមេនេះមានភាពសុខដុមរមណីយកម្មរវាងគ្រប់ផ្នែកពាក់ព័ន្ធ ជាពិសេសលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឱ្យមានការរីកចម្រើនតាមរយៈវិស័យទេសចរណ៍ប្រកបដោយសមធម៌៕

ដើមឈើប្រណីតនិងឈើផ្កាព្រៃចំនួន៤០០ដើមត្រូវបានដាំក្នុងបរិវេណប្រាសាទអង្គរវត្ត ក្រោមប្រធានបទ «សន្តិភាព យុត្តិធម៌ សាសនា បេតិកភណ្ឌ បរិស្ថាន»

ផ្សាយនៅថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០២០

ដើមឈើប្រណីតមានធ្នង់ គ្រញូង បេង នាងនួន សុក្រំនិង ឈើផ្កាវំដួល ថ្កុលមាស សរុបចំនួន៤០០ដើម បានដាំនៅក្នុងបរិវេណប្រាសាទអង្គរវត្ត នាព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ ក្រោមប្រធានបទ «សន្តិភាព យុត្តិធម៌ សាសនា បេតិកភណ្ឌ បរិស្ថាន»។

ពិធីដាំកូនឈើនេះអញ្ជើញចូលរួមដោយ **ឯកឧត្តម តី គាច** ប្រធានក្រុមមេធាវីរាជរដ្ឋាភិបាលនិងជាប្រធានក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន **ឯកឧត្តម ពៅ ពិសិទ្ធិ** គណៈអភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា និងមន្ត្រី បុគ្គលិកតាមស្ថាប័ននីមួយៗ សរុប២៣៤នាក់។

មានប្រសាសន៍នាឱកាសនោះ **ឯកឧត្តម ហង់ ពៅ** បានលើកឡើងថា អាជ្ញាធរជាតិអប្សរាបានដាំកូនឈើនៅក្នុងឧទ្យានអង្គរចាប់ពីឆ្នាំ២០០៤ ជាប្រយោជន៍សម្រាប់ការរស់នៅនិងការអភិរក្សប្រាង្គប្រាសាទ រួមទាំងបម្រើឱ្យវិស័យទេសចរណ៍ផង។ ឯកឧត្តម ក៏បានបញ្ជាក់ថា មុនកាប់ដើមឈើមួយដើមៗ គួរពិចារណាពីផលប្រយោជន៍របស់ដើមឈើ ហើយចូលរួមដាំឡើងវិញទាំងអស់គ្នា និងចងចាំថា «ដើមឈើខ្ញុំនៅក្នុងតំបន់អង្គរ»។ ក្នុងនោះដែរ ជាគោលដៅឆ្នាំនេះ អាជ្ញាធរជាតិអប្សរានឹងចែកជូនកូនឈើជាង១០ម៉ឺនដើមឱ្យទៅសាធារណជនយកទៅដាំនៅតាមសហគមន៍ និងបង្កើតគម្របបៃតងដល់បរិស្ថាន។

ឯកឧត្តម ពៅ ពិសិដ្ឋ ក៏បានលើកឡើងថា គ្រប់គ្នាតែងមានគំនិតព្រួយបារម្ភ ពីការរេចរិលព្រៃឈើនៅក្នុងប្រទេសកម្ពុជា នាំឱ្យបាត់បង់ទំនុកចិត្តក្នុងការដាំដើមឈើឡើងវិញតែសូមតាំងស្មារតីឡើងដើម្បីរួមគ្នាជាថ្មី ប្រយុទ្ធប្រឆាំងការបំផ្លាញព្រៃឈើ ឱ្យស្របតាមប្រសាសន៍របស់សម្តេចតេជោ គឺត្រូវដាំដើមឈើឱ្យបានរាប់ម៉ឺនហិកតារាប់លានដើមនៅក្នុងប្រទេសកម្ពុជា ខណៈស្រុកទេសមានសុខសន្តិភាព។ សូមកុំឱ្យមានត្រឹមទស្សនៈស្រឡាញ់ដើមឈើ តែមិនដាំ ហើយនាំតែគ្នាបំផ្លាញ។

ឯកឧត្តម តី គាច បានថ្លែងអំណរគុណចំពោះការសម្របសម្រួលរបស់អាជ្ញាធរជាតិអប្សរានិងគណៈអភិបាលខេត្តសៀមរាប រួមទាំងប្រជាពលរដ្ឋអនុញ្ញាតឱ្យក្រុមមេធាវីបានដាំដើមឈើនៅក្នុងបរិវេណខាងត្បូងប្រាសាទអង្គរវត្ត ទុកជាកេរតំណែល និងជាគំរូសម្រាប់បំផុសទឹកចិត្តឱ្យសាធារណជនស្រឡាញ់ ព្រមទាំងចូលរួមដាំដើមឈើទាំងតាមទីសាធារណៈស្ថាប័នតំបន់ប្រវត្តិសាស្ត្រនិងសហគមន៍ដែលខ្លួនរស់នៅកាន់តែច្រើន។

ឯកឧត្តម ក៏បានបញ្ជាក់ពីមូលហេតុនៃការរៀបចំពិធីនេះ គឺក្រោមការដឹកនាំរបស់សម្តេចតេជោ បានធ្វើឱ្យប្រទេសមានសន្តិភាព ដែលនាំមកនូវការអភិវឌ្ឍ យុត្តិធម៌ សាសនា សុខុដុមរមនា ការការពារបេតិកភណ្ឌ និងបរិស្ថានបានល្អ។

ក្រៅពីពិធីដាំកូនឈើ ថ្នាក់ដឹកនាំក្រុមមេធាវីស្ម័គ្រចិត្តរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំខេត្តសៀមរាប និងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា រួមទាំងសមាជិក សមាជិកា ក៏បានជិះកង់ដើម្បីបរិស្ថាន ហើយនឹងធ្វើពិធីបួងសួងសុំសេចក្តីសុខចម្រើនដល់វត្ថុស័ក្តិសិទ្ធិនៅប្រាសាទអង្គរវត្តថែមទៀតផង៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាៈ ដើមឈើមានតួនាទីសំខាន់ក្នុងការថែរក្សាអភិរក្សប្រាសាទបុរាណ នៅក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០២០

នៅក្នុងពិធីដាំកូនឈើនៅបរិវេណប្រាសាទអង្គរនៅព្រឹកថ្ងៃទី១៥ខែកក្កដាឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជម្រាបជូនអង្គពិធីទាំងមូលអំពីប្រយោជន៍សំខាន់របស់ព្រៃឈើក្នុងកិច្ចការអភិរក្សបេតិកភណ្ឌដោយមានប្រសាសន៍ថា ប្រាសាទបុរាណទាំងអស់នៅក្នុងតំបន់អង្គរត្រូវបានការការពារនិងថែរក្សាដោយសារដើមឈើ។ ឯកឧត្តមបានពន្យល់ថា តាមការវាស់វិទ្យាសាស្ត្រ ថ្មប្រាសាទ មានសីតុណ្ហភាពនៅពេលថ្ងៃរសៀលរហូតដល់ជិត៨០អង្សា និងធ្លាក់មកត្រឹមប្រមាណ២០អង្សានៅពេលយប់។ ដូច្នេះគម្លាតពេលថ្ងៃនិងយប់រហូតដល់៦០ដឺក្រេ។

ឯកឧត្តមបានបញ្ជាក់ថា នៅពេលថ្មក្តៅខ្លាំងវាអាចផ្ទាត់ ខូចជាក់ស្តែងឃើញមានបញ្ហាកើតមានទៅលើរូបចម្លាក់មួយចំនួន។ ប៉ុន្តែនៅពេលយើងមានដើមឈើច្រើននៅតំបន់អង្គរ ដើមឈើបានជួយធ្វើឱ្យមានសំណើម ដែលអាចជួយកាត់បន្ថយកំដៅទៅលើថ្ម ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការអភិរក្សប្រាសាទរបស់យើង។ ក្រៅពីការជួយធ្វើឱ្យមានសំណើមដល់ថ្មប្រាសាទហើយនោះ ដើមឈើក៏បានជួយរក្សាទឹកនៅក្រោមដី និងការពារខ្យល់បោកបក់មលលើប្រាសាទផងដែរ។ ដូច្នេះហើយបានជាអាជ្ញាធរជាតិអប្សរាបានដាំកូនឈើនៅក្នុងឧទ្យានអង្គរចាប់ពីឆ្នាំ២០០៤ ជាប្រយោជន៍សម្រាប់ការរស់នៅ និងការអភិរក្សប្រាង្គប្រាសាទ រួមទាំងបម្រើឱ្យវិស័យទេសចរណ៍ផង។

ឯកឧត្តមសូមអំពាវនាវថា មុនកាប់ដើមឈើមួយដើមៗ គួរពិចារណាពីផលប្រយោជន៍របស់ដើមឈើ ហើយចូលរួមដាំឡើងវិញទាំងអស់គ្នា និងចងចាំថា «ដើមឈើខ្ញុំនៅក្នុងតំបន់អង្គរ»។ ជាគោលដៅ ក្នុងឆ្នាំ២០២០នេះ អាជ្ញាធរជាតិអប្សរា នឹងចែកជូនកូនឈើជាង១សែនដើម ឱ្យទៅសាធារណជនយកទៅដាំនៅតាមសហគមន៍ និងបង្កើតគម្របបៃតងដល់បរិស្ថាន។

សូមបញ្ជាក់ថា ដើមឈើចំនួន៤០០ដើមដាំនៅក្នុងបរិវេណប្រាសាទអង្គរវត្តនៅថ្ងៃនេះ ក្រោមប្រធានបទ «សន្តិភាព យុត្តិធម៌ សាសនា បេតិកភណ្ឌ បរិស្ថាន» មានដូចជា ធ្នង់ ក្រញូង បេង នាងនួន សុក្រំនិងឈើផ្កាំរំដួល ថ្កុលមាស៕

អាជ្ញាធរជាតិអប្សរាផ្តល់កូនឈើជូនមន្ទីរបរិស្ថានខេត្តសៀមរាបចំនួន២៥០០ដើមបន្ថែមទៀត

ផ្សាយនៅថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០២០

នៅថ្ងៃទី១៦ខែកក្កដា ឆ្នាំ២០២០នេះអាជ្ញាធរជាតិអប្សរា បានផ្តល់កូនឈើ ជូនមន្ទីរបរិស្ថានខេត្តសៀមរាបចំនួន ២៥០០ដើមបន្ថែមទៀត ដើម្បីដាំស្តារព្រៃឡើងវិញ នៅក្នុង ឧទ្យានជាតិព្រះជ័យវរ្ម័ន-នរោត្តម ភ្នំគូលែន។ កូនឈើទាំង នោះរួមមាន គ្រញូង៥០០ដើម ធ្នង់៥០០ដើម បេង ៥០០ដើម កកោះ២៥០ដើម និងគគីរ៧៥០ដើម។

គួរបញ្ជាក់ថា នៅថ្ងៃទី៣ ខែកក្កដា កន្លងទៅ អាជ្ញាធរជាតិ អប្សរាក៏បានផ្តល់ដើមឈើទាំងនេះដល់មន្ទីរបរិស្ថានផងដែរ ដែលលើកមុនមានចំនួន ៣០០០ដើមមាន ឈើទាល ៥០០ដើម គគីរ៧៥០ដើម ធ្នង់៥០០ដើម គ្រញូង៧៥០ដើម និងបេង៥០០ដើម។ សរុបទាំង២លើក កូនឈើ៥,៥០០ ដើមហើយ ដែលផ្តល់ជូនដល់មន្ទីរបរិស្ថាន ដើម្បីយក ទៅដាំនៅតំបន់ភ្នំគូលែន៕

បាឋកថាស្តីអំពី «រចនាសម្ពន្ធសំណង់ឈើនៅស្រះអង្គរ»

ផ្សាយនៅថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០២០

អ្នកជំនាញបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាចំនួន៣រូប គឺលោកសាស្ត្រាចារ្យ អ៊ឹម សុខរិទ្ធី លោក ស្រ៊ុន តិច និង លោកស្រី ភិន វិជ្ជាសច្ចា៉ នឹងរួមគ្នាធ្វើបទបង្ហាញអំពី «ការស្រាវជ្រាវថ្មីៗនៅក្នុងតំបន់អង្គរ» ក្រោមប្រធានបទ «រចនាសម្ពន្ធសំណង់ឈើនៅស្រះអង្គរ» នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ខាងមុខនេះ នាវេលាម៉ោង៩: ០០នាទីព្រឹក ដល់ម៉ោង១២:០០នាទីថ្ងៃត្រង់ នៅសាលសន្និសីទអង្គរនៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។

ដូច្នេះ ដើម្បីជ្រាបកាន់តែច្បាស់អំពីខ្លឹមសារនៃបាឋកថាស្តីអំពី «រចនាសម្ពន្ធសំណង់ឈើនៅស្រះអង្គរ» អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមគោរពអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី បុគ្គលិកគ្រប់ស្ថាប័ន អ្នកស្រាវជ្រាវ មគ្គុទ្ទេសទេសចរណ៍ សិស្សានុសិស្ស និង សាធារណជនចំនួន៥០នាក់ប៉ុណ្ណោះ (អនុវត្តន៍តាមគោលការណ៍នៃការរីករាលដាលជំងឺកូវីដ១៩) ដើម្បីចូលរួមសិក្សា ស្តាប់បាឋកថានេះជាប្រយោជន៍ក្នុងការបង្កើនចំណេះដឹងដោយមេត្រី។

លិខិតអញ្ជើញ

មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាអញ្ជើញចូលរួម សិក្សា ស្តាប់បាឋកថា ស្តីពី "ការស្រាវជ្រាវបុរាណវិទ្យាថ្មីៗនៅតំបន់អង្គរ"

ក្រោមប្រធានបទ ៖ **រចនាសម្ព័ន្ធសំណង់ឈើនៅស្រះអង្គរ**

បទបង្ហាញដោយ ៖ - លោកសាស្ត្រាចារ្យ អ៊ឹម សុខរិទ្ធី
- លោក ស្រ៊ុន តិច
- លោកស្រី ភិន វិជ្ជាសច្ចា៉

នាថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង ១២:០០នាទីថ្ងៃត្រង់

នៅសាលសន្និសីទអង្គរ នៃអាជ្ញាធរជាតិអប្សរា

(បន្ទប់ធំទូលាយ ហើយកំណត់សាធារណជនចូលរួមស្តាប់ត្រឹមតែចំនួន ៥០ រូប ប៉ុណ្ណោះ ដោយអនុវត្តនូវគោលការណ៍ណែនាំស្តីពីការបង្ការការរីករាលដាលនៃជម្ងឺឆ្លង Covid 19)

<u>កំណត់សម្គាល់</u> ៖ ដើម្បីសម្រួលដល់ការរៀបចំ សូមមន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាផ្តល់ដំណឹងអំពីការចូលរួម តាមលេខទូរស័ព្ទ៖ ០១២ ៧៣៤ ៥២០/ ០៩២ ៣៦៩ ៨៨០ ឲ្យបាន០១ថ្ងៃ មុនថ្ងៃចាប់ផ្តើមកម្មវិធី។ សូមអរគុណ!

អាជ្ញាធរជាតិអប្សរាបន្តកិច្ចប្រជុំពិភាក្សាលើពង្រាងផែនការមេវិស័យទេសចរណ៍ខេត្តសៀមរាប ឆ្នាំ២០២០-២០៣៥

ផ្សាយនៅថ្ងៃទី១៧ ខែ កក្កដា ឆ្នាំ២០២០

នាថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ **ឯកឧត្តម ស៊ុំ ម៉ាប់** រដ្ឋលេខាធិការក្រសួងវប្បធម៌និងវិចិត្រសិល្បៈ តំណាង **លោកជំទាវ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្ប និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា រួមនឹងថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា បានបន្តពិភាក្សាលើពង្រាងផែនការមេវិស័យទេសចរណ៍នៅក្នុងខេត្តសៀមរាបនិងរមណីយដ្ឋានអង្គរ។

អង្គប្រជុំនៅថ្ងៃនេះ បានសង្កត់ធ្ងន់លើការកែតម្រូវចំណុចឮខ្វះខាត ការដកចេញចំណុចប៉ះពាល់ ការរកដំណោះស្រាយបញ្ហាផ្សេងៗការពិចារណានូវចំណុចមួយចំនួនតាមរយៈការទទួលបានពីកិច្ចពិភាក្សាក្នុងកិច្ចប្រជុំផ្ទៃក្នុងនិងអន្តរក្រសួងនាកិច្ចប្រជុំមុនៗ សម្រាប់តៀមយកទៅបង្ហាញក្នុងកិច្ចប្រជុំនាពេលខាងមុខ៕

អាជ្ញាធរជាតិអប្សរាសហការជាមួយអគ្គលេខាធិការដ្ឋានប្រជាជន និងការអភិវឌ្ឍ នៃក្រសួងផែនការដាំកូនឈើ៧៥០ដើមក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៩ ខែ កក្កដា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៨ខែកក្កដា ឆ្នាំ២០២០នៅបរិវេណខាងកើតប្រាសាទប្រី មានរៀបចំកម្មវិធីដាំកូនឈើឡើងវិញ ក្រោមការរៀបចំនិងសម្របសម្រួលដោយ អាជ្ញាធរជាតិអប្សរា ដោយ

មានការចូលរួមមកពីថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានប្រជាជននិងការអភិវឌ្ឍនៃក្រសួងផែនការចំនួន៣៥នាក់។ក្នុងពិធីនោះក៏មានការចូលរួមពីនគរបាលការពារបេតិកភណ្ឌ ភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្ដាប់ធ្នាប់ ភ្នាក់ងារអភិរក្សព្រៃឈើ ព្រមទាំងមន្ត្រី បុគ្គលិក ពលករនៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន ដែលសរុបអ្នកចូលរួមទាំងអស់ចំនួន ៩០នាក់។ កូនឈើដែលដាំនៅពេលនោះសរុប ៧៥០ដើម ដែលមានដើមបេង ចំនួន៥០០ដើមនិងដើមគ្រញូង២៥០ដើម៕

អាជ្ញាធរជាតិអប្សរាសហការជាមួយមន្ត្រីនៃរាជបណ្ឌិតសភាកម្ពុជាដាំកូនឈើ២០០០ដើម នៅខាងកើតប្រាសាទប្រែ

ផ្សាយនៅថ្ងៃទី២០ ខែ កក្កដា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា សហការជាមួយមន្ត្រីរាជការនៃរាជបណ្ឌិតសភាកម្ពុជា ដាំកូនឈើចំនួន ២០០០ដើមនៅបរិវេណខាងកើតប្រាសាទប្រែ។ កម្មវិធីដែលធ្វើឡើងនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ មានអ្នកចូលរួមសរុបជាង ២០០អង្គ/នាក់។

ដើមឈើដែលដាំក្នុងពិធីនៅពេលនោះរួមមានដើមគ្រញូង ចំនួន១០០០ដើម ដើមធ្នង់ ចំនួន៥០០ដើម និងដើមបេង ចំនួន៥០០ដើម។ ក្រៅពីខាងរាជបណ្ឌិតសភាកម្ពុជា ក្នុងនោះក៏មានការចូលរួមដាំពីកម្លាំងនគរបាលបេតិកភណ្ឌ ភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ ភ្នាក់ងារព្រៃឈើ បុគ្គលិក និងពលករ នៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរាផងដែរ៕

សិលាចារឹកដែលរកឃើញនៅប្រាសាទទន្លេស្ងួតត្រូវបានចុះលេខ K.1459 ក្នុងបញ្ជីសារពើភណ្ឌសិលាចារឹកកម្ពុជា

ផ្សាយនៅថ្ងៃទី២២ ខែ កក្កដា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា សហការជាមួយមន្ត្រីរាជការនៃរាជបណ្ឌិតសភាកម្ពុជា ដាំកូនឈើចំនួន ២០០០ដើមនៅបរិវេណខាងកើតប្រាសាទប្រើ។
កម្មវិធីដែលធ្វើឡើងនៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២០ មានអ្នកចូលរួមសរុបជាង២០០អង្គ/នាក់។

ដើមឈើដែលដាំក្នុងពិធីនៅពេលនោះរួមមានដើមគ្រញូង ចំនួន១០០០ដើម ដើមធ្នង់ ចំនួន៥០០ដើម និងដើមបេង ចំនួន៥០០ដើម។ ក្រៅពីខាងរាជបណ្ឌិតសភាកម្ពុជា ក្នុងនោះក៏មានការចូលរួមដាំពីកម្លាំងនគរបាលបេតិកភណ្ឌ ភ្នាក់ងារទេសចរណ៍ ភ្នាក់ងារសណ្តាប់ធ្នាប់ ភ្នាក់ងារព្រៃឈើ បុគ្គលិក និងពលករ នៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរាផងដែរ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា អាជ្ញាធរមូលដ្ឋាន ពិនិត្យ និងអនុញ្ញាត សំណើសុំជួសជុលសំណង់តូចតាចរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៣៦ សំណើ

ផ្សាយនៅថ្ងៃទី២២ ខែ កក្កដា ឆ្នាំ២០២០

កាលពីថ្ងៃអង្គារ ទី២១ ខែកក្កដា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា មានការចូលរួមជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះក្នុងបួនគោលដៅ របស់ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារសហគមន៍ប្រចាំស្រុកពួក ដឹកនាំដោយលោកអឿន សំអុន បានពិនិត្យនិងដោះស្រាយចំនួន ០៤សំណើ ស្ថិតក្នុងភូមិបឹងខ្នា ភូមិព្រៃក្មេង ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន ០៤សំណើ។

គោលដៅទី២ ក្រុមការងារសហគមន៍ប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ លោកស្រី ម៉ៅ ល្អ បានពិនិត្យ និងដោះស្រាយការស្នើសុំធ្វើបង្គន់គម្រោងបដិភាគ SDGERA ចំនួន ១៧សំណើ ស្ថិតក្នុងភូមិគោកស្រុក ឃុំរលួស។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន ១៥សំណើ។

គោលដៅទី៣ ក្រុមការងារសហគមន៍ប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយចំនួន ០៩សំណើ ស្ថិតក្នុងភូមិថ្នល់បណ្តោយ ភូមិថ្នល់ទទឹង និង ភូមិតាកុះ ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាត ០៩សំណើ។

គោលដៅទី៤ ក្រុមការងារសហគមន៍ប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយចំនួន ១២សំណើ ស្ថិតក្នុងភូមិសំរោង ភូមិក្លង់ ឃុំលាងដៃ។ក្រោយពីពិនិត្យទីតាំងនិងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាត ០៨សំណើ។

សរុបមក នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានបានពិនិត្យ និងដោះស្រាយសំណើរបស់ប្រជាពលរដ្ឋទាំង៥ស្រុកបានចំនួន៣៦ សំណើ៕

បាឋកថាស្តីអំពី «ព្រះពុទ្ធបដិមានៅអង្គរវត្ត»

ផ្សាយនៅថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០២០

ក្រោយកំណាយស្រាវជ្រាវបុរាណវិទ្យានៅទីធ្លាមុខរូតព្រះរយព្រះពាន់ បានប្រទះឃើញពុទ្ធរូបជាច្រើនអង្គកាលពីខែមេសា ឆ្នាំ២០២០កន្លងមក អ្នកជំនាញបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរាចំនួន៣រូប គឺលោកសាស្ត្រាចារ្យ អ៊ឹម សុខរិទ្ធី លោក ស្រ៊ុន តិច និងលោកស្រី ភិន វិជ្ជាសច្ចា៉ នឹងរួមគ្នាធ្វើបទបង្ហាញអំពី«ការស្រាវជ្រាវថ្មីៗនៅក្នុងតំបន់អង្គរ» ក្រោមប្រធានបទ «ព្រះពុទ្ធបដិមានៅអង្គរវត្ត» នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ខាងមុខនេះ នាវេលាម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង១២:០០នាទីថ្ងៃត្រង់ នៅសាលសន្និសីទអង្គរនៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរាខាងមុខនេះ។

ដូច្នេះ ដើម្បីជ្រាបកាន់តែច្បាស់អំពីខ្លឹមសារនៃបាឋកថាស្តីអំពី «ព្រះពុទ្ធបដិមានៅអង្គរវត្ត» អាជ្ញាធរជាតិអប្សរាមានកិត្តិយសសូមគោរពអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី បុគ្គលិកគ្រប់ស្ថាប័ន អ្នកស្រាវជ្រាវ មគ្គុទ្ទេសទេសចរណ៍ សិស្សានុសិស្ស និងសាធារណជនចំនួន៥០នាក់ប៉ុណ្ណោះ (អនុវត្តន៍តាមគោលការណ៍នៃការរីករាលដាលជំងឺកូវីដ១៩) ដើម្បីចូលរួមសិក្សា ស្តាប់បាឋកថានេះជាប្រយោជន៍ក្នុងការបង្កើនចំណេះដឹងដោយមេត្រី។



លិខិតអញ្ជើញ

មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាអញ្ជើញចូលរួម សិក្សា ស្តាប់បាឋកថាស្តីពី "ការស្រាវជ្រាវបុរាណវិទ្យាថ្មីៗនៅតំបន់អង្គរ"

ក្រោមប្រធានបទ ៖ **ព្រះពុទ្ធបដិមានៅអង្គរវត្ត**

បទបង្ហាញដោយ ៖ - លោកសាស្ត្រាចារ្យ អ៊ឹម សុខរិទ្ធី
- លោក ស្រ៊ុន តិច
- លោកស្រី ភិន វិជ្ជាសច្ចា៉

នាថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង ១២:០០នាទីថ្ងៃត្រង់

នៅសាលសន្និសីទអង្គរ នៃអាជ្ញាធរជាតិអប្សរា

(បន្ទប់ធំទូលាយ ហើយកំណត់សាធារណជនចូលរួមស្តាប់ត្រឹមតែចំនួន ៥០រូប ប៉ុណ្ណោះ ដោយអនុវត្តនូវគោលការណ៍ណែនាំស្តីពីការបង្ការការរីករាលដាលនៃជម្ងឺឆ្លង Covid 19)

កំណត់សម្គាល់ ៖ ដើម្បីសម្រួលដល់ការរៀបចំ សូមមន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាផ្តល់ដំណឹងអំពីការចូលរួម តាមលេខទូរស័ព្ទ៖ ០៩២ ៣៦៩ ៨៨០/០១២ ៧៣៤ ៥២០ ឲ្យបាន០១ថ្ងៃមុន

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ចុះពិនិត្យ និងដោះស្រាយ សំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៨សំណើ

ផ្សាយនៅថ្ងៃទី២៣ ខែ កក្កដា ឆ្នាំ២០២០

ក្រុមការងារសហគមន៍តែងចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលលើករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីអាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរ។

ជាក់ស្តែង នៅថ្ងៃព្រហស្បតិ៍ ទី២៣ ខែកក្កដា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន ២គោលដៅ ប្រចាំក្រុងសៀមរាប និងគោលដៅស្រុកពួក ដែលមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៨សំណើ ក្នុងចំណោម១៨សំណើ។

គោលដៅទី១ ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប ដឹកនាំដោយលោក ឡុង កុសល បានពិនិត្យនិងដោះស្រាយចំនួន១០សំណើ ស្ថិតក្នុងភូមិត្រពាំងសេស សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន០៤សំណើ។

រីឯក្រុមការងារសហគមន៍ប្រចាំស្រុកពួក ដឹកនាំដោយលោក អឿន សំអ៊ុន បានពិនិត្យនិងដោះស្រាយចំនួន០៨សំណើ ស្ថិតក្នុងភូមិគោកត្រាច ភូមិព្រៃធ្លក ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំងនិងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន០៤សំណើ៕

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០២០

តាមរបាយការណ៍របស់នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា នៅសប្តាហ៍ទី២ ខែកក្កដា ឆ្នាំ២០២០នេះ ក្រុមការងារនៃនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរប្រចាំច្រកទាំង០៦ របស់អាជ្ញាធរជាតិអប្សរា បានទទួលពាក្យស្នើសុំសាងសង់លំនៅដ្ឋាន និងជួសជុលតូចតាចចំនួន៤៩ករណី។

បន្ទាប់ពីទទួលបានសំណើខាងលើ មន្ត្រី-បុគ្គលិកជំនាញបានចុះពិនិត្យដល់ទីតាំងផ្ទាល់ដើម្បីពិនិត្យមើលលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់របស់ប្រជាពលរដ្ឋម្ចាស់សំណើចំនួន២១ករណី រួមមាន៖

១. ក្រុងសៀមរាប ចំនួន០៨ករណី
២. ស្រុកបន្ទាយស្រី ចំនួន០២ករណី
៣. ស្រុកអង្គរធំ ចំនួន០៤ករណី
៤. ស្រុកប្រាសាទបាគង ចំនួន០៧ករណី។

ក្រោយបានការអនុញ្ញាត មន្ត្រី-បុគ្គលិកជំនាញរបស់នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ ក៏បានចុះទៅដល់ទីតាំងសាងសង់ផ្ទាល់ ដើម្បីពិនិត្យតាមដាន ចំពោះប្រជាពលរដ្ឋណាដែលមានលក្ខខណ្ឌគ្រប់គ្រាន់លើការអនុញ្ញាត គឺក្រុមការងារផ្នែកស្ថាបត្យកម្ម ក៏បានជួយរៀបចំគំនូសប្លង់លំនៅដ្ឋានបែបខ្មែរជូនពួកគាត់បាន ០៨ករណី មានដូចជា៖

១.ក្រុងសៀមរាប ចំនួន០៤ករណី
២.ស្រុកបន្ទាយស្រី ចំនួន០១ករណី
៣.ស្រុកពួក ចំនួន០២ករណី
៤.ស្រុកប្រាសាទបាគង ចំនួន០១ករណី

អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យ ព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើ រហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ ពោលគឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ។

លិខិតអបអរសាទរលោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០២០

តាំងនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក គ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា និងតាំងនាមខ្លួនខ្ញុំផ្ទាល់ យើងខ្ញុំសូមសំដែងនូវការអបអរសាទរដ៏ឧត្តុង្គឧត្តម និងកោតសរសើរយ៉ាងជ្រាលជ្រៅបំផុតក្នុងឱកាសដែលលោកជំទាវរដ្ឋមន្ត្រីត្រូវបានព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់ផ្តល់គោរមងារកិត្តិយសនៃរាជបណ្ឌិត្យសភាកម្ពុជា ជូនលោកជំទាវជា «បណ្ឌិតសភាចារ្យ»។

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា អញ្ជើញចុះពិនិត្យរូបចម្លាក់ឧបករណ៍ភ្លេងបុរាណនៅតាមប្រាសាទក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែ កក្កដា ឆ្នាំ២០២០

ក្នុងឱកាសអញ្ជើញបំពេញភារកិច្ចនៅតាមបណ្តាខេត្តនៅថ្ងៃទី២៦ខែកក្កដាឆ្នាំ២០២០ **លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា អមដំណើរដោយថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរានិងអ្នកជំនាញឧបករណ៍ភ្លេងបុរាណលើចម្លាក់ប្រាសាទ បានអញ្ជើញពិនិត្យរូបចម្លាក់ដែលបង្ហាញពីឧបករណ៍ភ្លេងបុរាណនានានៅតាមប្រាសាទមួយចំនួន៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរាបញ្ជាក់ថា បដិមាដែលប្រទះឃើញនៅប្រាសាទអង្គរវត្ត គឺមិនមែនជាការកប់ចោលទេ

ផ្សាយនៅថ្ងៃទី២៧ ខែ កក្កដា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៧ កក្កដា ឆ្នាំ២០២០ នៅសាលសន្និសីទអង្គរនៃអាជ្ញាធរជាតិអប្សរា បានរៀបចំបាឋកថាស្តីពី «ព្រះពុទ្ធបដិមានៅអង្គរវត្ត» ដើម្បីចែករំលែកជុំវិញការងារដែលក្រុមអ្នកជំនាញអាជ្ញាធរជាតិអប្សរា បានប្រទះឃើញព្រះពុទ្ធបដិមាច្រើនអង្គ ក្នុងរណ្តៅដីនៅជ្រុងនិរតីនៃប្រាសាទអង្គរវត្ត។ តាមបទបង្ហាញរបស់ក្រុមអ្នកជំនាញ បានបង្ហាញឱ្យឃើញច្បាស់ថា ការកប់នេះមិនមែនជាការកប់ចោលលេងៗនោះទេ តែជាការរៀបចំត្រឹមត្រូវ និងដោយការគោរពចំពោះបដិមាទាំងនោះ។

បុរាណវិទូលោកស្រីភិនវិជ្ជាសច្ចារ៉ា អំឡុងពេលធ្វើបាឋកថា បានរៀបរាប់ថា តាមការសិក្សាយ៉ាងលម្អិត និងត្រួតពិនិត្យនៅក្នុងរណ្តៅកប់បំណែកព្រះពុទ្ធបដិមា ឃើញថាការកប់នេះមិនមែនជាការកប់បោះចោលនោះទេ។

លោកស្រីពន្យល់ថា ការកប់នេះគឺមានការយកចិត្តទុកដាក់បំផុត ដោយមានការកប់ជាដំណាក់ៗនិងដោយព្រឹត្តព្រៀងបំផុតដើម្បីចំណេញទីតាំង។

លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ ពន្យល់បន្ថែមថា ជាទូទៅសម្រាប់អ្នកមានជំនឿដែលជឿលើបដិមាដែលស័ក្តិសិទ្ធិទាំងនោះ គឺតែងរៀបចំរូបដែលបាក់បែកនៅកន្លែងទីតាំងសមរម្យ តែមិនមែនមានន័យថាបោះចោលទេ។ តួយ៉ាងករណីនៅប្រាសាទអង្គរវត្តនេះ គឺចាស់បុរាណសម័យមុនទុកដាក់រៀបចំកប់ត្រឹមត្រូវ និងដោយការគោរពវត្ថុទាំងនោះ។

គួររំលឹកថា នៅពាក់កណ្តាលខែមេសា ឆ្នាំ២០២០ ក្រុមការងាររបស់អាជ្ញាធរជាតិអប្សរានៃនាយកដ្ឋានគ្រប់គ្រងទឹកក្នុងគម្រោងរៀបចំប្រព័ន្ធស្រោចស្រពស្មៅ នៅបរិវេណប្រាសាទអង្គរវត្ត បានប្រទះឃើញបំណែកព្រះពុទ្ធបដិមាច្រើនអង្គក្នុងរណ្តៅរួមមួយ។ បំណែកទាំងនោះមាន ដងខ្លួនព្រះពុទ្ធបដិមាសម័យក្រោយអង្គរ បំណែករូបសិល្បៈ សម្ភារប្រើប្រាស់ កាំបិទ ដប។ល។ ដែលតាមការសន្និដ្ឋានរូបទាំងនោះត្រូវបាននាំយកពីរូតព្រះពាន់ និងតាមការសន្និដ្ឋានការកប់នេះអាចធ្វើឡើងនៅអំឡុងឆ្នាំ១៩៨០ប៉ុណ្ណោះ៕

អាជ្ញាធរជាតិអប្សរាផ្តល់កូនឈើ៣០០ដើមដល់ព្រះសង្ឃតំណាងសមាគមជីវិតនិងក្តីសង្ឃឹម

ផ្សាយនៅថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០២០

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា បានផ្តល់កូនឈើចំនួន៣០០ដើម ដល់ព្រះសង្ឃដែលជាតំណាងសមាគមជីវិត និងក្តីសង្ឃឹម ដើម្បីយកទៅដាំក្នុងបរិវេណសាលាបឋមសិក្សាថ្លាត ស្ថិតនៅភូមិថ្លាត ឃុំខ្វាស់ ស្រុកសូទ្រនិគម ខេត្តសៀមរាប។

កូនឈើដែលផ្តល់ជូននៅពេលនោះរួមមាន ឈើគ្រញូង ចំនួន ១៥០ដើម និងឈើធ្នង់ចំនួន ១៥០ដើម៕

ផ្ទៃដីដែលធ្លាប់ទន្រ្ទានខុសច្បាប់ក្នុងតំបន់រមណីយដ្ឋានអង្គរត្រូវបានដាំកូនឈើឡើងវិញ

ផ្សាយនៅថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០២០

ក្នុងបំណងបំពេញគម្របព្រៃឈើឡើងវិញ ក្រោយមានការកាប់ទន្ទ្រានខុសច្បាប់កន្លងមក នៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ ក្រុមភ្នាក់ងារព្រៃឈើនៃនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ សហការជាមួយនាយកដ្ឋាន

គ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា អាជ្ញាធរមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធមាន នគរបាលប៉ុស្តិ៍រដ្ឋបាល នគរបាលបេតិកភណ្ឌ មន្ត្រីឧទ្យាននុរក្ស បានចុះដាំកូនឈើឡើងវិញនៅចំណុចខាងកើតប៉ុស្តិ៍ត្រួតពិនិត្យសំបុត្រផ្លូវ៦០ម ស្ថិតនៅភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុង-ខេត្តសៀមរាប។ ដើមឈើដែលដាំបំពេញបន្ថែមនៅពេលនោះសុទ្ធសឹងជាពូជឈើប្រណីត ដែលរួមមាន ដើមគ្រញូងចំនួន ១៥០ដើម ដើមធ្នង់ចំនួន៧០ដើម និងដើមបេងចំនួន១០០ដើម សរុបមានចំនួន ៣២០ដើម៕

មន្ត្រី-បុគ្គលិកចំនួន៤០រូបនៃអាជ្ញាធរជាតិអប្សរាទទួលការបណ្តុះបណ្តាល អំពី របបសារព័ត៌មាន ការផ្តល់ព័ត៌មាន ទទួលព័ត៌មានក្នុងរង្វង់ មន្ត្រី-បុគ្គលិក

ផ្សាយនៅថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០២០

នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ បានរៀបចំបើកវគ្គបណ្តុះបណ្តាលរបបសារព័ត៌មាន ការផ្តល់ព័ត៌មាន ទទួលព័ត៌មានក្នុងរង្វង់មន្ត្រី-បុគ្គលិក ដល់មន្ត្រី-បុគ្គលិកមកពីនាយកដ្ឋានចំណុះនៃអាជ្ញាធរជាតិអប្សរាចំនួន៤០រូប។

ក្រោមការសម្របសម្រួលរបស់ លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា វគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបចំណេះដឹងដល់មន្ត្រី-បុគ្គលិកដែលទទួលខុសត្រូវផ្តល់ព័ត៌មាន របស់នាយកដ្ឋាននានានៃអាជ្ញាធរជាតិអប្សរា នូវការយល់ដឹងអំពីរបបសារព័ត៌មាន និងការទំនាក់ទំនងក្នុងការផ្តល់ព័ត៌មាននៅក្នុងប្រព័ន្ធផ្សព្វផ្សាយ។

សិក្ខាកាមនឹងបានស្វែងយល់កាន់តែច្បាស់អំពីការភ្ជាប់ទំនាក់ទំនងជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងសារៈសំខាន់របស់សារព័ត៌មាននៅក្នុងសង្គម។ រួមទាំងវិធីសាស្ត្រជាច្រើនក្នុងការផ្តល់ព័ត៌មានឱ្យមានប្រសិទ្ធភាព ច្បាស់លាស់ និងប្រកបដោយគុណភាព វិជ្ជាជីវៈ។

ក្រោយពីសិក្សាវគ្គបណ្តុះបណ្តាលខ្លីនេះ មន្ត្រី-បុគ្គលិកអាចយល់ពីការផ្តល់ព័ត៌មាន និងជួយសម្រួលការងារយកព័ត៌មានប្រសើរឡើងមួយកម្រិតថែមទៀត៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរារួមគ្នាបង្ហាញពី«អាថ៌កំបាំងសំណង់ប្រាសាទនៅក្រោមកុដិវត្តលលៃ»

ផ្សាយនៅថ្ងៃទី២៩ ខែ កក្កដា ឆ្នាំ២០២០

ថ្មីៗកន្លងមកនេះ ក្រុមអ្នកជំនាញស្រាវជ្រាវបុរាណវិទ្យានៃអាជ្ញាធរជាតិអប្សរា ទើបតែបញ្ចប់ការកំណាយនៅប្រាសាទលលៃ បានប្រទះឃើញរចនាសម្ពន្ធសំណង់ប្រាសាទ វត្ថុសិល្បៈ និងឧបករណ៍ប្រើប្រាស់ជាច្រើនដែលមានតម្លៃជាប្រវត្តិសាស្ត្រ ដែលបានកប់ក្នុងដីក្រោមកុដិវត្តលលៃជាច្រើនឆ្នាំ។

ដូច្នេះ ដើម្បីបង្ហាញពីរបកគំហើញនៃលទ្ធផលកំណាយស្រាវជ្រាវបុរាណវិទ្យាទាំងនេះជាប្រយោជន៍ដល់កូនខ្មែរ លោកសាស្ត្រាចារ្យ អ៊ា ដារិទ្ធ លោក ប៉ូ ប៊ុន និងលោកស្រី សៀ ង សុផានី នឹងរួមគ្នាធ្វើបទបង្ហាញអំពី «អាថ៌កំបាំងសំណង់ប្រាសាទនៅក្រោមកុដិវត្តលលៃ» នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ខាងមុខនេះ នាវេលាម៉ោង៩: ០០នាទីព្រឹកដល់ម៉ោង១២:០០នាទីថ្ងៃត្រង់ នៅសាលសន្និសីទអង្គរនៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី បុគ្គលិកគ្រប់ស្ថាប័ន អ្នកស្រាវជ្រាវ មគ្គុទ្ទេសទេសចរណ៍ សិស្សានុសិស្ស និងសាធារណជនចំនួន៥០នាក់ប៉ុណ្ណោះ (អនុវត្តន៍តាមគោលការណ៍នៃការរីករាលដាលជំងឺកូវីដ១៩) ដើម្បីចូលរួមសិក្សា ស្តាប់បាឋកថានេះជាប្រយោជន៍ក្នុងការបង្កើនចំណេះដឹងដោយមេត្រី។



លិខិតអញ្ជើញ

មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាអញ្ជើញចូលរួម សិក្សា ស្តាប់បាឋកថា ស្តីពី "ការស្រាវជ្រាវបុរាណវិទ្យាថ្មីៗនៅតំបន់អង្គរ"

ក្រោមប្រធានបទ ៖ **អាថ៌កំបាំងសំណង់ប្រាសាទនៅក្រោមកុដិវត្តលលៃ**

បទបង្ហាញដោយ ៖ - លោកសាស្ត្រាចារ្យ អ៊ា ដារិទ្ធ
- លោក ថូ ថុន
- អ្នកស្រី សៀង សុផានី

នាថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង ១២:០០នាទីថ្ងៃត្រង់ នៅសាលសន្និសីទអង្គរ នៃអាជ្ញាធរជាតិអប្សរា

(បន្ទប់ធំទូលាយ ហើយកំណត់សាធារណជនចូលរួមស្តាប់ត្រឹមតែចំនួន ៥០រូប ប៉ុណ្ណោះដោយអនុវត្តនូវគោលការណ៍ណែនាំស្តីពីការបង្ការការរីករាលដាលនៃជម្ងឺឆ្លង Covid 19)

កំណត់សម្គាល់ ៖ ដើម្បីសម្រួលដល់ការរៀបចំ សូមមន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាផ្តល់ដំណឹងអំពីការចូលរួម តាមលេខទូរស័ព្ទ៖ ០១២ ៧៣៤ ៥២០/ ០១៦ ៥៤៤ ០១៧ ឲ្យបាន០១ថ្ងៃមុន

អាជ្ញាធរជាតិអប្សរាផ្តល់កូនឈើ៥០ដើមដល់ពលរដ្ឋនៅភូមិជ្រាវ

ផ្សាយនៅថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០២០

នៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាបាន ផ្តល់កូនឈើចំនួន៥០ដើម ដល់លោកស្រី គេន មុំ ដែល ជាប្រជាពលរដ្ឋរស់នៅភូមិជ្រាវ សង្កាត់ជ្រាវ ក្រុងសៀមរាប ដើម្បីយកទៅដាំនៅបរិវេណដីផ្ទាល់ខ្លួន។ កូនឈើដែល ផ្តល់ជូននៅពេលនោះរួមមាន កកោះចំនួន២០ដើម បេង ចំនួន១០ដើមធ្នង់ចំនួន១០ដើមនិងគ្រញូងចំនួន១០ដើម។ គួររំលឹកថា ការផ្តល់ជូនកូនឈើនេះ គឺអាជ្ញាធរជាតិអប្សរា មិនគិតពីតែស្ថាប័នរដ្ឋនោះទេ តែសម្រាប់ស្ថាប័នឯកជន ឬប្រជាពលរដ្ឋទូទៅ ក៏អាចស្នើសុំកូនឈើទាំងនេះទៅដាំ នៅលើដីភូមិ ដីផ្ទះ ឬដីចម្ការផ្ទាល់ខ្លួនបាន។ បំណងនៃការ ចែកចាយនេះ គឺដើម្បីចូលរួមការពារបរិស្ថាន និងបង្កើន គម្របព្រៃឈើនៅក្នុងប្រទេសកម្ពុជា៕

ក្នុងខែកក្កដាឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យនិងផ្តល់នូវប្រឹក្សាយោបល់បច្ចេកទេស សាងសង់លំនៅដ្ឋានដល់អ្នកស្រុកអង្គរចំនួន៣៨៧គ្រួសារ

ផ្សាយនៅថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០២០

កំឡុងខែកក្កដា ឆ្នាំ២០២០ នេះ នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុង ឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរាបានចុះទៅពិនិត្យ និងផ្តល់នូវលក្ខណៈបច្ចេកទេស ដោយពុំគិតប្រាក់កម្រៃក្នុងដំណើរការសាងសង់លំនៅដ្ឋាន ក៏ដូចជាសំណង់ឧបសម្ព័ន្ធផ្សេងៗទៀត ដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងឧទ្យានអង្គរបានចំនួន ៣៨៧គ្រួសារ។

ក្នុងនោះដែរ នាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានចុះពិនិត្យក្រុងសៀមរាបចំនួន ១២១គ្រួសារ ស្រុកប្រាសាទបាគងចំនួន ៩៤គ្រួសារ ស្រុកបន្ទាយស្រីចំនួន ៦១គ្រួសារ ស្រុកពួកចំនួន ៦៩គ្រួសារ ស្រុកអង្គរធំចំនួន ៤២គ្រួសារ។

អាជ្ញាធរជាតិអប្សរានឹងប្រើពេល៤ខែអភិរក្សនិងជួសជុលប្រាសាទដំរីក្រាបនៅលើភ្នំគូលែន

ផ្សាយនៅថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០២០

កាលពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ **ឯកឧត្តម តឹម សុធិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរាបានដឹកនាំក្រុមការងារបច្ចេកទេស ធ្វើពិធីប្រុងពលីដើម្បីសុំសេចក្តីសុខចម្រើនក្នុងការអភិរក្សនិងជួសជុលប្រាសាទដំរីក្រាបនៅលើភ្នំគូលែនឱ្យមានស្ថានភាពល្អប្រសើរឡើងវិញ។

គម្រោងអភិរក្សនិងជួសជុលប្រាសាទនេះ មានរយៈពេល៤ខែ ដោយចាប់ផ្តើមពីថ្ងៃទី២០ខែកក្កដា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដឹកនាំដោយលោកបណ្ឌិត ឈាន រដ្ឋា និងអនុវត្តផ្ទាល់ដោយលោក ពុទ្ធ សុទ្ធ និងមន្ត្រីបុគ្គលិកជំនាញនៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ។

ប្រាសាទដំរីក្រាប រងការខូចខាតខ្លាំងដោយកត្តាទឹកភ្លៀង និងរុក្ខជាតិ ដែលធ្វើឱ្យគ្រឹះស្រុតផ្នែកខាងលិច បណ្តាលឱ្យមានស្នាមប្រេះតូចធំជាច្រើនកន្លែង និងផ្នែកខ្លះមានឫសឈើចាក់ចូលជញ្ជាំងបណ្តាលឱ្យស្នាមប្រេះកាន់តែរីកធំឡើង។ បញ្ហាសំណើមក៏ធ្វើឱ្យផ្នែកខឿនប្រាសាទពុកផុយខ្លាំង និងផ្នែកកណ្តាលមធ្យម។ រួមទាំងកត្តាមនុស្សដែលបានលួចបំផ្លិចបំផ្លាញក្បាច់ក្រឡោតខ្ពស់នៅលើជញ្ជាំង ហោជាង ផ្តែរ និងជីកកកាយគ្រឹះខាងក្នុងប្រាសាទ ធ្វើឱ្យលំនឹងប្រាសាទមានការប្រែប្រួល។

ដើម្បីលើកកម្ពស់តម្លៃប្រាសាទឱ្យផុតពីគ្រោះថ្នាក់ អាជ្ញាធរជាតិអប្សរាសម្រេចពង្រឹងខឿនដែលពុកផុយនៅជុំវិញតួប៉មជួសជុលខ្លោងទ្វារខាងកើត រៀបផ្ចិត ពង្រឹងស្នាមប្រេះតូចធំនៅលើជញ្ជាំង ដំបូល និងជួសជុលដំបូលដែលពុកផុយ។

ប្រាសាទដំរីក្រាប មានទីតាំងស្ថិតនៅភូមិអន្លង់ធំ ឃុំខ្នងភ្នំ ស្រុកស្វាយលើ ខេត្តសៀមរាប។ ជាប្រាសាទឥដ្ឋ ដែលមានតួប៉ម៣សង់លើខឿនតែ១ មានកំពែងព័ទ្ធជុំវិញ ហើយក៏ជាប្រាសាទមួយក្នុងចំណោមប្រាសាទជាច្រើនដែលស្ថិតនៅក្នុងរចនាបថគូលែនក្នុងរជ្ជព្រះបាទជ័យវរ្ម័នទី២ (គ.ស. ៨០២-៨៥០) ដែលជាការចាប់ផ្តើមនៃអារ្យធម៌អង្គរ។ ប្រាសាទនេះមិនសូវខុសប្លែកពីសម័យមុនៗទេ គឺបែរមុខទៅទិសខាងកើត និងមានទ្វារបញ្ឆោតចំនួន៣ ប្លង់បាតមានរាងការេ៕



កូនឈើ១,២០០ ត្រូវបានផ្តល់ជូនអ្នកភូមិក្នុងខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០២០

នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា បានផ្តល់ជូនកូនឈើចំនួន ១,២០០ដើម ដល់តំណាងភូមិត្រពាំងវែង សង្កាត់ក្របីរៀល ក្រុង/ខេត្តសៀមរាប និងតំណាងឃុំព្រៃជ្រូក ស្រុកពួក ខេត្តសៀមរាប។ ក្នុងនោះ ផ្តល់ឲ្យតំណាងភូមិត្រពាំងវែង ចំនួន៣២០ដើម ដើម្បីយកទៅដាំលំអតាមលំនៅដ្ឋាន និងតាមដងផ្លូវក្នុងភូមិ។ កូនឈើទាំងនោះរួមមាន គ្រញូងចំនួន៥០ដើម បេងចំនួន១០ដើម គគីរចំនួន២០ដើម ឈើទាលចំនួន១០ដើម លៀងរាជចំនួន១០០ដើម អង្គារដីចំនួន៥០ដើម ឥន្ទនេលចំនួន២០ដើម ស្តៅចំនួន២០ដើម សេដាចំនួន១០ដើម រំដួលចំនួន១០ដើម និងគុយចំនួន២០ដើម។

បន្ថែមពីនេះ បានផ្តល់កូនឈើជូនតំណាងឃុំព្រៃជ្រូក ចំនួន៧០០ដើម ដើម្បីយកទៅដាំលំអតាមដងផ្លូវពីភូមិប្រដាក់ទៅភូមិពង្រ ឃុំព្រៃជ្រូក ស្រុកពួក ខេត្តសៀមរាប ។ កូនឈើទាំងនោះរួមមាន គគីរចំនួន១០០ដើម គ្រញូងចំនួន១០០ដើមបេងចំនួន១០០ដើមឥន្ទនេលចំនួន២០០ដើម និងរំដួលចំនួន២០០ដើម៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន២១២ ករណីក្នុងខែកក្កដា ឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០២០

របាយការណ៍សកម្មភាពនិងលទ្ធផលការងាររបស់ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាប្រចាំខែកក្កដា ឆ្នាំ២០២០ បានចុះផ្សព្វផ្សាយអប់រំ និងចុះពិនិត្យការស្នើសុំ អនុញ្ញាតការជួសជុល និងសង់តូចតាចទាំង៥គោលដៅស្រុក/ក្រុងក្នុងតំបន់ឧទ្យានអង្គរ បានចំនួន២៩៧ សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន២១២ សំណើ។

ក្នុងករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងបានចំនួន៦៥ករណី ស្រុកអង្គរធំបានចំនួន៣១ករណី ស្រុកពួកបានចំនួន៣៥ករណី ក្រុងសៀមរាបបានចំនួន៣១ករណី និងស្រុកបន្ទាយស្រីបានចំនួន៥០ករណី សរុប២១២ករណី។

បន្ថែមពីនោះ ក្រុមការងារសហគមន៍បានចូលរួមក្នុងកិច្ចការមនុស្សធម៌ ជួយឧត្ដម្ភថវិកាដល់ចាស់ជរា កុមារមានជំងឺ គ្រួសារខ្វះខាតមួយចំនួន រួមទាំងចូលរួមក្នុងកិច្ចការសាសនា កម្មវិធីផ្សេងៗនៅក្នុងសហគមន៍ សំណេះសំណាលដល់ខ្នងផ្ទះប្រជាពលរដ្ឋ និងដោះស្រាយសំណើតាមភូមិទាំង១១២ភូមិក្នុងតំបន់អង្គរ។

សូមបញ្ជាក់ថា ជាគោលដៅបន្ត ក្រុមការងារសហគមន៍និងបន្តផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរឱ្យកាន់តែមានប្រសិទ្ធិភាព ទាន់ពេលវេលា៕

អាជ្ញាធរជាតិអប្សរាបន្តជួយសម្រួលដល់ការងារសាងសង់របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ២០២០

នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរាប្រចាំច្រកទាំង៦ ក្នុងសប្តាហ៍ទី៤នៃខែកក្កដាឆ្នាំ២០២០បានទទួលពាក្យស្នើសុំសាងសង់ពីប្រជាពលរដ្ឋធ្វើលំនៅដ្ឋាន សុំជួសជុលសំណង់ស្រាល និងសំណើសុំផ្សេងៗបម្រើឱ្យប្រយោជន៍សាធារណៈ រួមមានសាលារៀន និងស្តារហេដ្ឋារចនាសម្ពន្ធបុរាណ សរុបចំនួន ១៩ករណី។

ចំពោះការចុះដល់ទីតាំងស្នើសុំផ្ទាល់ ដើម្បីពិនិត្យមើលលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់ទីតាំងស្នើសុំរបស់ប្រជាពលរដ្ឋម្ចាស់សំណើ មន្ត្រី-បុគ្គលិកជំនាញចុះពិនិត្យបានចំនួន២១ករណី ហើយបានអនុញ្ញាតនៅក្រុងសៀមរាបចំនួន៥ករណី ស្រុកបន្ទាយស្រីចំនួន៧ករណី ស្រុកអង្គរធំចំនួន៣ករណី ស្រុកប្រាសាទបាគងចំនួន៦ករណី ។

ទាក់ទងនឹងការអនុញ្ញាតឱ្យធ្វើលំនៅដ្ឋាននិងជួសជុលតិចតួចនេះដែរ ចំពោះប្រជាពលរដ្ឋណាដែលមានលក្ខខណ្ឌគ្រប់គ្រាន់លើការអនុញ្ញាត គឺក្រុមការងារផ្នែកស្ថាបត្យកម្មក៏បានជួយរៀបចំគំនូសប្លង់លំនៅដ្ឋានបែបខ្មែរជូនចំនួន១១ករណីផ្សេងទៀត ដូចជា៖ នៅក្រុងសៀមរាបចំនួន១ករណី នៅស្រុកបន្ទាយស្រីចំនួន៣ករណី នៅស្រុកពួកចំនួន១ករណី នៅស្រុកប្រាសាទបាគងចំនួន៥ករណី និងនៅស្រុកអង្គរធំចំនួន១ករណីដែរ៕





ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែសីហា

អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យសកម្មភាពគម្រោងផ្សេងៗ ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែ សីហា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំមន្ត្រី បុគ្គលិកជំនាញពាក់ព័ន្ធចុះពិនិត្យការអនុវត្តការងារនៅតាមការដ្ឋាន ដូចជា គម្រោងកំណាយបុរាណវិទ្យាប្រាសាទបាយក្អែក ការចុះពិនិត្យមើលបរិស្ថានជុំវិញត្រពាំងសេស និងអតីតរោងចិញ្ចឹមដំរីខាងកើតភ្នំបាខែង។



ការចុះពិនិត្យផ្ទាល់នេះ គឺជាយន្តការមួយដើម្បីជំរុញនិងបង្កើនប្រសិទ្ធភាពការងារឱ្យមានភាពរលូននិងមានប្រសិទ្ធភាពខ្ពស់។ ជាពិសេសធ្វើការផ្លាស់ប្តូរយោបល់ ការណែនាំ និងការសម្រេចចិត្តក្នុងការអនុវត្តកិច្ចការក្នុងជំហានបន្តបន្ទាប់ទៀតឱ្យកាន់តែប្រសើរ៕

ឯកឧត្តម យិត ចាន់ដារដ្ឋ៖ ព្រៃឈើជាសម្បត្តិរួមដ៏មានសារៈសំខាន់បំផុតរបស់មនុស្ស បរិស្ថាន និងបុរាណដ្ឋាន

ផ្សាយនៅថ្ងៃទី០៤ ខែ សីហា ឆ្នាំ២០២០

ការដាំដើមឈើក្នុងរមណីយដ្ឋានអង្គ រ ជាការរួមចំណែកដ៏សំខាន់ក្នុងការបង្កើតគម្របបៃតងដល់បរិស្ថាន បង្កើតទេសភាពវប្បធម៌ ទាក់ទាញទេសចរ ជាជម្រកសត្វព្រៃ ពិសេសគឺការពារប្រាង្គប្រាសាទពីបម្រែបម្រួលនៃសីតុណ្ហភាព និងបរិយាកាស។

ជាក់ស្តែងនៅព្រឹកថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា មន្ត្រីសង្ឃខេត្តសៀមរាប ឯកឧត្តម លោកជំទាវ និងពុទ្ធបរិស័ទ ក្រោមការផ្តួចផ្តើមពីព្រះចៅអធិការវត្តអង្គរខាងជើង ព្រះចរណៃសោភ័ណ បណ្ឌិត គង់ សុភាព បិតប្បញ្ញោ ព្រះរាជាគណៈថ្នាក់កិត្តិយស បានប្រារព្ធពិធីដាំកូនឈើប្រណីតនិងឈើលម្អចំនួន៥០០ដើមក្នុងបរិវេណវត្ត។

ព្រះចរណៃសោភ័ណបណ្ឌិត គង់ សុភាព មានសង្ឃដីកាពីគោលបំណងនៃការដាំដើមឈើគឺដើម្បីលើកស្ទួយសោភ័ណភាពបៃតងក្នុងតំបន់អង្គរជាមួយអាជ្ញាធរជាតិអប្សរា បណ្តុះទឹកចិត្តស្រឡាញ់បរិស្ថានដល់កូនខ្មែរគ្រប់រូប និងរួមចំណែកកាត់បន្ថយបម្រែបម្រួលអាកាសធាតុជាមួយពិភពលោក ព្រោះដើមឈើនៃជាប្រភពនៃជីវិត ផ្តល់ខ្យល់បរិសុទ្ធ និងសារៈប្រយោជន៍ជាច្រើនក្នុងការរស់នៅរបស់មនុស្សសត្វ។ មិនតែប៉ុណ្ណោះ ដើមឈើគឺជាកន្លែងដែលព្រះពុទ្ធចាប់កំណើត ត្រាស់ដឹង និងបរិនិព្វានផង ហើយការដាំដើមឈើនេះ ក៏បានផលអានិសង្សបុណ្យច្រើនណាស់។

មានប្រសាសន៍នាឱកាសនោះ **ឯកឧត្តម យិត ចាន់ដារដ្ឋ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានលើកឡើងថា ក្រៅពីកិច្ចការអភិរក្ស ជួសជុលប្រាង្គប្រាសាទ អាជ្ញាធរជាតិអប្សរាបានយកចិត្តទុកដាក់ខ្ពស់លើបរិស្ថានធម្មជាតិដែលផ្តល់ប្រយោជន៍ចំពោះប្រាសាទផងនិងមនុស្សផង។ នេះជាសកម្មភាពដ៏ប្រពៃថ្លៃថ្លាដែលព្រះសង្ឃនៃវត្តអង្គរខាងជើង និងពុទ្ធបរិស័ទបានចូលរួមដាំដើមឈើប្រណីតៗ៥០០ដើមនៅក្នុងវត្ត ដើម្បីលើកតម្លៃបរិស្ថាននៅប្រាសាទអង្គរវត្ត។

ជាងនេះទៅទៀត ឯកឧត្តមក៏បានសំណូមពរដល់ជនមួយចំនួនដែលមិនពេញចិត្តនឹងសកម្មភាពរបស់អាជ្ញាធរជាតិអប្សរាថា «ទោះខឹងឬស្អប់ កុំបំផ្លាញដើមឈើដែលអាជ្ញាធរជាតិអប្សរាដាំ ព្រោះព្រៃឈើជាសម្បត្តិរួមដ៏មានសារៈសំខាន់បំផុតរបស់មនុស្ស បរិស្ថាន និងបុរាណដ្ឋាន»។ ឯកឧត្តមកោតសរសើរនិងលើកទឹកចិត្តដល់ព្រះសង្ឃ ប្រជាពលរដ្ឋ ស្ថាប័នរដ្ឋ វិស័យឯកជនបន្តចូលរួមដាំដើមឈើឱ្យបានច្រើន ហើយសម្អាតបរិស្ថានឱ្យបានល្អក្រោយដាំរួច ពិសេសចូលរួមថែរក្សាដើមឈើ ដែលដាំហើយឱ្យបានគ្រប់ៗគ្នា។

អាជ្ញាធរជាតិអប្សរា មានស្ថានីយបណ្តុះកូនឈើចំនួន៥កន្លែងក្នុងរមណីយដ្ឋានអង្គរ មានពូជឈើប្រណីត ឈើលម្អជាច្រើនប្រភេទសម្រាប់ដាំក្នុងរមណីយដ្ឋានអង្គរ និងចែកជូនសាធារណជន ហើសម្រាប់គោលដៅឆ្នាំ២០២០នេះ អាជ្ញាធរជាតិអប្សរានិងដាំដើមឈើ រួមទាំងចែកកូនឈើទៅសហគមន៍ចំនួន១០ម៉ឺនដើម៕

រយៈពេល២ថ្ងៃដើមខែសីហា អាជ្ញាធរជាតិអប្សរាចែកជូនកូនឈើជិត២ពាន់ដើម ដល់សាធារណជន

ផ្សាយនៅថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០២០

ប្រជាពលរដ្ឋជិតឆ្ងាយ បានបន្តស្នើសុំកូនឈើពីអាជ្ញាធរជាតិអប្សរា ដើម្បីយកទៅដាំនៅតាមតំបន់នានា ទាំងក្នុងខេត្តសៀមរាប និងខេត្តដទៃ។ នៅដើមខែ សីហា ឆ្នាំ២០២០នេះ គឺថ្ងៃទី១ និងថ្ងៃទី៣ ខែសីហា អាជ្ញាធរជាតិអប្សរា បានផ្តល់ជូនកូនឈើសរុបជិត២ពាន់ដើម ដល់ព្រះសង្ឃ និងប្រជាពលរដ្ឋយកទៅដាំតាមគោលដៅផ្សេងៗ។

នៅថ្ងៃទី១ ខែសីហា អាជ្ញាធរជាតិអប្សរា បានផ្តល់ជូនកូនឈើចំនួន៣០០ដើម ដល់លោក យ៉ាន់ ពន្លក អនុប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្តសៀមរាប ដើម្បីយកទៅដាំនៅវត្តមុនធ្យាន និងចែកជូនប្រជាពលរដ្ឋ រស់នៅក្នុងភូមិគោកឬស្សីខាងជើង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ក្នុងថ្ងៃដដែលនោះ ក៏បានផ្តល់ជូនកូនឈើ ១២២ដើម ដល់លោកស្រី អ៊ីសា រ៉ហានី ជាបុគ្គលិកនាយកដ្ឋានផ្សព្វផ្សាយនៃអាជ្ញាធរជាតិអប្សរា ដើម្បីយកទៅដាំក្នុងបរិវេណវិហារឥស្លាមស្ថិតនៅភូមិតាគង់ សង្កាត់សំបួរ ក្រុងសៀមរាប។

ដោយឡែកនៅថ្ងៃទី៣ ខែសីហា បានប្រគេនកូនឈើចំនួន៦០០ដើម ជូនព្រះតេជគុណ ឃី វឿត ព្រះចៅអធិការវត្តគីរីគង្គា ហៅវត្តដំណាក់ស្តេចដើម្បីយកទៅដាំនៅក្នុងបរិវេណវត្តស្ថិតនៅភូមិគោកដូងចាស់ ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប។ និងបានផ្តល់កូនឈើជូនអាជ្ញាធរជាតិព្រះ

វិហារចំនួន ៦៥០ដើម ដើម្បីដាំលម្អអមតាមដងផ្លូវក្នុងរមណីយដ្ឋានប្រាសាទព្រះវិហារ និងប្រាសាទកោះកេរ។ សរុប កូនឈើដែលផ្តល់ជូនរយៈពេល២ថ្ងៃ មានចំនួន ១,៦៧២ដើម ដែលរួមមានកូនឈើ គ្រញូង ធ្នង់ បេងកកោះ គគីរ រំដួល ឥន្ទនេល ក្រោក លឿងរាជ ត្របែកព្រៃ និងអង្គារបុស្ស៕

លិខិតអបអរសាទរក្នុងឱកាសខួបកំណើតគម្រប់៦៨ឆ្នាំឈានចូល៦៩ឆ្នាំ ជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ផ្សាយនៅថ្ងៃទី០៥ ខែ សីហា ឆ្នាំ២០២០

ក្នុងឱកាសដ៏សែនមហានក្ខត្តឫក្សថ្លៃថ្លានៃខួបកំណើតគម្រប់ ៦៨ឆ្នាំ ឈានចូល៦៩ឆ្នាំ នាថ្ងៃទី ០៥ ខែសីហា ឆ្នាំ២០២០ នេះ តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអាជ្ញាធរជាតិអប្សរា និងក្នុងនាមខ្ញុំផ្ទាល់ខ្ញុំបាទសូមសម្តែង នូវមនោសញ្ចេតនារីករាយឥតឧបមា និងសេចក្តីគោរព ស្រលាញ់ដ៏ជ្រាលជ្រៅបំផុត ព្រមទាំងសូមគោរពជូនពរ បវរមហាប្រសើរជូន សម្តេចតេជោនាយករដ្ឋមន្ត្រី ជាទីគោរព ដ៏ខ្ពង់ខ្ពស់ សូមមានជន្មាយុយឺនយូរមានសុខុមាលភាពល្អ បរិបូរណ៍ បញ្ញាញាណភ្លឺថ្លា ដើម្បីដឹកនាំរាជរដ្ឋាភិបាល និង ប្រទេសជាតិទទួលជោគជ័យដ៏ត្រចះត្រចង់ថ្មីៗថែមទៀត ជាពិសេសវឌ្ឍនភាព និងកិត្យានុភាពល្បីរន្ទឺលើឆាកអន្តរជាតិ។

កូនឈើចំនួន១,៤០០ដើមទៀត ត្រូវបានអាជ្ញាធរជាតិអប្សរាផ្តល់ជូនដល់ស្ថាប័នក្នុងខេត្តសៀមរាប និងខេត្តបន្ទាយមានជ័យ

ផ្សាយនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២០

តំណាងស្ថាប័នវត្តអារាមក៏ដូចជាប្រជាពលរដ្ឋជាបន្តបន្ទាប់ បានស្នើសុំកូនឈើពីអាជ្ញាធរជាតិអប្សរា ដើម្បីយកទៅដាំនៅតាមដីភូមិ ចម្ការ វត្តអារាម និងសាលារៀន។ល។ ក្នុងថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា បានផ្តល់កូនឈើដល់តំណាងវត្តអារាម និងស្ថាប័នសរុបចំនួន ១,៤០០ដើម។

កូនឈើចម្រុះចំនួន១,៤០០ដើម បានផ្តល់ជូនដល់ប្រជាពលរដ្ឋដែលជាតំណាងវត្តអារាម និងស្ថាប័ន ដែលបានដាក់ពាក្យស្នើសុំមកកាន់អាជ្ញាធរជាតិអប្សរា។

ការផ្តល់ជូននោះរួមមាន ជូនលោកស្រី មៀន សារិទ្ធ តំណាងវត្តឧទុម្ពរ ហៅវត្តល្វា ស្ថិតនៅភូមិល្វា ឃុំល្វា ស្រុកពួក ចំនួន ៨០០ដើម។ ជូនលោក តុប ច័ន្ទសុប្ញទ្ធី តំណាងវត្តអន្លង់ថ្វាន់ ភូមិបង់បត់ ឃុំបត់ត្រង់ ស្រុកមណ្ឌលបុរី ខេត្តបន្ទាយមានជ័យចំនួន១០០ដើម។ជូនតំណាងទីបញ្ជាការយោធភូមិភាគទី៤ ចំនួន ៥០០ដើម យកទៅដាំនៅទីធ្លាសាលាពលទាហានទី៤ ស្ថិតនៅភូមិតាកុះ ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប។ ដើមឈើដែលបានផ្តល់ជូននៅពេលនោះ រួមមាន កូនឈើគ្រញូង បេង ធ្នង់ រំដួល ឈើទាល លឿងរាជ និងស្តៅ៕

ប្រាសាទបាយក្អែកនឹងរៀបចំឱ្យក្លាយជាសារមន្ទីរលម្ហ

ផ្សាយនៅថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២០

ប្រាសាទបាយក្អែក មានទីតាំងនៅខាងលិចប្រាសាទអង្គរវត្តដែលមិនសូវមានអ្នកស្គាល់ហើយទេសចរភាគច្រើនឆ្លងកាត់ទៅហួសមកហួស។

បច្ចុប្បន្ន ប្រាសាទនេះមានស្ថានភាពបាក់បែកទ្រុឌទ្រោមនៅសល់តែគ្រឹះ ហើយមានរចនាសម្ពន្ធប្រាសាទ សម្ភារស្លាកស្នាមនៅសល់ ជើងទម្រ ព្រះសីសៈព្រះពោធិសត្វប្រាជ្ញបារមីតារចនាបថបាយ័ន និងសសរពេជ្រ ដែលតាមអ្នកជំនាញសន្និដ្ឋានថា ប្រាសាទនេះសាងសង់ឡើងក្នុង ស.វ.ទី១២ តាមរចនាបថបាយ័ន្ត។ នៅជុំវិញប្រាសាទជាទីសក្ការៈនេះ សម្បូរទៅដោយទួលជាច្រើនដែលមនុស្សរស់នៅ ហើយប្រហែលជាអាចមានមនុស្សរស់នៅមុនមានប្រាសាទក៏ថាបាន។
ក្នុងឱកាសចុះពិនិត្យការដ្ឋានកំណាយប្រាសាទបាយក្អែក នៅថ្ងៃទី០៣ ខែសីហា កន្លងមកនេះ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានសម្រេចជាមួយអ្នកជំនាញពាក់ព័ន្ធ រួមគ្នាលើកតម្លៃប្រាសាទបាយក្អែកឱ្យក្លាយជាសារមន្ទីរលម្ហដើម្បីទាក់ទាញទេសចរ និងអភិរក្សសំណង់ប្រាសាទឱ្យផុតពីហានីភ័យ។

ក្រុមការងារនឹងដាំដើមឈើ ដាំស្មៅ ស្តារស្រះ តាំងបង្ហាញប្រវត្តិប្រាសាទ និងលទ្ធផលបានពីកំណាយ រៀបចំទីតាំងនេះសម្រាប់ទាក់ទាញភ្ញៀវទេសចរមកទស្សនា សម្រាកកាយ និងការរៀបចំពិធីផ្សេងៗផង៕

ត្រឹម២ថ្ងៃ អាជ្ញាធរជាតិអប្សរាចែកកូនឈើជាង៤ពាន់ដើមទៀតដល់សាធារណជន

ផ្សាយនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា បានបន្តចែកជូនកូនឈើដល់សាធារណជនជិតឆ្ងាយ ដើម្បីយកទៅដាំក្នុងបំណងបង្កើនគម្របព្រៃឈើឡើងវិញនៅក្នុងប្រទេសកម្ពុជា។ នៅថ្ងៃទី៧ និងទី៨ ខែសីហា ឆ្នាំ២០២០ កូនឈើចំនួន ៤,៦២០ដើមទៀត បានចែកជូនដល់សាធារណជនក្នុងខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ និងខេត្តតាកែវ។

នៅថ្ងៃទី៧ ខែសីហា បានចែកកូនឈើចំនួន៣,០០០ដើម ដល់លោក ឃួង ប៊ុនទាន ស្ថិតនៅភូមិរំដួល ឃុំភ្នំលាភ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ។ បានចែកកូនឈើជូនប្រជាពលរដ្ឋឈ្មោះ ម៉ៅ ហាត់ ចំនួន២៧០ដើម ស្ថិតនៅភូមិពាក់ស្នែងថ្មី ឃុំពាក់ស្នែង ស្រុកអង្គរធំ ខេត្តសៀមរាប។ បានចែកកូនឈើជូនប្អូនស្រីឈ្មោះ ប៉ៃលិន លក្ខិណា តំណាងក្រុមយុវជនស្ម័គ្រចិត្តខេត្តសៀមរាប ចំនួន២០ដើម ស្ថិតក្នុងភូមិអារក្សស្វាយ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប។ ចែកកូនឈើដល់ ព្រះសង្ឃរួមជាមួយពុទ្ធបរិស័ទ ចំនួន៦០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តគិរីគង្គា ហៅវត្តដំណាក់ស្តេច ស្ថិតនៅភូមិគោកដូងចាស់ ឃុំគោកដូង ស្រុកអង្គរជុំ ខេត្តសៀមរាប។

នៅថ្ងៃទី៨ ខែសីហា បានផ្តល់កូនឈើជូនលោក ព្រហ្ម សំអ៊ាន ចំនួន៤០០ដើម ស្ថិតនៅភូមិគ្រញូង ឃុំតាសៀម ស្រុកស្វាយលើ ខេត្តសៀមរាប។ ផ្តល់កូនឈើជូនតំណាងសាលាបឋមសិក្សា១មករា ចំនួន៣០០ដើម ស្ថិតក្នុងភូមិគោកឫស្សីខាងត្បូង ឃុំដានរុន ស្រុកសូទ្រនិគម ខេត្តសៀមរាប។ ផ្តល់កូនឈើជូនលោក អ៊ុក ពៅ មន្ត្រីកងរាជអាវុធហត្ថខេត្តតាកែវ ចំនួន៣០ដើម ស្ថិតក្នុងភូមិរកាក្នុង សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។

កូនឈើដែលបានចែកនៅពេលនោះរួមមាន កូនឈើគ្រញូង បេង ធ្នង់ កកោះ គគីរ ច្រេស លៀងរាជ ត្របែកព្រៃ ឥន្ទនេល អង្គារបុស្ស គុយ និងរំដួល៕

អាជ្ញាធរជាតិអប្សរានឹងបន្តចែកកូនឈើដល់សាធារណជនទូទៅឲ្យបាន១១ម៉ឺនដើម

ផ្សាយនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

ក្នុងគោលបំណងស្តារគម្របព្រៃឈើ ក្នុងតំបន់ការពាររមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរឲ្យកាន់តែច្រើនឡើង និងបំផុសស្មារតីឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋអំពីកិច្ចការបរិស្ថាន។ ក្នុងន័យនេះ ចាប់ពីខែមិថុនាមកដល់បច្ចុប្បន្ន គឺមានរយៈពេលជាង២ខែមកហើយដែលអាជ្ញាធរជាតិអប្សរា បានចែកកូនឈើជាង៧ម៉ឺនដើមដល់អង្គ

ភាពរដ្ឋ អង្គការ សហគមន៍ សាលារៀន វត្តអារាម វិស័យឯកជន និងសាធារណជនទូទៅដែលបានដាក់ពាក្យស្នើសុំយកទៅដាំនៅតាមតំបន់ផ្សេងៗ ទាំងក្នុងខេត្តសៀមរាប និងខេត្តមួយចំនួនក្នុងប្រទេសកម្ពុជា។ កូនឈើទាំង៧ម៉ឺនដែលបានចែកជូនសាធារណជននោះ មានដូចជា កូនឈើគ្រញូង ធ្នង់ បេង ច្រេស ឈើទាល គគីរ កកោះ ពពេល អង្គាញ់ រំដួល លឿងរាជ គុយ សិរមាន់ ផ្ចៀរ អង្គារដី ផ្កាក្ងោកតូច ផ្កាក្ងោកធំ ផ្កាឥន្ទនេល ផ្កាអង្គាបុស្ស។

ជាមួយគ្នានេះ អាជ្ញាធរជាតិអប្សរាក៏សូមអំពាវនាវដល់ស្ថាប័នរដ្ឋ អង្គការ សហគមន៍ សាលារៀន វត្តអារ៉ាម និងសាធារណជនទូទៅធ្វើការទំនាក់ទំនងមកអាជ្ញាធរជាតិអប្សរាឲ្យបានមុនពាក់កណ្តាលខែកញ្ញា ដើម្បីទទួលយកកូនឈើទៅដាំតាមទីតាំងចាំបាច់របស់ខ្លួនដោយដាក់ពាក្យស្នើសុំកូនឈើនៅមជ្ឈមណ្ឌលសេវាកម្មអាជ្ញាធរជាតិអប្សរា៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំប្រជុំពិភាក្សាតាមដានការអនុវត្តការងារភ្នាក់ងារទេសចរណ៍

ផ្សាយនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំកិច្ចប្រជុំជាមួយភ្នាក់ងារទេសចរណ៍នៃនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ ដើម្បីពិនិត្យមើលការវិវត្តនៃការងារទូទៅ ក៏ដូចជាស្វែងយល់ពីផលលំបាកនិងបញ្ហាប្រឈមនានាដែលក្រុមការងារភ្នាក់ងារទេសចរណ៍តែងជួបប្រទះជាប្រចាំ។

ឆ្លៀតក្នុងឱកាសនៃកិច្ចប្រជុំនេះ ឯកឧត្តមអគ្គនាយកបានផ្តល់អនុសាសន៍មួយចំនួនសំដៅលើកកម្ពស់ប្រសិទ្ធិភាពការងារ ជាពិសេសជំរុញលើកទឹកចិត្តភ្នាក់ងារទាំងអស់ឱ្យសកម្មនឹងការងារ យកចិត្តទុកដាក់អនុវត្តភារកិច្ចនិងតួនាទីឱ្យបានត្រឹមត្រូវ៕

អាជ្ញាធរជាតិអប្សរារៀបចំសិក្ខាសាលាស្តីអំពី «ប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ សម្រាប់ឆ្នាំ២០២០»

ផ្សាយនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ នៅស្នាក់ការអាជ្ញាធរជាតិអប្សរា បានរៀបចំសិក្ខាសាលាផ្ទៃក្នុងស្តីពី «ប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ»។ សិក្ខាសាលានេះមានគោលបំណងផ្សព្វផ្សាយសៀវភៅប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ស្វែងយល់ និងចូលរួមការពារបរិស្ថានក្នុងតំបន់អង្គរ។

នៅក្នុងកម្មវិធីនេះ អញ្ជើញចូលរួមពីអ្នកតំណាងគ្រប់គ្រងបរិស្ថានអង្គរ ប្រធាន អនុប្រធាននាយកដ្ឋាន មន្រ្តី-បុគ្គលិក នាយកក្រុមហ៊ុនHCC-អង្គរ កម្មករសម្អាតភ្នាក់ងារសណ្តាប់ធ្នាប់ ប្រមាណ១០០នាក់។

មានមតិសំណេះសំណាល និងបើកសិក្ខាសាលាខាងលើ **ឯកឧត្តម សុខ លក្ខិណា** អ្នកតំណាងគ្រប់គ្រងបរិស្ថានអង្គរ បានលើកឡើងថា សិក្ខាសាលាថ្ងៃនេះ ជាការរឭកឡើងវិញ និងឆ្លុះបញ្ចាំងតថភាពខ្លះដែលបានឆ្លងកាត់ការអនុវត្តកន្លងមក។ ការអនុវត្តការងារគ្រប់គ្រងបរិស្ថានគឺជាការគ្រប់គ្រងការងារទាំងស្រុង ហើយការងារនេះមានជាប្រព័ន្ធ។ បើទោះបីឆ្នាំ២០២០ នេះ ពិភពលោកទទួលផលប៉ះពាល់គ្រប់វិស័យយ៉ាងធ្ងន់ធ្ងរពីជំងឺកូវីដ១៩រាតត្បាត រួមទាំងប្រទេសកម្ពុជា ពិសេសតំបន់រមណីយដ្ឋានអង្គរ ក៏អាជ្ញាធរជាតិអប្សរាឆ្លៀតយកផលលំបាកនេះប្រែជាសក្តានុភាពដើម្បីពង្រឹងការថែទាំ កែលម្អឱ្យកាន់តែល្អប្រសើរឡើង។ ជាក់ស្តែងការរៀបចំរចនាសម្ព័ន្ធ សួនច្បារ ប្រព័ន្ធស្រោចស្រពស្មៅនៅបរិវេណប្រាសាទអង្គរវត្ត។

ឯកឧត្តមសង្កត់ធ្ងន់ថា ការថែរក្សាបេតិកភណ្ឌ និងថែរក្សាបរិស្ថាននៅតំបន់ឧទ្យានអង្គរទាំងមូលសំខាន់ណាស់ដែលអាជ្ញាធរជាតិអប្សរា ភាគីពាក់ព័ន្ធទាំងអស់បានខិតខំកន្លងមកឱ្យរីកចម្រើនគ្រប់វិស័យ ក្នុងការទាក់ទាញភ្ញៀវទេសចរឱ្យកើនឡើងជាលំដាប់។
ដើម្បីរក្សាឱ្យបានរមណីយដ្ឋានធម្មជាតិ រក្សាធម្មជាតិកាន់តែប្រសើរឡើង ឯកឧត្តមរំឭកថា អាជ្ញាធរជាតិអប្សរាបានរៀបចំប្រព័ន្ធគ្រប់គ្រងបរិស្ថានមួយប្រកបដោយប្រសិទ្ធិភាព និងនិរន្តភាពដែលអនុលោមតាមស្តង់ដារ ISO 14001 ដែលមានការចូលរួមតាមដានរបស់ស្ថាប័នធានាគុណភាពជប៉ុន Japan Quality Assurance (JQA)។

ឯឧត្តមបន្ថែមថា មកដល់ពេលនេះ ក្រុមការងារបានអនុវត្តតាមស្តង់ដារ តាំងពី ISO14001 ឆ្នាំ២០០៤ដល់ឆ្នាំ២០១៨ អនុវត្តស្តង់ដារថ្មី គឺ ISO 14001:2015 ដែលមានការកែប្រែខ្លះ។ នៅខែកុម្ភៈ ឆ្នាំ២០២១នេះ ជាឆ្នាំចុងក្រោយដែលនឹងអស់សុពលភាពវិញ្ញាបនបត្រ ស្របពេលដែលសវនករតំណាងស្ថាប័ន JQAចុះមកពិនិត្យតាមដានដើម្បីបញ្ជាក់នូវភាពអនុលោមជាប្រចាំថ្ងៃនៃប្រព័ន្ធគ្រប់គ្រងបរិស្ថាននៅក្នុងរយៈពេលនៃសុពលភាព៣ឆ្នាំ នៃស្តង់ដា ISO14001:2015។

ក្រៅពីនោះ សិក្ខាសិលាបានធ្វើបទបង្ហាញស្តីពីការគ្រប់គ្រងបរិស្ថានក្នុងតំបន់អង្គរ សៀវភៅប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ការចូលរួមសម្អាតរមណីយដ្ឋានអង្គរ សំណួរ-ចម្លើយ មតិ និងសំណូមពរសម្រាប់សិក្ខាកាមលើកឡើងដល់វាគ្មិន៕

អាជ្ញាធរជាតិអប្សរាជួសជុលនិងស្តារប្រព័ន្ធបង្ហូរទឹកចាស់នៅលើស្ពានហាលខាងលិចប្រាសាទអង្គរវត្តឱ្យដំណើរការឡើងវិញ

ផ្សាយនៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០

ក្នុងគោលបំណងសង្គ្រោះរចនាសម្ពន្ធស្ពានហាលខាងលិចប្រាសាទអង្គរវត្តកុំឱ្យថ្មងាយខូចពុកផុយដោយសារបញ្ហាទឹកដក់ ទឹកហូរច្រោះនារដូវវស្សា នាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា បានជួសជុលនិងស្តារប្រព័ន្ធបង្ហូរទឹកចាស់នៅលើស្ពានហាលឱ្យដំណើការឡើងវិញ។ ប្រព័ន្ធបង្ហូរទឹកនេះត្រូវបានបារាំងរៀបចំឡើងនៅពេលជួសជុលស្ពានហាលកាលពីពេលកន្លងមក ប៉ុន្តែពុំបានបន្សល់ទុកនូវប្លង់បច្ចេកទេសលម្អិតទេ។

ដើម្បីអនុវត្តការងារស្តារប្រព័ន្ធឱ្យបានជោគជ័យ ក្រុមអ្នកបច្ចេកទេសនៃនាយកដ្ឋានគ្រប់គ្រងទឹក បានប្រើប្រាស់ឧបករណ៍ទំនើបបែបវិទ្យាសាស្ត្រ Drain and Pipe Inspection Camera ដែលជាប្រភេទម៉ាស៊ីនកាមេរ៉ាខ្សែសម្រាប់ថតពិនិត្យបញ្ហាដែលកកស្ទះក្នុងប្រព័ន្ធបង្ហូរទឹកដោយមិនចាំបាច់ប្រើប្រាស់កម្លាំងមនុស្សជាអ្នកលើកដាក់ថ្មឡើយ។

បន្ទាប់ពីកំណត់បាននូវបញ្ហាដែលកើតមានខាងក្នុងហើយ ក្រុមអ្នកបច្ចេកទេសបានប្រើម៉ាស៊ីន Drain Cleaning Machin S-200 ដើម្បីខួងលាងសម្អាតរន្ធកកស្ទះទាំងនោះចេញ ដែលបំពង់ខួងអាចបត់បែនបានតាមសណ្ឋាននៃប្រព័ន្ធបង្ហូរទឹកចាស់ ហើយនៅពេលនេះប្រព័ន្ធដោះទឹកនៅលើផ្លូវដើរស្ពានហាលមុខប្រាសាទអង្គរវត្តខាងលិចមានដំណើរការឡើងវិញហើយដោយពុំមានដក់ទឹកទៀតទេ។

ក្រុមអ្នកបច្ចេកទេសអះអាងថា បញ្ហាសំខាន់ដែលធ្វើឱ្យកើតមានការកកស្ទះគឺដោយសារមានកម្ទេចកម្ទី សំរាមប្លាស្ទិចនិងដីបិទជិត។ ដូច្នេះដើម្បីឱ្យប្រព័ន្ធរំដោះទឹកអាចដំណើរការឡើងវិញ ក្រុមអ្នកបច្ចេកទេសបានសម្អាតរន្ធបង្ហូរទឹកសរុបទាំងអស់ចំនួន៧កន្លែង៕

កូនឈើចំនួន ៣,៤០០ដើមបន្ថែមទៀត បានចែកជូនសាធារណជន

ផ្សាយនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាបានបន្តចែកជូនកូនឈើដល់សាធារណជន ហើយរយៈពេល៣ថ្ងៃគឺពីថ្ងៃទី១០ ដល់ទី១២ ខែសីហា ឆ្នាំ២០២០ កូនឈើចំនួន៣,៤០០ដើមទៀត ត្រូវបានចែកចាយ។

យោងតាមរបាយការណ៍ពីនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា កូនឈើទាំងនោះបានចែកចាយដល់សាធារណជន ដែលរួមមានជូនលោក តិត ទូរ ជំនួយការរដ្ឋបាលឃុំអំពិល ចំនួន ៩០០ដើម ដើម្បីយកទៅដាំនៅតាមដងផ្លូវសាលារៀន វត្តអារាមនានាក្នុងឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប។ ផ្ដល់កូនឈើជូនតំណាងវត្តស្លាតមានជ័យ ហៅវត្តកណ្ដាលពោធិព្រឹក ចំនួន២,៤០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តចំនួន២ និងដាំបន្ថែមក្នុងព្រៃសហគមន៍តាត្រាវ ស្ថិតក្នុងភូមិកណ្ដាល ភូមិតាត្រាវ ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប។ ផ្ដល់កូនឈើជូនលោកលឹមប៊ុនហាននាយកសាលាបឋមសិក្សាសុខសាន្ត ចំនួន១០០ដើម ដើម្បីយកទៅដាំក្នុងទីធ្លាសាលារៀន ស្ថិតក្នុងភូមិសុខសាន្ត ឃុំយាង ស្រុកពួក ខេត្តសៀមរាប។

កូនឈើដែលបានផ្ដល់ជូននៅពេលនោះ រួមមានប្រភេទកូនឈើ គ្រញូង បេង ធ្នង់ កកោះ រំដួល សិរមាន់ ត្របែកព្រៃ លឿងរាជ ឥន្ទនេល។ល។

ភ្ញៀវទេសចរជាច្រើន ទស្សនាប្រាសាទអង្គរវត្តអំឡុងថ្ងៃឈប់សម្រាក

ផ្សាយនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០

ថ្ងៃទី១៧ ខែសីហា ដែលជាថ្ងៃទី១នៃព្រឹត្តិការណ៍សម្រាកសៀមរាប ដែលរៀបចំឡើងដោយរដ្ឋបាលខេត្តសៀមរាប សហការជាមួយអាជ្ញាធរជាតិអប្សរានិងសហភាពសហព័ន្ធយុវជនកម្ពុជាខេត្តសៀមរាបមានទេសចរជាតិជាច្រើនបានចូលមកទស្សនាប្រាសាទអង្គរវត្ត។ វត្តមានដ៏ច្រើននេះ ជាលើកដំបូងក្រោយភាពស្ងប់ស្ងាត់មួយរយៈដោយសារជំងឺកូវីដ១៩។

សូមអញ្ជើញទស្សនាទិដ្ឋភាពទេសចរដើរទស្សនាប្រាសាទអង្គរវត្តនៅព្រឹកថ្ងៃទី១៧ខែសីហាឆ្នាំ២០២០នេះដូចតទៅ៖

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមពិធីបួងសួង សុំសេចក្ដីសុខរៀបចំព្រឹត្តិការណ៍ សម្រោកសៀមរាប

ផ្សាយនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០២០នេះ **ឯកឧត្តម តឹម សុផិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា បានចូលរួមក្នុងពិធីបួងសួងសុំសេចក្ដីសុខបើកព្រឹត្តិការណ៍សម្រោកសៀមរាប ក្រោមអធិបតីភាព **សម្ដេចពិជ័យសេនា ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ។ មានវត្តមានក្នុងពិធីនោះ រួមមាន **ឯកឧត្តម អ៊ឹង ហឿន** ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប **ឯកឧត្តម ទៀ សីហា** អភិបាលនៃគណៈអភិបាលខេត្តសៀមរាប **ឯកឧត្តម ហ៊ុន ម៉ានី** ប្រធានសហភាពសហព័ន្ធយុវជនកម្ពុជា ព្រមទាំងថ្នាក់ដឹកនាំខេត្ត មន្ត្រីរាជការសរុបប្រមាណជាង១០០នាក់។ កម្មវិធីបួងសួងសុំសេចក្ដីសុខបើកព្រឹត្តិការណ៍សម្រោកសៀមរាប ធ្វើឡើងនៅក្លោងទ្វារបែនប្រាសាទអង្គរវត្ត៕

ប្រជាពលរដ្ឋបន្តដើរកម្សាន្តក្នុងរមណីយដ្ឋានអង្គរនាថ្ងៃឈប់សម្រាក

ផ្សាយនៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០

នៅថ្ងៃទី២០ខែសីហាដែលជាថ្ងៃទី៤នៃថ្ងៃឈប់សម្រាកនេះ ប្រជាពលរដ្ឋជិតឆ្ងាយ បានបន្តបង្ហាញវត្តមាននៅតាមប្រាសាទនានាក្នុងតំបន់រមណីយដ្ឋានអង្គរ។ ប្រាសាទអង្គរវត្ត ជាគោលដៅសំខាន់សម្រាប់ការកម្សាន្តនាថ្ងៃឈប់សម្រាក ជំនួសថ្ងៃបុណ្យចូលឆ្នាំនេះ។

ក្រៅពីនេះ ភ្ញៀវទេសចរជាតិបានដើរកម្សាន្តនៅតាមប្រាសាទមួយចំនួនរួមមាន ប្រាសាទបាយ័ន ប្រាសាទនាគព័ន្ធ ប្រាសាទតាព្រហ្ម ប្រាសាទបន្ទាយស្រី និងនៅភ្នំគូលែន ជាដើម។ល។

អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើជិត៤ពាន់ដើមបន្ថែមទៀតដល់សាធារណជន

ផ្សាយនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២០

ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា បានបន្តចែកកូនឈើចម្រុះដល់ព្រះសង្ឃ និងសាធារណជនបន្ថែម ដែលសរុបទាំងអស់មានចំនួនជិត ៤ពាន់ដើម។ កូនឈើដែលបានចែកនៅពេលនោះ រួមមាន កូនឈើគ្រញូង បេង កកោះ ធ្នង់ គគីរ ឥន្ទនេល រំដួល អង្គារបុស្ស សិរមាន់ លឿងរាជ។ល។

ព្រះសង្ឃ និងប្រជាពលរដ្ឋ ដែលបានដាក់ពាក្យ និងទទួលបានកូនឈើសរុបជិត៤ពាន់ដើមខាងលើ រួមមាន៖

១. ប្រគេនជូនព្រះគ្រូវិចិត្រវង្សា ហែម គឹមសាន ព្រះគ្រូចៅអធិការវត្តប្រាសាទគោកចក ចំនួន៨៤០ដើម
២. ប្រគេនកូនឈើជូនព្រះតេជគុណ អ៊ាន សុឃា គង់នៅវត្តពោធិវ៉ោរាម ហៅវត្តស្ពឺ ស្រុកចំការលើ ខេត្តកំពង់ចាម ចំនួន១,០០០ដើម
៣. ផ្តល់កូនឈើជូន **ឯកឧត្តម ឈិត ប៊ូរ៉ាវុធ** ប្រធានក្រុមមេធាវីនៃអាជ្ញាធរជាតិអប្សរា ចំនួន៤៥០ដើម
៤. ផ្តល់កូនឈើជូនលោក ស៊ាន យឿន តំណាងសហគមន៍ គណៈគ្រប់គ្រងសាលា និងគណៈកម្មការវត្ត ចំនួន ១,០០០ដើម
៥. ផ្តល់កូនផ្កាឥន្ទនេលជូនប្អូនស្រី យឿម ស៊ីន តំណាងក្រុមយុវជនកម្ពុជា ខេត្តសៀមរាប ចំនួន២៥០ដើម
៦. ផ្តល់កូនឈើជូនលោក ដឹង ជន តំណាងសាលាបឋមសិក្សាអរញ្ញរង្សី ចំនួន១០០ដើម
៧. ផ្តល់កូនឈើជូនអ្នកស្រី នីសាន់ ដេវី រស់នៅភូមិធ្លកអណ្តូង សង្កាត់ស្លក្រាម ក្រុង/ខេត្តសៀមរាប ចំនួន ១៧០ដើម
៨. ផ្តល់កូនឈើជូនលោក ឃាន តួក បម្រើការងារនៅមូលនិធិគន្ធបុប្ផាកម្ពុជានៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំនួន១៧៥ដើម ដើម្បីយកទៅប្រគេន និងដាំក្នុងបរិវេណវត្តស្គន់ និងវត្តទួល ស្ថិតក្នុងស្រុកជើងព្រៃ និងស្រុកបាធាយ ខេត្តកំពង់ចាម៕

ដើមឈើចំនួន៨,៦០០ដើម បានដាំនៅតំបន់ជុំវិញខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាបានចែកជូន កូនឈើចំនួន ៨,៦០០ដើម ដល់សាធារណជន ហើយកូនឈើទាំងនោះ ត្រូវបានដាំនៅតាមតំបន់នានាជុំវិញខេត្តសៀមរាប។
ការដាំទាំងនោះរួមមាន៖

១. ថ្ងៃទី១៥ សីហា ឆ្នាំ២០២០ លោក ស៊ាន យឿម តំណាងប្រជាសហគមន៍នៅស្រុកក្រឡាញ់ ខេត្តសៀមរាប បានទទួលកូនឈើចំនួន១,០០០ដើមពី អាជ្ញាធរជាតិអប្សរា យកទៅចែកចាយ និងដាំក្នុងបរិវេណវត្តស្រណាលចំនួន២៨០ដើមវត្តស្នួលចំនួន១០០ដើមវត្តភ្នំបីចំនួន២០០ដើម សាលាបឋមសិក្សារោងគោចំនួន២០០ដើម សាលាបឋមសិក្សាស្នួលចំនួន២០០ដើម និងដាំតាមលំនៅដ្ឋានចំនួន២០ដើម។

២. លោក លឹម ប៊ុនហាន នាយកសាលាបឋមសិក្សាសុខសាន្ត ស្ថិតក្នុងភូមិសុខសាន្ត ឃុំយាង ស្រុកពួក ខេត្តសៀមរាប បានទទួលកូនឈើចំនួន១០០ដើមពី អាជ្ញាធរជាតិអប្សរា យកទៅដាំនៅក្នុងបរិវេណសាលា និងសាលាឃុំយាង។

៣. ថ្នាក់ដឹកនាំ នាយទាហាន និងពលទាហាននៃកងពលធំអន្តរាគមន៍លេខ២ បានដាំកូនឈើដែលទទួលបានពីអាជ្ញាធរជាតិអប្សរាចំនួន៥,០០០ដើមក្នុងបរិវេណទីបញ្ជាការដ្ឋាន កងពលធំអន្តរាគមន៍លេខ២ ស្ថិតនៅភូមិស្រះខ្វាវ ឃុំតៀ្បង ស្រុកបន្ទាយស្រី ខេត្តសៀមរាប។

៤.ថ្ងៃទី២៣ខែសីហាឆ្នាំ២០២០កូនឈើចំនួន២,៥០០ដើម ត្រូវបានដាំក្នុងបរិវេណវត្តប្រាសាទ ស្ថិតក្នុងឃុំ ជប់តាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប។ កូនឈើទាំងនោះ បានចូលរួមដាំដោយអាជ្ញាធរមូលដ្ឋាន និងយុវជនសរុបចំនួន ២០០នាក់៕

អាជីវករលក់ដូរនៅមុខប្រាសាទអង្គរវត្តបន្តការរុះរើតូបលក់ដូររបស់ខ្លួន ដើម្បីត្រៀមទៅលក់ដូរនៅកន្លែងថ្មី

ផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០

អាជីវករលក់ដូរសម្លៀកបំពាក់ វត្ថុអនុស្សាវរីយ៍ ម្ហូបអាហារនៅជុំវិញត្រពាំងសេស បាននាំគ្នារុះរើតូបលក់ដូររបស់ខ្លួនជាបន្តបន្ទាប់ ដើម្បីត្រៀមទៅកាន់កន្លែងថ្មីដែលអាជ្ញាធរជាតិអប្សរាផ្តល់ឱ្យ។

អ្នកស្រី ស៊ាង ស៊ត់ អាជីវករលក់បាយ មាន់អាំង និងម្ហូបកុម្ម៉ង់ តាំងពីឆ្នាំ១៩៩១ បានលើកឡើងថា កន្លែងនេះខ្ញុំមានអនុស្សាវរីយ៍ល្អៗជាច្រើនជាមួយភ្ញៀវជាតិ-អន្តរជាតិដែលមកពិសារអាហារនៅទីនេះ។ ទីនេះក៏បានផ្តល់នូវភាពធូរធារដល់ជីវភាពគ្រួសារខ្ញុំ ចិញ្ចឹមកូនៗបានរៀនសូត្រខ្ពង់ខ្ពស់។ ថ្ងៃនេះខ្ញុំរីករាយក្នុងការរុះរើសំណង់ទាំងនេះដោយស្ម័គ្រចិត្ត ព្រោះអាជ្ញាធរជាតិអប្សរាបានផ្តល់ទីតាំងថ្មីសម្រាប់ខ្ញុំលក់ដូរបន្តដែលថ្មីស្អាតហើយមានអនាម័យជាងកន្លែងចាស់។ អ្នកស្រី ស៊ត់ ក៏បានគាំទ្រចំពោះវិធានការរបស់អាជ្ញាធរជាតិអប្សរា ក្នុងការរៀបចំបរិវេណជុំវិញត្រពាំងសេសឱ្យស្អាត ដើម្បីអង្គរមានសណ្តាប់ធ្នាប់ មានភាពបៃតង ឱ្យភ្ញៀវទេសចរមកលេងកាន់តែច្រើន លក់ដូរក៏កាន់តែដាច់។

អ្នកស្រី មាស សាគុណ ម្ចាស់តូបចំនួន៤ខ្នង លក់វត្ថុអនុស្សាវរីយ៍បោះដុំនិងរាយនៅខាងកើតត្រពាំងសេស បានចាប់ប្រកបរបរនេះតាំងពីឆ្នាំ៩០ជាងនោះ ក៏ពុំបានជំទាស់នឹងវិធានការអភិវឌ្ឍបរិវេណមុខប្រាសាទអង្គរវត្តឡើយ ព្រោះអ្នកស្រីដឹងថា ទីនេះជាដីកម្មសិទ្ធិរបស់រដ្ឋ រដ្ឋយកវិញពេលណាក៏នឹងព្រមប្រគល់ជូនដោយស្ម័គ្រចិត្តដូចជាការរុះរើនៅថ្ងៃនេះស្រាប់។ ដំបូងឡើយ អ្នកស្រីក៏មានការបារម្ភណាស់ដែរ តែលុះបានទទួលព័ត៌មានពីអាជ្ញាធរជាតិអប្សរា បានឃើញកន្លែងលក់ដូរថ្មីក៏មានចិត្តសប្បាយរីករាយទទួលយក ព្រោះគ្រប់គ្នាត្រូវតែរុះរើចេញពីទីតាំងត្រពាំងសេសនេះដូចគ្នាទាំងអស់។

ក្នុងស្មារតីស្រឡាញ់អង្គរ ហើយក៏ជាអ្នកទទួលបានផលយ៉ាងច្រើនពីអង្គរ លោក យ៉ាង សុភាព ជាអ្នកលក់ម្ហូបអាហារ បានប្រាប់ពីអារម្មណ៍ថា ចំពោះវិធានការរបស់រដ្ឋ ខ្ញុំក៏តែងតែគាំទ្រ ពិសេសការរុះរើនេះ គឺរដ្ឋបានផ្តល់សំណងឱ្យ ហើយរដ្ឋអនុវត្តការងារនេះស្មើភាពគ្នា ដូច្នេះខ្ញុំគ្មានអ្វីដែលជំទាស់ទេ។ យូរហើយដែលយើងខ្ញុំបានអាស្រ័យផលនឹងអង្គរ ហើយក៏ដល់ពេលដែលត្រូវតបស្នងដល់អង្គរវិញ។ ខ្ញុំគាំទ្រអាជ្ញាធរជាតិអប្សរាចំពោះការរៀបចំទីតាំងថ្មីសម្រាប់លក់ដូរ ហើយកែប្រែទីនេះឱ្យមានសោភ័ណភាពស្អាតដើម្បីទាក់ទាញភ្ញៀវ។ លោក សុភាព ក៏សង្ឃឹមថា ការទៅលក់នៅទីតាំងថ្មីនឹងទទួលបានអតិថិជនច្រើនៗ ព្រោះទីនោះស្អាត មានអនាម័យ មានទឹកភ្លើង ងាយស្រួលជាងកន្លែងចាស់៕

សេចក្តីជូនដំណឹងស្តីពីការបិទជាបណ្តោះអាសន្នសម្រាប់ការទស្សនាថ្ងៃលិចនៅប្រាសាទប្រែរូប

ផ្សាយនៅថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា

APSARA

លេខ.០៦៤៣/អប.សជណ/២០

សេចក្តីជូនដំណឹង

ស្តីពី

ការបិទជាបណ្តោះអាសន្នសម្រាប់ការទស្សនាថ្ងៃលិចនៅប្រាសាទប្រែរូប

អាជ្ញាធរជាតិអប្សរាមានកិត្តិយស សូមជូនដំណឹងដល់ក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបថា ស្ថានភាពហានិភ័យជាក់ស្តែងមួយចំនួននៃរចនាសម្ព័ន្ធប្រាសាទប្រែរូប នៅតាមបណ្តោយកម្រាលនៃខឿនលើបង្អស់ផ្នែកខាងលិចដែលជាទីតាំងបណ្តុំភ្ញៀវទេសចរទស្សនាថ្ងៃលិច មានកម្រាលថ្មបានរំកិលចេញពីទីតាំងដើម ដែលអាចបង្កគ្រោះថ្នាក់ដល់ភ្ញៀវទេសចរជាយថាហេតុ។ ក្នុងន័យនេះ ដើម្បីថែរក្សាសុវត្ថិភាពដល់ភ្ញៀវទេសចរជាតិ អន្តរជាតិ សាធារណជន និងបងប្អូនប្រជាពលរដ្ឋទាំងអស់ អាជ្ញាធរជាតិអប្សរា នឹងបិទការទស្សនាថ្ងៃលិចនៅប្រាសាទប្រែរូបជាបណ្តោះអាសន្ន **គិតចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០នេះតទៅ** រហូតដល់ចំណុចគ្រោះថ្នាក់នៃប្រាសាទត្រូវបានជួសជុលរួចរាល់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមក្រសួង ស្ថាប័នជាតិ អន្តរជាតិ អាជ្ញាធរដែនដី មន្ទីរ-អង្គភាព សមាគមទីភ្នាក់ងារទេសចរណ៍ សមាគមមគ្គុទ្ទេសក៍ទេសចរណ៍ សមាគមដឹកជញ្ជូនភ្ញៀវទេសចរ ក្រុមហ៊ុនទេសចរណ៍ ភ្ញៀវទេសចរជាតិ-អន្តរជាតិ សាធារណជន ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃ..........ខែ.........ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

សៀមរាប ថ្ងៃទី..២៦..ខែសីហា ឆ្នាំ២០២០

ភ្នំពេញ:
អគារលេខ៤៤ ផ្លូវលេខ២១៤ សង្កាត់បឹងរាំង ខណ្ឌដូនពេញ
ទូរសព្ទ/ទូរសារ៖ ០២៣ ២១៥ ៧៧១/ ០២៣ ២១៥ ៧៧៦

អាជ្ញាធរដើម្បីការពារតំបន់ និងរៀបចំដែនដីតំបន់អង្គរ
Email: info@apsaraauthority.gov.kh
Website: apsaraauthority.gov.kh

សៀមរាប:
ភូមិបន្លោង ឃុំអំពិល ស្រុកប្រាសាទបាគង ខេត្តសៀមរាប
ទូរសព្ទ/ទូរសារ៖ ០៦៣ ៧៦៥ ៥៧៧/ ០៦៣ ៧៦៥ ៥៧៦

អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើជិត២ពាន់ដើមទៀតទៅសាធារណជន

ផ្សាយនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

ក្នុងបំណងបង្កើនគម្របព្រៃឈើឡើងវិញក្នុងប្រទេសកម្ពុជា អាជ្ញាធរជាតិអប្សរាបានបន្តចែកជូនកូនឈើដល់សាធារណជិតឆ្ងាយ ដើម្បីយកទៅដាំនៅតាមតំបន់ផ្សេងៗ។ នៅថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែ សីហា ឆ្នាំ២០២០ កូនឈើជិត ២ពាន់ដើមបន្ថែម បានចែកចាយដល់សាធារណជន។ កូនឈើដែលបានផ្តល់ជូននោះរួមមាន៖

១.ផ្តល់កូនឈើជូនលោក ឡាចវិបុល នាយកអនុវិទ្យាល័យបាគងម៉ូតវ៉ានីចំនួន១៥០ដើមដើម្បីយកទៅដាំក្នុងបរិវេណអនុវិទ្យាល័យ ដែលមានទីតាំងនៅក្បែរប្រាសាទបាគង ក្នុងភូមិថ្នល់ត្រង់ ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

២. ផ្តល់កូនឈើជូនលោក អ៊ាម ជឿម នាយកសាលាបឋមសិក្សាពោធិ៍ស្មើសង្គម ចំនួន១០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណសាលារៀន ស្ថិតក្នុងភូមិកំពង់ ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប។

៣. ផ្តល់កូនឈើជូនតំណាងគ្រឹះស្ថានអង្គរចំនួន ចំនួន៤៨ដើម ដើម្បីយកទៅដាំតាមបណ្តោយផ្លូវរណបផ្លូវ៦០ម៉ែត្រស្របមាត់ប្រឡាយដែលទើបជួសជុលកែលំអរួច ស្ថិតក្នុងភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុង/ខេត្តសៀមរាប។

៤.ផ្តល់កូនឈើជូនលោកអ៊ូចផ័ត្រាបម្រើការងារនៅនាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យនៃអាជ្ញាធរជាតិអប្សរា ចំនួន៦០ដើម ដើម្បីយកទៅដាំនៅភូមិស្វាយចេក ឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប។

៥. ផ្តល់កូនឈើជូនលោក ទាន វ៉ាត់ ចំនួន៣០ដើម ដើម្បីយកទៅដាំនៅភូមិល្អក់ ឃុំកណ្តែក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

៦. ផ្តល់កូនឈើជូនតំណាងរដ្ឋបាលឃុំប្រីយ៍ ចំនួន៦០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណអង្គភាពចំណុះរដ្ឋបាលឃុំប្រីយ៍ ស្រុកស្រីស្នំ ខេត្តសៀមរាប រួមមាន សាលាបឋមសិក្សាប្រីយ៍សាលាបឋមសិក្សាក្រូចចារសាលាបឋមសិក្សាត្រាំសសរ អនុវិទ្យាល័យប្រីយ៍ និងមណ្ឌលសុខភាពប្រីយ៍។

៧. ផ្តល់កូនឈើជូនតំណាងរដ្ឋបាលឃុំស្វាយចេក ចំនួន៥០០ដើម ដើម្បីយកទៅដាំលំអក្នុងបរិវេណសាលារៀន និងវត្តស្លាតរំដ័យ ក្នុងឃុំស្វាយចេក ស្រុកអង្គរធំ ខេត្តសៀមរាប៕

នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គររៀបចំផ្លាស់ប្តូរទីតាំងបំពេញការងាររបស់ប្រធាន-អនុប្រធានភ្នាក់ងារទេសចរណ៍ប្រចាំឆ្នាំ

ផ្សាយនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០

នារសៀលថ្ងៃទី២៦ខែសីហាឆ្នាំ២០២០នៅប្រាសាទអង្គរវត្ត **ឯកឧត្តម សុខ សង្វារ** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរបានដឹកនាំកិច្ចប្រជុំស្តីអំពី «ការផ្លាស់ប្តូរទីតាំងបំពេញការងាររបស់ប្រធាននិងអនុប្រធានភ្នាក់ងារទេសចរណ៍» ដែលធ្វើឡើងជាទៀងទាត់រៀងរាល់មួយឆ្នាំម្តងសម្រាប់គ្រប់គោលដៅទាំងអស់។

ឯកឧត្តម សុខ សង្វារ មានប្រសាសន៍ថា៖ ការផ្លាស់ប្តូរទីតាំងបំពេញការងាររបស់ប្រធាននិងអនុប្រធានភ្នាក់ងារទេសចរណ៍ ពុំមែនជារឿងថ្មីនោះទេ គឺយើងតែងតែធ្វើជារៀងរាល់មួយឆ្នាំម្តង។ ការធ្វើដូចនេះ គឺដើម្បីឱ្យភ្នាក់ងារទេសរណ៍ទាំងអស់មានការអភិវឌ្ឍសមត្ថភាព ទទួលបានបទពិសោធន៍ថ្មីៗពីការងារគ្រប់គ្រងទេសចរនៅតាមបណ្តាប្រាសាទតូចធំ ពង្រឹងប្រសិទ្ធភាពការងារ និងបញ្ចៀសការបង្កើតបក្សពួកនិយម ដោយសារស្ថិតនៅទីតាំងតែមួយដដែលៗយូរពេក។

ដើម្បីប្រសិទ្ធភាពការងារឱ្យស្របទៅនឹងវិសាលភាពតូចធំនៃប្រាសាទក្នុងតំបន់អង្គរ បូកនឹងសមត្ថភាពប្រធានអនុប្រធានភ្នាក់ងារទេសចរណ៍ទាំងអស់មិនស្មើនោះ ការផ្លាស់ប្តូរទីតាំងឈរជើងម្តងៗគឺធ្វើឡើងដោយថ្នាក់ដឹកនាំ

ដែលបានសង្កេតពិនិត្យហ្មត់ចត់លើអត្តចរិត សមត្ថភាពការងារជាក់ស្តែង និងចាត់តាំងទៅតាមទំហំការងាររបស់ប្រាសាទ រួមទាំងបទពិសោធន៍របស់ភ្នាក់ងារផ្ទាល់ ដែលចាំបាច់ត្រូវតែមានសមត្ថភាព ក្លាហាន និងឧស្សាហ៍ខ្លាំងទើបអាចទប់ស្កាត់សកម្មភាពអវិជ្ជមានរបស់ភ្ញៀវទេសចរបាន។

យោងតាមលទ្ធផលដែលបានពីការផ្លាស់ប្តូរទីតាំងនេះ ឯកឧត្តមសង្កេតឃើញថា ភ្នាក់ងារទេសចរណ៍ទទួលបាននូវបទពិសោធន៍ថ្មីៗបន្ថែមពីទីតាំងការងារថ្មី និងក្រុមមនុស្សថ្មីៗដែលខ្លួនទៅធ្វើការជាមួយ សមត្ថភាពពួកគាត់មានការអភិវឌ្ឍឡើងជាលំដាប់ហើយការងារកាន់តែមានប្រសិទ្ធភាពជាងមុន ដោយពួកគាត់អាចនាំយកបទពិសោធន៍ពីទីតាំងការងារផ្សេងៗទៅប្រៀបធៀបគ្នានិងស្វែងរកចំណុចល្អៗមកអនុវត្ត៕

គម្រោងផលិតឯកសារវីដេអូ «អង្គរ និងលើសពីនេះ» បានចាប់ផ្តើម

ផ្សាយនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

ក្រោមកិច្ចសហប្រតិបត្តិការរវាងអាជ្ញាធរជាតិអប្សរា និងសារព័ត៌មានថ្មីៗ ក្នុងការផលិតឯកសារវីដេអូក្នុងតំបន់រមណីយដ្ឋានអង្គរ ក្នុងគម្រោងដែលមានឈ្មោះថា «អង្គរ និងលើសពីនេះ» បានចាប់ផ្តើមដំណើរការហើយ។ ក្រុមការងារនៃសារព័ត៌មានថ្មីៗ ដែលមានកិច្ចសហការ និងការសម្របសម្រួលពីអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមចុះមកផលិតព័ត៌មានឯកសារនានាដែលទាក់ទងក្នុងតំបន់រមណីយដ្ឋានអង្គរ។

នៅថ្ងៃចាប់ផ្តើមនៃកម្មវិធី ក្រុមសារព័ត៌មានថ្មីៗ បានធ្វើកិច្ចសម្ភាស **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ពីគោលបំណងរួមនៃកម្មវិធី ក៏ដូចជាផលិតឯកសារស្តីពីកំពែង ការសម្អាតប្រាសាទជាដើម។ល។ កម្មវិធីនេះនឹងបន្តចុះមកផលិតឯកសារវីដេអូជាបន្តបន្ទាប់ ជុំវិញរឿងរ៉ាងទាក់ទងនឹងតំបន់រមណីយដ្ឋានអង្គរ។

អង្គរ និងលើសពីនេះ...! គឺជាកម្មវិធីផ្តោតជាពិសេសទៅលើតម្លៃប្រាង្គប្រាសាទ វប្បធម៌ ប្រពៃណី ធម្មជាតិ (សត្វ និងព្រៃ) បុរាណដ្ឋាន តំបន់ប្រវត្តិសាស្ត្រ ម្ហូបអាហារ សម្លៀកបំពាក់។ល។ ដែលស្ថិតនៅក្នុងខេត្តសៀមរាបនិយាយជារួម និងនិយាយដោយឡែកនៅក្នុងតំបន់រមណីយដ្ឋានអង្គរ។ សារព័ត៌មានអេឡិចត្រូនិក ថ្មីៗ ដោយមានការផ្តួចផ្តើមគំនិត និងយល់ព្រមសហការដោយអាជ្ញាធរជាតិអប្សរា នឹងព្យាយាមផលិតឯកសារវីដេអូប្រវត្តិសាស្ត្រទាក់ទងទៅនឹងតំបន់អង្គរបន្ថែមទៀតទៅតាមលទ្ធភាពដែលខ្លួនអាចធ្វើបាន។ ឯកសារវីដេអូនេះអាចនឹងឡើងជាពីរភាសា មានភាសាខ្មែរ និងអង់គ្លេស៕

សំណង់ភោជនីយដ្ឋាន តូបលក់ដូរ អាគាររដ្ឋសរុបប្រមាណ១៥០ខ្នងត្រូវបានរុះរើរួចរាល់ទាំងស្រុង នៅមុខបរិវេណខាងលិចប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

សំណង់ភោជនីយដ្ឋានអាគាររដ្ឋតូបលក់ដូរវត្ថុអនុស្សាវរីយ៍ លក់ម្ហូបអាហារ សម្លៀកបំពាក់ និងគ្រឿងកេសជ្ជៈផ្សេងៗ ចំនួនប្រមាណ១៥០ខ្នង ត្រូវបានរុះរើរួចរាល់ទាំងស្រុង នាថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ ពីបរិវេណខាងលិចប្រាសាទអង្គរវត្ត ទាំងផ្នែកខាងត្បូងផ្លូវចូល និងមាត់ត្រពាំងសេស។

កិច្ចការនេះ បានដំណើរការកាលពីដើមឆ្នាំ២០២០ ដោយមានការស្ម័គ្រ និងឆន្ទៈរួមចំណែកក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធ និងសម្បទាទេសចរណ៍របស់ម្ចាស់សំណង់អាជីវកម្ម ក្រោមកិច្ចសម្របសម្រួលរបស់អាជ្ញាធរជាតិអប្សរា ដើម្បីរួមគ្នាលើកតម្លៃរមណីយដ្ឋានអង្គរឱ្យសមជាបេតិកភណ្ឌពិភពលោក។

ចំពោះអាជីវករដែលបានរុះរើតូបខ្លួនរួចរាល់ហើយ នឹងចាប់ផ្តើមដំណើរការលក់ដូរឡើងវិញ ចាប់ពីថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០នេះតទៅ នៅក្នុងបរិវេណនៃបណ្តុំអាគារទីលានបដិសណ្ឋារកិច្ច ដែលជាសំណង់ថ្មី ស្អាត ងាយស្រួល ហើយមានអនាម័យជាងមុន។

តាមគម្រោងរបស់អាជ្ញាធរជាតិអប្សរានឹងកែប្រែតំបន់អតីតសំណង់ដែលរុះរើនេះហើយ រៀបចំឱ្យក្លាយជាផ្លូវថ្មើជើង សួនឈើប្រណីត ឈើផ្កាព្រៃ និងរុក្ខជាតិលម្អដែលមានក្លិនពិដោរក្រអូបៗផង ជាការកែប្រែទីនេះឱ្យមានភាពស្រស់បំព្រង មានពណ៌បៃតង បរិយាកាសល្អ និងសណ្តាប់ធ្នាប់កាន់ប្រសើរឡើង៕

រួមគ្នាដាំកូនឈើដើម្បីលើកកម្ពស់គម្របព្រៃឈើ បរិស្ថាន និងការអភិរក្សប្រាសាទ ក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ មានរៀបចំពិធីដាំកូនឈើនៅវត្តទេពប្រណម្យ ចូលរួមដោយ **លោក ឡុង កុសល** អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា ព្រះចៅអធិការវត្តពុទ្ធបរិស័ទ មន្ត្រី បុគ្គលិកនៃអាជ្ញាធរជាតិអប្សរា សរុបប្រមាណ១៥០អង្គ-នាក់។ កូនឈើ ប្រណីតមានគ្រញូង ១០០ដើម ធ្នង់៥០ដើម ប្រេស៥០ ដើម ឈើទាល៥០ដើម និងដើមផ្កាវិដ្ឋល៥០ដើម ត្រូវបានដាំនៅក្នុងបរិវេណវត្តទេពប្រណម្យ។

ការដាំដើមឈើនៅព្រឹកនេះ គឺដើម្បីរួមគ្នាថែរក្សាទេសភាពវប្បធម៌ បង្កើតគម្របបៃតងដល់បរិស្ថាននៅក្នុងតំបន់អង្គរ បង្កើនជម្រកសត្វព្រៃ និងជួយដល់ការអភិរក្សប្រាសាទផង។ ពិសេស គឺបណ្តុះគំនិតពុទ្ធបរិស័ទគ្រប់ស្រទាប់វណ្ណៈឱ្យមានការចូលរួម ស្រលាញ់ ថែរក្សា និងការដាំកូនឈើឡើងវិញឱ្យផុលផុសបំផុតដើម្បីថែរក្សាបរិយាកាស រួមទាំងការរស់នៅមានខ្យល់បរិសុទ្ធដល់មនុស្សសត្វផង។

អាជ្ញាធរជាតិអប្សរាក៏សូមថ្លែងអំណរគុណដល់ព្រះសង្ឃ ពុទ្ធបរិស័ទ មន្ត្រី បុគ្គលិក ដែលបានចូលរួមក្នុងការដាំកូនឈើក្នុងរមណីយដ្ឋានអង្គ។ ជាថ្មីម្តងទៀត អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ថា សម្រាប់បងប្អូនដែលមានបំណងចង់ដាំកូនឈើឬត្រូវការកូនឈើយកទៅដាំនោះ សូមទំនាក់ទំនងមកអាជ្ញាធរជាតិអប្សរា៕

អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា៖ ទិដ្ឋភាពខាងលិចប្រាសាទអង្គរវត្តទាំងស្រុងកំពុងតែកែប្រែឱ្យកាន់តែមានសម្រស់ស្រស់ស្អាត

ផ្សាយនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០

លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា មានប្រសាសន៍នៅថ្ងៃទី២៨ខែសីហាឆ្នាំ២០២០អំពីការអភិវឌ្ឍនៅបរិវេណខាងលិចប្រាសាទអង្គរវត្តថា៖ ចាប់ពីថ្ងៃនេះទៅបរិវេណខាងលិចប្រាសាទអង្គរវត្តទាំងស្រុង នឹងប្រែក្លាយរូបរាងទៅជាទិដ្ឋភាពមួយកាន់តែមានសម្រស់ស្រស់ស្អាតជាមួយនឹងភាពបៃតងនៃដើមឈើ វាលស្មៅ និងផ្កាចម្រុះពណ៌។ សូមកុំភ្លេចមកលេងអង្គរវត្ត! មកម្តងនេះ ភ្ញៀវទេសចរពិតជាប្លែកភ្នែក នឹងភាពស្រស់ស្អាតត្រជាក់ចិត្តមិនខាន!»

លោកកុសលបញ្ជាក់ថាពេលនេះក្រុមការងារអាជ្ញាធរជាតិអប្សរាកំពុងតែមមាញឹកនៅក្នុងការរៀបចំសួនច្បារបន្ថែមទៀត ដោយការដាំស្មៅ ដាំកូនឈើ ដាំផ្កាលម្អ រៀបចំផ្លូវដើរ កាត់ស្មៅ និងថែទាំរុក្ខជាតិដែលដាំហើយយ៉ាងសកម្ម។ ក្នុងនោះដែរ យើងក៏បានរៀបចំប្រព័ន្ធរំដោះទឹករួមទាំងការរៀបចំសណ្តាប់ធ្នាប់ផ្សេងៗកាន់តែប្រសើរជាងមុន ដើម្បីឱ្យបរិវេណខាងលិចប្រាសាទអង្គរវត្តកាន់តែមានរបៀបរៀបរយនិងស្រស់ស្អាតគួរឱ្យ ចាប់អារម្មណ៍ពីសំណាក់ភ្ញៀវទេសចរ ដែលមកកម្សាន្តនៅតំបន់រមណីយដ្ឋានអង្គរ ដើម្បីលម្ហែចិត្ត លម្ហែកាយ និងផ្តិតយករូបភាពដ៏ស្រស់ត្រកាលទាំងនេះទុកជាអនុស្សាវរីយ៍។

សូមបញ្ជាក់ថា ការរៀបចំហេដ្ឋារចនាសម្ពន្ធនិងរៀបចំសួនច្បារនៅខាងលិចប្រាសាទអង្គរវត្តនេះបានចាប់ផ្តើមពីដើមឆ្នាំ២០២០ ជាមួយនឹងការរុះរើសំណង់តូបលក់ដូរផង។ មកដល់ពេលនេះ យុទ្ធនាការរុះរើសំណង់ភោជនីយដ្ឋាន អាគាររដ្ឋ តូបលក់ដូរម្ហូបអាហារ លក់វត្ថុអនុស្សាវរីយ៍ សម្លៀកបំពាក់ប្រមាណជា១៥០ ខ្នងក៏បានរួចរាល់អស់ទាំងស្រុង ដោយការស្ម័គ្រចិត្តពីម្ចាស់កម្មសិទ្ធិ ហើយទីធ្លាខាងលិចប្រាសាទអង្គរវត្តនេះក៏ពេញទៅដោយការអភិវឌ្ឍហេដ្ឋារចនាសម្ពន្ធនិងសួនច្បារបៃតងបង្អួតសម្រស់ធម្មជាតិដ៏ស្រស់បំព្រងប្លែកភ្នែកជាខ្លាំងដល់ទេសចរតាមការគ្រោងទុក៕

បាឋកថាស្តីអំពី «វឌ្ឍនភាពនៃការជួសជុលស្ពានហាលអង្គរ»

ផ្សាយនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០

ក្រោយដំណើរការជួសជុលអស់រយៈពេល៤ឆ្នាំកន្លងមក ក្រោមកិច្ចសហការរវាងសាកលវិទ្យាល័យសូហ្វីយ៉ាប្រទេសជប៉ុននិងអាជ្ញាធរជាតិអប្សរា បានសម្រេចកិច្ចការជាច្រើនក្នុងការអភិរក្សស្ពាននេះ។ ជាការបង្ហាញពីសមិទ្ធផលដែលសម្រេចបាននៅក្នុងដំណាក់កាលទី១នេះ អ្នកជំនាញអាជ្ញាធរជាតិអប្សរាចំនួន៤រូប គឺលោក អន សុភាព លោក ម៉ៅ សុខនី លោក ឈុន សំបូរ និងលោកសាស្ត្រាចារ្យ អ៊ឹម សុខរិទ្ធី នឹងរួមគ្នាធ្វើបទបង្ហាញអំពី «ការស្រាវជ្រាវថ្មីៗនៅក្នុងតំបន់អង្គរ» ក្រោមប្រធានបទ «វឌ្ឍនភាពនៃការជួសជុលស្ពានហាលអង្គរ» នៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ នាវេលាម៉ោង៩:០០នាទីព្រឹក ដល់ម៉ោង ១២:០០នាទីថ្ងៃត្រង់ នៅសាលសន្និសីទអង្គរនៃមជ្ឈមណ្ឌលអាជ្ញាធរជាតិអប្សរា។

ដូច្នេះ ដើម្បីជ្រាបកាន់តែច្បាស់អំពីខ្លឹមសារនៃបាឋកថាស្តីអំពី «វឌ្ឍនភាពនៃការជួសជុលស្ពានហាលអង្គរ» អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមគោរពអញ្ជើញឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី បុគ្គលិកគ្រប់ស្ថាប័ន អ្នកស្រាវជ្រាវ មគ្គុទ្ទេសទេសចរណ៍ សិស្សានុសិស្ស និងសាធារណជនចំនួន៥០នាក់ប៉ុណ្ណោះ (អនុវត្តន៍តាមគោលការណ៍នៃការរីករាលដាលជំងឺកូវីដ១៩) ដើម្បីចូលរួមសិក្សាស្តាប់បាឋកថានេះជាប្រយោជន៍ក្នុងការបង្កើនចំណេះដឹងដោយមេត្រី។

បញ្ជាក់៖ សូមទាក់ទងតាមលេខទូរសព្ទនៅក្នុងសេចក្តីជូនដំណឹង ដើម្បីសាកសួរព័ត៌មានលម្អិតនិងការចុះឈ្មោះ។

លិខិតអញ្ជើញ

មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ មានកិត្តិយសសូមគោរពអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី មន្ត្រី-បុគ្គលិក នៃអាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាអញ្ជើញចូលរួម សិក្សា ស្តាប់បាឋកថាស្តីពី "ការវិវឌ្ឍន៍ថ្មីៗនៅតំបន់អង្គរ"

ក្រោមប្រធានបទ ៖ **វឌ្ឍនភាពជួសជុលស្ពានហាលអង្គរវត្ត**

បទបង្ហាញដោយ ៖ - លោក អន សុភាព
- លោក ម៉ៅ សុខនី
- លោក ឈុន សំបូរ
- លោក សាស្ត្រាចារ្យ អ៊ឹម សុខរិទ្ធី

នាថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ៩:០០នាទីព្រឹក ដល់ម៉ោង ១២:០០នាទីថ្ងៃត្រង់
នៅសាលសន្និសីទអង្គរ នៃអាជ្ញាធរជាតិអប្សរា

(បន្ទប់ធំទូលាយ ហើយកំណត់សាធារណជនចូលរួមស្តាប់ត្រឹមតែចំនួន ៥០រូប ប៉ុណ្ណោះដោយអនុវត្តនូវគោលការណ៍ណែនាំស្តីពីការបង្ការការរីករាលដាលនៃជម្ងឺឆ្លង Covid 19)

កំណត់សម្គាល់ ៖ ដើម្បីសម្រួលដល់ការរៀបចំ សូមមន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរា និងសាធារណជនទូទៅ មេត្តាផ្តល់ដំណឹងអំពីការចូលរួម តាមលេខទូរស័ព្ទ៖ ០១២ ៧៣៤ ៥២០/ ០១៦ ៥៤៤ ០១៧ ឲ្យបាន០១ថ្ងៃមុន មុនថ្ងៃចាប់ផ្តើមកម្មវិធី។ សូមអរគុណ!

សំណើចំនួន២២ករណីត្រូវបានអាជ្ញាធរជាតិអប្សរាចុះពិនិត្យនៅសប្ដាហ៍ទី៤នៃខែសីហា

ផ្សាយនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០

នៅក្នុងសប្ដាហ៍ទី៤ នៃខែសីហា ឆ្នាំ២០២០នេះ ក្រុមការងារជំនាញនៃនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរដែលទទួលបន្ទុក ចុះពិនិត្យដល់ទីតាំងស្នើសុំជាក់ស្ដែង ដើម្បីពិនិត្យមើលលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់ទីតាំងស្នើសុំរបស់ប្រជាពលរដ្ឋបាន២២ករណីរួមមាន៖

២.ស្រុកបន្ទាយស្រី ៧ករណី
៣. ស្រុកអង្គរធំ ៦ករណី
៤. ស្រុកប្រាសាទបាគង ២ករណី
៥. ស្រុកស្វាយលើ ២ករណី។



ដោយឡែកក្នុងរយៈពេលដូចគ្នានេះដែរ ប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្មបានជួយរៀបចំគំនូសប្លង់បានចំនួន ០១ករណី នៅស្រុកអង្គរធំ៕

អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើជាង៣ពាន់ដើមបន្ថែមទៀតដល់សាធារណជន

ផ្សាយនៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០

ក្នុងបំណងស្តារគម្របព្រៃឈើឡើងវិញក្នុងប្រទេសកម្ពុជា អាជ្ញាធរជាតិអប្សរាបានបន្ត ចែកចាយកូនឈើចំនួន ៣,២៤០បន្ថែមទៀត ដល់សាធារណជនយកទៅដាំដុះតាមតំបន់នានាក្នុងប្រទេសកម្ពុជា។

កូនឈើដែលបានផ្តល់ជូន និងចែកចាយចាប់ពីថ្ងៃទី២៧ ដល់ថ្ងៃទី២៩ ខែសីហា រួមមាន៖

១. ផ្តល់កូនឈើជូនតំណាងវិទ្យាល័យហ៊ុនសែនប្រាសាទបាគង ចំនួន២០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវិទ្យាល័យនេះ ស្ថិតក្នុងភូមិឪឡោក ឃុំបាគង ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

២. ផ្តល់កូនឈើជូនលោក ចុង ស៊ុនឡេង ចំនួន៣០ដើម ដើម្បីយកទៅដាំនៅស្រុកកំណើត។

៣. ផ្តល់កូនឈើជូនតំណាងនាយកដ្ឋានសណ្តាប់ធ្នាប់នៃអាជ្ញាធរជាតិអប្សរា ចំនួន៧៦០ដើម ដើម្បីយកទៅដាំនៅបរិវេណប្រាសាទបេងមាលា ដាំលម្អក្នុងនាយកដ្ឋានសណ្តាប់ធ្នាប់ដាំលើទីតាំងដីទំនេរនៅខាងកើតប្រាសាទអង្គរវត្ត និងកែងផ្លូវ៦០ម៉ែត្រក្នុងភូមិក្រវ៉ាន់ សង្កាត់នគរធំ ក្រុង/ខេត្តសៀមរាប។

៤. ប្រគេនកូនឈើជូនព្រះវរវិន្ទមុនី ទី ថា ព្រះចៅអធិការវត្តសុវណ្ណបទុម ចំនួន៦០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្ត ស្ថិតក្នុងភូមិរំដួល ឃុំវ៉ារិន ស្រុកវ៉ារិន ខេត្តសៀមរាប។

៥. ប្រគេនកូនឈើជូនព្រះគ្រូចៅអធិការ សាត់ សីលា ចំនួន១,៥០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តពោធិអម្ពវ័ន ហៅវត្តស្វាយទាប ស្ថិតក្នុងភូមិប្រមាត់ដី ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម។

៦. ផ្តល់កូនឈើជូនប្អូនស្រី វាសនា មករា បំរើការងារនៅនាយកដ្ឋានអភិវឌ្ឍន៍ទេសចរអង្គរនៃអាជ្ញាធរជាតិអប្សរា ចំនួន១០០ដើម ដើម្បីយកទៅដាំនៅភូមិសិង្ហ ឃុំគោកមន ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ។

៧. ប្រគេនកូនរំដួលជូនវត្តព្រះឥន្ទកោសាចំនួន៥០ដើម និងវត្តទេពពោធិវង្សចំនួន១០០ដើម ដើម្បីយកទៅដាំលំអក្នុងបរិវេណវត្ត៕

ព្រឹត្តិការណ៍ព័ត៌មាន ប្រចាំខែកញ្ញា

អាជ្ញាធរជាតិអប្សរាសហការជាមួយរដ្ឋបាលក្រុងសៀមរាប ចុះរុះរើសំណង់ខុសច្បាប់ នៅទីបុរាណដ្ឋានត្រពាំងហៃផ្កាជាលើកទី២

ផ្សាយនៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាសហការជាមួយរដ្ឋបាលក្រុងសៀមរាប ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប ចុះអនុវត្តន៍ការរុះរើសំណង់របស់លោក យន់ សុខន ដូចជារបង បន្ទប់ទឹក រោង ដែលធ្វើខុសច្បាប់ប៉ុនប៉ងយកទីបុរាណដ្ឋានត្រពាំងហៃផ្កាធ្វើជាកម្មសិទ្ធិឯកជនជាថ្មីម្តងទៀត នៅភូមិបុស្សក្រឡាញ់ សង្កាត់ជ្រាវ នាព្រឹកថ្ងៃអង្គារ ទី០១ ខែកញ្ញា ឆ្នាំ២០២០។

អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា លោក ឡុង កុសល មានប្រសាសន៍ថា៖ ការចុះរុះរើសំណង់ខុសច្បាប់នៅថ្ងៃនេះ គឺដើម្បីការពារការប៉ុនប៉ងយកដីបុរាណដ្ឋានត្រពាំងហៃផ្កាដោយខុសច្បាប់មកធ្វើជាកម្មសិទ្ធិឯកជនរបស់ខ្លួនជាថ្មីម្តងទៀត បន្ទាប់ពីក្រុមការងារចម្រុះបានរុះរើរបងដល់ដីនិងការយល់ព្រមបញ្ឈប់ការសាងសង់ទាំងអស់ពីម្ចាស់សំណង់កាលពីខែវិច្ឆិកា ឆ្នាំ២០១៩រួចមកហើយ។
អាជ្ញាធរជាតិអប្សរាបង្ហាញជំហរថា បើទោះបីជាយ៉ាងណាអាជ្ញាធរត្រូវតែប្រឆាំងចំពោះអំពើរំលោភបំពានប៉ុនប៉ងយកទីបុរាណដ្ឋានដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែលត្រូវការពារជាដាច់ខាត ហើយអ្វីដែលឈ្មោះ យន់ សុខន បានធ្វើម្តងជាពីរដងនេះ គឺបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់មរត៌កនៃបេតិកភណ្ឌ។

លោក សំរិទ្ធិ សុខុន ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តសៀមរាប លើកឡើងថា អំពើរំលោភបំពានបុរាណដ្ឋានធ្វើជាកម្មសិទ្ធិរបស់ខ្លួន គឺបុគ្គលនោះត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ទៅតាមស្ថានភាពនៃការបំផ្លាញដែលប៉ះពាល់ដល់សម្បត្តិវប្បធម៌ទាំងនោះ។

ជាមួយនឹងការរុះរើនូវ រាល់សំណង់ខុសច្បាប់ទាំងនោះ តំណាងរដ្ឋបាលក្រុងសៀមរាប លោក ហៃ យ៉ុង ក៏បានបង្ហាញពីគម្រោងអភិវឌ្ឍន៍ត្រពាំងហៃផ្កានិងការលើកតម្លៃទីបុរាណដ្ឋាននេះឡើងវិញ តាមរយៈការស្តារត្រពាំងហៃផ្កានេះឱ្យស្អាត ដើម្បីធ្វើជាប្រភពទឹកសម្រាប់អ្នកភូមិបានប្រើប្រាស់នៅពេលធាប់ៗ ដោយអាជ្ញាធរក្រុង បានទទួលបានច្បាប់អនុញ្ញាតជាគោលការណ៍ពីអាជ្ញាធរជាតិអប្សរារួចហើយដែរ។

ត្រពាំងហៃផ្កា មានបណ្តោយ៣៥០ម៉ែត្រ ទទឹង១៧០ម៉ែត្រ មានខ្នងទំនប់ពី៤០ទៅ៦០ម៉ែត្រ។ ត្រពាំងនេះ មានតាំងពីសម័យអង្គរ ជាសហគមន៍មនុស្សរស់នៅ ព្រោះមានបំណែកកុលាភាជន៍បុរាណនៅរ៉ាយប៉ាយពេលបុរាណដ្ឋាននេះ ហើយនៅខាងត្បូងត្រពាំង ក៏មានប្រាសាទហៃផ្កាមួយដែរដែលធ្វើពីឥដ្ឋ ជាទីគោរពបូជានាមនុស្សសម័យនោះ៕

ចម្លាក់ប្រអប់ព្រះហស្តឆ្វេងព្រះពុទ្ធបដិមាដ៏ធំមួយបានប្រទះឃើញនៅខាងត្បូងនៃប្រាសាទបាយ័ន្ត

ផ្សាយនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

ចម្លាក់ប្រអប់ព្រះហស្តព្រះពុទ្ធរូបខាងឆ្វេងមួយធ្វើអំពីថ្មភក់បានប្រទះឃើញនៅក្នុងព្រៃខាងត្បូង ចម្ងាយប្រហែល ៣០០ម៉ែត្រពីប្រាសាទបាយ័ន្ត។ ចម្លាក់នេះមានទំហំបណ្តោយ០.៩៥ម៉ែត្រ ទទឹង០.៤២ម៉ែត្រ និងកម្រាស់ ០.២៤ម៉ែត្រ ក្នុងសភាពហាក់មិនទាន់ធ្លាក់រួចរាល់ត្រឹមត្រូវនៅឡើយទេដោយឃើញមានស្នាមមុខពន្លាក និងមិនទាន់ខាត់រលីងនៅឡើយ។

តាមការបញ្ជាក់របស់លោក ឈូក សុម៉ាឡា មន្ត្រីចុះបញ្ជីបេតិកភណ្ឌរូបីនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការថា ចម្លាក់ដែលមានត្រឹមកដៃនិងម្រាមទាំង៥ ដែលលាផ្ងារបាតដៃទៅលើនេះ គឺស្ថិតនៅក្នុងសម័យកណ្តាល ទំនងជាព្រហស្តព្រះពុទ្ធបដិមាក្នុងកាយវិការភូមិស្បស៌មុទ្រា ឬហៅថាកាយវិការមារវិជ័យ ឬផ្ចាញ់មារ។ ទម្រង់កាយវិការនោះ ព្រះពុទ្ធទ្រង់គង់ភ្នែនដោយយកព្រះហស្តខាងស្តាំដាក់ផ្កាប់លើភ្លៅសំយ៉ុងម្រាមដៃចង្អុលទៅធរណី។ រីឯព្រះហស្តឆ្វេងដាក់នៅលើចន្លោះភ្លៅ ហើយលាផ្ងារបាតព្រះហស្តទៅលើ។

ការសន្និដ្ឋានជាកាយវិការភូមិស្បស៌មុទ្រាបែបដូចនេះ គឺយោងទៅលើហេតុផល ដែលមានព្រះពុទ្ធបដិមាធំៗចំនួន ២អង្គដែលស្ថិតនៅជុំវិញប្រាសាទបាយ័ន្ត រួមមាន ព្រះអង្គឥន្ទ្រទេពនិងព្រះអង្គជោក គឺសុទ្ធសឹងតែសង់ឡើងក្នុងទំហំធំ និងពីថ្មភក់ច្រើនដុំ ហើយស្ថិតនៅក្នុងកាយវិការភូមិស្បស៌មុទ្រាដូចគ្នា។

រីឯនៅបរិវេណដែលរកឃើញចម្លាក់នោះ គឺទំនងជា សំណង់ខឿនព្រះពុទ្ធសាសនា ត្បិតយើងឃើញមានថ្មសីមាមួយចំនួនផងដែរ។ យ៉ាងណាមិញ តាមការស្រាវជ្រាវ និងរូបថតពីលើអាកាសដែលថតដោយបច្ចេកវិទ្យា LiDAR ក៏បានរកឃើញស្លាកស្នាមទីតាំងមនុស្សរស់នៅជាច្រើននៅក្នុងបរិវេណក្រុងអង្គរធំ ហើយសំណង់ទាំងនោះក៏រួមមាន ខឿនពុទ្ធសានាជាច្រើនកន្លែង ដែលសង់ពីថ្មភក់ និងថ្មបាយក្រៀមនៅបរិវេណនោះ។

បច្ចុប្បន្នចម្លាក់ប្រអប់ព្រះហស្តនេះ ក្រុមការងារចុះបញ្ជីបេតិកភណ្ឌរូបីនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានសហការណ៍ជាមួយស្ថាបន័មានសមត្ថកិច្ចនគរបាលការពារបេតិកភណ្ឌប្រចាំតំបន់អង្គរ ព្រមទាំងមន្ត្រីអភិរក្សប្រាសាទ បានធ្វើកំណត់ហេតុប្រគល់ទទួលនិងដឹកយកទៅរក្សាទុកនៅមជ្ឈមណ្ឌលអជ្ញាធរជាតិអប្សរា ដើម្បីចុះបញ្ជី និងរក្សាទុករង់ចាំការជួសជុលនៅថ្ងៃអនាគត៕

សកម្មភាពដាំកូនឈើរបស់ក្រុមភ្នាក់ងារព្រៃឈើរបស់អាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

ក្នុងគម្រោងស្តារឡើងវិញនូវគម្របព្រៃឈើក្នុងរមណីយដ្ឋានអង្គរ ក្រុមភ្នាក់ងារព្រៃឈើរបស់អាជ្ញាធរជាតិអប្សរា បានបន្តចុះដាំកូនឈើឡើងវិញនៅតំបន់ដែលរងការទន្ទ្រាន កាប់បំផ្លាញដោយខុសច្បាប់។ ជាក់ស្តែង ការដាំកូនឈើទាំងនោះរួមមាន៖

១. ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២០ កម្លាំងភ្នាក់ងារព្រៃឈើបានដាំកូនឈើចំនួន២ទីតាំងផ្សេងគ្នាសរុប៣៨០ ដើម ដែលមានទីតាំងស្ថិតនៅ ជាប់ប៉ុស្តិ៍នគរបាលការពារបេតិកភណ្ឌច្រកខាងកើតប្រាសាទអង្គរវត្តដាំចំនួន ១៧០ដើម និងទីតាំងជាប់ប៉ុស្តិ៍នគរបាលការពារបេតិកភណ្ឌជាប់ផ្លូវ ៦០ម៉ែត្រដាំចំនួន ២១០ដើម។

២. ថ្ងៃទី២០ ខែសីហា ឆ្នាំ២០២០ ភ្នាក់ងារព្រៃឈើបេងមាលាបានចុះដាំកូនឈើចំនួន១០០ដើមនៅប្រាសាទជ្រៃ។ ថ្ងៃទី២៨ ខែសីហា បន្តចុះដាំកូនឈើមួយចំនួនតាមតំបន់គោលដៅដូចជា ទីតាំងទី១ ប្រាសាទជ្រៃបានដាំចំនួន១០០ដើម។ទីតាំងទី២ប្រាសាទកន្សែងបានដាំចំនួន១១៥ដើម។ទីតាំងទី៣ប្រាសាទគង់ភ្លុកបានដាំចំនួន៨៥។ សរុបកូនឈើទាំងអស់មានចំនួន ៣០០ដើម៕

អគ្គនាយកអាជ្ញាធរជាតិអប្សរានិងសហការីចុះពិនិត្យតាមដានវឌ្ឍនភាពការងារនៅតាមការដ្ឋាននានាក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំអគ្គនាយករង ប្រធាននាយកដ្ឋាន មន្ត្រី-បុគ្គលិកជំនាញពាក់ព័ន្ធ ចុះពិនិត្យមើលទីតាំងការងារមួយចំនួននៅប្រាសាទអង្គរវត្តដើម្បីតាមដានពីការរីកចម្រើននៃការងារទាំងនោះ។

ប្រធានបទសំខាន់ៗដែលលើកយកមកបង្ហាញនៅព្រឹកនេះមាន វឌ្ឍនភាពការងារកំណាយនៅប្រាសាទបាយក្អែក ការរុះរើសំណង់និងការកែលម្អសួនច្បារដាំស្មៅដាំផ្កាចម្រុះពណ៌ ដាំកូនឈើនៅបរិវេណខាងលិចប្រាសាទអង្គរវត្ត ការរៀបចំសណ្ដាប់ធ្នាប់សាធារណៈនៅក្នុងតំបន់អង្គរ ការ

លើកតម្លៃផ្លូវបុរាណភ្នំបាខែង-រលួស ការរៀបចំកែលម្អត្រពាំងសេស ការរីកចម្រើននៃការជួសជុលស្ពានហាល និងការដ្ឋានមួយចំនួននៅក្នុងប្រាសាទអង្គរវត្តដែលកំពុងជួសជុលដោយអាជ្ញាធរជាតិអប្សរានិងអន្តរជាតិ។

ការចុះពិនិត្យផ្ទាល់នៅថ្ងៃនេះ គឺដើម្បីបង្ហាញពីការយកចិត្តទុកដាក់របស់អាជ្ញាធរជាតិអប្សរាក្នុងកិច្ចការអភិរក្សនិងអភិវឌ្ឍន៍នៅក្នុងតំបន់រមណីយដ្ឋានអង្គរប្រកបដោយចីរភាព។ ក្នុងនោះដែរ ក៏ជាយន្តការមួយជំរុញនិងបង្កើនប្រសិទ្ធភាពការងារឱ្យដំណើរការដោយរលូននិងសម្រេចបានផលល្អប្រសើរ។

អាជ្ញាធរជាតិអប្សរាស្វាគមន៍ការចូលរួមរបស់ធនាគារ CIMB ក្នុងការដាំកូនឈើក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបសំណេះសំណាលជាមួយលោកប៊ុនយីននាយកប្រតិបត្តិនៃធនាគារ

CIMBឯកឧត្តមឈិតបូរ៉ាវុធមេធាវីប្រចាំអាជ្ញាធរជាតិអប្សរា និងសហការី ដើម្បីពិភាក្សាពីការចូលរួមស្តារគម្របព្រៃឈើនៅរមណីយដ្ឋានអង្គរ។

លោក ប៊ុន យីន បានលើកឡើងថា ដោយបានឃើញពីសកម្មភាពយ៉ាងសកម្មរបស់អាជ្ញាធរជាតិអប្សរាក្នុងការលើកកម្ពស់គម្របព្រៃឈើដើម្បីបរិស្ថាន និងការអភិរក្សប្រាង្គប្រាសាទ ធនាគារ CIMB មានបំណងចូលរួមជាមួយអាជ្ញាធរជាតិអប្សរាក្នុងការដាំដើមឈើដើម្បីទុកជាម្លប់ ជាកេរតំណែលសម្រាប់មនុស្សជំនាន់ក្រោយ។

ជាកិច្ចឆ្លើយតប លោក ឡុង កុសល បានសម្តែងសេចក្តីរីករាយចំពោះធនាគារ CIMB ដែលបានចូលរួមនិងផ្តល់តម្លៃដល់កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរជាតិអប្សរា និងមានបំណងក្នុងការដាំដើមឈើ ក្នុងរមណីយដ្ឋានអង្គរដើម្បីបរិស្ថាននិងបេតិកភណ្ឌ។ អាជ្ញាធរជាតិអប្សរា សូមគាំទ្រទាំងស្រុងនូវការចូលរួមរបស់ធនាគារ CIMB ក៏ដូចជាស្ថាប័នឯកជនផ្សេងៗទៀតព្រោះអាជ្ញាធរជាតិអប្សរាតែងតែបានបង្ហាញនូវជំហរចង់ឲ្យមានការចូលរួមចំណែកជាសាធារណពីគ្រប់មជ្ឈដ្ឋានក្នុងស្មារតីចូលរួមគិត ចូលរួមធ្វើ និងចូលរួមទទួលខុសត្រូវ។ ចំណុចទាំងនេះនឹងបង្កើនឲ្យមានការយល់ដឹង ស្រឡាញ់ ពីគ្រប់មជ្ឈដ្ឋានដើម្បីចូលរួមការពារនិងអភិរក្សកេរមតកដូនតាដ៏មានតម្លៃពុំអាចកាត់ថ្លៃបានសម្រាប់កូនខ្មែរគ្រប់ៗរូប៕

ក្រុមហ៊ុន Minebea ចូលរួមដាំកូនឈើជាមួយអាជ្ញាធរជាតិអប្សរា ចំនួន៣OOដើម នៅខាងត្បូងប្រាសាទបន្ទាយក្តី

ផ្សាយនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២០

នៅដើមខែកញ្ញា ឆ្នាំ២០២០ ក្រុមហ៊ុន Minebea របស់ជប៉ុន បានចូលរួមដាំកូនឈើគ្រញូងចំនួន៣០០ដើម នៅបរិវេណខាងត្បូងប្រាសាទបន្ទាយក្តី ស្ថិតក្នុងភូមិស្រះស្រង់ខាងត្បូង សង្កាត់នគរធំ ក្រុង/ខេត្តសៀមរាប។ កម្មវិធីនេះក្រោមកិច្ចសហការ និងរៀបចំដោយអាជ្ញាធរជាតិអប្សរា ដែលមានអ្នកចូលរួមពីស្ថាប័នទាំង២។

គួរបញ្ជាក់ថា អាជ្ញាធរជាតិអប្សរា បានប្រកាសពីគម្រោងដាំនិងចែកចាយកូនឈើចំនួន១១ម៉ឺនដើមនៅឆ្នាំ២០២០នេះ ក្នុងនោះវិស័យឯកជនក៏អាចចូលរួមដាំកូនឈើទាំងនោះក្នុងរមណីយដ្ឋានអង្គរផងដែរ ក្នុងបំណងស្តារគម្របព្រៃឈើឡើងវិញក្នុងប្រទេសកម្ពុជា៕

កូនឈើជិត២ពាន់ដើមដែលទទួលបានពីអាជ្ញាធរជាតិអប្សរា បានយកទៅដាំដើម្បីអភិវឌ្ឍន៍មូលដ្ឋាន

ផ្សាយនៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២០

បន្ទាប់ពីទទួលបានកូនឈើដែលផ្តល់ដោយអាជ្ញាធរជាតិអប្សរានាពេលកន្លងមក ព្រះសង្ឃ រួមនិងសាធារណជនជិតឆ្ងាយ បានរៀបចំពិធីដាំនៅតាមទីតាំងផ្សេងៗ បំណងដើម្បីបរិស្ថាន បង្កើនគម្របព្រៃឈើឡើងវិញ និងជាពិសេសចូលរួមចំណែកអភិវឌ្ឍន៍ជាក់ស្តែងនៅមូលដ្ឋានរៀងៗខ្លួន ដែលសកម្មភាពដាំកូនឈើទាំងនោះមាននៅ៖

១. ព្រះសង្ឃ អាជ្ញាធរ និងអ្នកភូមិចំនួន១៥០នាក់ បានចូលរួមដាំកូនឈើចំនួន៨០០ដើម នៅបរិវេណវត្តឧទុម្ពរ ហៅវត្តល្វា ក្នុងភូមិល្វា ឃុំល្វា ស្រុកពួក ខេត្តសៀមរាប។

២. កូនឈើចំនួន១០០ដើម បានដាំនៅបរិវេណសាលាបឋមសិក្សាពោធិ៍ស្នើសង្គម ស្ថិតនៅភូមិកំពង់ ឃុំជីក្រែង ស្រុកជីក្រែង ខេត្តសៀមរាប។

៣. កូនឈើចំនួន២០០ដើម បានដាំនៅក្នុងបរិវេណវិទ្យាល័យ ហ៊ុន សែន ប្រាសាទបាគង។

៤. អ្នកចូលរួមសរុប ២១០នាក់ បានដាំកូនឈើចម្រុះសរុប ៥០០ដើម នៅបរិវេណវត្ត ជ័យមុនីវនារាម ហៅវត្តជយោ ស្ថិតនៅភូមិជយោ ឃុំជយោ ស្រុកចំការលើ ខេត្តកំពង់ចាម។

៥. ក្រុមយុវជនចំនួន៤០នាក់ បានចូលរួមដាំដើមឈើឥន្ទនេលចំនួន២៥០ដើម លម្អតាមដងផ្លូវនៅភូមិត្បែងលិច ឃុំត្បែង ស្រុកបន្ទាយស្រី ខេត្តសៀមរាប៕



អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០

នៅក្នុងសប្តាហ៍ទី១នៃខែកញ្ញា ឆ្នាំ២០២០នេះ ក្រុមការងារជំនាញនៃនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានចុះពិនិត្យលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់ទីតាំងស្នើសុំរបស់ប្រជាពលរដ្ឋ បានចំនួន១៨ករណី រួមមាន៖ ក្រុងសៀមរាប ៣ករណី ស្រុកបន្ទាយស្រី ២ករណី ស្រុកអង្គរធំ២ករណី ស្រុកប្រាសាទបាគង៧ករណី ស្រុកពួក៣ករណី ស្រុកសូទ្រនិគម១ករណី។

ដោយឡែកក្នុងរយៈពេលដូចគ្នានេះដែរ ប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្ម បានជួយរៀបចំគំនូសប្លង់បានចំនួន០៨ករណី រួមមាន៖ ស្រុកអង្គរធំ៤ករណី ក្រុងសៀមរាប២ករណី ស្រុកប្រាសាទបាគង១ករណី និងស្រុកបន្ទាយស្រី១ករណី។

អាជ្ញាធរជាតិអប្សរា តែងយកចិត្តទុកដាក់និងពិនិត្យ ព្រមទាំងពង្រឹងការងាររបស់ខ្លួនបន្ថែម តាំងពីដំណាក់កាលទទួលសំណើ រហូតដល់ដំណាក់កាលឆ្លើយតបទៅកាន់ពលរដ្ឋវិញ ពោលគឺធ្វើយ៉ាងណាឱ្យសេវាកម្មរបស់អាជ្ញាធរជាតិអប្សរាខិតកាន់តែជិតប្រជាពលរដ្ឋ៕

ទូតឥណ្ឌាចប់អាណត្តិជួបសម្តែងការគួរសមនិងជម្រាបលាថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២០នេះ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យ **លោកជំទាវ** Manika Jain ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំកម្ពុជាចប់អាណត្តិជួបសម្តែងការគួរសម និងជម្រាបលាថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា។ក្នុងជំនួបនៅពេលនោះលោកជំទាវឯកអគ្គរដ្ឋទូតបានរំឭកពីកិច្ចសហប្រតិបត្តិការដែលប្រទេសឥណ្ឌាបានជួយការងារជួសជុលនៅប្រាសាទអង្គរវត្ត និងកំពុងជួយផ្នែកអភិរក្សនិងជួសជុលនៅប្រាសាទតាព្រហ្ម។ បើទោះបីជាចប់អាណត្តិក្តី តែលោកជំទាវប្តេជ្ញាថា នឹងរក្សាទំនាក់ទំនង ក៏ដូចជារាល់កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរឱ្យកាន់តែល្អប្រសើរ។ បន្ថែមពីនេះ លោកជំទាវអគ្គរដ្ឋទូត ក៏បានលើកពីគម្រោងបណ្តុះបណ្តាលវគ្គខ្លីៗដល់យុវជនកម្ពុជា លើការងារអភិរក្សប្រាសាទ ក៏ដូចជាលើផ្នែកសិល្បៈ និងវប្បធម៌ផងដែរ ដ្បិតប្រទេសទាំងពីរមានទម្រង់សិល្បៈនិងវប្បធម៌ស្រដៀងគ្នា។

ថ្លែងក្នុងជំនួបនៅពេលនោះ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានថ្លែងអំណរគុណដល់ **លោកជំទាវ** Manika Jain ចំពោះកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជានិងឥណ្ឌានាពេលកន្លងមក។ក្នុងនោះឯកឧត្តមអគ្គនាយកមានសេចក្តីសោមនស្សរីករាយ និងទទួលយកនូវសំណើររបស់លោកជំទាវលើការរៀបចំគម្រោងបណ្តុះបណ្តាលធនធានយុវជនកម្ពុជាលើការងារអភិរក្សនិងជួសជុលប្រាសាទ ដ្បិតថាការងារនេះ នឹងផ្តល់ប្រយោជន៍ច្រើនដល់យុវជនយើង ពិសេសជំរុញវគ្គបណ្តុះបណ្តាលលើផ្នែកសិល្បៈនិងវប្បធម៌៕

ភ្នាក់ងារទេសចរណ៍ទទួលការបណ្តុះបណ្តាលពីការគ្រប់គ្រងហានិភ័យប្រាសាទ

ផ្សាយនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី៩ខែកញ្ញាឆ្នាំ២០២០ក្រុមភ្នាក់ងារទេសចរណ៍ប្រចាំប្រាសាទអង្គរវត្ត ទទួលការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហានិភ័យប្រាសាទ។ វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងដោយនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ ដោយមានកិច្ចសហការដោយនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃអាជ្ញាធរជាតិអប្សរា។

លោក លឹម ស្រ៊ូ អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ មានមតិក្នុងពិធីបើកវគ្គបណ្តុះបណ្តាលដែលធ្វើឡើងនៅថែវរូតព្រះពាន់ នៃប្រាសាទអង្គរវត្ត យ៉ាងដូច្នេះថា គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះ គឺដើម្បីពង្រឹងសមត្ថភាពបន្ថែមដល់ភ្នាក់ងារទេសចរណ៍ដែលប្រចាំការផ្ទាល់នៅក្នុងប្រាសាទ។ លោកបន្ថែមថា ការសិក្សានេះ គឺជាទុនបន្ថែមដើម្បីឱ្យភ្នាក់ងារទាំងអស់ បានដឹងពីស្ថានភាពជាក់ស្តែងរបស់ប្រាសាទ និងដើម្បីធ្វើសម្រង់ស្ថិតិពីចំណុចនីមួយៗដល់ថ្នាក់ដឹកនាំ ក៏ដូចជាដើម្បីរាយការណ៍បន្ទាន់ដល់អ្នកអភិរក្សនិងជួសជុលប្រាសាទ។

តាមការបញ្ជាក់របស់លោក លឹម ស្រ៊ូ វគ្គបណ្តុះបណ្តាលនេះ នឹងធ្វើនៅតាមប្រាសាទសំខាន់ៗមួយចំនួនក្នុងរមណីយដ្ឋានអង្គរ ដើម្បីឱ្យប្រាកដថា ភ្នាក់ងារទេសចរណ៍ទាំងអស់ ទទួលបានចំណេះដឹងជាមូលដ្ឋានតាមប្រាសាទនីមួយៗ ដើម្បីរួមចំណែកក្នុងកិច្ចការអភិរក្សប្រាង្គប្រាសាទឱ្យកាន់តែល្អសម្រាប់បច្ចុប្បន្ន និងទៅអនាគត។

លោក អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ បានឱ្យដឹងដែរថា ប្រាសាទចាត់ទុកដូចជាផ្ទះសម្រាប់ភ្នាក់ងារទេសចរណ៍គ្រប់រូប ដូច្នេះគឺត្រូវចេះសង្កេតគ្រប់ទីកន្លែង ដើម្បីដឹងពីស្ថានភាពទូទៅរបស់ប្រាសាទ។ ហើយការដឹងទាន់ពេលវេលានេះ អាចឱ្យអ្នកជំនាញមានលទ្ធភាពគ្រប់គ្រាន់ក្នុងការជួសជុលឬអភិរក្ស។ លោកបន្ថែមថា រាល់ប្រាសាទទាំងអស់ត្រូវការការថែទាំ ដូចជាការថែទាំថ្មជាដើម ដែលការថែទាំងនេះដើម្បីពន្យឺតការសិករិករិលរបស់ថ្ម។

លោកពន្យល់ទៀតថា ពលរដ្ឋគ្រប់រូបមានការភារកិច្ចការពារ ថែរក្សាមរតកដូនតា ហើយការងារទាំងនេះ ជាផ្នែកមួយនៃការចូលរួមអភិរក្សប្រាសាទយ៉ាងដូច្នោះដែរ៕

វិទ្យាស្ថានបារាំងចុងបូព៌ាប្រគល់ឯកសារស្រាវជ្រាវតាំងពីជំនាន់បារាំង ឱ្យអាជ្ញាធរជាតិអប្សរាថែរក្សាទុក

ផ្សាយនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ នេះ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតឱ្យលោកបណ្ឌិត ប្រ៊ីស វ៉ាំងសង់ សាស្ត្រាចារ្យរង និងជាប្រធានវិទ្យាស្ថានបារាំងចុងបូព៌ាប្រទេស ក្រុងសៀមរាប ចូលជួប និងបង្ហាញពីឯកសារស្រាវជ្រាវទាំងប៉ុន្មាន ចាប់ពីស្ថាប័ននេះចូលរួមកិច្ចការអភិរក្សក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីរក្សាទុកក្នុងមជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរ របស់អាជ្ញាធរជាតិអប្សរា។

លោកបណ្ឌិត ប្រ៊ីស វ៉ាំងសង់ បានជម្រាបឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរាថា លោកបានប្រមែប្រមូលឯកសារដែលពាក់ព័ន្ធក្នុងតំបន់រមណីយដ្ឋាន និងដែលមានប្រយោជន៍ ប្រគល់ជូនអាជ្ញាធរជាតិអប្សរា សម្រាប់ជាឯកសារជាតិ។ តាមការបញ្ជាក់របស់លោកបណ្ឌិត ប្រ៊ីស វ៉ាំងសង់ ដើម្បីឱ្យដំណើរការចងក្រងឯកសារទាំងនេះមានប្រសិទ្ធភាពល្អ វិជ្ជាស្ថានបារាំងចុងបូព៌ា គ្រោងរៀបចំវគ្គបណ្តុះបណ្តាលដល់អ្នកពាក់ព័ន្ធរួមមានមន្ត្រីរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក៏ដូចជាអាជ្ញាធរជាតិអប្សរាជាដើម។ល។

មានប្រសាសន៍ក្នុងជំនួបនៅពេលនោះ **ឯកឧត្តម ហង់ ពៅ** បានថ្លែងអំណរគុណដល់តំណាងវិទ្យាស្ថានបារាំងចុងបូព៌ា ដែលយល់ព្រមប្រគល់ឯកសារទាំងអស់មកឱ្យអាជ្ញាធរជាតិអប្សរា ស្របតាមអនុសាសន៍របស់គណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ នាពេលកន្លងមក។ បន្ថែមពីនោះ ឯកឧត្តមអគ្គនាយក ក៏ស្នើដល់ភាគីបារាំង ពិនិត្យលទ្ធភាពប្រគល់រាល់ឯកសារលម្អិតៗ បន្ថែមជុំវិញកិច្ចការស្រាវជ្រាវ និងអភិរក្សក្នុងតំបន់រមណីយដ្ឋានអង្គរ លើសពីសៀវភៅ និងឯកសារដែលបានសរសេរឬចងក្រងរួច។

ឯកឧត្តមអគ្គនាយកជឿជាក់ថា ស្ថាប័នទាំងពីរនឹងធ្វើការជាមួយគ្នាដោយរលូនលើកិច្ចការទាំងនេះ៕

អ្នកជំនាញធ្វើបទបង្ហាញពីដំណើរការជួសជុលស្ពានហាលខាងលិចអង្គរវត្ត

ផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០

បាឋកថាស្តីពី «វឌ្ឍនភាពនៃការជួសជុលស្ពានហាលខាងលិចអង្គរវត្ត» ត្រូវបានរៀបចំឡើងនៅព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០២០ ដើម្បីបង្ហាញដល់សាធារណជនដែលមានបំណងចង់ឈ្វេងយល់ពីដំណើរការលម្អិតពីគម្រោងជួសជុលនេះ។ អ្នកជំនាញបានរៀបរាប់អំពីប្រវត្តិនៃការជួសជុលស្ពានហាល ជាពិសេសរៀបរាប់ពីដំណើរការក្នុងការដ្ឋានដែលកំពុងជួសជុលបច្ចុប្បន្ន។

លោក អន សុភាព បុរាណវិទូ និងជាអ្នកគ្រប់គ្រងដឹកនាំគម្រោងជួសជុលស្ពានហាលខាងលិចអង្គរវត្ត បានចាប់ផ្តើមធ្វើបទបង្ហាញនិងរំលឹកនូវប្រវត្តិនានាទាក់ទងនឹងការជួសជុលស្ពានហាល ដែលក្នុងនោះការស្រាវជ្រាវរកឃើញថាផ្នែកខ្លះនៃស្ពានហាលនេះត្រូវបានជួសជុលដំបូងនៅអំឡុងសតវត្សទី១៦ បន្ទាប់មកនៅសម័យបារាំងគ្រប់គ្រងចន្លោះពីឆ្នាំ ១៩៥៣ ដល់ឆ្នាំ១៩៧២។

ក្រោយមកទៀត នៅឆ្នាំ១៩៩៦ ប្រទេសជប៉ុនតាមរយៈសាកលវិទ្យាល័យសូហ្វីយ៉ាបានចាប់ផ្តើមគម្រោងជួសជុលជាដំណាក់កាលដំបូងរបស់ខ្លួន ដោយសហការជាមួយអាជ្ញាធរអប្សរា និងបានបញ្ចប់នៅឆ្នាំ២០០៧ ដែលមានប្រវែង១០០ម៉ែត្រ។ គម្រោងជួសជុលក្នុងដំណាក់កាលទី២នេះ គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យសូហ្វីយ៉ា និងអាជ្ញាធរជាតិអប្សរា ចាប់ផ្តើមពីពាក់កណ្តាលឆ្នាំ២០១៦មក ដើម្បីបង្ហើយផ្នែកដែលនៅសល់ប្រវែង៩០ម៉ែត្រនិងកំពុងទឹក ហើយគ្រោងនឹងបញ្ចប់ឱ្យបានមុនឆ្នាំ២០២៤។

លោក អន សុភាព មន្ត្រីនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរា បានប្រាប់ពីមូលហេតុដែលការដ្ឋាននេះត្រូវបិទចរាចរណ៍មិនឱ្យទេសចរធ្វើដំណើរឆ្លងកាត់ ដ្បិតថា ក្នុងការដ្ឋានត្រូវប្រើគ្រឿងចក្រធុនធ្ងន់និងធំហើយការបិទនេះដើម្បីបញ្ចៀសហានិភ័យនានាដែលកើតជាយថាហេតុ។

លោកបន្ថែមថា គម្រោងជួសជុលនេះមានការត្រួតពិនិត្យនិងតាមដានយ៉ាងលម្អិតពីអ្នកជំនាញនៃគណៈកម្មាធិការអន្តរជាតិ អាយស៊ីស៊ី-អង្គរ ដោយបច្ចេកទេសភាគច្រើនគោរពទៅតាមទម្រង់ពីបុរាណ។
យ៉ាងណា អ្នកជំនាញរូបនេះប្រាប់ថា ចំណុចប្រឈមនៃគម្រោងជួសជុលនេះ គឺបញ្ហាទឹក ដែលពេលខ្លះបានធ្វើឱ្យអាក់ខាននៃដំណើរការជួសជុល។

លោក ម៉ៅ សុខនី ស្ថាបត្យករ ដែលធ្វើការក្នុងគម្រោងនេះដែរ ឱ្យដឹងថា ស្ពានហាលខាងលិចអង្គរវត្តមានប្រវែងសរុប ១៩៧.៤ម៉ែត្រឬប្រមាណ២០០ម៉ែត្រ ទទឹង ១១.៦៤ម៉ែត្រ និងមានកម្ពស់ ៣.៣៨៥ម៉ែត្រ។ ស្ពាននេះមានគ្រឹះធ្វើពីថ្មបាយក្រៀមស្រទាប់។ស្ថានភាពស្រុតចុះនៃកម្រាលថ្មភក់ជាចំណុចប្រឈមខ្លាំងដែលជំរុញឱ្យពន្លឿននៃគម្រោងជួសជុលនេះ។

សេចក្តីប្រកាសព័ត៌មាន

ផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា សូមបដិសេធទាំងស្រុងអំពីការផ្សព្វផ្សាយចោទប្រកាន់គ្មានមូលដ្ឋានរបស់គណនីហ្វេសប៊ុកឈ្មោះTNMTVOnlineនិងសូមឲ្យអ្នកគ្រប់គ្រងគណនីហ្វេសប៊ុកខាងលើធ្វើការសុំទោសជាសាធារណៈក្នុងរយៈពេលមួយសប្តាហ៍។ ប្រសិនបើ អ្នកគ្រប់គ្រងគណនីហ្វេសប៊ុក TNM TV Online ពុំធ្វើការសុំទោសជាសាធារណៈមកអាជ្ញាធរជាតិអប្សរានោះទេ អាជ្ញាធរជាតិអប្សរានឹងចាត់វិធានការច្បាប់ជាធរមាន។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ ០០៩/២០ ហ.អបរ

សេចក្តីប្រកាសព័ត៌មាន

អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនសាធារណៈជនមេត្តាជ្រាបថា កាលពីថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០ គណនីហ្វេសប៊ុកឈ្មោះ TNM TV Online បានធ្វើការផ្សព្វផ្សាយចោទប្រកាន់មកលើអាជ្ញាធរជាតិអប្សរា ចំនួន៣ចំណុច ដូចជា៖

១- បានហ៊ុំព័ទ្ធយកដី ចំនួន១៤០ហិកតា របស់ប្រជាពលរដ្ឋ៤៧គ្រួសារ ស្ថិតនៅភូមិសាលាក្រវ៉ាន់ ឃុំរំចេក ស្រុកបន្ទាយស្រី ខេត្តសៀមរាប

២- បានយកលុយចំនួន៣០០ដុល្លារទៅ៤០០ដុល្លារ ជាថ្នូរនឹងការអនុញ្ញាតឱ្យសាងសង់លំនៅដ្ឋាន

៣- និងប្រជាពលរដ្ឋរស់នៅក្នុងភូមិសាលាក្រវ៉ាន់ ឃុំរំចេក ស្រុកបន្ទាយស្រី ដែលមានចម្ងាយ៣០គម ពីប្រាសាទអង្គរវត្ត ដូច្នេះពុំគួរស្ថិតក្នុងតំបន់ការពារបេតិកភណ្ឌពិភពលោកអង្គរនោះទេ។

បន្ទាប់ពីបានឃើញការផ្សព្វផ្សាយ និងក្នុងន័យដើម្បីយល់ច្បាស់ពីបញ្ហាពិតនៃការចោទប្រកាន់នេះ អាជ្ញាធរជាតិអប្សរា រួមជាមួយរដ្ឋបាលស្រុកបន្ទាយស្រី និងមន្ត្រីនៃសាលាឃុំរំចេក បានចុះជួបជាមួយប្រជាពលរដ្ឋពាក់ព័ន្ធនៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង២:៣០នាទីរសៀល នៅសាលាឃុំរំចេក ស្រុកបន្ទាយស្រីដោយផ្ទាល់ ហើយទទួលបានព័ត៌មានដូចខាងក្រោម៖

១- ពុំមានករណីហ៊ុំព័ទ្ធយកដី ចំនួន១៤០ហិកតា របស់ប្រជាពលរដ្ឋចំនួន៤៧គ្រួសារដែលរស់នៅក្នុង ភូមិសាលាក្រវ៉ាន់ ឃុំរំចេក ស្រុកបន្ទាយស្រី ដូចការលើកឡើងរបស់គណនីហ្វេសប៊ុកឈ្មោះ TNM TV Online នោះទេ ព្រោះទីតាំងដី១៤០ហិកតា ដែលប្រជាពលរដ្ឋបានលើកឡើងនោះ ពុំស្ថិតក្នុងតំបន់ការពារបេតិកភណ្ឌពិភពលោកអង្គរទេ។

២- ករណីយកលុយ៣០០ដុល្លារទៅ៤០០ដុល្លារ ជាថ្នូរនឹងការសាងសង់ខុសច្បាប់ ប្រជាពលរដ្ឋបានអះអាងថា នេះគ្រាន់តែជាពាក្យនិយាយតាមគ្នាប៉ុណ្ណោះ គ្មានអ្វីបញ្ជាក់ទេ។ ផ្ទុយទៅវិញ ប្រជាពលរដ្ឋ បែរជានិយាយផ្សេងថា ពួកគាត់ដែលបានដាក់ពាក្យស្នើសុំសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់ ឬជួសជុលតូចតាចនោះ តែងតែទទួលបានការអនុញ្ញាតតាមការស្នើសុំដោយពុំមានការបង់ប្រាក់ជាថ្នូរអ្វីឡើយ។ ត្រង់ចំណុចនេះ លោក អ៊ឹម អ៊ីង មេឃុំរំចេកក៏បានអះអាងថា ខ្លួនលោកតែងតែចូលរួមយ៉ាងជិតស្និទ្ធជាមួយក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាធ្វើការចុះពិនិត្យការស្នើសុំជួសជុលតូចតាចរបស់ប្រជាពលរដ្ឋតាមខ្នងផ្ទះ ហើយក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរា ពុំដែលតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់ ជាថ្នូរនឹងការចុះមកពិនិត្យ ឬការអនុញ្ញាតនោះទេ។ ដោយឡែក អាជ្ញាធរជាតិអប្សរា សូមបញ្ជាក់ជូនថា ក្នុងករណីដែលថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកពាក់ព័ន្ធទាំងឡាយណា ត្រូវបានរកឃើញថាពាក់ព័ន្ធនឹងសកម្មភាពខុសច្បាប់បែបនេះ អាជ្ញាធរជាតិអប្សរា នឹងចាត់វិធានការទៅតាមផ្លូវច្បាប់ និងបញ្ឈប់ពីការងារ ដោយគ្មានការលើកលែងទេ។ ហើយអាជ្ញាធរជាតិអប្សរា ក៏តែងតែលើកទឹកចិត្តដល់បងប្អូនប្រជាពលរដ្ឋ ផ្តល់ព័ត៌មានមកអាជ្ញាធរជាតិអប្សរា ពាក់ព័ន្ធនឹងករណីនេះ ដើម្បីឱ្យអាជ្ញាធរជាតិអប្សរាអាចចាត់វិធានការនានាប្រឆាំងនឹងបុគ្គលខិលខូចទាំងអស់នោះ។

៣- ចំពោះករណីលើកឡើងអំពីព្រំសីមាតំបន់ការពារបេតិកភណ្ឌពិភពលោកអង្គរ គឺជាការលើកឡើងដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់ និងមិនបានស្វែងយល់ពីកិច្ចការពារបេតិកភណ្ឌ។ ការកំណត់ព្រំសីមាតំបន់ការពាររមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរត្រូវបានកំណត់ដោយលិខិតបទដ្ឋានគតិយុត្ត ដូចមានចែងនៅក្នុងព្រះរាជក្រឹត្យលេខ ០០១នស ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៤ ស្តីពីការកំណត់ និងការចាត់ចែងគ្រប់គ្រងតំបន់សៀមរាប-អង្គរ។ម្យ៉ាងទៀត ការកំណត់ព្រំសីមាតំបន់ការពាររមណីយដ្ឋានបេតិកភណ្ឌអង្គរគឺជា លក្ខខណ្ឌចាំបាច់បំផុតមួយក្នុងចំណោមលក្ខខណ្ឌចាំបាច់ទាំង៥ របស់គណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៃអង្គការយូណេស្កូដើម្បីចុះរមណីយដ្ឋានអង្គរក្នុងបញ្ជីបេតិកភណ្ឌពិភពលោកនាចុងឆ្នាំ១៩៩២។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរាសូមធ្វើការបដិសេធទាំងស្រុងនូវរាល់ការចោទប្រកាន់ដោយគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់របស់គណនីហ្វេសប៊ុកឈ្មោះ TNM TV Online និងសូមឱ្យគណនីហ្វេសប៊ុកឈ្មោះ TNM TV Online ធ្វើការសុំទោសជាសាធារណៈមកអាជ្ញាធរជាតិអប្សរា យ៉ាងយូរយៈពេលមួយសប្តាហ៍បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្តីប្រកាសព័ត៌មាននេះ។ ក្នុងករណីគណនីហ្វេសប៊ុកខាងលើមិនបានធ្វើការសុំទោសជាសាធារណៈតាមកាលកំណត់ទេ អាជ្ញាធរជាតិអប្សរានឹងចាត់វិធានការតាមផ្លូវច្បាប់ជាធរមានប្រឆាំងនឹងបុគ្គលដែលគ្រប់គ្រងគណនីហ្វេសប៊ុកខាងលើ។

ទន្ទឹមនឹងនេះ អាជ្ញាធរជាតិអប្សរា សូមអំពាវនាវដល់ប្រជាពលរដ្ឋទាំងអស់មេត្តាផ្តល់ព័ត៌មាន ឬសាកសួរដើម្បីបំភ្លឺនូវរាល់ចម្ងល់នានា មកមន្ត្រីមានសមត្ថកិច្ចនៃអាជ្ញាធរជាតិអប្សរា តាមរយៈទូរស័ព្ទលេខ 092 899 966 និងហ្វេសប៊ុកផ្លូវការរបស់អាជ្ញាធរជាតិអប្សរា ដើម្បីសហការគ្នាលុបបំបាត់នូវសកម្មភាពអវិជ្ជមាន និងជៀសវាងការខូចខាតប្រយោជន៍នានាជាយថាហេតុ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណៈជនទាំងអស់មេត្តាជ្រាប និងចូលរួមសហការតាមការគួរ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
សៀមរាប ថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ២០២០

Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

សំណង់ព្រះវិហារបុរាណនៅវត្តរាជបូណ៌ប្តូរសោភ័ណភាពថ្មីដ៏ស្រស់ស្អាតបន្ទាប់ពីជួសជុលហើយ

ផ្សាយនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០

គម្រោងជួសជុលនិងអភិរក្សព្រះវិហារបុរាណវត្តរាជបូណ៌ ដែលទទួលបានថវិកាទាំងស្រុងពីអាជ្ញាធរជាតិអាប្សរ បានបញ្ចប់ដោយជោគជ័យ កាលពីថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០២០ ក្រោមកិច្ចខិតខំប្រឹងប្រែង ដឹកនាំ និងត្រួតពិនិត្យលក្ខណៈបច្ចេកទេស ពីសំណាក់មន្ត្រីជំនាញរបស់អាជ្ញាធរជាតិអប្សរា។

ការជួសជុលនេះគឺដើម្បីរួមចំណែកថែរក្សាមត៌កវប្បធម៌ខ្មែរលើវិស័យព្រះពុទ្ធសាសនា ព្រមទាំងជួយអភិរក្ស និងលើកតម្លៃវប្បធម៌នៃសិល្បៈរបស់ខ្មែរពីបុរាណកាលឱ្យរស់រវើកឡើងវិញ។ ក្រុមការងារបច្ចេកទេស បានផ្តោតលើការជួសជុលក្បាច់ជញ្ជាំង ជើងជញ្ជាំង បាំងសាច កាំជណ្តើរ ការ៉ូក្បាច់លើទ្វារ-បង្អួច និងខឿនព្រះវិហារ និងបញ្ហាប្រឈមមួយចំនួនទៀតឱ្យផុតពីហានីភ័យ រហូតធ្វើឱ្យព្រះវិហារយ៉ចំណាស់នេះលេចរូបរាងដ៏ស្រស់ត្រកាលជាថ្មីម្តងទៀតលើទឹកដីអង្គរ ក្នុងក្រុងសៀមរាប។

អាជ្ញាធរជាតិអប្សរា សូមថ្លែងអំណរព្រះគុណនិងអរគុណយ៉ាងជ្រាលជ្រៅ ចំពោះព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិនសែម ព្រះរាជាគណៈថ្នាក់ទោ សមាជិកថេរសភាសង្ឃ ជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយក និងជាព្រះគ្រូចៅអធិការវត្តរាជបូណ៌ ព្រមទាំងព្រះសង្ឃ ពុទ្ធបរិស័ទ ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិក អាជ្ញាធរជាតិអប្សរាទាំងអស់ ដែលបាននិមន្ត និងចូលរួមសហការយ៉ាងជិតស្និទ្ធក្នុងការថែរក្សាសម្បត្តិវប្បធម៌ជាតិឱ្យបានគង់វង្សតរៀងទៅ៕

ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាចូលរួមពិភាក្សាជាមួយសមាគមសណ្ឋាគារ អំពីវិស័យទេសចរណ៍នៅខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០២០នេះ សមាគមសណ្ឋាគារកម្ពុជាប្រចាំខេត្តសៀមរាបបានរៀបចំកិច្ចប្រជុំពិភាក្សាអំពីលទ្ធភាពស្តារវិស័យទេសចរណ៍ក្នុងខេត្តសៀមរាប ស្របពេលដែលវិស័យនេះកំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារការរីករាលដាលនៃជំងឺកូវីដ១៩។

ឯកឧត្តម សុខ សខ្វារ អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍ក្នុងតំបន់អង្គរ ក៏ត្រូវបានអញ្ជើញឱ្យចូលរួមផងដែរ ដើម្បីចូលរួមផ្តល់យោបល់និងតាមដានស្ថានភាពទេសចរណ៍ក្នុងខេត្តសៀមរាប។

អង្គប្រជុំនេះបានពិភាក្សាគ្នាលើចំណុចសំខាន់ៗមួយចំនួនដូចជា ការតាមដានអំពីវិធានការរបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងវិស័យទេសចរណ៍ក្នុងស្ថានភាពកូវីដ១៩ ការផ្សព្វផ្សាយអំពីតំបន់ទេសចរណ៍នៅខេត្តសៀមរាប ការរៀបចំផែនការ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ក្នុងខេត្តសៀមរាប និងការបង្ហាញអំពីបច្ចុប្បន្នភាពនៃការរៀបចំវិស័យទេសចរណ៍របស់អាជ្ញាធរជាតិអប្សរា។

មានប្រសាសន៍ក្នុងកិច្ចពិភាក្សានេះ **ឯកឧត្តម សុខ សខ្វារ** បានជម្រាបជូនអង្គប្រជុំអំពីការត្រៀមខ្លួនរបស់អាជ្ញាធរជាតិអប្សរានាពេលបច្ចុប្បន្នដូចជា ការជួសជុលហេដ្ឋារចនាសម្ព័ន្ធ ការដាំដើមឈើ រៀបចំសួនដើម្បីឱ្យទេសភាពក្នុងរមណីយដ្ឋានអង្គរមានភាពស្រស់បំព្រង និងជាពិសេស គឺការបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីបុគ្គលិក ដើម្បីពង្រឹងដល់ការគ្រប់គ្រងវិស័យទេសចរណ៍៕

អាជ្ញាធរជាតិអប្សរាស្វាគមន៍គ្រប់ស្ថាប័នដើម្បីចូលរួមដាំកូនឈើក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២០ នេះ អាជ្ញាធរជាតិអប្សរា ក្រោមកិច្ចសហការជាមួយរដ្ឋបាលខេត្តសៀមរាប និងធនាគារ CIMB បានរៀបចំពិធីដាំកូនឈើចំនួន ១,៥០០ដើម នៅបរិវេណប្រាសាទបន្ទាយក្តី ក្រោមប្រធានបទ«យើងដាំ យើងចំណាំ យើងថែរក្សា ប្រាង្គប្រាសាទដែលជាបេតិកភណ្ឌមនុស្សជាតិ»។ ក្នុងពិធីនៅពេលនោះ លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា ក្នុងនាម **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានសម្តែងអារម្មណ៍រីករាយ និងរំពឹងថា ស្ថាប័នសាធារណៈ ពាក់ព័ន្ធនិងស្ថាប័នឯកជនដទៃទៀត នឹងបន្តចូលរួមកាន់តែច្រើនក្នុងការដាំកូនឈើក្នុងរមណីយដ្ឋានអង្គរ ព្រោះថាកិច្ចការថែទាំបេតិកភណ្ឌមិនមែនជាភារកិច្ចអាជ្ញាធរជាតិអប្សរាតែម្នាក់ឯងនោះទេ ប៉ុន្តែជាភារកិច្ចសម្រាប់កូនខ្មែរគ្រប់រូប។ មានវត្តមានក្នុងពិធីនោះ រួមមាន **ឯកឧត្តម ពិន ប្រាកដ** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប លោក ប៊ុន យីម នាយកប្រតិបត្តិនៃធនាគារ CIMB **ឯកឧត្តម ឈិត ប៊ូរ៉ាឡុង** ប្រធានក្រុមមេធាវីអាជ្ញាធរជាតិអប្សរា ព្រមទាំងព្រះសង្ឃ បុគ្គលិកធនាគារ CIMB និងមន្ត្រីបុគ្គលិកអាជ្ញាធរជាតិអប្សរាសរុបទាំងអស់ប្រមាណជាង ៦០០ អង្គ/នាក់។

លោក ឡុង កុសល បានបន្តលើកទឹកចិត្តដល់សាធារណជន ស្ថាប័នរដ្ឋ និងឯកជននានា ដែលមានបំណងរៀបចំពិធីដាំកូនឈើក្នុងតំបន់រមណីយដ្ឋានអង្គរ ដើម្បីរួមចំណែកលើកិច្ចការអភិរក្សប្រាង្គប្រាសាទក្នុងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរ ព្រោះព្រៃឈើបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងកិច្ចការការពារ និងអភិរក្សបាង្គប្រាសាទ។

បន្ថែមពីនេះ លោក ឡុង កុសល ក៏បានជម្រាបជូនអំពីគម្រោង«ដើមឈើខ្ញុំនៅអង្គរ»ដែលគ្រោងនឹងរៀបចំឡើងដោយអាជ្ញាធរជាតិអប្សរាក្នុងស្មារតីលើកទឹកចិត្តសាធារណជនគ្រប់រូប មានចំណែកអភិរក្សប្រាសាទបុរាណខ្មែរតាមរយៈការដាំកូនឈើក្រោមរូបភាព ចូលរួមធ្វើ ចូលរួមគិត និងចូលរួមថែរក្សា។

គួរបញ្ជាក់ថា កូនឈើដែលដាំក្នុងពិធីខាងលើសរុបចំនួន ១,៥០០ ដើម ដែលរួមមាន គ្រញូង ៣០០ដើម ធ្នង់ ២០៥ ដើម បេង ១០០ដើម នាងនួន ២០ដើម ស្រឡៅ ១៥០ ដើម ឈើទាល ៣០០ដើម កកោះ ៥០ដើម ពពាល ៥០ដើម និងសុគ្រំ ៥០ដើម៕

ក្នុងពាក់កណ្ដាលខែកញ្ញានេះ អាជ្ញាធរជាតិអប្សរាបានចែកកូនឈើជាង ១៥,០០០ដើម បន្ថែមទៀតដល់សាធារណជន

ផ្សាយនៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០

ក្នុងគោលបំណងស្តារគម្របព្រៃឈើក្នុងតំបន់រមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរឲ្យកាន់តែមានចំនួនច្រើនឡើង ក៏ដូចជាក្នុងន័យបំផុសស្មារតីឲ្យមានការចូលរួមរបស់ប្រជាពលរដ្ឋអំពីកិច្ចការបរិស្ថានជាបន្តបន្ទាប់អាជ្ញាធរជាតិអប្សរាបានបន្តចែកជូនកូនឈើដល់សាធារណជនជិតឆ្ងាយ ដើម្បីយកទៅដាំនៅតាមតំបន់នានាក្នុងប្រទេសកម្ពុជា។

ក្នុងពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២០ គឺចាប់ពីថ្ងៃទី១ ដល់ថ្ងៃទី១២ ខែកញ្ញា អាជ្ញាធរជាតិអប្សរាបានបន្តចែកជូនកូនឈើចម្រុះសរុបចំនួន ១៥,០៣០ ដើម ដល់សាធារជនជិតឆ្ងាយ ដែលក្នុងនោះរួមមាន៖

១. ផ្តល់ជូនកូនឈើជូនតំណាងសាលាបឋមសិក្សាវត្តស្វាយ ចំនួន៥០ដើម ដើម្បីយកទៅដាំនៅបរិវេណសាលា។
២.ផ្តល់ជូនកូនឈើដល់លោកស្រី ជាវ គឹមស៊ាន ចំនួន ១០០ដើម យកទៅដាំនៅបរិវេណវត្តសំបូរ ស្ថិតក្នុងឃុំសំបូរ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។
៣.ផ្តល់កូនឈើជូនតំណាងកងធំអន្តរាគមន៍លេខ២ នៃកងទ័ពជើងគោក ចំនួន ៣,០០០ដើម។
៤. ផ្តល់ជូនកូនឈើដល់លោក ជា វណ្ណៈ ចំនួន ៣០០ដើម។
៥. ប្រគេនកូនឈើជូនព្រះសង្ឃតំណាងសាលាបឋមសិក្សាឈើទាល ចំនួន ៥០០ ដើម។
៦.ផ្តល់កូនឈើជូនតំណាងក្រុមការងារគម្រោងអភិវឌ្ឍន៍ភូមិធម្មជាតិរុនតាឯក ចំនួន ២,៧០០ដើម។
៧.ផ្តល់កូនឈើជូនតំណាងក្រុមហ៊ុនភូមិមង្គល ចំនួន ៣,០០០ ដើម។
៨.ប្រគេនកូនឈើជូនព្រះសង្ឃតំណាងវត្តបឋិតសត្ថារាមរង្សី ហៅវត្តព្រះដាក់ ចំនួន ១០០ ដើម។
៩.ផ្តល់កូនឈើរំដួលចំនួន ២២០ដើម ដើម្បីយកទៅដាំក្នុងបរិវេណទីលានបដិសណ្ឋារកិច្ចប្រាសាទអង្គរវត្ត។
១០. ប្រគេន និងផ្តល់ជូនកូនឈើ ៣៣៥ ដើមដល់តំណាងវត្តព្រះឥន្ទកោសា និងតំណាងរដ្ឋបាលឃុំក្តីរុន។
១១.ផ្តល់កូនឈើជូនអង្គការ ICF Cambodia Campus ចំនួន ៤០០ដើម។
១២.ផ្តល់កូនឈើជូនលោក ជឹម តៃលី នាយកវិទ្យាល័យនគរធំ ចំនួន ២០០ ដើម។
១៣.ផ្តល់កូនឈើជូនលោករុន ស៊ីណា សមាជិកក្រុមប្រឹក្សាឃុំរុនតាឯក ចំនួន ២០០ ដើម។
១៤.ផ្តល់កូនឈើជូនតំណាងរដ្ឋបាលស្រុកពួក ចំនួន ១,៥០០ ដើម។
១៥.ផ្តល់កូនឈើជូនលោក អៀម ស្មើ ចំនួន ១០០ ដើម។
១៦.ផ្តល់កូនឈើជូនលោក ពុត សុខមាន ចំនួន ២៥០ ដើម។
១៧.ផ្តល់កូនឈើជូនលោក ឌី សំណាង នាយកសាលាបឋមសិក្សាក្រវ៉ាន់ ចំនួន ៥៥ ដើម។
១៨. ផ្តល់កូនឈើជូនលោក លឹម ណាម ចំនួន ៣២០ ដើម។
១៩.ផ្តល់កូនឈើជូនលោក ប៉ាន់ ប៉ូច តំណាងរដ្ឋបាលឃុំសំរោងយា ចំនួន ៣០០ ដើម។
២០.ផ្តល់កូនឈើជូនលោក ម៉ុយ សុខធៀម ចំនួន ២៥០ ដើម។
២១.ផ្តល់កូនឈើជូនលោក មុំ សុពណ៌ ចំនួន ៥០ ដើម។
២២.ប្រគេនកូនឈើជូនព្រះសង្ឃតំណាងវត្តជ័យមុនីវនារាម ហៅវត្តជយោ និងវត្តពោធិវនារាម ហៅវត្តស្ពឺចំនួន ១,០០០ ដើម៕

ការប្រកាន់ទម្លាប់នៃការចូលប្រាសាទដូចពីបុរាណកាល គឺរក្សាបាននូវតម្លៃអភិរក្សប្រាង្គប្រាសាទ

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

ដូនតាខ្មែរបានកសាងប្រាសាទខ្លះមានខ្លោងទ្វារចេញចូល ៤ទិស ខ្លះ២ទិស និងខ្លះ១ទិស ដែលឱ្យមនុស្សចេញចូលតាមទិសខាងកើតឬខាងលិចដែលកំណត់ថាជាខ្លោងទ្វារធំ ដោយយោងទៅលើប្រាង្គសំខាន់បែរមុខទៅទិសណា។

ដូចករណីនៅបាយ័ន្តនិងកំពែងក្រុងអង្គរធំ គឺមានខ្លោងទ្វារច្រើន ដែលខ្លះចូលចំប្រាសាទធំពីខាងកើត តែមនុស្សពុំសូវចេញចូល គេហៅថាខ្លោងទ្វារខ្មោចឬខ្លោងទ្វារខ្មាក់ ហើយច្រកដែលមនុស្សចេញចូលជាប្រចាំ គេហៅខ្លោងទ្វារជ័យ។ រីឯប្រាង្គប្រាសាទខ្លះមានទ្វារទាំង៤មែន តែបិទជិតឈឹង ឬចំហ ហៅថាទ្វារបញ្ឆោត ក៏មិនអនុញ្ញាតឱ្យចេញចូលដែរ ដោយសារមានកសិន្ធុជុំវិញ។ការកសាងខ្លោងទ្វារនិងកំពែងច្រើនដូច្នេះ គឺជាការរៀបចំតាមក្បួនកិច្ចពិធីផង សាសនាផង និងឋានានុក្រមសង្គមផងដែលចាស់បុរាណប្រកាន់ខ្ជាប់បំផុត។

ប៉ុន្តែសព្វថ្ងៃ ទម្លាប់នៃការចេញចូលច្រកទ្វារខ្លះ ហាក់ប្រាសចាកពីបុរាណកាល ហើយក៏មានភាពសេរី ដោយមិនបានបែងចែកថាខ្លោងទ្វារនេះសម្រាប់ព្រះមហាក្សត្រ ខ្លោងទ្វារនោះសម្រាប់រាស្ត្រសាមញ្ញចេញចូលឡើយ។ ជាក់ស្តែងនៅប្រាសាទអង្គរវត្ត មនុស្សមួយចំនួននិយមចេញចូលតាមច្រកខាងកើត ជំនួសឱ្យច្រកចេញចូលខាងលិចវិញ ដើម្បីទៅធ្វើបុណ្យនិងទៅទស្សនាប្រាសាទ ដែលពេលខ្លះបង្កភាពកកស្ទះនិងការប៉ះពាល់ដល់ប្រាង្គប្រាសាទផង។

តាមការបញ្ជាក់របស់លោកសាស្ត្រាចារ្យ អ៊ឹម សុខរិទ្ធី ប្រធាននាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ ឱ្យដឹងថា ច្រកចេញចូលសំខាន់នៃប្រាសាទអង្គរវត្តគឺមានតែមួយគត់ គឺនៅខាងលិច ឯច្រកខាងកើតគ្រាន់តែធ្វើបណ្ដោះអាសន្នសម្រាប់កិច្ចការអភិរក្សដើម្បីយកគ្រឿងចក្រទៅជួសជុលប្រាសាទខាងក្នុង ជាពិសេសថែវខាងត្បូងដែលបែកបាក់កាលសម័យបារាំង និងសម័យក្រោយៗមកទៀត ព្រមទាំងការចេញចូលរបស់ព្រះសង្ឃដែលគង់នៅវត្តអង្គរខាងជើងនិងខាងត្បូងប៉ុណ្ណោះ។ បើនៅខាងកើតអង្គរវត្តមានច្រកចូលសំខាន់មែននោះ គឺច្បាស់ជាមានស្ពានហាលផ្លូវចូលក្រាលថ្មមានរបងល្អដូចខាងលិចពុំខានមិនមែនមានត្រឹមទំនប់ទឹកនោះទេ។ ជាក់ស្ដែងកាលពីដើមឡើយ ទាំងអ្នកអភិរក្ស ទាំងប្រជាជន ទាំងភ្ញៀវមកទស្សនាគឺចេញចូលតែខ្លោងទ្វារខាងលិចប៉ុណ្ណោះ។

សង្កត់ធ្ងន់លើការផ្លាស់ប្តូរទម្លាប់ចេញចូលប្រាសាទអង្គរវត្តនាបច្ចុប្បន្ន ដើម្បីទៅធ្វើបុណ្យឬទៅទស្សនាដោយចូលពីច្រកខាងកើតវិញ លោក សុខរិទ្ធី ថាមកពីការប្រញាប់ប្រញាល់ពុំមានការគោរពសណ្ដាប់ធ្នាប់ល្អភាពទំយើររបស់មនុស្ស ចង់បានស្រួល ចង់បានលឿន ទៅធ្វើបុណ្យដើម្បីបង្គ្រប់តែកិច្ច ពុំទាន់មានទម្លាប់ល្អក្នុងការចូលប្រាសាទជាទីសក្ការៈ។ បើប្រៀបធៀបនឹងបណ្ដាប្រទេសជិតខាងដែលគេគោរពសាសនាព្រះពុទ្ធដូចយើងដែរ ឃើញថាគេមានទម្លាប់ល្អមានការគោរពទីសក្ការៈមានសណ្ដាប់ធ្នាប់ពេលគេចេញចូលទស្សនាប្រាសាទទៅគោរពបូជានិងធ្វើបុណ្យ។ អាជ្ញាធរជាតិអប្សរាក៏កំពុងរៀបចំសណ្ដាប់ធ្នាប់ បង្កើតជាទីលានចំណតនៅខាងលិច កន្លែងលក់ដូរ។ល។និង។ល។ ដោយសង្ឃឹមថាសណ្ដាប់ធ្នាប់ល្អនឹងត្រូវបានចូលរួមអនុវត្តជាបណ្ដើរៗ។

លោក សុខរិទ្ធី បានលើកឡើងថា អង្គរវត្ត គឺជាអត្តសញ្ញាណជាតិ ប្រជិស្ទនៅលើទង់ជាតិខ្មែរ ហើយដែលគ្មាននរណាអាចបង្អាប់ជាន់ឈ្លីបាន។ នេះហើយជាមូលហេតុដែលខ្មែរយើងគួរនាំគ្នាចូលរួមគោរពនិងលើកតម្កើង។ វាជាការល្អណាស់ បើមនុស្សទូទៅដើរទៅទស្សនាប្រាសាទឬទៅធ្វើបុណ្យដោយឆ្លងច្រកខាងលិច កាត់តាមកសិន្ធុ ស្លៀកហូលផាមួង អាវស អាវប៉ាក់ កាន់ចានស្រាក់ វែកអង្រែកម្ទូបអាហារ មានផ្លែឈើ នំអន្សមទៅធ្វើបុណ្យនោះ វាសមនឹងភាពផូរផង់នៃវប្បធម៌ខ្មែរ តពីបុរាណដែលមានតម្លៃដ៏ខ្ពង់ខ្ពស់។

វាដូចគ្នានឹងប្រទេសជិតខាងមានឡាវ ភូមា ថៃជាដើមដែលពុទ្ធបរិស័ទជ្រះថ្លានឹងសាសនា គោរពប្រណិប័តន៍ប្រពៃណី វត្តអារាម និងបុរាណដ្ឋានដែរ។ បើអាចមានដូច្នេះមែន រូបភាពមនុស្សចេញចូលអង្គរកាលពីសម័យមុនៗ ដែលយើងតែងចែករំលែកគ្នាតាមបណ្ដាញសង្គមនោះនឹងមានពិតមែន ហើយបន្តរស់រវើកដល់ឥឡូវ និងមិនមែនជារូបភាពគ្រាន់ជាអនុស្សាវរីយ៍ទៀតឡើយ។ នោះយើងអាចការពាររក្សាបាននូវទេសភាពវប្បធម៌ ជួយដល់បរិស្ថាន បន្ថយផ្សែងពុល លើកតម្លៃ និងការអភិរក្សប្រាង្គប្រាសាទផង តាមរយៈបន្ថយទម្ងន់សង្កត់បន្ថយលំញ័រភាពកកស្ទះនៃចរាចរណ៍នាំប៉ះពាល់រចនាសម្ពន្ធប្រាសាទ។ យើងក៏បានជួយរក្សាតម្លៃរតនវត្ថុដែលដូនតាខ្មែរបន្សល់ទុកឱ្យនិងបន្តទៅមនុស្សជំនាន់ក្រោយៗទៀត៕

អាជ្ញាធរជាតិអប្សរាបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ជាមួយរមណីយដ្ឋានហ័ងសាន

ផ្សាយនៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២០

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២០ **ឯកឧត្តម សុខ សង្វារ** អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរនៃអាជ្ញាធរជាតិអប្សរា និងលោក HONG Jianchun អនុប្រធានគណៈកម្មាធិការរដ្ឋបាលហ័ងសាន បានបន្តពង្រឹងកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍នៅតំបន់បេតិកភណ្ឌអង្គរនិងហ័ងសាន។



នៅក្នុងជំនួបតាមប្រព័ន្ធវីដេអូ ភាគីទាំងពីរបានសម្ដែងការសោកស្ដាយ ព្រោះជំងឺកូវីដ១៩មិនអាចចុះអនុស្សារណៈដោយផ្ទាល់ ពុំបានរៀបចំការតាំងពិព័រណ៍រូបថតទេសភាព និងទស្សនកិច្ចជាក្រុមដូចឆ្នាំ២០១៥។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរជាតិអប្សរានិងភាគីចិន ប្ដេជ្ញាបន្តពង្រឹងទំនាក់ទំនងនិងជឿជាក់ថា ការរីករាលដាលនៃជំងឺសាកលនឹងគ្រប់គ្រងបានល្អដោយការខិតខំរួមគ្នា ហើយឆ្លងផុតវិបត្តិក្នុងវិស័យទេសចរណ៍យើងនឹងវិលមករកភាពធម្មតាវិញ ដើម្បីផ្សព្វផ្សាយពីតំបន់ទេសចរណ៍អង្គរ-ហ័ងសាន រួមគ្នាយ៉ាងជិតស្និទ្ធម្ដងទៀត៕

ក្រុមការងារនៃនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការចូលរួមដាំកូនឈើ នៅតំបន់ប្រាសាទព្រះខ័ន

ផ្សាយនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២០ នេះ ក្រុមការងារនៃនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ នៃអាជ្ញាធរជាតិអប្សរា បានសហការចូលរួមដាំកូនឈើជាមួយកម្លាំងនគរបាលការពារបេតិកភណ្ឌ ដោយបានដាំកូនឈើសរុបចំនួន ១០០ដើម នៅតាមដងផ្លូវស្ថិតនៅភូមិក្លូង សង្កាត់អង្គរធំ ក្រុងសៀមរាប។ កូនឈើទាំងនោះត្រូវបានដាំឡើងវិញដើម្បីបំពេញចន្លោះព្រៃឈើនៅតាមដងផ្លូវ និងចូលរួមចំណែកក្នុងកិច្ចការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាពរមណីយដ្ឋានអង្គរ៕

ក្រុមការងារសណ្តាប់ធ្នាប់សាធារណៈនៃអាជ្ញាធរជាតិអប្សរាចុះណែនាំអ្នកលក់ដូរតាមប្រាសាទ

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០

ភ្នាក់ងារសណ្តាប់ធ្នាប់សាធារណៈនៃនាយកដ្ឋានសណ្តាប់ធ្នាប់និងកិច្ចសហប្រតិបត្តិការអាជ្ញាធរជាធរជាតិអប្សរា នាព្រឹកថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០នេះ បានចុះណែនាំ

អាជីវករលក់ដូរតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ ឱ្យលក់ដូរមានរបៀបរៀបរយ ត្រឹមត្រូវតាមទីតាំងដែលបានកំណត់ និងចូលរួមសម្អាតបរិស្ថានឱ្យបានស្អាតជុំវិញកន្លែងលក់ដូររបស់ខ្លួន៕

ក្រុមការងារគ្រប់គ្រងទឹករបស់អាជ្ញាធរជាតិអប្សរាប្រមូលទឹកស្តុកទុកមិនឱ្យជន់លិចរមណីយដ្ឋានអង្គរនាអំឡុងពេលមានភ្លៀងធ្លាក់ខ្លាំងក្រោមឥទ្ធិពលរបស់ព្យុះនូល

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០

ប្រទេសកម្ពុជា បានរងនូវឥទ្ធិពលពីព្យុះនូលចាប់ពីថ្ងៃទី១៨ រហូតដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០ ដែលបណ្តាលឱ្យតំបន់មួយចំនួនមាន ភ្លៀងធ្លាក់ជាបន្តបន្ទាប់ និងតំបន់ខ្លះមានជំនន់ទឹកភ្លៀងទៀតផង។ ខេត្តសៀមរាបក៏ទទួលរងឥទ្ធិពលនៃព្យុះនេះដោយទទួលបាននូវទឹកភ្លៀងដ៏ច្រើនដែរ។

ដូច្នេះដើម្បីទប់ទល់នឹងស្ថានការណ៍នេះ ក្រុមការងារគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា បានខិតខំប្រឹងប្រែងក្នុងការចាត់ចែងគ្រប់គ្រងទឹកទាំងនោះ ដើម្បីបញ្ចៀសមិនឱ្យជន់លិចតំបន់រមណីយដ្ឋានអង្គរ ក៏ដូចជាក្រុងសៀមរាប ដោយសារឥទ្ធិពលនៃព្យុះនូល។

ម្យ៉ាងទៀត ដោយរដូវវស្សាឆ្នាំនេះមានភ្លៀងធ្លាក់យឺតយ៉ាវ ហើយមានបរិមាណតិចតួចធ្វើអោយការប្រមូលទឹកចូលក្នុងអាងស្តុកមានការលំបាក ហើយក៏ជាការព្រួយបារម្ភដ៏ធំសំរាប់ការផ្គត់ផ្គង់ទឹកនៅរដូវប្រាំង ដល់កិច្ចការអភិរក្សប្រាសាទ ទឹកស្អាតនិងស្រោចស្រពកសិកម្មរបស់បងប្អូនប្រជាពលរដ្ឋ។

ក្នុងន័យនេះ ក្រុមអ្នកជំនាញទឹកនៃនាយកដ្ឋានគ្រប់គ្រងទឹកអាជ្ញាធរជាតិអប្សរា ឆ្លៀតពេលមានទឹកភ្លៀងដ៏ច្រើននេះ បានធ្វើការចាត់ចែង និងប្រមូលទឹកភ្លៀងទាំងនោះតាមប្រព័ន្ធផ្លូវទឹកបុរាណដើម្បីបញ្ជូនទៅរក្សាក្នុងបារាយណ៍ខាងជើង បារាយណ៍លលៃ កសិន្ទុអង្គរវត្ត កសិន្ទុក្រុងអង្គរធំ បារាយណ៍ខាងលិច កសិន្ទុប្រាសាទចៅស្រីវិបុលនិង អាងស្តុកផ្សេងៗទៀត៕

ក្រុមការងារសណ្តាប់ធ្នាប់សាធារណៈនៃអាជ្ញាធរជាតិអប្សរាចុះរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០នេះ ក្រុមការងារសណ្តាប់ធ្នាប់សាធារណៈរបស់នាយកដ្ឋានសណ្តាប់ធ្នាប់ និងកិច្ចសហប្រតិបត្តិការនៃអាជ្ញាធរជាតិអប្សរា បានចុះរៀបចំសណ្តាប់ធ្នាប់តាមដងផ្លូវនៅតាមប្រាសាទនានាក្នុងរមណីយដ្ឋានអង្គរ។

កិច្ចការនេះមានការរៀបចំបង្គោលរបងខណ្ឌផ្លូវកុំឱ្យយានជំនិះជិះចូលឬចតទុក ឱ្យមានរៀបរៀបរយនិងកាប់ឆ្ការមែកឈើផ្សេងៗដែលប៉ះពាល់ដល់ការធ្វើដំណើរទៅប្រាសាទ ដើម្បីឱ្យមានសោភ័ណភាពស្រស់ស្អាតនិងបង្ការគ្រោះថ្នាក់ដល់ទេសចរ៕

ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម បំផុសគំនិតឱ្យពលរដ្ឋខ្មែរដាំដើមពោធិ៍ឡើងវិញ

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

ព្រះមហាវិមលធម្ម សិរីសុវណ្ណោ ពិន សែម រាជាគណៈថ្នាក់ទោ និងជាឧត្តមទីប្រឹក្សាគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា និងជាព្រះចៅអធិការវត្ត រាជបូណ៌ បានដឹកនាំព្រះសង្ឃប្រមាណ៦០អង្គចូលរួមដាំដើមពោធិ៍នៅបរិវេណកសិន្ទុខាងជើងនៃប្រាសាទអង្គរវត្ត។ព្រះអង្គមានបន្ទូលថា ដើមពោធិ៍មានសារប្រយោជន៍ដ៏អស្ចារ្យដែលប្រជាពលរដ្ឋខ្មែរត្រូវដឹង និងចូលរួមដាំឡើងវិញកុំឱ្យបាត់បង់។ ពិសេសជាងនេះ ដើមពោធិ៍ជារុក្ខជាតិដ៏ខ្ពង់ខ្ពស់ក្នុងសាសនាព្រាហ្មណ៍ និងប្រើប្រាស់សម្រាប់ជាឱសថព្យាបាលរោគផង។

មានបន្ទូលទៅកាន់ព្រះសង្ឃ និងប្រជាពលរដ្ឋ ក្នុងពិធីដាំដើមពោធិ៍ចំនួន៨៤ដើម នារសៀលថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ព្រះមហាវិមលធម្មពិនសែមមានបន្ទូលជាច្រើនជុំវិញសារប្រយោជន៍នៃរុក្ខជាតិដើមពោធិ៍ក៏ដូចជាការចំណាយពេលវេលារបស់ព្រះអង្គច្រើនឆ្នាំក្នុងការស្វែងរកពូជពោធិ៍ដែលល្អសម្រាប់បណ្ដុះ និងដាំឡើងវិញក្នុងតំបន់អង្គរនៅពេលនេះ។ ពូជដែលយកមកដាំនៅពេលនេះ គឺនាំយកពីឃុំរើលនៃស្រុកពួក ខេត្តសៀមរាប ពូជមួយទៀតនាំយកពីស្រុកព្រះនេត្រព្រះនៃខេត្តបន្ទាយមានជ័យ និង២ប្រភេទទៀត យកពីខេត្តបាត់ដំបង ដែលសុទ្ធសឹងជាពូជដែលគ្មានជ័រ និងមានឱជារសឆ្ងាញ់។

គោលបំណងសំខាន់ដែលព្រះមហាវិមលធម្ម ពិន សែម ស្វះស្វែងរកពូជពោធិ៍មកដាំនៅពេលនេះ ព្រោះព្រះអង្គយល់ពីតម្លៃដ៏មហាសាលរបស់វា ដែលព្រះអង្គរៀបរាប់ថា តាមក្បួនតម្រាបុរាណបាននិយាយថា ពោធិ៍អាចប្រើជាឱសថសម្រាប់ព្យាបាលរោគ ជាថ្នាំចម្រើនអាយុ ជួយសរីរាង្គកាយមនុស្សបានច្រើន ជួយឱ្យមានកម្លាំង សាច់សម្បុរស្អាត។ល។ និងជារុក្ខជាតិដែលត្រូវបានលើកតម្កើងក្នុងសាសនាព្រាហ្មណ៍ ដោយគេតែងនិយាយថា ជារុក្ខជាតិរបស់ព្រះសិវៈ ព្រោះស្លឹករបស់វាក្នុងមួយទងមាន៣សន្លឹក គឺដូចជាលំពែងត្រីសូល្យរបស់ព្រះឥសូរ ម្យ៉ាងទៀតក៏ដូចភ្នែកព្រះឥសូរយ៉ាងដូច្នោះដែរ។ ពោធិ៍គឺជារុក្ខជាតិដែលប្រើក្នុងព្រះរាជពិធីរបស់ព្រះមហាក្សត្រផងដែរ ដូចជាគេប្រើស្លឹករបស់វាក្នុងពិធីឡើងគ្រងរាជ្យសម្បត្តិ និងព្រះរាជពិធីចម្រើនព្រះជន្មរបស់ព្រះមហាក្សត្រជាដើម។

ដោយយល់ពីតម្លៃនៃរុក្ខជាតិពោធិ៍ដ៏លើសលុបយ៉ាងដូច្នេះហើយ ទើបព្រះមហាវិមលធម្ម ពិន សែម បានផ្ដួចផ្ដើមគំនិតបំផុសឱ្យមានការដាំឡើងវិញនៅតំបន់អង្គរ និងអាចទាក់ទាញភ្ញៀវទេសចរបានផងដែរ ព្រោះផ្ការបស់វាជះក្លិនក្រអូបរយៈពេលពេញមួយខែ។ លើសពីនេះព្រះអង្គក៏ចង់ឱ្យប្រជាពលរដ្ឋខ្មែរទាំងអស់ ចាប់ផ្ដើមដាំរុក្ខជាតិណាដែលមានតម្លៃឡើងវិញ ដូចជា ពោធិ៍ ស្ដៅ ក្រសាំង និងអំពិលជាដើម ដែលព្រះអង្គយល់ថា វាបានបម្រើដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋខ្មែរ តែយើងបែរជាមិនយល់ពីតម្លៃរបស់វា និងមិននាំគ្នាដាំឡើងវិញ។

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ថា អាជ្ញាធរជាតិអប្សរារីករាយសហការ និងផ្ដល់ទីតាំងសម្រាប់ដាំដើមពោធិ៍នេះ។ ឯកឧត្តមបន្ថែមថា អាជ្ញាធរជាតិអប្សរាបានត្រៀមដីមួយកន្លែងនៅខាងជើងក្រុងអង្គរធំ សម្រាប់ធ្វើជាចម្ការពោធិ៍ និងដាំពូជពោធិ៍ចម្រុះសម្រាប់ជាប្រយោជន៍ទៅថ្ងៃក្រោយ ក៏ដូចជាទុកសម្រាប់ប្រជាពលរដ្ឋខ្មែរស្គាល់ដើមពោធិ៍នេះផង។ ឯកឧត្តមបន្ថែមទៀតថា ក្នុងរមណីយដ្ឋានអង្គរគឺដើមឈើរហូត ១៨៣ប្រភេទ ហើយគោលការណ៍របស់អាជ្ញាធរជាតិអប្សរា គឺចង់ថែរក្សាតំបន់នេះនៅតែសម្បូរធនធានធម្មជាតិចម្រុះបែបជារហូតតទៅ៕

ប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន៣០៩គ្រួសារ ត្រូវបានអាជ្ញាធរជាតិអប្សរាចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន

ផ្សាយនៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២០

តាមរបាយការណ៍របស់នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា ខែកញ្ញា ឆ្នាំ២០២០នេះ ក្រុមការងារ បានចុះពិនិត្យនិងជួយសម្រួលលក្ខណៈបច្ចេកទេសដល់ប្រជាពលរដ្ឋដែលសាងសង់លំនៅដ្ឋានចំនួន៣០៩គ្រួសារ នៅក្នុងតំបន់អង្គរ។

លំនៅដ្ឋានទាំង៣០៩គ្រួសារ រួមមាន នៅក្រុងសៀមរាប ចំនួន៨១គ្រួសារ ស្រុកប្រាសាទបាគង ចំនួន៧២គ្រួសារ ស្រុកបន្ទាយស្រីចំនួន ៧០គ្រួសារ ស្រុកអង្គរធំ ចំនួន៤៦ គ្រួសារ និងស្រុកពួក ចំនួន៤០ គ្រួសារ។

សូមបញ្ជាក់ថា ក្រុមការងារនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា តែងតែចុះពិនិត្យជាប្រចាំ ដើម្បីសម្រប សម្រួលករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វ ផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីនិងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា៕

កូនឈើចំនួន៥០០ដើម ត្រូវបានដាំនៅបរិវេណវត្តតាំងតុក្នុងក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២០នេះ មន្ត្រី និងបុគ្គលិកនៃអាជ្ញាធរជាតិអប្សរា រួមមាននាយកដ្ឋានផ្សព្វផ្សាយ នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ និងនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានចូលរួមជាមួយព្រះសង្ឃ និងកម្លាំងនគរបាលបេតិកភណ្ឌ ដាំកូនឈើចំនួន៥០០ដើម នៅក្នុងបរិវេណវត្តតាំងតុ ស្ថិតនៅតាមបណ្តោយផ្លូវឆ្ពោះទៅខ្លោងទ្វារជ័យ នៃក្រុងអង្គរធំ។

លោក ឡុង កុសល អ្នកនាំពាក្យអាជ្ញាធរជាតិអប្សរា និងជាប្រធាននាយកដ្ឋានផ្សព្វផ្សាយដែលដឹកនាំកម្មវិធីដាំកូនឈើនៅពេលនោះបានឱ្យដឹងថា ការដាំកូនឈើគឺដូចជាការផ្តល់នូវជីវិតឡើងវិញ ក៏ដូចជាបានរួមចំណែកគិតគូរពីបញ្ហាបរិស្ថាននៅក្នុងប្រទេសកម្ពុជា។ លោកបន្ថែមថា ការចូលរួមនេះទោះតិចឬច្រើនគឺយើងបាននាំប្រយោជន៍ដល់សង្គមជាតិ ពិសេសបានរួមចំណែកកាត់បន្ថយការបំពុលបរិស្ថាន

ដែលជាកង្វល់របស់ពិភពលោក។ ជាងនេះទៅទៀត ការដាំកូនឈើឡើងវិញក្នុងរមណីយដ្ឋានអង្គរ គឺជាចំណែកដ៏សំខាន់ក្នុងវិស័យបេតិកភណ្ឌ ដ្បិតថា ព្រៃឈើជាផ្នែកមួយដ៏សំខាន់ក្នុងកិច្ចការការពារបេតិកភណ្ឌជាតិ ក្នុងតំបន់រមណីយដ្ឋានអង្គរ៕

អ្នកជួសជុលប្រាសាទភ្នំបាខែងមានមោទនភាពចំពោះការងារអភិរក្សប្រាង្គប្រាសាទ

ផ្សាយនៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២០

ក្រោមស្នាដៃជួសជុលដោយកូនខ្មែរ និងបរទេសក្នុងការអភិរក្សប្រាសាទភ្នំបាខែងឱ្យផុតពីគ្រោះថ្នាក់ អាជ្ញាធរជាតិអប្សរាសហការជាមួយមូលនិធិប្រាសាទពិភពលោក (World Monument Fund) តាំងពីឆ្នាំ២០០៧ បានធ្វើការអភិរក្ស ជួសជុល ប្រាសាទភ្នំបាខែង ដោយប្រែស្ថានភាពពីចាស់ទ្រុឌទ្រោមបាក់បែកមកជាសំណង់ប្រាសាទដែលមានភាពរឹងមាំ សោភ័ណភាពស្អាត និងទាក់ទាញទេសចរ។

លោក ឈឹម សុខា អ្នកជំនាញជួសជុលប្រាសាទបានចូលបម្រើការងារផ្នែកអភិរក្សតាំងឆ្នាំ២០០១ បានសម្តែងការពេញចិត្តជាខ្លាំងចំពោះសមិទ្ធផលការងារដែលសម្រេចបានក្នុងការជួសជុលប្រាសាទភ្នំបាខែងឱ្យរួចផុតពីគ្រោះថ្នាក់។

លោកបានបញ្ជាក់ថា «ខ្ញុំសប្បាយចិត្តណាស់ ដែលបានធ្វើការជួសជុលមរតកដូនតាឱ្យល្អប្រសើរឡើងវិញ។ យើងខ្ញុំធ្វើការបម្រើអង្គរដោយស្មោះត្រង់ ដោយកម្លាំងញើសឈាម ធ្វើការទាំងក្តៅ ទាំងភ្លៀង ជួបការលំបាកជាច្រើន សូម្បីថ្មបាយក្រៀមក៏រុញឡើង ថ្មនៅតែដាប់ ធ្វើការបែកដៃបែកជើង ហូរញើសដោកខ្លួនជាមួយបរទេសដើម្បីតែភាពរឹងមាំរបស់ប្រាសាទ។ដូច្នេះសូមបងប្អូនជួយស្រឡាញ់វត្ថុបុរាណនិងបេតិកភណ្ឌរបស់យើងឡើងវិញ។ យើងខ្ញុំស្រឡាញ់បេតិកភណ្ឌដូនតាណាស់»។

លោកស្រីGinevraBaottoប្រធានគម្រោងមូលនិធិប្រាសាទពិភពលោកប្រចាំកម្ពុជាបានឱ្យដឹងថា WMF មានការិយាល័យនៅខេត្តសៀមរាបក្នុងឆ្នាំ១៩៩២ បានជួសជុលប្រាសាទព្រះខ័នតាសោមអង្គរវត្តនិងបច្ចុប្បន្ននៅភ្នំបាខែង។ យើងជាអង្គការមិនរកប្រាក់ចំណេញ ដែលផ្តោតលើការអភិរក្សសមិទ្ធផលស្ថាបត្យកម្មពិភពលោក តាមរយៈការធ្វើការយ៉ាងជិតស្និទ្ធជាមួយសហគមន៍ដែលនៅជុំវិញបុរាណដ្ឋាន ដែលនឹងក្លាយជាអ្នក ជំនាន់ថ្មីបន្តថែរក្សាបេតិកភណ្ឌវប្បធម៌កម្ពុជា ដោយខ្លួនឯងនាអនាគតប្រកបដោយជំនាញវិជ្ជាជីវៈតាមស្តង់ដារ។

លោកស្រី Ginevra បន្តថា «ខ្ញុំរីករាយដែលបានឃើញការខិតខំរបស់ពួកគេនៅក្នុងរឿងកិច្ចការអភិរក្ស តាមរយៈគំនិតផ្តួចផ្តើមនិងការប្រាស្រ័យទាក់ទងផ្សេងៗ។

លោកស្រីបន្ថែមថា ក្រុមការងារអន្តរជាតិទាំងអស់ដែលធ្វើការនៅតំបន់អង្គរនិងអាជ្ញាធរជាតិអប្សរាក៏កំពុងធ្វើការជាមួយគោលដៅរួមគ្នាដើម្បីផ្តល់ផលប្រយោជន៍ដល់ប្រទេសកម្ពុជានិងប្រជាជនកម្ពុជា តាមរយៈការថែរក្សាមរតករបស់ខ្លួនតាមរយៈការផ្តល់ជំនាញថ្មីៗនិងឱកាសការងារមានស្ថេរភាព ដើម្បីរួមចំណែកដល់ការរក្សាសន្តិភាព ស្ថិរភាព ទំនុកចិត្ត និងការយល់ដឹងអំពីខ្លួនឯង នៅក្នុងប្រទេសដែលធ្លាប់ហែកហួរដោយសង្គ្រាម៕

បរិវេណមុខប្រាសាទអង្គរវត្តបានប្រែមុខមាត់ថ្មីក្រោយមានការអភិវឌ្ឍជាបន្តបន្ទាប់

ផ្សាយនៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២០

បច្ចុប្បន្នបរិវេណមុខប្រាសាទអង្គរវត្ត បានចាប់ផ្ដើមប្រែមុខមាត់ថ្មីជាបណ្ដើរៗ ស័ក្តិសមជារមណីយដ្ឋានបេតិកភណ្ឌពិភពលោកដែលមានភាពទាក់ទាញដ៏អស្ចារ្យ ដោយលោកអ្នកអាចឃើញនូវទស្សនីយភាពថ្មី ប្លែកភ្នែក ពេលមកទស្សនាប្រាសាទអង្គរវត្ត ក្រោយពីតំបន់នេះមានការអភិវឌ្ឍជាបន្តបន្ទាប់ពីសំណាក់អាជ្ញាធរជាតិអប្សរា។

សូមអញ្ជើញទស្សនា ទិដ្ឋភាពនៅជុំវិញបរិវេណខាងមុខប្រាសាទអង្គរវត្ត ដែលបានរៀបចំសួនច្បារ និងដាំដើមឈើដើមផ្កាលម្អយ៉ាងស្រស់ស្អាត



អាជ្ញាធរជាតិអប្សរា បានកាត់សម្អាតដើមឈើដែលដួលរលំដោយសារភ្លៀង និងខ្យល់កន្ត្រាក់ក្នុងរដូវវស្សាឆ្នាំនេះបានចំនួន៩៨ដើម

ផ្សាយនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

ដើម្បីឲ្យសោភ័ណភាពបានប្រសើរឡើងវិញនៅក្នុងឧទ្យានអង្គរ និងតំបន់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន បានធ្វើការកាត់សម្អាតដើមឈើដែលដួលរលំដោយសារភ្លៀង និងខ្យល់កន្ត្រាក់ក្នុងរដូវវស្សាឆ្នាំនេះបានចំនួន៩៧ដើម ដែលដើមឈើទាំងនោះមានមុខកាត់ពី១០ស.ម ដល់៧០ស.ម និងស្ថិតនៅតាមទីតាំងផ្សេងៗគ្នាដូចជា៖

- នៅតាមផ្លូវវង់ធំ ចំនួន១១ដើម រួមមាន ដើមសិរមាន់ ដើមក្រាយ ដើមត្រសេក ដើមស្លាក្រពុល ដើមខ្វាស់ ដើមក្រឡាញ់ ដើមជម្ពូ និងដើមត្រាច។
- ក្នុងបរិវេណអង្គរធំ ចំនួន២៤ដើម រួមមាន ដើមពភ្លា ដើមចំនទំពាំង ដើមស្លែង ដើមកំពីងរាជ ដើមអង្កាញ់ ដើមសង្កែ ដើមឈើទាល ដើមស្នាយ និងដើមស្រឡៅ។
- នៅបរិវេណប្រាសាទព្រះខ័ន ចំនួន៤ដើម រួមមាន ដើមឈើទាល ដើមខ្នារ និងដើមមៀនព្រៃ។
- នៅបរិវេណប្រាសាទភ្នំបាខែង ចំនួន៤ដើម រួមមាន ដើមក្រឡាញ់ ដើមត្រមែង ដើមសិរមាន់ និងដើមស្លែង។
- តំបន់រលួស ចំនួន៧ដើម រួមមាន ដើមឈើទាល ដើមស្ដៅ ដើមអំពិល ដើមកន្ទ្រៀក និងដើមស្វាយចន្ទី។
- នៅបរិវេណប្រាសាទអង្គរវត្ត និងតំបន់ជុំវិញ ចំនួន១៣ដើម រួមមាន ដើមក្រឡាញ់ ដើមស្នាយ ដើមគ ដើមក្បោក ដើមក្រឡាញ់ ដើមត្រសេក ដើមឈើទាល ដើមរំដួល ដើមស្ទូល ដើមចាមរី និងដើមសង្កែ។
- នៅខាងលិចប្រាសាទតានៃ និងប្រាសាទតាកែវ ចំនួន២ដើម រួមមាន ដើមត្រសេក និងដើមឈើទាល។
- នៅបរិវេណប្រាសាទបន្ទាយប្រី និងប្រាសាទប្រី ចំនួន៤ដើម រួមមាន ដើមអាកាស្យា ដើមចំបក់ និងដើមក្របៅ។
- ខាងត្បូងប្រាសាទប្រែរូបមាន ដើមសង្កែចំនួន១ដើម
- នៅបរិវេណស្រះស្រង់ ប្រាសាទបន្ទាយក្ដី និងប្រាសាទតាព្រហ្ម ចំនួន១៣ដើម រួមមាន ដើមកន្ទុំថេត ដើមពង្រ ដើមឈើទាល ដើមត្រយឹង ដើមបង្គួរដំរី ដើមស្ដៅ ដើមស្វាយគគីត ដើមពពូល ដើមអង្កោលដើមសង្កែ និងដើមពភ្លា។
- នៅប្រាសាទវត្តអធ្វារមាន ដើមដូនកាយចំនួន១ដើម
- នៅប្រាសាទនាគព័ន្ធ ចំនួន២ដើម រួមមាន ដើមគ្រញូង និងដើមដោះក្របី។
- នៅបរិវេណប្រាសាទបន្ទាយស្រី ចំនួន៧ដើម រួមមាន ដើមឈើទាល ដើមពង្រ ដើមក្រឡាញ់ ដើមខ្វាស់ និងដើមសង្កែ។
- តាមបណ្ដោយផ្លូវហ្សាដឺហ្គោល ដល់ស្ពានអង្គរ និងប្រាសាទក្រវ៉ាន់ ចំនួន៥ដើម រួមមាន ដើមខ្នារ ដើមពោធិ៍ ដើមថ្កូវ ដើមស្ទូល និងដើមពង្រ។

ភាគីបារាំងប្តេជ្ញាបន្តកិច្ចសហប្រតិបត្តិការកាន់តែល្អប្រសើរក្នុងការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច

ផ្សាយនៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០នេះ អគ្គនាយកអាជ្ញាធរជាតិអប្សរា ដែលអមដំណើរដោយលោក គ្រីស្តុហ្វ ហ្សីហ្គូដូ (CHRISTOPHE GIGAUDAUT) ទីប្រឹក្សាសហ

ប្រតិបត្តិការ និងកិច្ចការវប្បធម៌ នៃស្ថានទូតបារាំងប្រចាំកម្ពុជា បានធ្វើទស្សនកិច្ចទៅកាន់ការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច ដើម្បីស្វែងយល់ពីការងារទូទៅ។ នេះជាទស្សនកិច្ចដំបូងរបស់សហប្រធានភាគីបារាំង ខណៈដែលលោកទើប នឹងចូលមកជំនួសការងារពីអតីតសហប្រធានចាស់ ដែលចប់អាណត្តិ។

លោក គ្រីស្តុហ្វ ហ្សីហ្គូដូ បានវាយតម្លៃខ្ពស់ និងបានសម្តែងអារម្មណ៍រីករាយក្នុងការបំពេញទស្សនកិច្ចមកកាន់ការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិចនៅពេលនេះ។

លោកបន្ថែមថា ទស្សនកិច្ចជាលើកដំបូងនេះ គឺដើម្បីស្វែងយល់កាន់តែស៊ីជម្រៅលើការងារនានា ដើម្បីឱ្យកិច្ចសហប្រតិបត្តិការរវាងភាគីបារាំង និងអាជ្ញាធរជាតិអប្សរា កាន់តែល្អប្រសើរ។ តំណាងស្ថានទូតបារាំងបានប្តេជ្ញាថា លោកនឹងខិតខំធ្វើយ៉ាងណាឱ្យការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិច ដែលភាគីបារាំងផ្តល់ថវិកាហិរញ្ញប្បទានសម្រាប់ការជួសជុលនេះដំណើរការដោយរលូន និងមានតម្លាភាព។

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា មានសេចក្តីសោមនស្សចំពោះកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងបារាំង ហើយឯកឧត្តមក៏មានការរំពឹងថា សហប្រធានថ្មីរបស់ស្ថានទូតបារាំង និងបន្តកិច្ចសហប្រតិបត្តិការនៅការដ្ឋានជួសជុលប្រាសាទមេបុណ្យខាងលិចនេះ ឱ្យកាន់

អាជ្ញាធរជាតិអប្សរាបន្តចែកកូនឈើដល់សាធារណជនជាង៣ពាន់ដើមនៅចុងខែកញ្ញានេះ

ផ្សាយនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០

កូនឈើជាបន្តបន្ទាប់បានចែកជូនដល់សាធារណជនដែលបានមកស្នើសុំដើម្បីយកទៅដាំ នៅតាមតំបន់នានាក្នុងប្រទេសកម្ពុជា។ តួយ៉ាង រយៈពេល៦ថ្ងៃ គឺចាប់ពីថ្ងៃទី២១ ដល់ថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា បានចែកជូនកូនឈើចំនួន ៣,២៧៧ដើម។
កូនឈើដែលបានផ្តល់ជូននៅពេលនោះរួមមាន៖

- ផ្តល់កូនឈើជូនលោក ឆាន់ សុផល ចំនួន១០០ដើម ដើម្បីយកទៅដាំនៅភូមិពង្រ ឃុំព្រៃជ្រូក ស្រុកពួក ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនលោក ឆេង ឡុច ចំនួន៥០០ដើម ដើម្បីយកទៅដាំព័ទ្ធជុំវិញត្រពាំងរួមពើកពុល ស្ថិតក្នុងភូមិគោកស្គួល ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនលោក តិល សុរីរៈ ចំនួន១៥០ដើម ដើម្បីយកទៅដាំនៅបរិវេណវត្តកោះពងសត្វ វត្តកំព្រីង និងវត្តភ្នាត ក្នុងខេត្តបន្ទាយមានជ័យ។
- ផ្តល់កូនឈើជូនតំណាងសាលា JPA ចំនួន៦០០ដើម ដើម្បីយកទៅដាំលើដីទំនេរក្នុងបរិវេណសាលារៀននេះ ស្ថិតក្នុងភូមិអំពិលពាម ឃុំខ្នាត ស្រុកពួក ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនលោក ប៉ុច ពុំ ចំនួន១១០ដើម ដើម្បីយកទៅដាំនៅឃុំលាងដៃ ស្រុកអង្គរធំ ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនលោក លឹង ទត ចំនួន២០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវត្តព្រះនង្គ័ល ស្ថិតក្នុងភូមិព្រះនង្គ័ល ឃុំចំណារក្រោម ស្រុកស្ទោង ខេត្តកំពង់ធំ។
- ផ្តល់កូនឈើជូនអ្នកស្រី សូ គឹមលាង ចំនួន១០០ដើម ដើម្បីយកទៅដាំតាមរបងដីចម្ការ ស្ថិតក្នុងភូមិយុនរាមចាស់ ឃុំយុនរាម ស្រុកបន្ទាយស្រី ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនតំណាងធនាគារអេស៊ីលីដា ភីអិលស៊ី សាខាខេត្តសៀមរាប ចំនួន៣០០ដើម ដើម្បីយកទៅដាំក្នុងបរិវេណវិទ្យាល័យ ស្នាតេជោ៣១៧ ស្ថិតក្នុងភូមិស្នាតេជោ ឃុំបល្ល័ង្គ ស្រុកប្រាសាទបាគង ខេត្តសៀមរាប។
- ផ្តល់កូនឈើជូនតំណាង **ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋលេខាធិការក្រសួងបរិស្ថាន ចំនួន៧០០ដើម ដើម្បីយកទៅដាំលម្អនៅតាមដងផ្លូវជាតិ សាលារៀន និងក្នុងបរិវេណវត្តអារាមនានា ក្នុងក្រុងសួង ខេត្តត្បូងឃ្មុំ។
- ផ្តល់កូនឈើជូនលោក អ៊ឹម សុខរិទ្ធី បម្រើការងារនៅអាជ្ញាធរជាតិអប្សរា ចំនួន៣៧ដើម។
- ផ្តល់កូនឈើជូនលោក សោម ប៊ុតរស្មី បំរើការងារនៅអាជ្ញាធរជាតិអប្សរា ចំនួន២០ដើម។
- ផ្តល់កូនឈើជូនលោក រឿន ចំណាន បម្រើការងារនៅអាជ្ញាធរជាតិអប្សរា ចំនួន៦០ដើម ដើម្បីយកទៅដាំនៅខេត្តកំពង់ឆ្នាំង។
- ផ្តល់កូនឈើជូន**ឯកឧត្តម ឈិត ប៊ូរ៉ាឌុធ** ប្រធានក្រុមមេធាវីជួយការងារច្បាប់អាជ្ញាធរជាតិអប្សរា ចំនួន៤០០ដើម ដើម្បីយកទៅដាំនៅតាមសាលារៀននានា ក្នុងឃុំស្ពៅ ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែតុលា

ការជួសជុលផ្ទះ និងសាងសង់សំណង់តូចតាចចំនួន២៥០៧សំណើ ត្រូវបានអនុញ្ញាតក្នុងរយៈពេល៩ខែ ដោយអាជ្ញាធរជាតិអប្សរា

ផ្សាយនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០

របាយការណ៍លេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរា រយៈពេល៩ខែ ចាប់ពីខែមករា ដល់ខែកញ្ញា ឆ្នាំ២០២០ បង្ហាញថា ក្រុមការងារសហគមន៍បានចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋដើម្បីពិនិត្យនិងដោះស្រាយសំណើស្នើសុំជួសជុលផ្ទះ រួមទាំងសាងសង់តូចតាចតាមភូមិទាំង១១២ភូមិ ក្នុងតំបន់ឧទ្យានអង្គរ ដោយក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋបានចំនួន២៥០៧សំណើ ក្នុងចំណោម៣៤៣៩សំណើ។

ករណីអនុញ្ញាតសំណើខាងលើផ្តល់ជូនប្រជាពលរដ្ឋនៅស្រុកបាគង៣៧៨សំណើ ស្រុកអង្គរធំចំនួន៣៨៧សំណើ ស្រុកពួកចំនួន៥៣៤សំណើ ស្រុកបន្ទាយស្រីបានចំនួន៧៦៤សំណើ និងក្រុងសៀមរាបចំនួន៤៤៤សំណើ។

ប្រភេទសំណើដែលក្រុមការងារសហគមន៍ចុះពិនិត្យនិងដោះស្រាយមាន ១. ការជួសជុលផ្ទះ៖ ការជួសជុលឬប្តូរដំបូល ប្តូរជញ្ជាំង ប្តូរសសរ ប្តូរឬតសំយ៉ាប ជួសជុលជណ្តើរ ជួសជុលរបងមានស្រាប់ បន្ទប់ក្រោមផ្ទះ។ ២. សំណង់តូចតាច៖ សង់បង្គន់ សង់ទ្រុងមាន់ ទា ជ្រូក ជង្រុកស្រូវ តូប ឬរោងលក់ដូរមុខផ្ទះ។ ៣.ចាក់ដី៖ ចាក់ដីលុបគ្រលុកក្នុងបរិវេណផ្ទះក្រោម។ល។ រាល់ការស្នើសុំច្បាប់សាងសង់គឺពុំមានការបង់ប្រាក់ទេ។

ក្រុមការងារសហគមន៍តែងចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលលើករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីអាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរ។

លើសពីនេះ ក្រុមការងារក៏បានឧត្តម្ភថវិកាដល់ចាស់ព្រឹទ្ធាចារ្យ ចាស់ជរា ជនពិការ ជនទីទ័លក្រ អ្នកជំងឺ កុមារពិការ និងជួយឧបត្ថម្ភជាសម្ភារដូចជាស៊ីម៉ងត៍ ស័ង្កសី ព្រមទាំងបានជួយឧត្តម្ភគាំទ្រវិស័យព្រះពុទ្ធសាសនាដែរ៕

លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន អញ្ជើញទស្សនកិច្ចការងារនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០

ក្នុងឱកាសដ៏មមាញឹកបំពេញបេសកកម្មការងារនៅខេត្តសៀមរាប ព្រឹកថ្ងៃព្រហស្បតិ៍ ទី១ ខែតុលា ឆ្នាំ២០២០ **លោកជំទាវកិត្តិសង្គហបណ្ឌិត ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច បានអញ្ជើញទស្សនកិច្ចការងារនៅរមណីយដ្ឋានអង្គរ។

ក្នុងនាមអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានសម្តែងគារវកិច្ចដោយក្តីគោរព និងថ្លែងអំណរគុណចំពោះវត្តមានដ៏ឧត្តុង្គឧត្តមរបស់លោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ព្រមទាំងបានជម្រាបជូនលោកជំទាវកិត្តិសង្គហបណ្ឌិត ឧបនាយករដ្ឋមន្ត្រី នូវវឌ្ឍនភាពការងារលើផ្នែកអភិរក្ស ជួសជុលប្រាង្គប្រាសាទបុរាណ ព្រមទាំងកិច្ចការជាច្រើនផ្សេងទៀតដែលអាជ្ញាធរជាតិអប្សរាបានបំពេញដើម្បីត្រៀមទទួលភ្ញៀវទេចរនាពេលខាងមុខ។ ជាពិសេសកិច្ចការរៀបចំសណ្តាប់ធ្នាប់សាធារណសោភ័ណភាពបរិស្ថាននៅបរិវេណមុខប្រាសាទអង្គរវត្ត៕

ក្រុមកម្មករកំពុងមមាញឹកជួសជុលប្រាសាទមេបុណ្យខាងលិច

ផ្សាយនៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០

ប្រាសាទមេបុណ្យខាងលិច កំពុងចាប់ផ្តើមចេញរូបរាងជាបណ្តើរៗ ក្រោយពេលមានការជួសជុលចាប់ពីឆ្នាំ២០១២ មក។ បច្ចុប្បន្ន ក្រុមកម្មករកំពុងបំពេញការងារយ៉ាងមមាញឹក ដើម្បីឱ្យគម្រោងជួសជុល និងលើកតម្លៃនៃប្រាសាទមេបុណ្យខាងលិចនេះ ប្រព្រឹត្តិទៅតាមការគ្រោងទុក និងដើម្បីស្វាគមន៍ភ្ញៀវទេសចរចូលទៅទស្សនា។

សូមអញ្ជើញទស្សនា ទិដ្ឋភាពនៃការដ្ឋានប្រាសាទមេបុណ្យខាងលិច នាថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០ ដែលថតដោយលោក ហុំ រិទ្ធី នៃនាយកដ្ឋានផ្សព្វផ្សាយ ដូចតទៅ

អាជ្ញាធរជាតិអប្សរាបញ្ចប់វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពភ្នាក់ងារទេសចរណ៍ នៅតាមប្រាសាទក្នុងតំបន់អង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០

វគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពភ្នាក់ងារទេសចរណ៍អំពីហានិភ័យប្រាសាទនៅក្នុងរមណីយដ្ឋានអង្គរ ដែលរៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ សហការជាមួយនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ និងមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ រយៈពេល ១ខែ បានបញ្ចប់នាថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០។

លោក លឹម ស្រ៊ូ ប្រធានភ្នាក់ងារទេសចរណ៍ក្នុងតំបន់អង្គរ បានឱ្យដឹងថា វគ្គបណ្តុះបណ្តាលអំពីហានីភ័យប្រាសាទមានភ្នាក់ងារទេសចរណ៍ចូលរួមចំនួន១៥៥នាក់ នៅតាមប្រាសាទសំខាន់ៗដូចជា ប្រាសាទអង្គរវត្ត ប្រាសាទបាយ័ន្ត ប្រាសាទតាព្រហ្ម ប្រាសាទប្រែរូប និងប្រាសាទបាគង។

លោក លឹម ស្រ៊ូ បន្តថា វគ្គបណ្តុះបណ្តាលនេះ បង្រៀនសិក្ខាកាមទាំងអស់អំពីតួនាទីរបស់ភ្នាក់ងារទេចរណ៍ ការពន្យល់ពីអ្នកជំនាញជាតិ-អន្តរជាតិអំពីប្រវត្តិសាស្ត្រទូទៅនៃឧទ្យានអង្គរ ប្រវត្តិនៃការអភិរក្សនិងការជួសជុលប្រាសាទ ការចុះពិនិត្យទីតាំងដែលមានហានីភ័យផ្ទាល់ និងវិធានការការពារដើម្បីសង្គ្រោះប្រាសាទ។ តាមរយៈមេរៀនទាំងនេះ គឺដើម្បីឱ្យភ្នាក់ងារទេសចរណ៍មានមូលដ្ឋានជាគ្រឹះខ្លះៗ អាចចូលរួមអង្កេត ផ្តល់ព័ត៌មាន និងរួមចំណែកផ្តល់សញ្ញាព័ត៌មានដល់ភ្ញៀវទេសចរបានជ្រាបនិងទប់ស្កាត់ហានីភ័យផ្សេងៗនៅតាមប្រាសាទ។

មានប្រសាសន៍នាឱកាសបិទវគ្គបណ្តុះបណ្តាលភ្នាក់ងារទេសចរណ៍នៅប្រាសាទបាគង **ឯកឧត្តម សុខ សង្វារ** អគ្គនាយករងទទួលបន្ទុកនាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគ្រូឧទ្ទេសក៍ទាំងអស់ដែលបានចូលរួមចែករំលែកចំណេះដឹង និងបទពិសោធន៍ដល់ក្រុមការងារ ហើយសង្ឃឹមថាក្រុមការងារដែលបានយកចិត្តទុកដាក់ទទួលការបណ្តុះបណ្តាល នឹងយកចំណេះដឹងទាំងនេះទៅប្រើប្រាស់ និងចែករំលែកចំណេះដឹងថ្មីនេះបន្តទៀតប្រកបដោយផ្លែផ្កាល្អក្នុងការងារប្រចាំថ្ងៃ ដើម្បីភាពល្អប្រសើរក្នុងតំបន់អង្គរ៕

សត្វព្រៃ២ប្រភេទផ្សេងទៀត ត្រៀមដោះលែងបន្ថែមក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០

កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ គម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ ក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរា រដ្ឋបាលព្រៃឈើភ្នំពេញ និងអង្គការ Wildlife Alliance បានដឹកជញ្ជូនសត្វឆ្មារដាវ(Leopard Cat) ចំនួន ១គូ និងសត្វកេងកងតូច(Oriental Pied Hornbill) ចំនួន ១គូ ពីមជ្ឈមណ្ឌលថែទាំ និងសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ មកផ្សាំក្នុងទ្រុងនៅជិតខ្លោងតាការសម្រាប់កេងកងតូច និងនៅជិតខ្លោងដីឆ្នាំងសម្រាប់ឆ្មារដាវ ដែលក្រុមការងារគម្រោងនឹងធ្វើការដោះលែងសត្វទាំងនេះចេញពីទ្រុងចូលទៅក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គនៅពេលខាងមុខ។



សូមបញ្ជាក់ជូនថា តាមរយៈកិច្ចសហការនេះ ចាប់តាំងពីឆ្នាំ២០១៣មក គម្រោងទទួលបានជោគជ័យក្នុងការដោះលែងសត្វចូលក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរ បានជាច្រើនប្រភេទដូចជា សត្វទោចមកុដចំនួន១២ក្បាល (កើតកូនបានចំនួន៤ក្បាល) សត្វឈ្លូសចំនួន៤ក្បាល សត្វស្វាព្រាមចំនួន១២ក្បាល សត្វសំពោចក្រអូបចំនួន៥ក្បាល សត្វភេខ្លួនរលោងចំនួន៥ក្បាល (កើតកូនបានចំនួន២ក្បាល) ដែលមកដល់ពេលនេះសត្វទាំងអស់នោះនៅតែមានវត្តមាននៅទីនោះនៅឡើយ ក្រោមការយកចិត្តទុកដាក់តាមដាន និងថែទាំជាប្រចាំពីក្រុមការងារ។

ដើម្បីឲ្យសត្វព្រៃទាំងអស់នោះបន្តវត្តមាននៅក្នុងព្រៃធម្មជាតិនៃឧទ្យានអង្គរយើង និងបង្កើនចំនួនបន្ថែមទៀត អាជ្ញាធរជាតិអប្សរា និងគម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ សូមអំពាវនាវជូនសាធារណជន ភ្ញៀវជាតិ អន្តរជាតិ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ ចូលរួមថែរក្សាសត្វព្រៃទាំងនោះទាំងអស់គ្នា ជៀសវាងពេលប្រទះឃើញមានបំណងមិនល្អ និងមេត្តាកុំផ្តល់ចំណីឲ្យសត្វទាំងនោះ។

បន្ទប់ទឹកសាធារណៈកម្រិតស្តង់ដារអន្តរជាតិនឹងដាក់ឱ្យដំណើរការនៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០

នៅក្នុងកិច្ចការរៀបចំសណ្តាប់ធ្នាប់និងសោភ័ណភាពនៅបរិវេណខាងលិចប្រាសាទអង្គរវត្ត អាជ្ញាធរជាតិអប្សរាបានដាក់ឱ្យដំណើរការបន្ទប់ទឹកអនាម័យកម្រិតស្តង់ដារអន្តរជាតិដែលមានទីធ្លាធំទូលាយ និងបំពាក់ទៅដោយសម្ភារ បរិក្ខារ ទំនើប នាថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ នៅក្នុងទីលានបដិសណ្ឋារកិច្ច។

អគារនេះត្រូវបានសាងសង់ដោយក្រុមហ៊ុន Green Angkor Culture PLC., មានបន្ទប់ស្រី ចំនួន៨ បុរសចំនួន៦ បង្គន់នោមបុរសចំនួន៦ និងបង្គន់សម្រាប់ជនពិការចំនួន២ (ស្រី១ប្រុស១) សម្រាប់ឱ្យភ្ញៀវទេសចរជាតិ អន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋអាចប្រើប្រាស់ ក្នុងគោលបំណងលើកកម្ពស់សោភ័ណភាព បរិស្ថាន និងអនាម័យ នៅតំបន់រមណីយដ្ឋានអង្គរ បេតិកភណ្ឌពិភពលោក ។

បន្ទប់ទឹកអនាម័យនេះ នឹងស្ថិតក្រោមការថែទាំរបស់គ្រឹះស្ថានអង្គរ ដើម្បីចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការផ្តល់សេវាកម្មទេសចរណ៍ ក្នុងរមណីយដ្ឋាន អង្គរ៕

បារាយណ៍ខាងលិចក្រោយបញ្ចូលទឹក ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

រចនាសម្ពន្ធកំពែងទី៣ប្រាសាទបន្ទាយស្រីត្រូវបានជួសជុលឱ្យផុតពីហានិភ័យ

ផ្សាយនៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០

ព្យុះនូលដែលកើតឡើងកាលពីថ្ងៃទី១៨រហូតដល់ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០ បានបណ្តាលឱ្យផ្នែកខ្លះនៃព្រះរាជាណាចក្រកម្ពុជាទទួលបានទឹកភ្លៀងដ៏ច្រើន។ ខេត្តសៀមរាបក៏ទទួលបានទឹកភ្លៀងជាច្រើនផងដែរ។

ដើម្បីជាប្រយោជន៍ដល់កិច្ចការអភិរក្សប្រាសាទ ទឹកស្អាត និងស្រោចស្រពកសិកម្មរបស់ប្រជាពលរដ្ឋ អ្នកជំនាញផ្នែកគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាបានធ្វើការចាត់ចែង និងប្រមូលទឹកភ្លៀង ទាំងនោះតាមប្រព័ន្ធផ្លូវទឹកបុរាណ ដើម្បីបញ្ជូនទៅរក្សាក្នុងបារាយណ៍ខាងជើង បារាយណ៍លលៃកសិន្ធុអង្គរវត្តកសិន្ធុក្រុងអង្គរធំបារាយណ៍ខាងលិច កសិន្ធុប្រាសាទចៅស្រីវិបុលនិង អាងស្តុកផ្សេងៗទៀត។

បារាយណ៍ខាងជើងមុនបញ្ចូលទឹក ថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២០

កម្រិតទឹកនៅបារាយណ៍ខាងលិច ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

បារាយណ៍ខាងជើងក្រោយបញ្ចូលទឹក ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២០

កូនឈើចម្រុះចំនួន៤៥០ដើមត្រូវបានដាំឡើងវិញនៅទីតាំងកាប់ទន្ទ្រាន នៃតំបន់ការពារប្រាសាទបន្ទាយអំពិល

ផ្សាយនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

នៅថ្ងៃទី០២ ខែតុលា ឆ្នាំ២០២០ ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារព្រៃឈើ ថ្នាំប្រាសាទ ពលករនៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះដាំកូនឈើឡើងវិញនៅទីតាំងដែលមានការកាប់ទន្ទ្រានដីព្រៃនៃតំបន់ការពារប្រាសាទបន្ទាយអំពិល ស្ថិតនៅភូមិសំរោង ឃុំខ្វាវ ពោធិ៍ ស្រុកសូទ្រនិគម ខេត្តសៀមរាប ដែលតំបន់នេះកន្លងមករងការកាប់ទន្ទ្រានខុសច្បាប់ពីពលរដ្ឋមួយចំនួន ក្នុងបំណងពង្រីកផ្ទៃដីចម្ការ និងកាន់កាប់ដោយខុសច្បាប់។

ដើម្បីបំពេញគម្របព្រៃឈើឡើងវិញស្របតាមគោលការណ៍របស់រាជរដ្ឋាភិបាល ក្រុមការងារចម្រុះបានចុះដាំកូនឈើចម្រុះឡើងវិញរួមមាន ដើមគ្រញូងចំនួន៥០ដើម ដើមច្រេសចំនួន៥០ដើម ដើមបេងចំនួន៥០ដើម ដើមគគីរចំនួន៥០ដើម ដើមអង្កាញ់ចំនួន១០០ដើម ដើមត្រសេកចំនួន៥០ដើម និងដើមសំរោងចំនួន១០០ដើម សរុបមានចំនួន៤៥០ដើម៕

រចនាសម្ពន្ធកំពែងទី៣ប្រាសាទបន្ទាយស្រីត្រូវបានជួសជុលឱ្យផុតពីហានីភ័យ

ផ្សាយនៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០

រចនាសម្ពន្ធកំពែងទី៣ នៃប្រាសាទបន្ទាយស្រីដែលរងនូវការខូចខាតទ្រុឌទ្រោមត្រូវបានអ្នកជំនាញផ្នែកអភិរក្សធ្វើការជួសជុលនិងទល់ទ្រឱ្យរួចផុតពីហានីភ័យ។

កំពែងទី៣ដែលបានជួសជុលនិងទល់ទ្រនាពេលនេះមានចំនួន៥ទីតាំង និងមានប្រវែងសរុប៤០ម៉ែត្រ។

គោលបំណងសំខាន់នៃការជួសជុល គឺដើម្បីកាត់បន្ថយការខូចខាតធ្ងន់ធ្ងរនៃរចនាសម្ពន្ធកំពែង ព្រមទាំងសង្គ្រោះរចនាសម្ពន្ធពាក់ព័ន្ធផ្សេងៗទៀតដែលកំពុងរងគ្រោះថ្នាក់ឱ្យទាន់ពេលវេលា។

លោក សារាយ គឹមហួល បុរាណវិទូនិងជាប្រធានគម្រោងជួសជុលអភិរក្សបន្ទាយស្រី ឱ្យដឹងពីមូលហេតុនៃការទ្រុឌទ្រោមរចនាសម្ពន្ធរបស់កំពែងនិងប្រាសាទ គឺបណ្ដាលមកពីកត្តាធម្មជាតិ គួបផ្សំនឹងអាយុកាលដ៏យូរលង់នៃសំណង់ ពោលគឺមួយភាគនៃសំណង់រងការបំផ្លាញដោយការរលំបាក់នៃដើមឈើសង្កត់ រីឯឫសនៃដើមឈើធំៗ បានចាក់បំបើងគ្រឹះបណ្ដាលឱ្យស្រុតទ្រេតនិងប្រេះខូចខុសពីទម្រង់ដើម។

ប្រាសាទបន្ទាយស្រីបានចាប់ផ្ដើមអភិរក្សឡើងវិញអំឡុងឆ្នាំ១៩១៦ដោយជនជាតិបារាំង។ ចាប់ពីឆ្នាំ១៩២៤មកសាលាបារាំងចុងបូព៌ា (EFEO) បានត្រួសត្រាយព្រៃនិងចាប់ផ្ដើមសិក្សាស្រាវជ្រាវជាបន្តបន្ទាប់។

នៅឆ្នាំ១៩៣១-១៩៣៦ ការជួសជុលទ្រង់ទ្រាយធំ តាមបច្ចេកទេសអាណាស្ទីឡូ ក៏បានចាប់ផ្ដើមឡើង ដែលដឹកនាំដោយលោក Henry Marchal។

នៅឆ្នាំ២០០៥ ប្រទេសស្វីសនិងអាជ្ញាធរជាតិអប្សរាបានសហការធ្វើកំណាយស្រាវជ្រាវសង្គ្រោះប្រាសាទដើម្បីរក្សាសោភ័ណភាពពីបុរាណ ហើយរៀបចំជាទីលានបដិសណ្ឋារកិច្ចដំបូងគេនៅឧទ្យានអង្គរ។

ឆ្នាំ២០១៦ អាជ្ញាធរជាតិអប្សរាបានជួសជុលពង្រឹងរចនាសម្ពន្ធខ្លោងទ្វារនិងកំពែងថ្មបាយក្រៀម ដោយរក្សាទម្រង់ដើមរបស់សំណង់ និងគិតអំពីការប្រើប្រាស់បច្ចេកទេសបុរាណឡើងវិញ រួមទាំងសម្ភារនិងប្រវត្តិនៃសំណង់ជាដើម។ ទោះជាយ៉ាងណា បន្ទាយស្រីក៏នៅមានរចនាសម្ពន្ធជាច្រើនទៀតដែលមិនទាន់បានជួសជុលហើយទាមទារការអភិរក្សជួសជុលជាបន្តទៀត៕

ចរាចរណ៍ចេញចូលប្រាសាទអង្គរវត្តតាមស្ពានហាលខាងលិច នឹងអាចចាប់ផ្តើមឡើងវិញ នៅខែសីហា ឆ្នាំ២០២១

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០

តាមការអះអាងរបស់អ្នកជំនាញទទួលបន្ទុកការជួសជុលស្ពានហាលខាងលិចប្រាសាទអង្គរបានឱ្យដឹងថា ចរាចរណ៍ចេញចូលប្រាសាទអង្គរវត្តតាមស្ពានហាលខាងលិចអាចនឹងចាប់ផ្តើមឡើងវិញនៅខែសីហា ឆ្នាំ២០២១ ខាងមុខ។

ការអះអាងបែបនេះគឺបន្ទាប់ពីកិច្ចប្រជុំបច្ចេកទេសរវាងអ្នកជំនាញអាជ្ញាធរជាតិអប្សរានិងសាកលវិទ្យាល័យសូហ្វីយ៉ា ប្រទេសជប៉ុន បានសម្រេចផែនការបច្ចេកទេសជួសជុលនាពេលថ្មីៗនេះ។

ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរជាតិអប្សរានិងសាកលវិទ្យាល័យសូហ្វីយ៉ា ក៏នៅតែបន្តការជួសជុលស្ពានហាលនេះរហូតដល់រួចរាល់ទាំងស្រុងទៅតាមការគ្រោងទុក៕

អាជ្ញាធរជាតិអប្សរាបើកវគ្គបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋមដល់សិក្ខាកាមចំនួន១២០នាក់

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០

មជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរនៃអាជ្ញាជាតិអប្សរា បានរៀបចំពិធីបើកវគ្គបណ្តុះបណ្តាលវិជ្ជាសង្គ្រោះបឋមរយៈពេល១ខែ ចាប់ពីខែតុលាដល់ខែវិច្ឆិកា ឆ្នាំ២០២០ ដល់សិក្ខាកាមចំនួន១២០នាក់ មកពីនាយក ដ្ឋានគ្រប់គ្រងទឹក នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ និងនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌និងបរិស្ថាន។

វគ្គបណ្តុះបណ្តាលនេះបង្រៀនដោយមន្ត្រីជំនាញផ្នែកវិជ្ជាសង្គ្រោះបឋមប្រចាំសាខាកាកបាទក្រហមកម្ពុជា ខេត្តសៀមរាបនិងគ្រូបង្គោលវិជ្ជាសង្គ្រោះបឋមជំនាន់ទី១ នៃអាជ្ញាធរជាតិអប្សរា ក្នុងគោលបំណងបញ្ជ្រាបការយល់ដឹង និងកសាងសមត្ថភាពបុគ្គលិក ភ្នាក់ងារ និងពលករនៃអាជ្ញាធរជាតិអប្សរា ដែលកំពុងបំពេញការងារនៅតាមការដ្ឋាន តំបន់ប្រាសាទ និងក្នុងព្រៃ ដើម្បីបង្ការនិងសង្គ្រោះភ្ញៀវទេសចរ មនុស្សជុំវិញខ្លួនពីគ្រោះថ្នាក់ដោយថាហេតុណាមួយដែលអាចនឹងកើតមានឡើងនៅពេលបំពេញការងារ។

កញ្ញា ហ៊ែរ រិទ្ធារី ប្រធានស្តីទីមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ ឱ្យដឹងថា រយៈពេល១ខែនៃវគ្គបណ្តុះបណ្តាលនេះ រៀបចំឡើងចំនួន០៦វគ្គ ក្នុង១វគ្គមានសិក្ខាកាមចំនួន២០នាក់ មកពីនាយកដ្ឋានគោលដៅបំពេញការងារសំខាន់ៗក្នុងនិងក្រៅតំបន់អង្គរ។ មេរៀនសំខាន់ៗមាន៖ តួនាទីអ្នកសង្គ្រោះ គោលការណ៍គ្រឹះ ស្ថានភាពជំណោក សន្លប់ CPR ស្លាក់ លង់ទឹក គ្រោះថ្នាក់ចរាចរណ៍ ការពុល ប្រកាច់ ពស់ចឹក ឆ្កែខាំ របួស ការហូរឈាមគ្រប់ប្រភេទ ការឃាត់ឈាម ការបាក់ឆ្អឹង ការដឹកជញ្ជូន និងករណីផ្សេងៗទៀត។ វគ្គបណ្តុះបណ្តាលនេះ ក៏អនុវត្តន៍ដោយគោរពទៅតាមគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាល ដើម្បីបង្ការជំងឺកូវីដ១៩ដែរ ដើម្បីសុវត្ថិភាពរបស់ក្រុមការងារគ្រប់គ្នា។

លោក លិវ ឡុន មន្ត្រីជំនាញផ្នែកវិជ្ជាសង្គ្រោះបឋមប្រចាំសាខាកាកបាទក្រហមកម្ពុជា ខេត្តសៀមរាបបានបញ្ជាក់ថា នេះជាលើកទី៥ហើយ ដែលសាខាកាកបាទក្រហមកម្ពុជា ខេត្តសៀមរាប បានសហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ រៀបចំវគ្គនេះឡើង។ នេះជាគំនិតដ៏ល្អបំផុត ដើម្បីរួមចំណែកផ្តល់ចំណេះដឹង ដល់សិក្ខាកាមទៅតាមចំណេះនិងជំនាញដែលខ្លួនមាន ដើម្បីឱ្យពួកគាត់យកទៅផ្សព្វផ្សាយបន្ត និងប្រើប្រាស់នូវចំណេះដឹងទាំងនេះឱ្យមានប្រយោជន៍ក្នុងការជួយសង្គ្រោះខ្លួនឯង និងមនុស្សជុំវិញខ្លួនប្រកបដោយប្រសិទ្ធិភាពខ្ពស់៕

អាជ្ញាធរជាតិអប្សរា គ្រោងដាំប្រភេទផ្កាព្រៃនៅតាមផ្លូវក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០

ជាចំណែកដើម្បីអភិរក្សពូជផ្កាព្រៃ ក៏ដូចជាការលម្អ និងទាក់ទាញភ្ញៀវទេសចរផងនោះ អាជ្ញាធរជាតិអប្សរា បាន និងកំពុងរៀបចំដាំដើមផ្កាព្រៃលម្អតាមបណ្តោយផ្លូវនានាក្នុងតំបន់រមណីយដ្ឋានអង្គរ។ បច្ចុប្បន្ន គម្រោងនេះកំពុងរៀបចំនៅបរិវេណខាងមុខប្រាសាទអង្គរវត្ត និងពង្រីកការរៀបចំនៅតំបន់ជុំវិញបន្ថែមទៀត។

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ជុំវិញការរៀបចំនេះយ៉ាងដូច្នេះថា អាជ្ញាធរជាតិអប្សរា មានផែនការគិតគូរពីការរៀបចំនេះរួចរាល់ហើយ ហើយគម្រោងនេះបានចាប់ផ្តើមមុនគេ នៅតាមផ្លូវមុខប្រាសាទអង្គរវត្ត ដែលដាំប្រភេទផ្កាព្រៃមួយចំនួនមានដូចជា ផ្កាក្រោក ចំប៉ី ត្របែកព្រៃ ផ្ការលួស និងផ្ការំដួលជាដើម។

ឯកឧត្តមអគ្គនាយកបន្ថែមថា ទៅថ្ងៃក្រោយអាជ្ញាធរជាតិអប្សរានឹងយកគំនិតនេះដើម្បីរៀបចំដាំនៅតាមបណ្តោយផ្លូវវង់តូចវង់ធំ គឺត្រូវមានផ្កាចម្រុះពណ៌ ដើម្បីជាទស្សនីយភាពកាន់តែទាក់ទាញដល់ភ្ញៀវទេសចរពេលជិះកាត់តាមផ្លូវទាំងនោះ។

ថ្លែងប្រាប់ក្រុមអ្នកសារព័ត៌មានកាលពីពេលថ្មីៗ នៅមុខប្រាសាទអង្គរវត្ត ក្នុងពិធីដាំដើមឈ្មៅជាមួយព្រះសង្ឃ **ឯកឧត្តម ហង់ ពៅ** បានបន្ថែមថា ក្រៅពីកិច្ចការការអភិរក្សពូជផ្កាព្រៃហើយ ក្នុងនោះអាជ្ញាធរជាតិអប្សរា ក៏បានគិតពីពូជផ្កាណាដែលមានក្លិនក្រអូបផងដែរ ដែលក្លិនរបស់វាជាចំណែកមួយក្នុងការទាក់ទាញ និងធ្វើឱ្យទេសចរមានអារម្មណ៍ល្អពេលដើរកាត់សួនផ្កាទាំងនោះ៕

លិខិតជូនពរលោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា នាឱកាសខួបកំណើតគម្រប់៦០ឆ្នាំឈានចូល៦១ឆ្នាំ

ផ្សាយនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០

យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកប្រោសប្រទានពរជ័យ សិរីមង្គលវិបុលសុខ មហាប្រសើរ ជូនចំពោះលោក **ជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា** រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិអប្សរា នាឱកាសខួបកំណើតគម្រប់៦០ឆ្នាំ ឈានចូល៦១ឆ្នាំ សូមលោកជំទាវបណ្ឌិត្យសភាចារ្យ ព្រមទាំងក្រុមគ្រួសារជួបប្រទះតែសេចក្តីសុខចម្រើននិងសុភមង្គល ព្រមទាំងបានសមប្រកបនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

អាជ្ញាធរជាតិអប្សរាសម្រេចបញ្ឈប់បុគ្គលិកដែលប្រព្រឹត្តិខុសនឹងច្បាប់ចេញពីស្ថាប័ន

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០

យោងតាមសេចក្តីសម្រេចរបស់អគ្គនាយកអាជ្ញាធរជាតិអប្សរា ចុះហត្ថលេខាថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ បានសម្រេចលុបឈ្មោះ លោក សៀវ សុមិត្រា ជាបុគ្គលិកបម្រើការងារនៅក្នុងនាយកដ្ឋានសណ្តាប់ធ្នាប់និងកិច្ចសហប្រតិបត្តិការ ដែលប្រព្រឹត្តិខុសធ្ងន់ធ្ងរនឹងច្បាប់ស្ថាប័ន ក៏ដូចជាច្បាប់សង្គម ចេញពីស្ថាប័នអាជ្ញាធរជាតិអប្សរាជាស្ថាពរចាប់ពីថ្ងៃចេញផ្សាយសេចក្តីជូនដំណឹងនេះតទៅ។

ករណីបុគ្គល សៀវ សុមិត្រា ប្រព្រឹត្តិនូវកំហុសឆ្គងអ្វីផ្សេង អំពីថ្ងៃនេះទៅ ពុំទាក់ទងនឹងស្ថាប័នអាជ្ញាធរជាតិអប្សរាទៀតឡើយ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខៈ ២២៧/ឥប-សសរ/២០

សេចក្តីសម្រេច
ស្តីពី
ការលុបឈ្មោះបុគ្គលិក នៃអាជ្ញាធរជាតិអប្សរា
អគ្គនាយកអាជ្ញាធរជាតិអប្សរា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៣ ចុះថ្ងៃទី២០ ខែកម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិអប្សរាជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា
- លិខិតលេខ៣៧៥/២០ ន.ស.ស ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ របស់នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ

សម្រេច

ប្រការ១ ៖ លុបឈ្មោះលោក **សៀវ សុមិត្រា** បុគ្គលិកនៅនាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ នៃអាជ្ញាធរជាតិអប្សរា គិតចាប់ពីថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០ តទៅ ដោយមូលហេតុប្រព្រឹត្តបទល្មើសជាក់ស្តែងផ្ទុយពីច្បាប់។

ប្រការ២ ៖ រាល់សេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

ប្រការ៣ ៖ នាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ នាយកដ្ឋានហិរញ្ញកិច្ច និងគណនេយ្យ នាយកដ្ឋានសណ្តាប់ធ្នាប់ និងសហប្រតិបត្តិការ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ៥ រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
អង្គរ ថ្ងៃទី០៧ ខែតុលា ឆ្នាំ២០២០
អគ្គនាយក
ហង់ ពៅ

ចម្លងជូន៖
- ដូចប្រការ៣ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋានៈ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពារបេតិកភណ្ឌ និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

Scanned with CamScanner

អគ្គនាយកអាជ្ញាធរជាតិអប្សរាដឹកនាំក្រុមការងារចុះពិនិត្យការដ្ឋានមួយចំនួន ក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី៨ ខែតុលា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំក្រុមការងារចុះពិនិត្យមើលការដ្ឋានមួយចំនួន ក្នុងតំបន់រមណីយដ្ឋានអង្គរ។ គោលបំណងសំខាន់ គឺដើម្បីពិនិត្យ តាមដាន និងសុំយោបល់សម្រេចជារួមលើកិច្ចការអភិរក្ស និងអភិវឌ្ឍន៍នានាក្នុងតំបន់រមណីយដ្ឋានអង្គរ។

ក្រុមការងារ បានជួបជុំគ្នានៅទីតាំងយានដ្ឋានរបស់អាជ្ញាធរជាតិអប្សរា ក្នុងនោះ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរាបានជំរុញឱ្យរៀបចំនិងកែប្រែយានដ្ឋានឱ្យមានរបៀបរៀបរយ និងពង្រឹងផ្នែកសុវត្ថិភាពឱ្យកាន់តែល្អប្រសើរ។

បន្ទាប់មកក្រុមការបានអញ្ជើញទៅពិនិត្យការងារនៅមុខព្រះលានជល់ដំរីដោយផ្តោតលើការសហការគ្នាពិនិត្យមើលគម្រោងកែលម្អនៅទីនោះ៕

អាជ្ញាធរជាតិអប្សរារៀបចំផ្លូវចូលរមណីយដ្ឋានភ្នំក្បាលស្ពានដែលរងការបំផ្លាញដោយសារទឹកភ្លៀង

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០

ផ្លូវចូលនិងផ្លូវត្រង់ចំណុចអូរឆ្លងស្ពានឡើងទៅលើរមណីយដ្ឋានភ្នំក្បាលស្ពាន បានរងការខូចខាតជាខ្លាំងដោយសារទឹកភ្លៀងនារដូវវស្សានេះ បណ្តាលឱ្យមានទឹកដក់ មានគ្រលុក ខូចផ្លូវ ពិបាកក្នុងការធ្វើដំណើរចេញចូល។

អាជ្ញាធរជាតិអប្សរាក្រោមការអនុវត្តការងារផ្ទាល់ពីនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ កាលពីថ្ងៃទី០២ដល់ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២០ បានរៀបចំបំពេញដីលើផ្លូវដែលខូចខាត លុបគ្រលុកទឹកដក់ និងកន្លែងទឹកភ្លៀងហូរច្រោះ ឱ្យមានភាពរាបស្មើ ជាប់មាំជាងមុន ដើម្បីបង្កភាពងាយស្រួលដល់ភ្ញៀវទេសចរធ្វើដំណើរនិងរក្សាសោភ័ណភាពនៃរមណីយដ្ឋាននេះ៕

រយៈពេល២ថ្ងៃ ក្រុមសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៦០សំណើ

ផ្សាយនៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០២០

ថ្ងៃទី៦ និងទី៧ ខែតុលា ឆ្នាំ២០២០ ក្រុមការសហគមន៍ចំនួន ៤គោលដៅ ដោយមានការចូលរួមជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៦០សំណើ។

ក្រុមសហគមន៍ប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយចំនួន០៨សំណើ ស្ថិតក្នុងភូមិគិរីមានន្ទ ភូមិគោកចាន់ ភូមិតាប៉ាង ភូមិត្រពាំងរុន និងភូមិត្នោត ឃុំអំពិល ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតទាំង០៨សំណើ។ ក្រុមសហគមន៍ប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយចំនួន៤៤សំណើ ស្ថិតក្នុងភូមិសំរោង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៣៨សំណើ។

ក្រុមសហគមន៍ប្រចាំស្រុកពួកដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយចំនួន០៩សំណើ ស្ថិតក្នុងភូមិគោកស្នួល ភូមិគោកត្រាច ភូមិខ្នាត និងភូមិប្រឡាយ ឃុំខ្នាត ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាត០៦សំណើ។ ក្រុមសហគមន៍ប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម ខ្ញុយ តឹមទូ** បានពិនិត្យ និងដោះស្រាយចំនួន១៣សំណើ ស្ថិតក្នុងភូមិអារក្សស្វាយ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន០៨សំណើ។

សរុបមក ទាំងពីរថ្ងៃ ក្រុមសហគមន៍ទាំង៤គោលដៅបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៦០សំណើ ក្នុងចំនួន ៧៤សំណើ៕

ក្រុមការងាររៀបចំទីលានបដិសណ្ឋារកិច្ចមុខអង្គរវត្តបន្តរៀបចំអគារផ្តល់ព័ត៌មាន និងបកស្រាយវប្បធម៌

ផ្សាយនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី៩ ខែតុលា ឆ្នាំ២០២០ ក្រុមការងាររៀបចំទីលានបដិសណ្ឋារកិច្ចមុខប្រាសាទអង្គរវត្ត បន្តប្រជុំពិភាក្សាលើការរៀបចំកន្លែងអគារផ្តល់ព័ត៌មាន និងបកស្រាយវប្បធម៌ ព្រមទាំងបានចុះទៅពិនិត្យមើលទីតាំងអគារ និងសិក្សាទៅលើខ្លឹមសារ និងការរចនារៀបចំយ៉ាងណាឱ្យមានភាពទាក់ទាញ និងអាចផ្តល់នូវការយល់ដឹងទូលំទូលាយអំពីអង្គរជូនដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិ ។



ឯកឧត្តម យិត ចាន់ដារ៉ូ អគ្គនាយករងអាជ្ញាធរជាតិអប្សរា ដែលដឹកនាំកិច្ចប្រជុំនៅពេលនោះ មានប្រសាសន៍ថា មកដល់បច្ចុប្បន្ននេះ ការរៀបចំទីលានបដិសណ្ឋារកិច្ចមុខអង្គរវត្ត កំពុងដំណើរការដោយរលូន និងសម្រេចបាននូវសមិទ្ធផលច្រើនគួរជាទីមោទន។ បើតាមការបញ្ជាក់ពីឯកឧត្តមអគ្គនាយករង បច្ចុប្បន្នអាជ្ញាធរជាតិអប្សរាបានបើកឱ្យអ្នកលក់ដូរក្នុងស្រុកដែលផ្លាស់ពីមុខអង្គរនិងត្រពាំងសេស អាចចូលលក់នៅទីតាំងថ្មីដែលមានសោភ័ណ ផាសុកភាព និងរបៀបរៀបរយ បានដាក់ឱ្យដំណើរការនៃបង្គន់អនាម័យដ៏ទំនើប រៀបចំផ្លូវដើរមុខអង្គរ និងកំពុងដំណើរការចាត់កៅស៊ូផ្លូវថ្នល់ ព្រមទាំងរៀបចំសួនច្បារដ៏ស្រស់ស្អាត។

លោកជំទាវ ចៅ ស៊ុនគិរិយា ទីប្រឹក្សាក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បម្រើការងារនៅអាជ្ញាធរជាតិអប្សរា ដែលមានបទពិសោធន៍រៀបចំទីលានបដិសណ្ឋារកិច្ចនៅប្រាសាទបន្ទាយស្រី និងកំពុងចូលរួមផ្តល់ប្រឹក្សាយោបល់លើគម្រោងខាងលើនេះ មានចំណាប់អារម្មណ៍ថា ទីលានបដិសណ្ឋារកិច្ចនៅតាមប្រាសាទមួយៗ គឺសំខាន់ណាស់ ហើយការរៀបចំនៅអង្គរវត្តកាន់តែពិសេស ព្រោះជាមុខមាត់របស់ប្រទេសជាតិ ក៏ដូចជាតំណាងឱ្យបេតិកភណ្ឌជាតិទាំងមូល។ លោកជំទាវបន្ថែមថា បំណងសំខាន់នៃការរៀបចំទីលាននេះ គឺដើម្បីបញ្ចៀសការកកស្ទះរបស់ទេសចរ និងធ្វើឱ្យទេសចរមានអារម្មណ៍សប្បាយរីករាយពេលមកទស្សនាប្រាសាទអង្គរវត្ត ក៏ដូចជាបានស្វែងយល់ពីប្រវត្តិសាស្ត្រ អារ្យធម៌ និងវប្បធម៌ក្នុងតំបន់រមណីយដ្ឋានអង្គរទាំងមូល៕

អាជីវករសម្ដែងការរីករាយនឹងកន្លែងលក់ដូរថ្មីនៅទីលានបដិសណ្ឋារកិច្ចប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០២០

បន្ទាប់ពីបើកឱ្យ ដំណើរការលក់ដូរនៅទីតាំងថ្មីនៅក្នុងទីលានបដិសណ្ឋារកិច្ចនៃប្រាសាទអង្គរវត្ត តាំងពីដើមខែកញ្ញា ឆ្នាំ២០២០មក អាជីវករលក់ម្ហូបអាហារ វត្ថុអនុស្សាវរីយ៍ សម្លៀកបំពាក់និងភេសជ្ជៈបានសម្ដែងការរីករាយដែលបានចូលមកកាន់ទីតាំងថ្មី ដែលមានបរិស្ថានល្អ កន្លែងលក់ដូរស្អាត និងមានអនាម័យជាងមុន។

អ្នកស្រី ស៊ត់ អាជីវករលក់ម្ហូបអាហារ បានចាប់ផ្ដើមលក់នាពាក់កណ្ដាលខែកញ្ញា បានលើកឡើងចំពោះ ទីតាំងថ្មីថា នៅទីនេះមានភាពងាយស្រួលជាងមុន ទាំងការលក់ដូរមានទឹក មានភ្លើង កន្លែងស្អាត មានអនាម័យ ទុកដាក់សម្ភារមានវត្ថិភាព និងមិនបាច់ចំណាយកម្លាំងហត់នឿយក្នុងការរៀបចំកន្លែង។អ្នកស្រីបានថ្លែងអរគុណដល់អាជ្ញាធរជាតិអប្សរាដែលបានរៀបចំពីកន្លែងមិនស្អាត មកកន្លែងដែលមានអនាម័យ បរិស្ថានល្អ។ អ្នកស្រីសង្ឃឹមថា ពេលចប់ជំងឺកូវីដ១៩ នឹងមានភ្ញៀវមកលេងច្រើននិងការលក់ដូរបានដាច់ស្រួល។

ជាអាជីវករលក់ដូរសម្លៀកបំពាក់និងវត្ថុអនុស្សាវរីយ៍ជិត ២០ឆ្នាំមកហើយ អ្នកស្រី គីម សុខវីន បានមកលក់កន្លែងថ្មីនៅអំឡុងខែកញ្ញាដែរបានឱ្យដឹងថាតូបថ្មីតូចជាងមុនបន្តិចមែន តែគ្មានដីហុយ មិនធ្វើឱ្យប្រឡាក់សម្លៀកបំពាក់និងវត្ថុអនុស្សាវរីយ៍ដូចកន្លែងចាស់ ងាយស្រួលក្នុងការលក់ដូរមានអនាម័យ ការទុកដាក់អីវ៉ាន់ក៏ស្រួល មានសុវត្ថិភាព មានសន្តិសុខ ទឹកភ្លើង។ អ្នកស្រីពេញចិត្តណាស់ចំពោះទីតាំងថ្មី និងអរគុណដល់អាជ្ញាធរជាតិអប្សរាដែលរៀបចំកន្លែងលក់ដូរស្អាត បរិស្ថានល្អ និងការកែលម្អផ្សេងៗនៅអង្គរវត្តយ៉ាងស្រស់បំព្រង។

ចាប់អាជីពជាអ្នកលក់គុយទាវជាង២០ឆ្នាំមកហើយនៅមុខបរិវេណប្រាសាទអង្គរវត្តអ្នកស្រីចាក៏សប្បាយរីករាយដែលបានមកកាន់ទីតាំងថ្មី ជាកន្លែងស្អាត រៀបចំបានល្អ មានសណ្ដាប់ធ្នាប់ និងសុវត្ថិភាពជាងកន្លែងចាស់៕

ទឹកជាច្រើនលានម៉ែត្រគូបត្រូវបានប្រមូលរក្សាទុក

ផ្សាយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០

ទឹកជាច្រើនលានម៉ែត្រគូប ត្រូវបានអាជ្ញាធរជាតិអប្សរា ប្រមូលរក្សាទុកនៅតាមអាងស្តុកទឹកនានាក្នុងតំបន់រមណីយដ្ឋានអង្គរ បន្ទាប់ពីកម្ពុជាមានភ្លៀងធ្លាក់ជាបន្តបន្ទាប់ដោយសារការរងនូវឥទ្ធិពលព្យុះ ពីតំបន់ជុំវិញនារយៈពេលចុងក្រោយនេះ។ក្នុងការងារនេះអាជ្ញាធរជាតិអប្សរាបានបង្ហាញនូវអារម្មណ៍ជាទីមោទនបំផុត ក្នុងការប្រមូលទឹកស្តុកទុកដើម្បីបម្រើកិច្ចការអភិរក្សប្រាសាទ ក៏ដូចជាត្រៀមសម្រាប់ចែកចាយដល់ប្រជាពលរដ្ឋក្នុងតំបន់សម្រាប់ប្រើប្រាស់នារដូវប្រាំងខាងមុខនេះ។

លោក គឿន សុឃីម អនុប្រធាននាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា ឱ្យដឹងថា នាពេលបច្ចុប្បន្ននេះ ក្រុមការងាររបស់លោកបានខិតខំ និងប្រមូលទឹកស្តុកទុក ស្ទើរពេញទាំងស្រុងនៅតាមកសិន្ធុអង្គរវត្ត កសិន្ធុក្រុងអង្គរធំ បារាយណ៍ខាងជើង បារាយណ៍ខាងលិច និងតាមទំនប់នានា ដោយរំពឹងថា នារដូវប្រាំងខាងមុខនេះ ពុំមានកង្វះទឹកប្រើប្រាស់ឡើយ។ លោកបន្ថែមថា កម្រិតទឹកដែលបានបញ្ចូលនៅពេលនេះ គឺស្ថិតក្នុងកម្រិតអតិបរិមា។

លោកគឿន សុឃីម ពន្យល់បន្ថែមថា ក្រោយពីអាជ្ញាធរជាតិអប្សរារៀបចំស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្របុរាណមក គឺការងារគ្រប់គ្រងទឹកមានភាពងាយស្រួល ពិសេសបញ្ចៀសទឹកភ្លៀងមិនឱ្យជន់លិចតំបន់អង្គរនិងក្នុងក្រុងសៀមរាប។ ការងារបញ្ចៀសទឹកនេះ គឺអ្នកជំនាញទឹករបស់អាជ្ញាធរជាតិ

អប្សរា បានធ្វើការបង្វែរទម្លាក់ទៅតាមដៃស្ទឹងមួយចំនួន ក៏ដូចជាតាមប្រឡាយជាដើម។

យ៉ាងណាក៏ដោយ ដ្បិតថាអ្នកជំនាញទឹករបស់អាជ្ញាធរជាតិអប្សរា បានព្យាករណ៍ថា នារដូវប្រាំងឆ្នាំនេះអាចពុំមានកង្វះទឹកប្រើប្រាស់ក្នុងតំបន់យ៉ាងណាក្តី តែបានស្នើឱ្យពលរដ្ឋទាំងអស់គួរប្រើប្រាស់ទឹកដោយការសន្សំសំចៃខ្ពស់។

លោក គឿន សុឃីម ពន្យល់ថា អាកាសធាតុនៅលើពិភពលោកមានការប្រែប្រួលហើយទឹកមានសារសំខាន់សម្រាប់ជីវិតមនុស្សសត្វ ដូច្នេះយើងត្រូវប្រើប្រាស់ដោយការសន្សំសំចៃ ជៀសវាងការខ្វះខាត៕

សកម្មភាពកម្មករដឹកជញ្ជូនថ្មទៅជួសជុលប្រាសាទកណ្ដាលស្រះស្រង់

ផ្សាយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០

ប្រាសាទកណ្ដាលស្រះស្រង់ បានដំណើរការជួសជុលឱ្យមានរូបរាងឡើងវិញកាលពីអំឡុងខែឧសភា ឆ្នាំ២០២០ ដោយអ្នកជំនាញអាជ្ញាធរជាតិអប្សរា។ មកដល់ពេលនេះ ក្រុមការងារបានរៀបគ្រឹះប្រាសាទជិតរួចរាល់ហើយ។

ទាក់ទងនឹងការជួសជុលប្រាសាទនៅកណ្ដាលស្រះស្រង់ ជួបប្រទះការលំបាកបំផុត គឺការដឹកជញ្ជូនសម្ភារយកទៅការដ្ឋាន ព្រោះប្រាសាទនេះហ៊ុំព័ទ្ធទៅដោយទឹកស្រះស្រង់។ប៉ុន្តែទោះជាយ៉ាងណាក្រុមការងារបានប្រើរទេះរុញ និងក្បូនដើម្បីជញ្ជូនថ្មម្ដងមួយៗយកទៅជួសជុល។

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យប្រព័ន្ធទ្វាររំដោះទឹកក្នុងតំបន់រមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០

ថ្ងៃទី១១ ខែតុលា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកនៃអាជ្ញាធរជាតិអប្សរានិងសហការី បានចុះពិនិត្យស្ថានភាពទឹកក្នុងតំបន់រមណីយដ្ឋានអង្គរ។

ក្នុងការគ្រប់គ្រងទឹកក្នុងតំបន់រមណីយដ្ឋានអង្គរនេះដែរ បានប្រើប្រាស់ធារាសាស្ត្របុរាណឡើងវិញដើម្បីចែកចាយទឹកទៅទីតាំងផ្សេងៗ និងកន្លែងដែលចាំបាច់នានា ជាពិសេសបានបញ្ចៀសទឹកជំនន់ក្នុងតំបន់ប្រាសាទ និងក្រុងសៀមរាប រួមទាំងប្រមូលទឹកយកទៅរក្សាទុកនៅបារាយណ៍ធំៗក្នុងរមណីយដ្ឋានអង្គរដែលជាអាងស្តុកទឹកនាសម័យបុរាណ។

ម្យ៉ាងទៀត ដោយយល់ឃើញថាស្ទឹងរលួសមានទឹកកើនច្រើន អាជ្ញាធរជាតិអប្សរាបានប្រើប្រព័ន្ធធារាសាស្ត្របុរាណនេះដើម្បីរំលែកទឹកខ្លះមកស្ទឹងសៀមរាបក្នុងការបញ្ជូនបន្តទៅផ្នែកខាងក្រោមនិងទៅដល់ទន្លេសាប៕

ព្រះចៅអធិការវត្តព្រះឥន្ទ្រទេពប្រគល់បំណែកបដិមាចំនួន៤១ដុំជូនអាជ្ញាធរជាតិអប្សរារក្សាទុក

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០

បំណែកបដិមានិងថ្មចម្លាក់ចំនួន៤១ដុំ ត្រូវបានបានព្រះចៅអធិការវត្តព្រះឥន្ទទេព ព្រះនាម សែម សំ ពេញព្រះទ័យប្រគល់ជូនអាជ្ញាធរជាតិអប្សរាថែរក្សា ក្រោយពីព្រះអង្គបានប្រមូលយកទៅរក្សាទុកបណ្តោះអាសន្ននៅក្នុងបរិវេណវត្តដែលស្ថិតនៅជ្រុងអាគ្នេយ៍នៃប្រាសាទបាយ័ន្ត។

ទាក់ទងនឹងការរក្សាវត្ថុបុរាណនេះទុក តាមព្រះចៅអធិការ សែម សំ មានសង្ឃដីកាថា ដើមឡើយបំណែកចម្លាក់ទាំង៤១ដុំនេះ ស្ថិតនៅរាយប៉ាយក្នុងបរិវេណវត្តព្រះឥន្ទទេព ហើយខ្លះទៀតនៅផ្នែកខាងក្រោយនៃខឿនព្រះអង្គទេព។ ដូច្នេះដើម្បីឱ្យមានសុវត្ថិភាពព្រះអង្គក៏បានប្រមូលយកមករក្សាទុកនៅក្នុរោងផ្នែកខាងត្បូងវត្ត ការពារការបាត់បង់និងខូចខាតដោយប្រការផ្សេងៗ។

លោក ឈូក សុម៉ាឡា មន្ត្រីក្រុមចុះបញ្ជីសារពើភណ្ឌនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការនៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា ក្នុងចំណោមចម្លាក់ទាំងនេះ មានមួយចំនួនធំជាព្រះពុទ្ធបដិមាដែលនៅសល់តែព្រះភ្នែននិងបល្ល័ង្គផ្កាឈូក ឯខ្លះទៀតឃើញមានត្រឹមព្រះបាទទ្រង់ឈរលើជើងទម្រប៉ុណ្ណោះ។

តាមការពិនិត្យឃើញថា ព្រះពុទ្ធបដិមាទាំងនេះ មានខ្លះស្ថិតនៅក្នុងរចនាបថបាយ័ន្តប្រហែលនាចុងសតវត្សរ៍ទី១២ទៅដើម១៣ និងខ្លះទៀតស្ថិតនៅក្នុងរចនាបថសម័យកណ្តាលប្រហែលជានៅសតវត្សរ៍ទី១៥ឬទី១៦។

បន្ទាប់ពីបានទទួលដំណឹងពីក្រុមសម្ភកិច្ចការពារបេតិកភណ្ឌតំបន់អង្គរ ក្រុមចុះបញ្ជីសារពើភណ្ឌ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ និងអាជ្ញាធរអប្សរាបានចុះទៅទទួលបំណែកបដិមាខាងលើ មករក្សាទុកនៅការិយាល័យនាយកដ្ឋាននៃអាជ្ញាធរជាតិអប្សរា ដើម្បីធ្វើការងារចុះបញ្ជីថតរូបនិងពិពណ៌នាទុកជាឯកសារសម្រាប់ធ្វើការជួសជុលនៅថ្ងៃក្រោយ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន២៥សំណើ

ផ្សាយនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០

ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅ មានការចូលរួមជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយចំនួន ១៨សំណើ ស្ថិតក្នុងភូមិលាងដៃ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន១៤សំណើ។ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយចំនួន ១០សំណើ ស្ថិតក្នុង ភូមិគោកត្រាចភូមិព្រៃធ្លក ភូមិប្រឡាយ ភូមិអំពិលពាម ភូមិស្វាយ ភូមិជ្រលង ស្ថិតក្នុងភូមិសំរោង ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានចុះពិនិត្យ និងនិងដោះស្រាយចំនួន ចំនួន៨សំណើ ស្ថិតក្នុងភូមិ ភូមិថ្នល់ទទឹងនិង ភូមិតាកុះ ឃុំព្រះដាក់ ភូមិរំចេក ឃុំរំចេក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សូមបញ្ជាក់ថា ក្រុមការងារសហគមន៍ទាំង៣គោលដៅបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរដោយអនុញ្ញាតបានចំនួន២៥សំណើលើចំនួន៣៦សំណើ៕

រដ្ឋមន្ត្រីក្រសួងព័ត៌មានចុះសិក្សាស្វែងយល់ពីការងារអភិវឌ្ឍន៍នៅបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ជួន** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយអគ្គនាយករង ថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីបុគ្គលិក បានចូលរួមគោរពព្រះវិញ្ញាណក្ខន្ធថ្វាយ **ព្រះរាជកុសលព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ខួបសោយទិវង្គត៨ព្រះវស្សានៅព្រះរាជដំណាក់ខេត្តសៀមរាប។

ក្នុងឱកាសដ៏ក្រៀមក្រំនេះ តាំងនាមឱ្យថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា សូមសម្តែងព្រះរាជមរណទុក្ខយ៉ាងក្រៀមក្រំបំផុត ចំពោះការយាងចូលទិវង្គតរបស់សម្តេចតា សម្តេចទួត ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ និងបង្រួបបង្រួមជាតិខ្មែរ។

អាជ្ញាធរជាតិអប្សរា ចងចាំជានិច្ចនូវរាល់ស្នាព្រះហស្ថ ព្រះរាជបូជនីយកិច្ច និងគុណូបការៈដ៏ធំធេងរបស់ព្រះអង្គ ដែលបានលះបង់ព្រះកាយពល ព្រះបញ្ញាញាណ ដើម្បីបូរណភាពទឹកដីកម្ពុជា ក៏ដូចជាព្រះរាជកិច្ចដាក់បញ្ចូលតំបន់អង្គរជាបេតិកភណ្ឌពិភពលោករហូតដល់សព្វថ្ងៃនេះ៕

សូមថ្វាយមហាព្រះរាជកុសល
ព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ
"ព្រះបរមរតនកោដ្ឋ"

ផ្សាយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០

យើងខ្ញុំជាកូន ចៅ ចៅទួត សូមថ្វាយមហាព្រះរាជកុសល ខួប៨ឆ្នាំការយាងសោយព្រះទិវង្គតនៃព្រះករុណាព្រះបាទ សម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" ១៥ តុលា ២០១២ - ១៥ តុលា ២០២០/៕



អាជ្ញាធរជាតិអប្សរាចូលរួមគោរពព្រះវិញ្ញាណក្ខន្ធថ្វាយព្រះរាជកុសល ព្រះបរមរតនកោដ្ឋខួបសោយទិវង្គត៨ព្រះវស្សា

ផ្សាយនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី១៥ ខែតុលា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយអគ្គនាយករង ថ្នាក់ដឹកនាំនាយកដ្ឋាន និងមន្ត្រីបុគ្គលិក បានចូលរួមគោរពព្រះវិញ្ញាណក្ខន្ធ ថ្វាយព្រះរាជកុសល **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ព្រះបរមរតនកោដ្ឋ ខួបសោយទិវង្គត៨ព្រះវស្សា នៅព្រះរាជដំណាក់ខេត្តសៀមរាប។

អាជ្ញាធរជាតិអប្សរា ចងចាំជានិច្ចនូវរាល់ស្នាព្រះហស្ថ ព្រះរាជបូជនីយកិច្ច និងគុណូបការៈដ៏ធំធេងរបស់ព្រះអង្គ ដែលបានលះបង់ព្រះកាយពល ព្រះបញ្ញាញាណ ដើម្បីបូរណភាពទឹកដីកម្ពុជា ក៏ដូចជាព្រះរាជកិច្ចដាក់បញ្ចូលតំបន់អង្គរជាបេតិកភណ្ឌពិភពលោករហូតដល់សព្វថ្ងៃនេះ៕

ក្នុងឱកាសដ៏ក្រៀមក្រំនេះ តាំងនាមឱ្យថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា សូមសម្តែងព្រះរាជមរណទុក្ខយ៉ាងក្រៀមក្រំបំផុត ចំពោះការយាងចូលទិវង្គតរបស់សម្តេចតា សម្តេចតាទួត **ព្រះបាទសម្តេចព្រះនរោត្តម សីហនុ** ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ និងបង្រួបបង្រួមជាតិខ្មែរ។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ប្រចាំក្រុងសៀមរាបចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋបាន៨សំណើ

ផ្សាយនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០

ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ក្រុមការងារសហគមន៍ប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម ខូយ តឹមឆ្ន** ដែលមានការចូលរួមជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋចំនួន

១៤សំណើ ស្ថិតក្នុងភូមិវាល សង្កាត់គោកចក។ ក្រោយពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាត ០៨សំណើ៕

អាជ្ញាធរជាតិអប្សរាបណ្តុះនិងដាំដើមត្នោតរាប់ពាន់ដើមក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០២០

ដើមត្នោតគឺជាប្រភេទរុក្ខជាតិនិមិត្តរូបជាតិនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រភេទរុក្ខជាតិដែលមានសារសំខាន់ជាទីបំផុតសម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ។ គ្រប់ផ្នែកទាំងអស់នៃរុក្ខជាតិនេះអាចប្រើប្រាស់បានទៅតាមតម្រូវការជាក់ស្តែងក្នុងជីវភាពប្រចាំថ្ងៃ ព្រមទាំងអាចប្រើប្រាស់ជាសម្ភារផ្គុំសំណង់ផ្ទះ និងធ្វើជាទូកសម្រាប់ជាមធ្យោបាយធ្វើដំណើរតាមផ្លូវទឹកទៀតផង។

ដោយយល់ឃើញពីសារប្រយោជន៍នៃដើមត្នោត អាជ្ញាធរជាតិអប្សរាបានរៀបចំបណ្តុះនិងដាំដើមត្នោតឡើងវិញបានចំនួន៦០០០ដើមក្នុងរមណីយដ្ឋានអង្គរក្នុងរយៈពេល៤ឆ្នាំកន្លងមកនេះ។ នៅពេលធំ ត្នោតទាំងនោះមិនត្រឹមតែផ្តល់ជាប្រយោជន៍ដល់ប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គរប៉ុណ្ណោះទេ តែថែមទាំងបានបង្កើតជាទស្សនីយភាពវប្បធម៌ដ៏ល្អស្វាត្យទៀតផង។

អាជ្ញាធរជាតិអប្សរានឹងបន្តបណ្តុះនិងដាំកូនត្នោតទៀតឲ្យបានកាន់តែច្រើន៕

របៀបផ្តិតសិលាចារឹក

ផ្សាយនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០២០

ការងារផ្តិតសិលាចារឹកមិនតម្រូវទាល់តែជាអ្នកបច្ចេកទេសបុរាណវិទ្យាអ្នកប្រវត្តិសាស្ត្រឬអក្សរសាស្ត្រទើបអាចផ្តិតបាននោះឡើយ។ វាអាស្រ័យលើអ្នកដែលមានចិត្តអំណត់ និងប្រុងប្រយ័ត្ន ត្បិតអីត្រូវចំណាយពេលយូរ និងដំណើរការក៏ច្រើនដំណាក់កាល មួយទៀតសោតក្រដាសផ្តិតស្តើងពេលត្រូវទឹកផុយងាយរហែកណាស់។

សម្ភារសំខាន់ៗសម្រាប់ផ្តិតនិងសម្អាតសិលាចារឹកមានដូចជា ច្រាសមានដង ច្រាសដុសធ្មេញ ចង្កាក់ឈើ ដបបាញ់ទឹក ជក់ធំ កំណាត់ក្រាស់រមូលជាដុំ (សម្រាប់តប់ដេញខ្យល់) ស្កុតក្រដាស ទឹកខ្មៅប្រអប់ ទឹកខ្មៅដប ប៉ុងកំណាត់បីខ្នាតសម្រាប់តប់ទឹកថ្នាំ ក្រដាសផ្តិត២ប្រភេទ គឺក្រាស់និងស្តើង។

ទាក់ទងនឹងបច្ចេកទេសនៃការផ្តិតសិលាចារឹក លោក រិទ្ធ ភិរម្យ បុរាណវិទូនៃអាជ្ញាធរជាតិអប្សរាបានបញ្ជាក់ថា គឺអាស្រ័យនឹងស្ថានភាព ទីតាំង និងទំហំនៃសិលារឹក។ ដូច្នោះយើងត្រូវស្វែងយល់ពីលក្ខខណ្ឌទាំងអស់នេះសិន មុននឹងចុះទៅផ្តិត ថាសិលាចារឹកនោះជាថ្មគោលឬស្ថិតនៅលើមេទ្វារប្រាសាទ ជាប្រភេទអក្សរជ្រៅឬរាក់ ដែលអាចឱ្យយើងងាយត្រៀមប្រភេទ និងទំហំក្រដាសជាដើម។ មុនពេលផ្តិតយើងត្រូវមើលពីស្ថានភាពនៃថ្មចារឹក ថាតើមានជាប់ដីឬមានស្លែដុះ ជាហេតុនាំឱ្យរហែកនិងប្រឡាក់ក្រដាស។ ប្រសិនបើមានករណីនេះមែន ត្រូវសម្អាតដោយប្រើទឹកស្អាត ប្រើច្រាសទន់ដុសថ្នមៗលើផ្ទៃអក្សរ និងប្រើចង្កាក់ឬស្សីឆ្កឹះកំណកដីឬស្លែដែលជាប់ក្នុងតួអក្សរបើមាន។



បន្ថែមពីនោះ ក្រោយពេលសម្អាតរួចរាល់ហើយ ត្រូវទុកឱ្យថ្មស្ងួតបន្តិចសិនទើបយើងរៀបចំបិទក្រដាសផ្តិត ទៅលើផ្ទៃដែលមានអក្សរដោយប្រើស្កុតក្រដាសហើយក្រដាសដែលប្រើគឺអាស្រ័យនឹងប្រភេទអក្សរចារឹក បើអក្សរជ្រៅប្រើក្រដាសក្រាស់ តែបើរាក់ប្រើក្រដាសស្តើង។ ក្រដាសត្រូវលាតឱ្យធឹងល្អសិនមុននឹងបិទទៅនឹងថ្ម ធ្វើបែបនេះទើបមិនមានខ្យល់ច្រើននៅក្នុងក្រដាសពេលយើងបាញ់ទឹកលើក្រដាសនោះ។ ក្រោយពេលបាញ់ទឹកសព្វទាំងផ្ទៃក្រដាសហើយ យើងនឹងឃើញថាក្រដាសនឹងចាប់រាបជាប់ទៅនឹងសាច់ថ្ម ហើយនៅលើកន្លែងខ្លះទៀតពុំជាប់ដោយសារតែមានខ្យល់នៅក្នុងនោះ។ ហេតុដូច្នេះត្រូវយកខ្យល់ចេញឱ្យអស់ពីក្រដាស ព្រោះខ្យល់នេះហើយជាហេតុធ្វើឱ្យរហែកក្រដាសពេលយើងវាយក្រដាសបញ្ចូលក្នុងតួអក្សរដោយប្រើច្រាស។ ឆ្លៀតពេលដែលយើងកំពុងរៀបចំក្រដាស យើងត្រូវត្រៀមទឹកខ្មៅក្នុងប្រអប់យកទៅហាលថ្ងៃឱ្យស្រេច លុះដល់ក្រដាសរួចរាល់ ទឹកខ្មៅក៏រាវល្មមអាចផ្តិតបាន។

ចំពោះរបៀបយកខ្យល់ចេញពីក្រដាសវិញ យើងអាចប្រើឧបករណ៍ពីរប្រភេទ ទីមួយជក់ធំនិងទីពីរគឺកំណាត់ដែលរមូលជាដុំ។ យើងប្រើជក់ទៅគោះដេញតិចៗនៅកន្លែងដែលមានខ្យល់ គោះដេញពីផ្នែកកណ្តាលទៅគែមសងខាងនៃថ្មត្រូវគោះដោយប្រុងប្រយ័ត្នបំផុត ព្រោះក្រដាសសើមងាយនឹងរហែកឬច្បូត់មានស្នាម។ បន្ទាប់មកប្រើផ្ទៃរាបទាំងសងខាងនៃកំណាត់រមូលទៅតប់ពង្រាបក្រដាសមួយលើកទៀតជាការស្រេច។

ការងារបន្ទាប់មកទៀត គឺប្រើច្រាសជងវែងវាយផ្ទៃក្រដាស ដោយផ្តោតសំខាន់ត្រង់កន្លែងដែលមានអក្សរឬស្លាកស្នាមគូសវាសផ្សេងៗ។ ការធ្វើបែបនេះក្នុងគោលបំណងឱ្យសាច់ក្រដាសលិចចូលទៅក្នុងប្រឡោះអក្សរឱ្យបានសព្វល្អលុះពេលផ្តិតទឹកខ្មៅទៅគឺជាប់តែផ្ទៃខាងលើនៃក្រដាសប៉ុណ្ណោះ រីឯអក្សរវិញគឺពណ៌សមិនប្រឡាក់ទឹកថ្នាំឡើយ។ ក្រោយពេលវាយក្រដាសចូលក្នុងប្រឡោះអក្សរសព្វហើយ ត្រូវទុកក្រដាសឱ្យស្រពាប់បន្តិច (មិនឱ្យស្ងួតខ្លាំងទេ)ទើបអាចផ្តិតបានព្រោះបើសើមពេកធ្វើឱ្យទឹកថ្នាំរាច តែបើស្ងួតពេក ក្រដាសនឹងហើបចេញពីសាច់ថ្មមកវិញ។
បន្ទាប់មកទៀត ត្រូវរៀបចំសម្អាតប៉ុងកំណាត់ផ្តិតនិងជ្រើសខ្នាតក្រដាសតាមទំហំសិលាចារឹកដាក់ស្តែង ហើយប្រើប៉ុងកំណាត់ផ្តិតលើទឹកខ្មៅ និងប្រើប៉ុងមួយទៀតមករីគ្នាឱ្យសព្វសាច់ល្អហើយទើបអាចផ្តិតបាន ព្រោះបើពុំដូច្នោះទេពេលផ្តិតទៅនឹងចេញស្នាមដុំៗមិនស្មើសាច់ល្អទេ។ យើងត្រូវផ្តិតពីស្តាំមកឆ្វេងឬពីឆ្វេងមកស្តាំ និងពីលើចុះក្រោម ទៅតាមទំនោរអ្នកផ្តិត។ ត្រូវផ្តិតថ្នមៗដោយរលាស់ប៉ុងតិចៗផងពេលផ្តិតទើបវាស្មើសាច់ល្អ។ អនុវត្តវិធីខាងលើម្តងហើយម្តងទៀតរហូតឃើញថា ផ្ទៃក្រដាសខ្មៅសព្វល្អ តែមិនខ្មៅពេកដែលជាហេតុអាចប្រឡាក់ដល់ក្នុងអក្សរ។
លុះរួចរាល់ហើយទុកក្រដាសឱ្យស្ងួតបន្តិចទើបអាចបកបាន តែមិនឱ្យស្ងួតពេកទេ ព្រោះអាចធ្វើឱ្យក្រដាសស្អិតជាប់នឹងថ្ម នាំឱ្យរហែកពេលយើងបកចេញ។ ពេលបកចេញមកហើយ ក្រដាសត្រូវយកទៅហាលថ្ងៃនៅលើផ្ទៃរាបស្មើឱ្យស្ងួតល្អ។ បន្ទាប់មកត្រូវពិនិត្យលើផ្ទៃថ្មសិលាចារឹកម្តងទៀត ថាមានប្រឡាក់ទឹកខ្មៅឬអត់ បើមានត្រូវយកច្រាសដុសធ្មេញមកដុសសម្អាតថ្នមៗ និងបាញ់ជម្រះដោយប្រើទឹកស្អាត។ ការងារចុងក្រោយគេគឺចុះលេខK. ឈ្មោះ ទីតាំង ថ្ងៃខែ និងក្រុមការងារផ្តិត នៅខាងស្តាំផ្នែកខាងក្រោមនៃក្រដាសផ្តិត៕

អាជ្ញាធរជាតិអប្សរាយកចិត្តទុកដាក់លើសំណើសុំសាងសង់របស់ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

រយៈពេលពីរសប្តាហ៍នៃខែតុលា ឆ្នាំ២០២០នេះ ក្រុមការងារជំនាញនៃនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានចុះពិនិត្យលក្ខខណ្ឌនៃការរស់នៅ និងប្រើប្រាស់ទីតាំងស្នើសុំរបស់ប្រជាពលរដ្ឋ បានចំនួន៨៥ករណីរួមមាន៖ ក្រុងសៀមរាប ២៥ករណី ស្រុកបន្ទាយស្រី ១២ករណី ស្រុកអង្គរធំ ៦ករណី ស្រុកប្រាសាទបាគង ២៤ករណី ស្រុកពួក៧ករណី ស្រុកសូទ្រនិគម ៣ករណី និងស្រុកស្វាយលើ ៨ករណី។



ដោយឡែកក្នុងរយៈពេលដូចគ្នានេះដែរ ប្រជាពលរដ្ឋដែលមានលក្ខខណ្ឌគ្រប់គ្រាន់ដើម្បីទទួលបានការអនុញ្ញាត ក្រុមការងារផ្នែកស្ថាបត្យកម្មបានជួយរៀបចំគំនូសប្លង់បានចំនួន ៣៧ករណីរួមមាន៖ ស្រុកអង្គរធំ ៤ករណី ក្រុងសៀមរាប ១៣ករណី ស្រុកប្រាសាទបាគង ១៣ករណី ស្រុកបន្ទាយស្រី ៤ករណី ស្រុកពួក ១ករណី និងស្រុកស្វាយលើ ២ករណី៕

ស្ថានភាពទឹកក្នុងរមណីយដ្ឋានអង្គរស្ថិតក្រោមការគ្រប់គ្រង

ផ្សាយនៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០

ក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ ភ្លៀងយ៉ាងច្រើនបានធ្លាក់ចុះជាបន្តបន្ទាប់បណ្តាលឱ្យស្ថានភាពទឹកមានការកើនឡើងនៅភាគខាងជើងនៃរមណីយដ្ឋានអង្គរចាប់ពីម៉ោង៤ព្រឹក ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២០ និងបន្តធ្លាក់ចុះមកផ្នែកកណ្តាលនៃរមណីយដ្ឋានអង្គរ។

ប៉ុន្តែទោះជាយ៉ាងនេះក្តី អ្នកជំនាញផ្នែកគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាបានបង្វែរទឹកទាំងនោះឱ្យធ្លាក់បន្តចុះទៅផ្នែកខាងក្រោមតាមប្រព័ន្ធធារាសាស្ត្របុរាណដោយពុំឱ្យមានការជន់លិចក្នុងតំបន់ប្រាសាទនិងក្រុងសៀមរាបឡើយ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះប្រជាជនក្នុងឧទ្យានអង្គរបាន១០សំណើ

ផ្សាយនៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០

នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម ខូយ តឹមទូ** បានពិនិត្យ និងដោះស្រាយចំនួន៩សំណើ ស្ថិតក្នុងភូមិស្រះស្រង់ខាងត្បូងនិងភូមិអញ្ចាញ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានចុះពិនិត្យនិងនិងដោះស្រាយចំនួន៧សំណើ ស្ថិតក្នុងភូមិសំរោង ឃុំលាងដៃ។ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០នេះ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា បានអនុញ្ញាតជូនប្រជាពលរដ្ឋបានចំនួន១០សំណើ៕

អាជ្ញាធរជាតិអប្សរាសហការជាមួយសារព័ត៌មានអេឡិចត្រូនិកថ្មីៗដើម្បីរៀបចំឯកសារស្ដីពីអង្គរ

ផ្សាយនៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០២០

កម្មវិធី "អង្គរ និងលើសពីនេះ..." គឺជាកិច្ចសហការថ្មីមួយរវាងអាជ្ញាធរជាតិអប្សរានិងសារព័ត៌មានអេឡិចត្រូនិចថ្មីៗក្នុងការរៀបចំឯកសារទាំងភាសាជាតិ និងបរទេសដើម្បីផ្សព្វផ្សាយមិនត្រឹមតែអំពីកិច្ចអភិរក្ស អភិវឌ្ឍន៍ប្រកបដោយចីរភាពប៉ុណ្ណោះទេ ប៉ុន្តែរួមមានអាថ៌កំបាំងជាច្រើនដែលមានតម្លៃជាបេតិកភណ្ឌអរូបីនៅក្នុងរមណីយដ្ឋានអង្គរដែរ។ ឯកសារទាំងនេះមានចរិតជាប្រវត្តិសាស្ត្រផង និងមានចរិតបច្ចុប្បន្នភាពផងដែលធ្វើឲ្យអ្នកទស្សនាអាចស្វែងយល់មួយផ្នែកអំពីខ្លឹមសារនៃប្រវត្តិសាស្ត្រពាក់ព័ន្ធ និងប្រៀបធៀបទៅនឹងទិដ្ឋភាពជាក់ស្តែងនាពេលបច្ចុប្បន្ន។

ក្នុងកម្មវិធីនេះ ក្រុមការងារនឹងធ្វើបទសម្ភាសន៍ជាមួយថ្នាក់ដឹកនាំ អ្នកជំនាញ បុគ្គលិកនៃអាជ្ញាធរជាតិអប្សរា ព្រះសង្ឃ មហាជនទូទៅ ដើម្បីប្រមូលផ្តុំនូវខ្លឹមសារសំខាន់ៗដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ សឹជម្រៅស្របតាមលក្ខណៈវិទ្យាសាស្ត្រ៕

ក្រុមការងារគ្រប់គ្រងព្រៃឈើ កំពុងកាត់ដកហូតដើមឈើ ដែលមានហានិភ័យខ្ពស់ក្នុងបរិវេណប្រាសាទបន្ទាយស្រី

ផ្សាយនៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០

ឆ្លើយតបចំពោះដើមឈើដែលកំពុងមានហានិភ័យខ្ពស់មកលើប្រាង្គប្រាសាទបន្ទាយស្រី ក្រុមការងារនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា កំពុងអនុវត្តការងារកាត់ដកហូតដើមឈើទាលមួយដើមដែលមានមុខកាត់១០០ស.មនិងកំពស់ប្រហែល៤០ម៉ែត្រ ដុះជាប់នឹងកំពែងខាងត្បូងក្នុងប្រាសាទបន្ទាយស្រី មានលក្ខណៈទ្រេតខ្លាំងទៅលើកំពែង និងថ្មចម្លាក់ សណ្ឋានដីជ្រាយនិងមានប្រព័ន្ធឫសខ្សោយ។ដោយសារទីតាំងដើមឈើនោះកៀកនឹងប្រាសាទ និងមានកម្ពស់ខ្ពស់ផង មិនអំណោយផលដល់រថយន្តស្ទូចដើម្បីចូលទៅកាត់ ដែលតម្រូវឲ្យក្រុមការងារត្រូវប្រើប្រាស់រន្ទាដែកជំនួសវិញ ជាហេតុត្រូវប្រើពេលវេលាយូរបន្តិចក្នុងការដំឡើង ប៉ុន្តែផ្តល់សុវត្ថិភាពខ្ពស់ចំពោះប្រាសាទផង និងមនុស្សផង។

ក្រៅពីដើមឈើទាលមួយដើមនេះក្រុមការងារក៏បានសិក្សាពីហានិភ័យដើមឈើផ្សេងទៀត ស្ថិតក្នុង និងក្រៅបរិវេណប្រាសាទបន្ទាយស្រី ដែលអាចនឹងបង្កគ្រោះថ្នាក់ដល់ប្រាសាទនិងមនុស្សនិងបានរៀបចំជាផែនទីហានិភ័យដើមឈើរួចហើយ ដែលក្នុងនោះមានដើមឈើសរុបចំនួន៥០ដើម ដោយបែកចេញជា៣កម្រិតហានិភ័យគឺ៖ ហានិភ័យខ្លាំងមានចំនួន១០ដើម(ត្រូវកាត់ដកហូតចេញ) ហានិភ័យមធ្យមចំនួន៣០ដើម(កាត់ក្រីមែកខ្លះ)និងហានិភ័យខ្សោយចំនួន១០ដើម(កាត់ក្រីមែកខ្លះ)។

ជាវិធានការដើម្បីបង្ការហានិភ័យដើមឈើទាំងអស់នេះមកលើប្រាសាទបន្ទាយស្រី អាជ្ញាធរជាតិអប្សរា នឹងដាក់ជូនសុំយោបល់ពីអ្នកជំនាញនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់អង្គរ(ICC-Angkor) ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍បន្តទៀត ដើម្បីការងារនេះអនុវត្តបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់៕

កុលាលភាជន៍ដែលបានពីការស្តារប្រឡាយនៅបរិវេណប្រាសាទព្រះខ័ន ត្រូវបានយកមករក្សាទុកដើម្បីជួសជុល

ផ្សាយនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

កុលាលភាជន៍ចំនួន១៩ ថ្មដុសថ្នាំចំនួន២ អង្រែកិនថ្នាំ១ និងបំណែកលុលាលភាជន៍ចំនួន៣០ ដែលបានពីការស្តារប្រឡាយនៅបរិវេណថ្នាលបណ្តុះកូនឈើប្រាសាទព្រះខ័ន កាលពីដើមឆ្នាំ២០២០ ត្រូវបានអាជ្ញាធរជាតិអប្សរាយកមករក្សាទុកដើម្បីជួសជុល នារសៀលថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០។

តាមការបញ្ជាក់របស់លោក ញ៉ែម រស្មី មន្ត្រីនាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា កុលាលភាជន៍ និងថ្មកិនថ្នាំ ដែលរកឃើញដ៏ច្រើននេះ គឺជីកបាននៅខែមីនា ឆ្នាំ២០២០ នៅពេលក្រុមការងារស្តារប្រឡាយចំនួន ១៧០០ម៉ែត្រនៃបរិវេណប្រាសាទព្រះខ័ន។ វត្ថុបុរាណទាំងអស់នេះ ស្ថិតនៅរាយប៉ាយពីគ្នា ក្នុងជម្រៅ១ម៉ែត្រជាង។

ក្រោយប្រទះឃើញ ក្រុមការងារក៏បានរក្សាទុកវត្ថុបុរាណទាំងអស់ រហូតដល់បញ្ចប់ការស្តារប្រឡាយ ទើបប្រគល់ជូនមជ្ឈមណ្ឌលស្រាវជ្រាវ និងតម្កល់ឯកសារអង្គរយកទៅអភិរក្ស ដោយមានការដឹងឮពីនគរបាលបេតិកភណ្ឌជាសាក្សី។

ចំពោះកិច្ចអភិរក្សវត្ថុបុរាណទាំងអស់នេះ អាជ្ញាធរជាតិអប្សរានឹងយកទៅរក្សាទុក ដើម្បីចុះបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ ដុសសម្អាត រួមទាំងជួសជុលឱ្យផុតពីហានិភ័យទុកជាសម្បត្តិជាតិ ពិសេសគឺសម្រាប់សិក្សាស្រាវជ្រាវពីប្រវត្តិបន្ថែមទៀត៕

សិក្ខាកាមចំនួន២៥រូប ទទួលបានការបណ្តុះបណ្តាលស្តីពី «ការអភិរក្ស និងគ្រប់គ្រងបេតិកភណ្ឌ»

ផ្សាយនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០

នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ នៃអាជ្ញាធរជាតិអប្សរា បានបើកវគ្គបណ្តុះបណ្តាលស្តីពី «ការអភិរក្សនិងគ្រប់គ្រងបេតិកភណ្ឌ» ក្រោមវត្តមានលោកស្រី Barbara J.Anello-Armani ជាសាស្ត្រាចារ្យបង្រៀនភាសាអង់គ្លេសលើវិស័យការងារអភិរក្សនិងគ្រប់គ្រងបេតិកភណ្ឌ។

វគ្គបណ្តុះបណ្តាលនេះចាប់ពីថ្ងៃទី២២ ខែតុលា រហូតដល់ថ្ងៃទី៣១ខែធ្នូឆ្នាំ២០២០ដល់សិក្ខាកាមមកពីមជ្ឈមណ្ឌលខេមរសិក្សា និងអាជ្ញាធរជាតិព្រះវិហារ សរុបចំនួន២៥រូប ដែលជាគ្រូបង្រៀនកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងអ្នកអប់រំបម្រើការងារនៅតាមសារមន្ទីរក្នុងខេត្តសៀមរាប និងខេត្តព្រះវិហារ។

លោកស្រី Barbara J.Anello-Armani បានបញ្ជាក់ថា វគ្គបណ្តុះបណ្តាលនេះបានសហការជាមួយមជ្ឈមណ្ឌលបណ្តុះបណ្តាលអង្គរ មជ្ឈមណ្ឌលខេមរសិក្សា និងអាជ្ញាធរជាតិព្រះវិហារ ដើម្បីពង្រឹងសមត្ថភាពនិងចំណេះដឹងដល់លោកគ្រូ អ្នកគ្រូដែលជាទិស ដៅសំខាន់ក្នុងការផ្សព្វផ្សាយបន្តដល់សិស្សានុសិស្សឱ្យបានស្គាល់ ស្រឡាញ់ និងចូលរួមថែរក្សាបេតិកភណ្ឌទាំងអស់គ្នា។មិនតែប៉ុណ្ណោះក៏ដើម្បីបង្កើនសមត្ថភាពផ្នែកភាសាអង់គ្លេសដល់មន្ត្រី បុគ្គលិកអាជ្ញាធរជាតិអប្សរានិងអាជ្ញាធរជាតិព្រះវិហារ ឱ្យមានសមត្ថភាពទំនាក់ទំនងការងារជាមួយបុគ្គលិក,ឬអ្នកជំនាញអន្តរជាតិក្នុងបេសកកម្មការងារអភិរក្ស អភិវឌ្ឍន៍ប្រាសាទ។

កញ្ញា ម៉ៅ សេងយាន គ្រូបង្គោលនៃវគ្គបណ្តុះ បណ្តាលបានឱ្យដឹងថា រយៈពេល២ខែកន្លះនៃវគ្គបណ្តុះបណ្តាលនេះនឹងបង្រៀនសិក្ខាកាម អំពីតួនាទីនិងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរាទាក់ទងនឹងកិច្ចការអភិរក្សនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់អង្គរ។

ក្រោយបញ្ចប់វគ្គបណ្តុះបណ្តាល កញ្ញា សេងយ៉ាន សង្ឃឹមថា សិក្ខាកាមទាំងអស់នឹងទទួលបានចំណេះដឹងថ្មីច្រើនពីកិច្ចការអភិរក្សបេតិកភណ្ឌ ដើម្បីយកទៅអនុវត្តការងារ ក៏ដូចជាបង្រៀនដល់អ្នកផ្សេងៗទៀតបានល្អប្រសើរ ក្នុងការបណ្តុះគំនិតឱ្យស្រឡាញ់សម្បត្តិវប្បធម៌ជាតិកាន់តែខ្លាំងថែមទៀត៕

អាជ្ញាធរជាតិអប្សរា បានដាំដើមត្នោតចំនួន៧៣០ដើមបន្ថែមទៀតនៅតាមទំនប់បុរាណនៃរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០

ថ្មីៗនេះ នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានដាំដើមត្នោតចំនួន ៧៣០ដើម បន្ថែមទៀតនៅតាមទំនប់អមប្រឡាយបុរាណ ស្ថិតក្នុងភូមិលាងដៃ ឃុំលាងដៃ ស្រុកអង្គរធំ។ អាជ្ញាធរជាតិអប្សរា ដាំដើមត្នោតបានចំនួន៦០០០ដើមរួចមកហើយ ក្នុងរយៈពេល៤ឆ្នាំកន្លងមកក្នុងបរិវេណរមណីយដ្ឋានអង្គរ។

ក្រៅពីដាំដើមត្នោត អាជ្ញាធរជាតិអប្សរា ក៏បានដាំដើមស្ដៅ និងអំពិលបានជាច្រើនដើមផងដែរ នៅលើដីទំនេរតាមទំនប់អមប្រឡាយបុរាណ ដើម្បីឲ្យប្រជាពលរដ្ឋដែលស្ថិតនៅជុំវិញនោះអាចអាស្រ័យផល និងដោះស្រាយជីវភាពប្រចាំថ្ងៃ។

អាជ្ញាធរជាតិអប្សរា ក៏សូមអំពាវនាវផងដែរ សូមបងប្អូនមេត្តាកុំលែងសត្វគោ ក្របី ឲ្យចូលក្នុងបរិវេណនោះ ដែលអាចធ្វើឲ្យប៉ះពាល់ដល់ការលូតលាស់របស់រុក្ខជាតិទាំងនោះ។

អាជ្ញាធរជាតិអប្សរាសហការជាមួយទីភ្នាក់ងារអភិវឌ្ឍន៍របស់ប្រទេសស៊ុយអែត រៀបចំសិក្ខាសាលាស្តីពី «ការអភិវឌ្ឍទឹកស្អាត និងអនាម័យ នៅទីក្រុងប្រកបដោយចីរភាព SUWAS»

ផ្សាយនៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០២០

ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០២០ នៅទីស្នាក់ការអាជ្ញាធរជាតិអប្សរា ខេត្តសៀមរាប បានរៀបចំសិក្ខាសាលាស្តីពី "ការអភិវឌ្ឍទឹកស្អាតនិងអនាម័យនៅទីក្រុងប្រកបដោយចីរភាព" ក្រោមការជួយឧបត្ថម្ភដោយទីភ្នាក់ងារអភិវឌ្ឍន៍របស់ប្រទេសស៊ុយអែត ហៅកាត់ថា Sida និងគាំទ្របច្ចេកទេសដោយ NIRAS និងWater Aid ។

សិក្ខាសាលនេះធ្វើឡើងក្នុងគោលបំណងផ្តល់ចំណេះដឹង និងជំនាញលើការងារអភិវឌ្ឍន៍ទឹកស្អាត និងអនាម័យនៅក្នុងសហគមន៍ ដល់ស្ថាប័នពាក់ព័ន្ធក្នុងខេត្តសៀមរាប។ ដោយមានអ្នកចូលរួមចំនួន៥០នាក់ មកពីក្រសួងបរិស្ថាន សាលាខេត្តសៀមរា ប សាលាក្រុងសៀមរាប អាជ្ញាធរជាតិអប្សរា មន្ទីរសាធារណ ការខេត្ត មន្ទីរអភិវឌ្ឍន៍ជនបទខេត្ត មន្ទីរបរិស្ថានខេត្ត រដ្ឋាករទឹកស្វយ័តសៀមរាប អង្គការលំនៅឋានមនុស្សជាតិកម្ពុជា (Habitat for Humanity Cambodia) ក្រុមហ៊ុនហ្គាអៀ និងក្រុមហ៊ុនNIRAS។

ឯកឧត្តមជុំ សុខមករាអគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា បានមានប្រសាសន៍ក្នុងកម្មវិធីបើកសិក្ខាសាលាថា៖ ទឹកមានសារៈសំខាន់ណាស់សម្រាប់ទ្រទ្រង់ជីវិតយើងទាំងអស់គ្នា។ ដូច្នេះយើងត្រូវចេះគ្រប់គ្រងទឹកឱ្យបានល្អ ជាពិសេសទឹកស្អាត និងអនាម័យ។ សិក្ខាសាលានេះពិតជាសំខាន់ដែលទាមទារស្ថានប័នពាក់ព័ន្ធទាំងអស់នៅខេត្តសៀមរាបត្រូវយល់ដឹងពីទឹកស្អាតដើម្បីយកទៅផ្សព្វផ្សាយ និងអនុវត្តក្នុងមូលដ្ឋានរបស់ខ្លួន ដែលជាប្រយោជន៍ដល់សុខភាពសាធារណៈ។

លោក សុខ វណ្ណា តំណាងក្រុមហ៊ុន NIRAS និងអ្នកសម្របសម្រួលសិក្ខាសាលានាពេលនេះ បានលើកឡើងថា៖ NIRAS ជាក្រុមហ៊ុនប្រឹក្សាវិស្វកម្មលំដាប់ពិភពលោក ហើយជាក្រុមហ៊ុនគាំទ្របច្ចេកទេសដល់ទីភ្នាក់ងារអភិវឌ្ឍន៍របស់ប្រទេសស៊ុយអែត Sida ដល់ប្រទេសមួយចំនួនក្នុងតំបន់អាស៊ីដូចជា ប្រទេសបង់ក្លាដេស នេប៉ាល់ ឡាវ ភូមា និងកម្ពុជា លើគម្រោងការអភិវឌ្ឍវិស័យទឹកស្អាត និងអនាម័យក្នុងទីប្រជុំជនប្រកបដោយចីរភាព។ លោកសង្ឃឹមថា សិក្ខាសាលានេះនឹងផ្តល់ចំណេះដឹងនិងចែករំលែកបទពិសោធន៍ដល់មន្ត្រីស្ថាប័នពាក់ព័ន្ធលើវិស័យទឹកស្អាត និងអនាម័យប្រកបដោយចីរភាព។

គួរបញ្ជាក់ផងដែរថា វគ្គសិក្ខាសាលាបណ្តុះបណ្តាលកម្រិតអន្តរជាតិស្តីពី"ការអភិវឌ្ឍវិស័យទឹកស្អាតនិងអនាម័យក្នុងទីប្រជុំជនប្រកបដោយចីរភាព " នេះតែងធ្វើឡើងជារៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០១៧មក ដោយមានសិក្ខាកាមចូលរួមចន្លោះពី៣០នាក់ ទៅ៥០នាក់ក្នុងមួយវគ្គ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៩សំណើ

ផ្សាយនៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០

ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានចុះពិនិត្យ លើទីតាំង និងឯកសារជាក់ស្តែងក្រុមការងារ បានអនុញ្ញាតចំនួន៤សំណើ។គោលដៅទី២ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ លោក ឡុង កុសល បានចុះពិនិត្យលើទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២០នេះ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងពីរគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៩ សំណើ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៤សំណើ

ផ្សាយនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០

ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋទាំង១១២ភូមិ នៅក្នុងឧទ្យានអង្គរ។

ជាក់ស្តែងក្រុមគោលដៅទី១ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម ខូយ តីមទូ** បានចុះពិនិត្យ និងដោះស្រាយសំណើស្ថិតក្នុងភូមិរហាលនិងភូមិក្រវ៉ាន់ សង្កាត់នគរធំ ដោយបានអនុញ្ញាតចំនួន៤សំណើ។

គោលដៅទី២ ក្រុមការងារសហគមន៍នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ ក្រុមទី៦ ដឹកនាំដោយលោក សំ សារ៉េត បានចុះពិនិត្យ និងដោះស្រាយ នៅក្នុងភូមិបឹងមាលា ឃុំបឹងមាលា។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានចុះពិនិត្យ និងដោះស្រាយនៅក្នុងភូមិលាងដៃ ឃុំលាងដៃ ភូមិស្វាយចេក ឃុំស្វាយចេក។

ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។
សរុបមក នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០នេះ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងពីរគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន១៤ សំណើ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៨សំណើ

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន១គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម ខូយ គឹមឆ្ន** បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិគោកតាចាន់ សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ៕

សារលិខិតថ្វាយព្រះពរ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសព្រះរាជពិធីខួបលើកទី១៦ នៃការយាងគ្រងរាជសម្បត្តិ

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

ក្នុងឱកាសដ៏មហានក្ខត្តឫក្សវិសេសវិសាលនេះ ទូលព្រះបង្គំយើងខ្ញុំសូមលើកហត្ថប្រណម្យបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក មានទេវតារក្សាព្រះមហាស្វេតឆ្ឆ័ត្រ សូមជួយប្រោះព្រំសព្ទសាធុការពរសិរីសួស្តីជ័យមង្គលវិបុលសុខបរមមហាប្រសើរថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រមទាំងព្រះញាតិវង្សានុវង្ស សូមបានប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជានុរាស្ត្រខ្មែរ ជានិច្ចនិរន្តរ៍។

លិខិតថ្វាយព្រះពរ
សូមទេវតារក្សាព្រះមហាស្វេតឆ្ឆ័ត្រ និងវត្ថុស័ក្តិសិទ្ធិក្នុងលោកប្រោះព្រំសព្ទសាធុការពរ
សិរីសួស្តីជ័យមង្គលវិបុលសុខបរមមហាប្រសើរថ្វាយ
ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា
ក្នុងឱកាសព្រះរាជពិធីខួបលើកទី១៦នៃការយាងគ្រងព្រះបរមរាជសម្បត្តិ
ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា សូមព្រះបរមរាជាសម្តែងនូវកតញ្ញុតាតវេទីយ៉ាងជ្រាលជ្រៅ
និងស្មោះស្ម័គ្រជាទីបំផុតថ្វាយព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ដែលជានិច្ចកាល
ព្រះអង្គតែងតែយកចិត្តព្រះទ័យទុកដាក់ខ្ពស់បំផុតក្នុងការបំពេញព្រះរាជបេសកកម្ម
ដ៏ឧត្តុង្គឧត្តម ព្រមទាំងលះបង់កម្លាំងព្រះកាយពល និងព្រះបញ្ញាញាណ
មិនខ្លាចនឿយហត់ ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជានុរាស្ត្រជាទីស្រលាញ់
សូមព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមបានប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ
អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីគង់ប្រថាប់
ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជានុរាស្ត្រ ខ្មែរ ជានិច្ចនិរន្តរ៍។
ក្រាបបង្គំទូលថ្វាយពី
ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងថ្នាក់ដឹកនាំ
មន្ត្រីរាជការ បុគ្គលិក កម្មករ និងពលករទាំងអស់

មន្ត្រីស្ថានទូតប្រទេសជប៉ុនចុះពិនិត្យនិងសិក្សាស្វែងយល់ពីការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២០

នៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២០ លោក Atsushi KARIMATA មន្ត្រីស្ថានទូតប្រទេសជប៉ុនប្រចាំនៅកម្ពុជា ដែលនឹងត្រូវទទួលភារកិច្ចជាសហប្រធានបច្ចេកទេសនៃគណៈកម្មាធិការអន្តរជាតិសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍តំបន់ប្រវត្តិសាស្ត្ររមណីយដ្ឋានអង្គរ ហៅកាត់ថា «អាយស៊ីស៊ី-អង្គរ» រួមដំណើរដោយ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ព្រមទាំងមន្ត្រីពាក់ព័ន្ធ បានចុះពិនិត្យនិងស្វែងយល់ពីកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរ។

ក្នុងអំឡុងពេលបំពេញភារកិច្ចនៅរមណីយដ្ឋានអង្គរ លោក Atsushi KARIMATA បានចុះទៅស្វែងយល់អំពីការជួសជុលផ្សេងៗនៅតាមប្រាសាទមួយចំនួនរួមមាន ប្រាសាទតានៃ ប្រាសាទប្រែរូប ប្រាសាទអង្គរវត្ត៕



ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែវិច្ឆិកា

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៥សំណើ

ផ្សាយនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី២ខែវិច្ឆិកាឆ្នាំ២០២០ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន១គោលដៅ ដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យនិងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។ ជាក់ស្តែង ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម ខូយ តីមទូ** បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិវាលសង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

ខែវិច្ឆិកា ឆ្នាំ២០២០

ខែតុលា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើជួសជុលផ្ទះ និងសាងសង់សំណង់តូចតាចចំនួន២៥៧សំណើ

ផ្សាយនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០

របាយការណ៍លេខាធិការដ្ឋានសហគមន៍នៃអាជ្ញាធរជាតិអប្សរា ប្រចាំខែតុលា ឆ្នាំ២០២០ បានបង្ហាញថា ក្រុមការងារសហគមន៍បានចុះសម្របសម្រួលជាមួយប្រជាពលរដ្ឋ ដើម្បីពិនិត្យនិងដោះស្រាយសំណើស្នើសុំជួសជុលផ្ទះ រួមទាំងសាងសង់តូចតាចតាមភូមិទាំង១១២ភូមិ ក្នុងតំបន់រមណីដ្ឋានអង្គរ ដោយក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋបានចំនួន២៥៧សំណើ ក្នុងចំណោម៣៦៥សំណើ។

ករណីអនុញ្ញាតសំណើខាងលើផ្តល់ជូនប្រជាពលរដ្ឋនៅស្រុកបាគង២៦សំណើ ស្រុកអង្គរធំចំនួន៩៤សំណើ ស្រុកពួកចំនួន២៨សំណើ ស្រុកបន្ទាយស្រីបានចំនួន៣៧សំណើ និងក្រុងសៀមរាបចំនួន៧២សំណើ។

រាល់ការស្នើសុំច្បាប់សាងសង់គឺពុំមានការបង់ប្រាក់ទេ។

ប្រភេទសំណើដែលក្រុមការងារសហគមន៍ចុះពិនិត្យនិងដោះស្រាយមាន ១. ការជួសជុលផ្ទះ៖ ការជួសជុលឬប្តូរដំបូល ប្តូរជញ្ជាំង ប្តូរសសរ ប្តូរឬតសំយ៉ាប ជួសជុលជណ្តើរ ជួសជុលរបងមានស្រាប់ បន្ទប់ក្រោមផ្ទះ ២. សំណង់តូចតាច៖ សង់បង្គន់ សង់ទ្រុងមាន់ ទា ជ្រូក ជង្រុកស្រូវ តូបឬរោងលក់ដូរមុខផ្ទះ ៣.ចាក់ដី៖ ចាក់ដីលុបគ្រលុកក្នុងបរិវេណផ្ទះក្រោម។ល។

ក្រុមការងារសហគមន៍តែងចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលលើករណីសំណើផ្សេងៗនិងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីអាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងរមណីយដ្ឋានអង្គរ។ ក្រៅពីចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ ក្រុមការងារក៏បានចូលរួមក្នុងកិច្ចការងារមនុស្សធម៌ ឧបត្ថម្ភថវិកាដល់ចាស់ព្រឹទ្ធាចារ្យ ចាស់ជរា ជនពិការ ជនទីទ័លក្រ អ្នកជំងឺ កុមារពិការដែរ៕

ក្រុមការងារសហគមន៍ប្រចាំស្រុកបន្ទាយស្រី ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះបានចំនួន៥សំណើ

ផ្សាយនៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចំនួន១គោលដៅដែលមានការសហការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយ ស្ថិតក្នុងភូមិអូរទទឹង ភូមិថ្នល់ទទឹង ឃុំព្រះដាក់។

ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន ៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុលគឺពុំមានការបង់ប្រាក់ទេ។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាប្រចាំស្រុកពួក និងក្រុងសៀមរាប ចុះពិនិត្យដោះស្រាយសំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋបាន១២សំណើ

ផ្សាយនៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី៤ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចំនួន២គោលដៅ ដោយមានការសហការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានចុះពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិតាស្នេហ៍ ភូមិអន្លង់គ្គន់ ភូមិត្នោតជ្រើស ភូមិប្រាសាទចារ្យ និងភូមិដូនអុន ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយលោក ឡុង កុសល បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិជ័យ និងភូមិបន្ទាយឈើ សង្កាត់ទឹកវិល។ ក្រោយពីពិនិត្យទីតាំងនិងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុលគឺពុំមានការបង់ប្រាក់ទេ។

អាជ្ញាធរជាតិអប្សរាបើកសិក្ខាសាលាស្តីអំពីដំណើរការគ្រប់គ្រងបរិស្ថានអង្គរ

ផ្សាយនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០

នៅសាលសន្និសីទអង្គរនាព្រឹកថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២០ អាជ្ញាធរជាតិអប្សរា បានរៀបចំបើកសិក្ខាសាលាស្តីអំពីការដំណើរការគ្រប់គ្រងបរិស្ថានអង្គរ ដល់មន្ត្រី-បុគ្គលិក មកពីនាយកដ្ឋានផ្សេងៗចំណុះឱ្យអាជ្ញាធរជាតិអប្សរាប្រមាណ ១០០នាក់ចូលរួម។

សិក្ខាសាលានេះ បង្កើតឡើងក្នុងគោលបំណងផ្សព្វផ្សាយ និងណែនាំការប្រើប្រាស់សៀវភៅប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ។ ផ្សព្វផ្សាយគោលនយោបាយបរិស្ថានរបស់អាជ្ញាធរជាតិអប្សរា។ ផែនការ និងការងារគ្រប់បរិស្ថានអង្គរ ស្វែងយល់ពីបញ្ហាប្រឈមមុខ និងកែលម្អប្រព័ន្ធគ្រប់គ្រងប្រព័ន្ធគ្រប់គ្រងបរិស្ថានក្នុងតំបន់អង្គរ។

ប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ មានផលប្រយោជន៍នៃការអនុវត្តន៍ប្រពន្ធ័គ្រប់គ្រងអង្គរ រួមមាន ១. ការបន្ថយការចំណាយផ្សេងៗ (ដោយសំចៃ ប្រើឡើងវិញ ច្នៃវិញ) ២. គោរពច្បាប់បញ្ញត្តិបរិស្ថាន ៣. ផ្តល់ការប្រាស្រ័យទាក់ទងល្អ ផ្ទៃក្នុងផ្ទៃក្រៅ ៤. ការពារ និងបង្ការផលប៉ះពាល់អាក្រក់ជាមុន (ឧទាហរណ៍ ភ្លើងឆេះព្រៃ) ៥. ចំណាប់អារម្មណ៍ល្អទៅបេតិកភណ្ឌអង្គរ(នៃភ្ញៀវទេសចរ) ៦. ថែរក្សាសម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌ឱ្យបានគង់វង្សសម្រាប់អ្នកជំនាន់ក្រោយ៕

មានមតិសំណេះសំណាល បើកកម្មវិធី **ឯកឧត្តម សុខ លក្ខិណា** អ្នកតំណាងគ្រប់គ្រងបរិស្ថានបានលើកឡើងថា ការងារបរិស្ថានមិនមែនជាការងាររបស់អង្គភាពណាមួយ ឬបុគ្គលណាមួយឡើយ គឺជាការងាររួម។ បើយើងយល់ពីបរិស្ថាន យើងធ្វើកិច្ចការនេះបានល្អនោះយើងនឹងបានលទ្ធផលល្អ។ ដូច្នោះហើយបានជាអាជ្ញាធរជាតិអប្សរាបានបង្កើតនូវអង្គភាពមួយហៅថា អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ ដែលចូលរួមសហការយ៉ាងស្អិតរមួតជាមួយនាយកដ្ឋាននានានៃអាជ្ញាធរជាតិអប្សរា។

ឯកឧត្តមបន្តថា ហេតុអ្វីការងារមានភាពសំខាន់ ? ពីព្រោះថា មកដល់ថ្ងៃនេះអាជ្ញាធរជាតិអប្សរាបានទទួលវិញ្ញាបនប័ត្រ ISO 4001 ចំនួន៥ដងមកហើយ។ វិញ្ញាបនបត្រនេះជារង្វាស់ផង និងជាត្រីវិស័យផង សម្រាប់ការអនុវត្តការងារដែលមានប្រសិទ្ធិភាពទ្វេឡើង។

ក្រៅពីនោះ សិក្ខាសិលាស្តីពីដំណើរការការគ្រប់គ្រងបរិស្ថានអង្គរ បានធ្វើបទបង្ហាញទាក់ទងនឹងការអនុវត្តន៍ប្រព័ន្ធគ្រប់គ្រងអង្គរ និងបានផ្តល់ឱកាសឲ្យសិក្ខាកាមទាំងអស់ដែលមានចម្ងល់នានា អាចសួរទៅអ្នកតំណាងគ្រប់គ្រងបរិស្ថាន និងវាគ្មិនដែរ៕

ខែវិច្ឆិកា ឆ្នាំ២០២០

ភាជន៍ដីដុតពណ៌បៃតងមួយត្រូវបានប្រទះឃើញក្នុងដំណើរការជួសជុលប្រាសាទលលៃ

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

ភាជន៍ធ្វើពីដីដុតមានស្រទាប់រលោងពណ៌បៃតងចំនួនមួយ បានរកឃើញនៅលើខឿនត្រង់មាត់ជណ្ដើរខាងលិចនៃតួប៉មឦសានប្រាសាទលលៃ។ ភាជន៍ធ្វើពីដីដុតដែលមានទំហំមាត់២០ស.ម និងកម្ពស់១០ស.មនេះ ប្រើប្រាស់ជាកោដ្ឋសម្រាប់ដាក់ធាតុ និងបានបញ្ចុះនៅជុំវិញបរិវេណប្រាសាទបុរាណ។

ទំនៀមបុរាណនេះ បានបន្តរៀងមក ទោះមានការប្រែប្រួលខ្លះ តែក្នុងបំណងដើម្បីឱ្យអ្នកដែលស្លាប់នោះបានទៅភ្ជាប់និស្ស័យនឹងទេព។

លោក ឈូក សុម៉ាឡា បុរាណវិទូនិងជាមន្ត្រីក្រុមចុះបញ្ជីសារពើភណ្ឌនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ បានឱ្យដឹងថា នេះមិនមែនជាលើកទីមួយទេ ដែលក្រុមការងារជួសជុលបានរកឃើញភាជន៍ដែលប្រើប្រាស់ជាកោដ្ឋដាក់ធាតុបញ្ចុះនៅជុំវិញបរិវេណនៃតួប៉មប្រាសាទលលៃនេះ។ តួយ៉ាងដូចជានៅឆ្នាំ២០១៤ យើងធ្លាប់រកឃើញកោដ្ឋចំនួន១១រួចមកហើយ ដែលបានកប់បញ្ចុះនៅក្បែរៗគ្នានៅជ្រុងឦសាននៃតួប៉មដដែលនេះ ហើយភាជន៍ទាំងនោះភាគច្រើនជាភាជន៍មានរាងមូលដូចជាចានគោម ដោយខ្លះមានគម្រប និងខ្លះគ្មាន ។

លោកបានបន្ថែមទៀតថា ភាជន៍ប្រើជាកោដ្ឋដែលបានរកឃើញថ្មីនេះ មានមាត់ធំ ខ្លួនត្រង់ និងបាតរាបស្មើ ប្លែកខុសពីគេ រាងដូចជាផើង គ្មានគម្រប ដែលមិនធ្លាប់ឃើញមានពីមុននោះឡើយ។ រីឯផ្ទៃសាច់ភាជន៍មានស្រទាប់រលោងក្រាស់ពណ៌បៃតង។ តាមក្រុមអ្នកជំនាញផ្នែកកុលាលភាជន៍ បានឱ្យដឹងថាភាជន៍នេះជាប្រភេទភាជន៍នាំចូលពីប្រទេសចិន ដែលប្រហែលជានៅសតវត្សទី១៩។

ក្រោយពីធ្វើការកាយសម្អាត គូរ និងថតរូបតាមបែបបុរាណវិទ្យាដើម្បីចងក្រងទុកជាឯកសារសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយសិក្សាបន្តរួចមក ក្រុមការងារបានបញ្ចុះកោដ្ឋនោះទៅតាមលក្ខណៈដើមវិញ ដូចគ្នានឹងភាជន៍ដែលធ្លាប់រកឃើញមុនៗមកដែរ ដើម្បីថែរក្សានិងអភិរក្សបេតិកភណ្ឌអរូបី គឺជាលក្ខណៈពិសេសរបស់អង្គរ ដែលបេតិកភណ្ឌរូបីនិងអរូបីមិនអាចកាត់ផ្ដាច់ពីគ្នាបាន។ ទន្ទឹមនឹងនេះក៏ជាការសម្ដែងសេចក្ដីគោរពដល់គោលបំណងរបស់គ្រួសារអ្នកស្លាប់ ដែលចង់ឱ្យបុព្វការីជនរបស់ខ្លួនរស់នៅឯបរលោកជាមួយនឹងទេព៕

អាជ្ញាធរជាតិអប្សរានិងអង្គការមូលនិធិប្រាសាទពិភពលោកពិភាក្សាបច្ចេកទេស ជួសជុលប្រាសាទតាសោម

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានជួបពិភាក្សាការងារបច្ចេកទេសជាមួយតំណាងស្ថាប័នរបស់អង្គការមូលនិធិប្រាសាទពិភពលោក (WMF) ដើម្បីជួសជុលប្រាសាទតាសោម។ ក្រុមការងារបានចុះសិក្សារួមគ្នាលើលទ្ធភាពនានាក្នុងការការពារ ការអភិរក្ស ក៏ដូចជាកិច្ចការជួសជុលបន្ថែម ក្រោយពេលស្ថាប័នសហរដ្ឋអាមេរិក WMF ជួសជុលរួចរាល់តាំងពីឆ្នាំ២០១២មក។

នាឱកាសចុះពិនិត្យការដ្ឋានការងារនៅពេលនោះ ក្រុមការងារបានសិក្សារួមគ្នារកដំណោះស្រាយដើម្បីបញ្ចៀសបញ្ហាអវិជ្ជមានមួយចំនួនអំឡុងពេលជួសជុលពិសេសស្របតាមតម្លៃនៃសម្បត្តិបេតិកភណ្ឌជាតិ។ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា បានណែនាំនូវចំណុចចំនួនដើម្បីរៀបចំបរិវេណប្រាសាទតាសោមឱ្យមានសោភណ្ឌភាពល្អ និងទាក់ទាញភ្ញៀវទេសចរ។

គួររំឭកថា អង្គការមូលនិធិប្រាសាទពិភពលោក ក្រោមកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរជាតិអប្សរា បានចាប់ផ្តើមជួសជុលប្រាសាទតាសោមចាប់ពីឆ្នាំ ២០០០ រហូតដល់ ឆ្នាំ ២០១២។ យ៉ាងណាក៏ដោយ ក្រោយជួសជុលរយៈពេល១០ឆ្នាំមកនេះ ស្ថាប័ននេះសង្កេតឃើញថា មានបញ្ហាមួយចំនួនដែលត្រូវដោះស្រាយបន្តដូចជា ការរៀបចំប្រព័ន្ធទឹកដែលជាបញ្ហាប្រឈមខ្លាំង ដែលធ្វើឱ្យហូរច្រោះដល់ឫសឈើធំៗ ដែលអាចមានហានិភ័យទៅអនាគត។

សិក្ខាកាមចំនួន២៥រូបនៃវគ្គបណ្តុះបណ្តាល «ការអភិរក្សនិងគ្រប់គ្រងបេតិកភណ្ឌ» ចុះសិក្សាដោយផ្ទាល់ពីប្រវត្តិសាស្ត្រក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ សិក្ខាកាម២៥នាក់ ជាមន្ត្រី-បុគ្គលិកនៃអាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ គ្រឹះស្ថានអប់រំកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សានៃវគ្គបណ្តុះបណ្តាល «ការអភិរក្សនិងគ្រប់គ្រងបេតិកភណ្ឌ» បានចុះសិក្សាដោយផ្ទាល់និងស្តាប់បទបង្ហាញពីលោក អ៊ឹម សុខរិទ្ធី បុរាណវិទូនៃអាជ្ញាធរជាតិអប្សរាអំពី «ប្រវត្តិសាស្ត្រក្រុងអង្គរធំ»។

វគ្គបណ្តុះបណ្តាលនេះ រៀបចំដោយអាជ្ញាធរជាតិអប្សរាសហការជាមួយលោកស្រី Barbara J.Anello-Armani ជាសាស្ត្រាចារ្យបង្រៀនភាសាអង់គ្លេសលើវិស័យការងារអភិរក្សនិងគ្រប់គ្រងបេតិកភណ្ឌ ចាប់ពីថ្ងៃទី២២ ខែតុលា រហូតដល់ថ្ងៃទី៣១ខែធ្នូឆ្នាំ២០២០ដើម្បីពង្រឹងសមត្ថភាព និងចំណេះដឹងដល់លោកគ្រូ អ្នកគ្រូដែលជាទិស ដៅសំខាន់ក្នុងការផ្សព្វផ្សាយបន្តដល់សិស្សានុសិស្សឱ្យ បានស្គាល់ស្រឡាញ់ និងចូលរួមថែរក្សាបេតិកភណ្ឌទាំងអស់គ្នា។

លោក អ៊ឹម សុខរិទ្ធី បានលើកឡើងថា បទបង្ហាញពីប្រវត្តិសាស្ត្រក្រុងអង្គរធំ បានពន្យល់ពីពាក្យអង្គរ ការកកើតរាជធានីនៅអង្គរ ប្រវត្តិមនុស្សរស់នៅ និងស្លាកស្នាមបុរាណវិទ្យានៃសំណង់អាគារដែលបានបន្សល់ទុកពីសម័យបុរាណនៅក្រុងអង្គរធំនេះផ្ទាល់ហើយចាត់ទុកថានេះជាសញ្ញាណល្អសម្រាប់យុវជនជំនាន់ក្រោយដែលត្រូវបន្តវេនពីចាស់ៗក្នុងការស្វែងយល់ពីប្រវត្តិសាស្ត្រខ្មែរ ដើម្បីរួមគ្នាការពារមរតកវប្បធម៌ឱ្យបានគង់វង្ស។

ពិសេសវគ្គបណ្តុះបណ្តាលនេះ គឺចំគោលដៅបំផុត ព្រោះគ្រូបង្រៀនគឺជាអ្នកចែកចាយចំណេះដឹងដ៏មានប្រសិទ្ធភាពទៅកាន់ក្មេងៗ៕

អាជ្ញាធរជាតិអប្សរាបិទវគ្គបណ្តុះបណ្តាលស្តីពីជំនាញ បច្ចេកទេសសង្គ្រោះបឋម បន្ទាប់ពីបានបណ្តុះបណ្តាលរយៈពេលមួយខែរួចមក

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

នៅរសៀលថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០នេះ អាជ្ញាធរជាតិអប្សរាបានបិទវគ្គបណ្តុះបណ្តាលស្តីពីជំនាញបច្ចេកទេសសង្គ្រោះបឋម និងចែកវិញ្ញាបនបត្រជូនសិក្ខាកាមចំនួន ១២០នាក់ មកពីនាយកដ្ឋានគ្រប់គ្រងទឹក នាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍អង្គរ នាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ នាយកដ្ឋានអភិរក្សក្រៅឧទ្យានអង្គរ នាយកដ្ឋានសណ្តាប់ធ្នាប់និងសហប្រតិបត្តិការ នាយកដ្ឋានគ្រប់គ្រងព្រៃឈើទេសភាពវប្បធម៌និងបរិស្ថាន។

វគ្គបណ្តុះបណ្តាលនេះរៀបចំឡើងក្នុងគោលបំណង ដើម្បីបញ្ជ្រាបការយល់ដឹង និងកសាងសមត្ថភាពបុគ្គលិក ភ្នាក់ងារ និងពលករ នៃអាជ្ញាធរជាតិអប្សរា ដែលកំពុងបំពេញការងារនៅតាមការដ្ឋាន តំបន់ប្រាសាទ និងក្នុងព្រៃ ដើម្បីបង្ការ និងសង្គ្រោះភ្ញៀវទេសចរ មនុស្សជុំវិញខ្លួនពីគ្រោះថ្នាក់ដោយថាហេតុណាមួយដែលអាច នឹងកើតមានឡើងនៅពេលបំពេញការងារ។

ក្រោយពីបានបញ្ចប់វគ្គបណ្តុះបណ្តាលនេះ សិក្ខាកាម ទាំងអស់ទទួលបាននូវចំណេះដឹងនេះទៅអនុវត្តឱ្យមានប្រសិទ្ធភាពដើម្បីធ្វើឱ្យ ប្រសើរឡើងនូវសេវាកម្មទេសចរណ៍ក្នុងតំបន់អង្គរ និងជួយអប់រំបន្តដល់អ្នកផ្សេងទៀត។ លើសពីនេះអាចជួយភ្ញៀវទេសចរ អ្នករួមការងារ ព្រមទាំងអាចជួយបងប្អូនសាច់ញាតិ និងអ្នកស្រុកអ្នកភូមិរបស់ពួកគាត់បានទៀតផង៕

ខែវិច្ឆិកា ឆ្នាំ២០២០

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា៣គោលដៅ ពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋបាន១៥សំណើ

ផ្សាយនៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣ក្រុម ដែលមានការសហការចូលរួមជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោក ព្រហ្ម សំអ៊ាន បានចុះពិនិត្យនិងនិងដោះស្រាយស្ថិតក្នុងភូមិសំពេង និងភូមិលាងដៃ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្នើក្រុមការងារបានអនុញ្ញាតចំនួន ៣សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយលោក អឿន សំអុន បានចុះពិនិត្យនិងនិងដោះស្រាយស្ថិតក្នុងភូមិគោកស្គួល ភូមិគោកត្រាច ភូមិប្រឡាយ ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្នើក្រុមការងារបានអនុញ្ញាតចំនួន ៧សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម ខ្ញុយ គីមទួ** បានពិនិត្យនិងដោះស្រាយនៅក្នុងភូមិវាល សង្កាត់គោកចក ។ ក្រោយពីពិនិត្យទីតាំងនិងឯកសារដាក់ស្នើក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង៣ គោលដៅ បានពិនិត្យ និងដោះស្រាយបានចំនួន១៥សំណើ៕

អាជ្ញាធរជាតិអប្សរាចូលរួមគោរពទិវាឯករាជ្យជាតិលើកទី៦៧

ផ្សាយនៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០២០ នៅវិមានរំឭកគុណអតីតវីរយុទ្ធជនខេត្តសៀមរាប **ឯកឧត្តម តឹម សុជិន** អគ្គនាយករងអាជ្ញាធរជាតិអប្សរា ដឹកនាំមន្ត្រី-បុគ្គលិកនៃអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធអតីតវីរយុទ្ធជន រំឭកខួបអនុស្សាវរីយ៍លើកទី៦៧ នៃទិវាឯករាជ្យជាតិខ្មែរ និងការបង្កើតកងយុទ្ធពលខេមរភូមិន្ទកាលពីថ្ងៃទី០៩ វិច្ឆិកា ១៩៥៣។

សុខសន្តិភាព សេរីភាព និងការទទួលបានឯករាជ្យជាតិពីអាណានិគមនិយមបារាំង គឺកូនចៅគ្រប់គ្នាចងមិនភ្លេចឡើយពីស្នាព្រះហស្តដ៏ធំធេងរបស់អតីតព្រះមហាក្សត្រ ព្រះបរមរតនកោដ្ឋ រួមនឹងអតីតវីរយុទ្ធជន ដែលបានបូជាព្រះកាយពល កម្លាំងប្រាជ្ញា សាច់ស្រស់ឈាមស្រស់ ដើម្បីស្វែងរកសេចក្តីសុខជូនប្រជាជននិងរំដោះប្រទេស។

ក្នុងកាយវិការដឹងគុណនាថ្ងៃទី០៩ វិច្ឆិកា ២០២០ ខួបលើកទី៦៧នេះ ក្នុងនាមអាជ្ញាធរជាតិអប្សរា សូមសម្តែងសេចក្តីដឹងគុណជាពន្លឹកដល់អង្គព្រះមហាក្សត្រ ដល់អតីតវីរយុទ្ធជនខ្មែរ ដែលបានពលីជីវិតសង្គ្រោះជាតិ ប្រជាជនឱ្យបានសុខសន្តិភាព សេរីភាព និងឯករាជ្យក្នុងនាមជាខ្មែរ។

អាជ្ញាធរជាតិអប្សរាប្តេជ្ញាបន្តសកម្មភាពដ៏ថ្លៃថ្លាក្នុងការការពារសម្បត្តិវប្បធម៌ជាតិ ប្រជាជនក្នុងតំបន់អង្គរ និងធ្វើខ្លួនជាស្ថាប័នគំរូ ដើម្បីតបស្នងសងគុណដល់បុព្វបុរសនិងជាដឹកនាំគំរូដល់អ្នកជំនាន់ក្រោយផង។

អាជ្ញាធរជាតិអប្សរា សូមថ្វាយព្រះរាជ្យកុសល ជូនបុណ្យកុសលដល់អង្គព្រះមហាក្សត្រនិងអតីតវីរយុទ្ធជនគ្រប់អង្គគ្រប់រូប សូមបានសោយសុខក្នុងទីបរមសុខកុំបីឃ្លៀងឃ្លាតឡើយ។ កូនចៅគ្រប់រូបនឹងចូលរួមថែរក្សាទឹកដី មរតកវប្បធម៌របស់ដូនតាខ្មែរ ឱ្យបានគង់វង្សរៀងរហូតទៅ៕

ពលរដ្ឋបង្ហាញអារម្មណ៍គាំទ្រនិងរីករាយចំពោះការរៀបចំបរិវេណមុខប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២០

ប្រជាពលរដ្ឋដែលពឹងអាស្រ័យផល ក៏ដូចជាទេសចរមកទស្សនានៅតំបន់អង្គរ បានបង្ហាញអារម្មណ៍រីករាយ ជាមួយនឹងការអភិវឌ្ឍជាបន្តបន្ទាប់នៅបរិវេណមុខប្រាសាទអង្គរវត្ត។ ការអភិវឌ្ឍទាំងនោះរួមមាន ការរៀបចំសួនច្បារ ដាំដើមឈើប្រណិត ឈើផ្កាព្រៃ ក៏ដូចជាសណ្តាប់ធ្នាប់របៀបរៀបរយនៅកន្លែងលក់ដូរ និងចំណតជាដើម។ល។

លោក ស៊ាន សុខៈ មគ្គុទ្ទេសក៍ទេសចរណ៍នៅតំបន់អង្គរ យល់ថាការរៀបចំកែលម្អបរិវេណមុខប្រាសាទអង្គរវត្ត ជាការល្អ និងមានប្រយោជន៍សម្រាប់វិស័យទេសចរណ៍។ លោក សុខៈ បានធៀបនឹងពេលមុន ថាមានភាពខុសគ្នាឆ្ងាយ ដ្បិតបច្ចុប្បន្នមានរៀបចំជាសួនបៃតង ដាំដើមឈើកម្រៗដូចជាធ្នង់ បេង ជាដើម ដែលជាផ្នែកមួយជួយទាក់ទាញភ្ញៀវទេសចរ ក៏ដូចជាឱ្យពួកគេស្គាល់ពូជឈើទាំងនោះ។

ចំណែកលោក អ៊ួច សុវណ្ណ វិញក៏សប្បាយរីករាយជាមួយទិដ្ឋភាពថ្មីនៃបរិវេណមុខអង្គរវត្តនេះដែរ។ ក្នុងនាមជាពលរដ្ឋខេត្តសៀមរាបមួយរូប លោកសូមចូលរួមអបអរសាទរជាមួយសមិទ្ធផលមួយនេះ និងរំពឹងថា ក្រោយវិបត្តិកូវីដនឹងមានភ្ញៀវទេសចរកាន់តែច្រើនចូលមកទស្សនារមណីយដ្ឋានអង្គរ។ ជាជាងថតមួយរូប លោក អ៊ួច សុវណ្ណ សង្កេតឃើញថា មានទេសចរមួយចំនួនចាប់អារម្មណ៍ជាមួយសម្រស់សួនច្បារបៃតងនៅមុខអង្គរវត្តនេះ និងបានថតរូបទុកជាអនុស្សាវរីយ៍ផងដែរ។ ក្រៅពីគាំទ្រចំពោះការអភិវឌ្ឍនេះហើយ លោក អ៊ួច សុវណ្ណ ក៏លើកទឹកចិត្តដល់អាជ្ញាធរជាតិអប្សរាបន្តរៀបចំនិងដាំដើមឈើឱ្យបានកាន់តែច្រើន។

គួរបញ្ជាក់ថា ក្នុងបំណងដើម្បីកែប្រែសោភ័ណភាពនៅបរិវេណមុខប្រាសាទអង្គរវត្តឱ្យស័ក្តសមជាសម្បត្តិបេតិកភណ្ឌពិភពលោក អាជ្ញាធរជាតិអប្សរាបានចាប់ផ្តើមគម្រោងកែលម្អនេះចាប់ពីចុងឆ្នាំ២០១៩មក ដោយក្នុងនោះមានការរៀបចំសួនច្បារ ទីលានបដិសណ្ឋារកិច្ចថ្មី ដោយរើសំណង់តូបលក់ដូរទាំងអស់ចេញពីបរិវេណខាងមុខអង្គរវត្ត ការបញ្ឈប់មិនឱ្យមានការលក់រញ៉េរញ៉ៃ និងចំណតយានយន្តគ្មានសណ្តាប់ធ្នាប់ជាដើម។ល។

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះប្រជាពលរដ្ឋបានចំនួន១៤សំណើ

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួកដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយនៅភូមិបឹងខ្នារ ភូមិព្រៃក្មេង ភូមិខ្នាត ភូមិជ្រលង ភូមិព្រៃធ្លក និងភូមិស្វាយ ឃុំខ្នាត។ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាត៩សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ លោក ឡុង កុសល បានពិនិត្យ និងដោះស្រាយនៅភូមិបឹងដូនប៉ា ភូមិទ្រាំង និងភូមិមណ្ឌលបី សង្កាត់ស្លក្រាម។

ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អ្នករៀបចំសួនមុខប្រាសាទអង្គរវត្តបង្ហាញពីចំណាប់អារម្មណ៍ដែលបានបំពេញការងារសម្រាប់អង្គរ

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០

បច្ចុប្បន្នបរិវេណខាងលិចប្រាសាទអង្គរវត្តបានប្រែមុខមាត់ជាខ្លាំង លម្អដោយផ្កា សួនស្មៅពណ៌បៃតង និងដើមឈើជាច្រើនដើម។ ចំណែកទីលានបដិសណ្ឋារកិច្ច អាជ្ញាធរជាតិអប្សរាកំពុងមមាញឹកសាងសង់អគារផ្តល់ព័ត៌មាន អគារសង្គ្រោះបឋម និងអគារផ្សេងៗទៀតដើម្បីផ្តល់ភាពងាយស្រួលដល់ភ្ញៀវទេសចរជាតិនិងអន្តរជាតិកម្រិតស្តង់ដារអន្តរជាតិ ដែលគ្រោងនឹងបញ្ចប់ការជួសជុលទាំងស្រុងនាពាក់កណ្តាលឆ្នាំ២០២១ខាងមុខ។

លោកស្រី ហូ សិលា ជាបុគ្គលិកបម្រើការងារផ្នែករៀបចំសួនបានឱ្យដឹងថា៖ មិនដល់១ឆ្នាំផង មុខប្រាសាទអង្គរបានប្រែជាស្រស់បំព្រងដោយព្រៃឈើ ផ្កា និងស្មៅខៀវស្រងាត់ឃើញហើយស្រស់ថ្លាចិត្ត បាត់អស់ភាពនឿយហត់ក្នុងការបំពេញការងារ។

ដូចគ្នានេះដែរ លោកស្រី ជួន ស្រីមុំ បានរៀបរាប់ថា ភ្ញៀវទេសចរដែលមកទស្សនាអង្គររយៈពេលចុងក្រោយ នឹងលាន់មាត់សរសើរពីសោភណ្ឌភាពដ៏ស្រស់ស្អាតនិងមានសណ្តាប់ធ្នាប់ល្អនៅអង្គរមិនខាន។ លោកស្រី ក៏បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរាដែលយកចិត្តទុកដាក់និងខិតខំកែលម្អបរិវេណមុខប្រាសាទអង្គរវត្តឱ្យកាន់តែល្អប្រសើរឡើង។

ក្នុងនាមជាអ្នកបំពេញការងាររៀបចំសួនមុខបរិវេណមុខប្រាសាទអង្គរវត្ត លោកស្រី ហូ សិលា និងលោកស្រី ជួន ស្រីមុំ បានអំពាវនាវឱ្យភ្ញៀវទេសចរដែលមកទស្សនានៅអង្គរថែរក្សាបរិស្ថាន មានអនាម័យ បោលសំរាមក្នុងធុងសំរាមជានិច្ច ព្រោះបើគ្មានការចូលរួមពីសាធារណជនទេក៏មិនអាចរក្សាបរិស្ថានឱ្យនៅតែស្រស់ស្អាតបានដែរ។

លោក ពៅ ស៊ីណិត បុគ្គលិបច្ចេកទេសនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា ដែលដឹកនាំរៀបចំសួននៅមុខបរិវេណប្រាសាទអង្គរវត្តបានឱ្យដឹងថា នៅផ្លូវចូលមុខបរិវេណប្រាសាទអង្គរវត្តនេះមានដាំប្រភេទដើមផ្កាឆ្អឹងមាន់ខ្មៅ ផ្កាស្លឹកក្រហម និងស្មៅជើងទាស្មៅជើងក្រាស់ដែលធន់សក្តិសមដាំនៅទីនេះដែលមានមនុស្សដើរទៅមក។ លោកបន្តថា ក្រៅពីនេះ ក្រុមការងារក៏កាត់ក្រីមែកឈើ ដកហូតដើមឈើដែលមានហានិភ័យចេញដើម្បីរក្សាសុវត្ថិភាពដល់ភ្ញៀវទេសចរ និងដាំដើមឈើបន្តវមានដូចជា ដើមធ្នង់ ដើមក្ងោក ដើមនាងនួន ដើមបេង ដើមគគីជាដើម៕

ព្រះសង្ឃគង់នៅវត្តព្រះឥន្ទកោសាប្រគល់ថ្មបុរាណចំនួន៣ដុំជូនអាជ្ញាធរជាតិអប្សរា រក្សាទុកជាសម្បត្តិជាតិ

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២០ ព្រះសទ្ធម្មប្បកាសនី តាត មហាទី ព្រះចៅអធិការវត្តព្រះឥន្ទ្រកោសា បានស្ម័គ្រព្រះទ័យប្រគល់ថ្មបុរាណចំនួន៣ដុំជូនអាជ្ញាធរជាតិអប្សរារក្សាទុកជាសម្បត្តិជាតិ ដោយមានការចូលរួមពីពុទ្ធបរិស័ទ និងនគរបាលបេតិកភណ្ឌផង។

លោក ឈូក សុម៉ាឡា បុរាណវិទូនិងជាមន្ត្រីក្រុមចុះបញ្ជីសារពើភណ្ឌនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ បានឱ្យដឹងថា ថ្មទាំង៣ដុំ ជាប្រភេទថ្មភក់ទាំងអស់។ ថ្ម២ដុំ ជាចម្លាក់ព្រះពុទ្ធរូបដែលឆ្លាក់មិនទាន់ហើយ និងមួយដុំទៀត ជាចម្លាក់ខឿនប្រាសាទមានលម្អដោយក្បាច់ផង។ វត្ថុទាំង៣នេះ នឹងយកទៅរក្សាទុកនៅអាជ្ញាធរជាតិអប្សរាដើម្បីរក្សាសុវត្ថិភាព ចុះលេខបញ្ជីសារពើភណ្ឌវត្ថុសិល្បៈ សិក្សាស្រាវជ្រាវពីប្រភព ដុសសម្អាត និងទុកជាប្រយោជន៍សម្រាប់កិច្ចការផ្សេងៗ។

ទាក់ទងនឹងការស្ម័គ្រព្រះទ័យប្រគល់វត្ថុបុរាណទាំង៣ជូនអាជ្ញាធរជាតិអប្សរា ព្រះតេជគុណ តាត មហាទី មានសង្ឃដីកាថា នេះជាការរួមចំណែកជាមួយក្រសួងពាក់ព័ន្ធដើម្បីរក្សាវត្ថុបុរាណទុកជាសម្បត្តិជាតិ ការពារសុវត្ថិភាព និងការស្រាវជ្រាវចំពោះវត្ថុបុរាណ ដែលនៅរ៉ាយប៉ាយឱ្យមានសណ្តាប់ធ្នាប់ ចៀសផុតពីការជួញដូរ ឬការធ្វើឱ្យខូចខាតដោយប្រការផ្សេងៗព្រោះការពុំយល់ដឹង។

ព្រះអង្គក៏បានបញ្ជាក់ពីប្រភពថ្មទាំង៣ដែរថា ចំពោះថ្ម២ដុំដែលពុំមានរូបរាងច្បាស់លាស់នោះ គឺស្រង់បានពេលស្តារស្ទឹងសៀមរាប។ចំណែកចម្លាក់ខឿនប្រាសាទមួយផ្ទាំងនោះ គឺស្ថិតក្នុងចំនួន១០ដុំផ្សេងគ្នាដែលយកមកពីវត្តពោធិ៍លង្កា ហើយត្រូវបានគេយកទៅប្រើសម្រាប់សំលៀងកាំបិត តែព្រះអង្គបានសុំរក្សាទុក និងមួយចំនួនរក្សាទុកក្រោមបល្លង្គព្រះ បើរដ្ឋការត្រូវការពេលណាព្រះអង្គនឹងស្ម័គ្រព្រះទ័យក្នុងការប្រគល់ជូនដោយរីករាយ៕

អាជ្ញាធរជាតិអប្សរាសម្អាតប្រព័ន្ធលូនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០

ការលើកកម្ពស់ហេដ្ឋារចនាសម្ពន្ធប្រព័ន្ធបង្ហូរទឹកនៅក្នុងរមណីយដ្ឋានអង្គរ ជាភារកិច្ចប្រចាំថ្ងៃរបស់ក្រុមការងារនាយកដ្ឋានគ្រប់គ្រងទឹកនៃអាជ្ញាធរជាតិអប្សរា ដើម្បីសម្អាតប្រព័ន្ធលូ កុំឱ្យមានការកកស្ទះដោយសំរាម ស្តារកំណកដីដែលហូរចូលតាមទឹក និងជួសជុលលូដែលបាក់បែកខូចខាត។



ពេលនេះក្រុមការងារនាយកដ្ឋានទឹក កំពុងមមាញឹកនឹងការជួសជុលលូដែលខូចខាត កាយសំរាម និងស្តារកំណកដីនៅតាមប្រព័ន្ធលូនៅក្នុងបរិវេណប្រាសាទអង្គរវត្តនិងក្រុងអង្គរធំ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៥សំណើ

ផ្សាយនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែងគោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិសំរោង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតទាំង៤សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយ នៅភូមិអំពិលពាម និងភូមិគោកត្រាច ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតទាំង៥សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ លោក នង សុវណ្ណារិទ្ធ បានពិនិត្យ និងដោះស្រាយក្នុងភូមិអញ្ចាញ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សរុបមក នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅ បានពិនិត្យ និងដោះស្រាយសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៥សំណើ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន៧សំណើ

ផ្សាយនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោកព្រហ្មសំអ៊ានបានពិនិត្យនិងដោះស្រាយក្នុងភូមិភ្លង់ និងភូមិគោកគ្រើល ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៣សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម មុី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិស្រែចង្ហូត ភូមិតាឯក និងភូមិជ័យ ឃុំព្រះរុនតាឯក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សរុបមក នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៧សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១២សំណើ

ផ្សាយនៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ដាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ លោកស្រី ម៉ៅ ល្អ បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិដូននំ ឃុំមានជ័យ ភូមិរលួសខាងលិច និងភូមិដូនទាវ ឃុំរលួស។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្តែង ក្រុមការងារបានអនុញ្ញាតទាំង៧សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិរំចេក ឃុំរំចេក។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន១២សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១៨សំណើ

ផ្សាយនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៣គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយក្នុងភូមិសំពោង ភូមិតាប្រុក និងភូមិត្រពាំងស្វាយ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួកដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិគោកថ្មី ភូមិពាម និងភូមិតាស្នេហ៍ ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយលោកនង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយនៅភូមិវាល សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕



ប្រជាពលរដ្ឋក្នុងរមណីយដ្ឋានអង្គររៀបរាប់ពីនិតិវិធីស្នើសុំការសាងសង់ផ្ទះថ្មីជំនួសផ្ទះចាស់

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០

ការសាងសង់លំនៅដ្ឋាននៅក្នុងតំបន់រមណីយដ្ឋានអង្គរ ត្រូវតែប្រព្រឹត្តិទៅតាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ដែលគ្រប់គ្រងដោយអាជ្ញាធរជាតិអប្សរា ដើម្បីរក្សាបាននូវទេសភាពវប្បធម៌ អត្តសញ្ញាណខ្មែរ បុរាណដ្ឋានត្រូវការពារ និងចៀសវាងការបំផ្លាញផ្សេងៗនៅក្នុងតំបន់បេតិកភណ្ឌពិភពលោក។

តើប្រជាពលរដ្ឋក្នុងតំបន់អង្គរត្រូវមានឯកសារអ្វីខ្លះដើម្បីស្នើសុំសាងផ្ទះថ្មីជំនួសផ្ទះចាស់បាន? តាមការរៀបរាប់របស់លោកតា កែវ ផៃ ប្រជាពលរដ្ឋនៅភូមិអូរទទឹង ឃុំព្រះដាក់ ស្រុកបន្ទាយស្រី ខេត្តសៀមរាប ដែលទើបសង់ផ្ទះរួចមានប្រសាសន៍ថា៖ ខ្ញុំស្នើសុំច្បាប់សាងសង់ផ្ទះមិនមានការលំបាកទេ ត្រឹម១ខែគេចេញច្បាប់ឱ្យធ្វើ ព្រោះខ្ញុំមានឯកសារគ្រប់គ្រាន់និងត្រឹមត្រូវតាមលក្ខខណ្ឌដែលអាជ្ញាធរជាតិអប្សរាបានកំណត់ដូចជា ខ្ញុំជាអ្នកស្រុកចាស់រស់នៅតាំងពីឆ្នាំ១៩៨០ជាង មានខ្ទងផ្ទះចាស់ មានឯកសារកាន់កាប់ដីធ្លីស្របច្បាប់ មានសៀវភៅគ្រួសារ និងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ។មុននិងក្រោយអនុញ្ញាតច្បាប់សាងសង់ អាជ្ញាធរជាតិអប្សរាតែងចុះមកពិនិត្យ ថតរូប ក៏ដូចជាប្រឹក្សាយោបល់ផ្សេងៗ។ ពេលបានសាងសង់ហើយ សូមប្រជាពលរដ្ឋកុំធ្វើហួសពីការស្នើសុំ ឬក៏លួចធ្វើដោយគ្មានការអនុញ្ញាត។

ជាប្រជាពលរដ្ឋដែលរស់នៅភូមិអូរទទឹងដែរ លោក សួង ដានី បានលើកឡើងថា ខ្ញុំបានសុំច្បាប់សាងសង់តាមរយៈមេភូមិ ហើយមិនមានជួបការលំបាកអីទេ ព្រោះខ្ញុំភ្ជាប់ជាមួយឯកសារដែលគេត្រូវការត្រឹមត្រូវ។ មិនតែប៉ុណ្ណោះអាជ្ញាធរជាតិអប្សរាបានជួយសម្របសម្រួល គូស ប្លង់បច្ចេកទេស និងរចនាបទផ្ទះបែបខ្មែរឱ្យខ្ញុំទៀតផង។ ចំពោះការដាក់ពាក្យស្នើសុំវិញ ក៏ពុំមានការបង់ប្រាក់ដែរ ហើយខ្ញុំក៏គោរពទៅតាមការស្នើសុំទាំងម៉ូតផ្ទះ ទំហំ របង មិនឱ្យសពីច្បាប់សុំ។ លោក ដានី ក៏បានផ្តាំផ្ញើដល់ប្រជាពលរដ្ឋនៅក្នុងឧទ្យានអង្គរទាំងអស់ មុនធ្វើផ្ទះ ធ្វើសំណង់អ្វីមួយត្រូវគោរពតាមច្បាប់ ត្រូវមានឯកសារគ្រប់គ្រាន់ និងស្របតាមលក្ខខណ្ឌកំណត់នោះមិនមានផលលំបាកក្នុងការស្នើសុំសាងសង់ទេ ហើយចៀសវាងការលួចធ្វើតាមចិត្តឯង ដែលនាំឱ្យប៉ះពាល់ដល់តម្លៃរមណីយដ្ឋានអង្គរនិងផលប្រយោជន៍ខ្លួន។

លោក ខៀវ វិចិត្រ មន្ត្រីបច្ចេកទេសនៃនាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងតំបន់អង្គរបាន បញ្ជាក់ថា បើប្រជាពលរដ្ឋមានបំណងចង់ដាក់ពាក្យស្នើសុំសាងសង់លំនៅដ្ឋាន ជួសជុលតូចតាច និងសំណើផ្សេងៗអាចមកដាក់ពាក្យនៅច្រកចេញចូលទាំង៦របស់អាជ្ញាធរជាតិអប្សរាដែលមានមន្ត្រីបុគ្គលិកប្រចាំការនៅទីនោះចាំប្រឹក្សាយោបល់អំពីឯកសារដែលត្រូវភ្ជាប់មកជាមួយដូចជា លិខិតកាន់កាប់ដីធ្លីស្របច្បាប់ សៀវភៅគ្រួសារ សំបុត្រកំណើត ប្លង់ដី និងអត្តសញ្ញាណប័ណ្ណ។ ពេលបានលិខិតអនុញ្ញាត ក្រុមការងារនឹងចុះមកពិនិត្យទីតាំងផ្ទាល់ រួមទាំងតាមដានសកម្មភាពសាងសង់ថាត្រឹមត្រូវឬខុសពីលក្ខខណ្ឌដែលបានស្នើសុំ។ ករណីប្រជាពលរដ្ឋដែលគោរពតាមគោលការណ៍ក្នុងការស្នើសុំ អាជ្ញាធរជាតិអប្សរានឹងមានលិខិតសរសើរដល់ពួកគាត់បានចូលរួមលើកស្ទួយតម្លៃតំបន់អង្គរ ហើយរាល់ការដាក់ពាក្យស្នើសុំ គឺពុំមានបង់ថវិកាឡើយ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរា ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៨សំណើ

ផ្សាយនៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ មានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយក្នុងភូមិគោកចាន់ ភូមិត្រពាំងរុន ភូមិបង្កោង ឃុំអំពិល។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែង ក្រុមការងារបានអនុញ្ញាតទាំង៦សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ លោក នង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិថ្នល់ សង្កាត់ស្រង៉ែ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន២សំណើ។

សរុបមក នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន៨សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាបើកកិច្ចប្រជុំសវនកម្មផ្ទៃក្នុងគ្រប់នាយកដ្ឋាន និងអង្គភាពចំណុះដើម្បីបញ្ជាក់នូវភាពអនុលោមជាប្រចាំនៃប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរ

ផ្សាយនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី២៤ ខែវិច្ឆកា ឆ្នាំ២០២០ អង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរនៃអាជ្ញាធរជាតិអប្សរាបានបើកកិច្ចប្រជុំសវនកម្មផ្ទៃក្នុងគ្រប់នាយកដ្ឋាននិងអង្គភាពចំណុះ ដើម្បីបញ្ជាក់នូវភាពអនុលោមជាប្រចាំនៃប្រព័ន្ធគ្រប់គ្រងបរិស្ថានអង្គរតាមតម្រូវការនៃស្តង់ដារ ISO-14001:2015 នៅក្នុងរយៈពេលនៃការអនុវត្តបន្តពីសវនកម្មឆ្នាំមុន។

ឯកឧត្តម ឃិត ចាន់ដារដ្ឋ អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា មានប្រសាសន៍ក្នុងកម្មវិធីបើកសវនកម្មផ្ទៃក្នុងថា បរិស្ថាននៅទីនេះផ្តោតលើធាតុ២សំខាន់ គឺធម្មជាតិ និងវប្បធម៌ជាអ្វីៗដែលស្ថិតនៅជុំវិញខ្លួនយើង ហើយកត្តាទាំង២នេះ គឺមានការចូលរួមរបស់មនុស្ស ជាអ្នកជំរុញការងារឱ្យមានភាពប្រទាក់ក្រឡា និងសុខដុមរមនាជាមួយគ្នាដោយមិនអាចខ្វះមួយណាបានឡើយ។

ឯកឧត្តមរំឭកថា តាំងពីឆ្នាំ២០០៦មក អាជ្ញាធរជាតិអប្សរាបានទទួលវិញ្ញាបណ្ណបត្រ៥ដងរួចមកហើយ ដែលឆ្លងកាត់ការវាយតម្លៃយ៉ាងហ្មត់ចត់ពីស្ថាប័នធានាគុណភាពជប៉ុន Japan Quality Assurance (JQA)។ ភាពជោគជ័យទាំងអស់បានមកពីការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំមន្រ្តី-បុគ្គលិករបស់អាជ្ញាធរជាតិអប្សរា ដែលសហការគ្នារវាងនាយកដ្ឋាននីមួយៗ ក្នុងការជំរុញកិច្ចការងារបរិស្ថាននេះ។

ឯកឧត្តម សុខ លក្ខិណា ទីប្រឹក្សាអាជ្ញាធរជាតិអប្សរា និងជាប្រធានអង្គភាពប្រព័ន្ធគ្រប់គ្រងប្រព័ន្ធបរិស្ថាន-អង្គរ បានបញ្ជាក់ថា គោលបំណងសំខាន់នៃការធ្វើសវនកម្ម គឺដើម្បីកំណត់ថា ប្រព័ន្ធគ្រប់គ្រងបរិស្ថាននៃអាជ្ញាធរជាតិអប្សរាអនុលោមទៅតាមកម្មវត្ថុការព្រមព្រៀង ទៅតាមគ្រោងទុកដែរឬទេ? តើគ្រប់នាយកដ្ឋានទាំងអស់បានអនុវត្តតាមផែនការសកម្មភាពរបស់ខ្លួនអនុលោមតាមចំណុចទាមទារទាំងឡាយរបស់ស្តង់ដារ ISO-14001:2015 ដែរទេ?

ឯកឧត្តមបន្តថា ការបើកសវនកម្មផ្ទៃក្នុងនៅពេលនេះ ក្នុងគោលបំណងដើម្បីត្រៀមលក្ខណៈជាមុន និងពិនិត្យឱ្យឃើញនូវភាពអនុលោម និងភាពមិនអនុលោមទាំងឡាយសំដៅកែលម្អ ត្រៀមលក្ខណៈទទួលធ្វើសវនកម្មផ្ទៃក្រៅដែលនឹងប្រព្រឹត្តិទៅ នៅឆ្នាំ២០២១ខាងមុខនេះ៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរបានចំនួន១២សំណើ

ផ្សាយនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទ១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិដូនឪ ឃុំលាងដៃ និងភូមិព្រះគោ ឃុំស្វាយចេក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំស្រុកបន្ទាយស្រីដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ាន់ឌី** បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិព្រះដាក់ និងភូមិតាកុះ ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន១២សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលព្រះពុទ្ធបដិមាមួយអង្គនៅរូតបាកាណកំពូលប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០

ព្រះពុទ្ធបដិមាមួយអង្គនៅទិសខាងត្បូងនៃរូតបាកាណកំពូលប្រាសាទអង្គរវត្តដែលមានបញ្ហាចុះខ្សោយគុភាពសំណង់ ត្រូវបានអ្នកជំនាញអភិរក្សចម្លាក់នៃអាជ្ញាធរជាតិអប្សរាជួសជុលរួចរាល់ជាស្ថាពរ នាខែវិច្ឆិកា ឆ្នាំ២០២០នេះ។

លោក សយ សុភារិន្ទ មន្រ្តីជំនាញអភិរក្សចម្លាក់នៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ និងជាអ្នកជួសជុលបានលើកឡើងថា ព្រះពុទ្ធបដិមាអង្គនេះមានបញ្ហាមួយចំនួននៅត្រង់ព្រះកេស ព្រះភក្រ្ត ជើងផ្នែកខាងក្រោម និងជើងទម្រទប់លំនឹង។ ដោយសារតែជើងទម្រទប់លំនឹងខ្សោយគុណភាព ធ្វើឱ្យទម្ងន់រូបសង្កត់ធ្ងន់លើបាតជើងក្រោម ដែលនាំឱ្យជើងក្រោមប្រេះបែកបាក់ ព្រោះទ្រទម្ងន់ធ្ងន់ពេក។

លោក សុភារិន្ទ បន្តថា ដើម្បីសង្គ្រោះបដិមាឱ្យល្អប្រសើរឡើងវិញ ក្រុមអ្នកអភិរក្សត្រូវតាមដានអង្កេតមើលពីស្ថានភាពខូចខាតជាប្រចាំ ហើយសិក្សាស្រាវជ្រាវចងក្រង និងជួសជុលឱ្យបានទាន់ពេលវេលា បង្ការកុំឱ្យមានបញ្ហាធ្ងន់ធ្ងរដល់បដិមាទាំងមូល។ បច្ចុប្បន្ននេះ អ្វីដែលត្រូវធ្វើដំបូង គឺពង្រឹងជើងក្រោម ផ្លាស់ប្តូរទ្រនល់សម្រាប់ទប់បដិមាឱ្យមានលំនឹងឡើងវិញដើម្បីកាត់បន្ថយកម្លាំងសង្កត់ទៅលើជើងទម្រ។ចំពោះព្រះកាយបដិមាក្រុមការងារបានប្រើវិធីសម្អាតស្ងួតដោយប្រើប្រាស ជក់ ទន់ៗបោសធូលី ក្តាំងធូលី សំបុកពីងពាង ផ្ទៃងាំងឱ្យស្អាត រួចហើយសម្អាតសើមដោយសម្អាតស្នឹមខ្មៅដែលបណ្តាលមកពីផ្សែងធូបទៀនរុំ កំណកក្តាំងអំបិលនៅលើព្រះកាយ ព្រះភក្រ្ត និងព្រះកេស ដោយប្រើវត្ថុធាតុដើម្បីវិភាគថា តើជាតិអ្វីដែលអាចសម្អាតអំបិលបាន ពង្រឹងកន្លែងពុកផុយបាន ជាតិអ្វីអាចរក្សាពណ៌ដើមបាន។

ព្រះពុទ្ធអង្គនេះ ដើមឡើយគឺនៅជាប់នឹងជញ្ជាំងបិទសន្ទប់ទ្វារបន្ទប់នៅរូតបាកាណ តែត្រូវបានដាប់ចេញពីជញ្ជាំងនៅក្នុងសម័យបារាំងប្រហែលឆ្នាំ១៩៤៣ដើម្បីជីកកំណាយអណ្តូងកណ្តាលតួបាកាណចុះទៅក្រោមក្នុងបំណងស្រាវជ្រាវបុរាណវិទ្យា៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះ

ស្រាយស្ថិតនៅក្នុងភូមិប្រឡាយ ភូមិគោកស្នូល ភូមិគោកត្រាច ភូមិព្រៃធ្លក ភូមិបឹងខ្នារ ឃុំខ្នាត។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៩សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ **ឯកឧត្តម ខូយ តីមន្ទ** បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិត្រពាំងសេះ សង្កាត់គោកចក។

ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

សរុបមក នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង២គោលដៅចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ បានចំនួន១៦សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

លិខិតចូលរួមរំលែកមរណទុក្ខ ឯកឧត្តម អ៊ឹង ហឿន ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២០

នៅក្នុងពេលវេលាពោរពេញដោយសមានទុក្ខ និងសេចក្តីសោកស្តាយជាពន់ពេកនេះយើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រីបុគ្គលិក ភ្នាក់ងារ ឆ្មាំ និងពលករទាំងអស់នៃអាជ្ញាធរជាតិអប្សរា សូមរំលែកនូវមរណទុក្ខដ៏សែនក្រៀមក្រំបំផុតជាមួយ លោកជំទាវ និង ក្រុមគ្រួសារចំពោះការបាត់បង់ **ឯកឧត្តម អ៊ឹង ហឿន** ដែលជាការបាត់បង់នៅស្វាមី ឪពុកដ៏តាមួយរូបដែលប្រកបដោយព្រហ្មវិហារធម៌ និងជាទីគោរពស្រលាញ់នៃកូនចៅចៅទួតទាំងអស់ហើយក៏ជាការបាត់បង់នៅវីរកុលបុត្រខ្មែរដ៏ឆ្នើមមួយរូប ដែលបានលះបង់កំលាំងកាយចិត្តពេញមួយជីវិតរបស់ ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្ត ក្នុងបុព្វហេតុជាតិជាពិសេសការលើកស្ទួយកិច្ចអភិវឌ្ឍខេត្តសៀមរាបឲ្យមានការរីកកចម្រើនមកដល់សព្វថ្ងៃនេះ។

អគ្គនាយកអាជ្ញាធរជាតិអប្សរាចូលរួមគោរពវិញ្ញាណក្ខន្ធ ឯកឧត្តម អ៊ឹង ហឿន ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប

ផ្សាយនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

នាព្រឹកថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា បានដឹកនាំសហការីចូលរួមគោរពវិញ្ញាណក្ខន្ធ **ឯកឧត្តម អ៊ឹង ហឿន** ប្រធានក្រុមប្រឹក្សាខេត្តសៀមរាប អាណត្តិទី៣ ដែលបានទទួលមរណភាពកាលពីថ្ងៃទី២៣ខែវិច្ឆិកា ឆ្នាំ២០២០ដោយរោគាពាធ។

ក្នុងនាមថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា **ឯកឧត្តម ហង់ ពៅ** ក៏បានសម្តែងនូវការគោរពនិងចូលរួមរំលែកនូវមរណទុក្ខដ៏ក្រៀមក្រំបំផុតជាមួយ **លោកជំទាវ ប៊ី មាលា** និងក្រុមគ្រួសារចំពោះការបាត់បង់ **ឯកឧត្តម អ៊ឹង ហឿន** ដែលជាស្វាមី ឪពុក ជីតាមួយរូបប្រកបដោយព្រហ្មវិហារធម៌ និងជាទីគោរពស្រលាញ់នៃកូន ចៅ ចៅទួតទាំងអស់នៅក្នុងគ្រួសារ។ មិនតែប៉ុណ្ណោះ នេះក៏ជាការសោកស្តាយចំពោះប្រទេសជាតិដែលបានបាត់បង់វីរកុលបុត្រខ្មែរដ៏ឆ្នើមមួយរូប ដែលបានលះបង់កម្លាំងកាយចិត្តពេញមួយជីវិតរបស់ឯកឧត្តមប្រធានក្រុមប្រឹក្សាខេត្តក្នុងបុព្វហេតុជាតិ ជាពិសេសការលើកស្ទួយកិច្ចអភិវឌ្ឍន៍ខេត្តសៀមរាបឱ្យមានការរីកកចម្រើនមកដល់សព្វថ្ងៃនេះ។

ក្នុងឱកាសដ៏សោកសៅនេះ ឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរានិងសហការី ក៏សូមឧទ្ទិសកុសលផលបុណ្យដែលបានសាងនិងបួងសួងសូមឱ្យវិញ្ញាណក្ខន្ធរបស់ **ឯកឧត្តម អ៊ឹង ហឿន** បានទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងការគោរព ដឹងគុណ និងចងចាំជានិច្ចនូវស្នាដៃរបស់ឯកឧត្តមចំពោះប្រទេសជាតិ ពិសេសការអភិវឌ្ឍនៅខេត្តសៀមរាប៕

សវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ របស់អាជ្ញាធរជាតិអប្សរា បង្ហាញថាមានភាពល្អប្រសើរលើសឆ្នាំកន្លងមក

ផ្សាយនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០

រយៈពេល៣ថ្ងៃ ក្រោយពីចុះពិនិត្យឯកសារ និងលទ្ធផលការងារនៅតាមនាយកដ្ឋានអង្គភាពចំណុះនៃអាជ្ញាធរជាតិអប្សរា រួមទាំងបានចុះពិនិត្យដល់ទីតាំងជាក់ស្តែងក្នុងតំបន់រមណីយដ្ឋានអង្គរ សវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរត្រូវ បានបិទបញ្ចប់នៅថ្ងៃទី២៦ វិច្ឆិកា ឆ្នាំ២០២០។

នៅក្នុងពិធីបិទសវនកម្មផ្ទៃក្នុងប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ISO-14001:2015 លោកអ៊ុន មុន្នីនីតា ប្រធានសវនករ បានបង្ហាញថា សវនកម្មនៅឆ្នាំ២០២០នេះ មានភាពល្អប្រសើរគួរជាទីមោទនភាពជាងឆ្នាំកន្លងមក ហើយភាពល្អប្រសើរឡើង គឺក្នុងនោះមិនមានចំណុចមិនអនុលោមឡើយ ចំណុចតាមអង្កេត២ចំណុចប្រសើរ១៦និងអនុសាសន៍១០។

លោកបានកោតសរសើរចំពោះលទ្ធផលនៃសវនកម្មនៅឆ្នាំនេះ និងសូមឱ្យគ្រប់នាយកដ្ឋាននិងអង្គភាពទាំង១៦ យកចិត្តទុកដាក់កែលម្អជាបន្ថែមទៀតដើម្បីទទួលបានលទ្ធផលកាន់តែប្រសើរថែមទៀត។

ឯកឧត្តម សុខ លក្ខិណា ប្រធានអង្គភាពប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ បានសាទរចំពោះលទ្ធផលដ៏ល្អដែលទទួលបាននៅពេលនេះ និងបញ្ជាក់ថា ភាពជោគជ័យល្អប្រសើរនេះបានមកពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ រួមទាំងមន្ត្រី-បុគ្គលិកទាំងអស់។ ឯកឧត្តម បានផ្តាំផ្ញើដល់គ្រប់នាយកដ្ឋានទាំងអស់ ត្រូវបង្កើនការយកចិត្តទុកដាក់បន្ថែមដើម្បីធ្វើយ៉ាងណា ឱ្យលទ្ធផលកាន់តែប្រសើរជាងនេះជាបន្តបន្ទាប់។

គួរបញ្ជាក់ថា សវនកម្មផ្ទៃក្នុងលើប្រព័ន្ធគ្រប់គ្រងបរិស្ថាន-អង្គរ ធ្វើឡើងដើម្បីប្រសិទ្ធភាព ផ្តោតលើលទ្ធផលសម្រេចបានតាមគោលនយោបាយ និងគោលបំណងបរិស្ថាន។ ស្ថានភាពនៃការគោរពច្បាប់បញ្ញត្តិទាក់ទងនឹងបរិស្ថាន ឆ្លើយតបទៅនឹងការប្រាស្រ័យទាក់ទងជាមួយភាគីផ្ទៃក្រៅ ស្ថានភាពនៃការកែតម្រូវ និងការបង្ការភាពមិនអនុលោម កែលម្អការសម្តែងបរិស្ថានទាំងមូល៕

យុវជននិងគ្រូបង្រៀនចំនួន១៥០នាក់នៃក្រសួងអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ស្វែងយល់អំពីការគ្រប់គ្រងបេតិកភណ្ឌក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០

នារសៀលថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០ លោក ង៉ែត សុខចាន់ ប្រធានការិយាល័យយុវជននៃមន្ទីរអប់រំ និងយុវជនរាជធានីភ្នំពេញ បានដឹកនាំក្រុមប្រឹក្សាកុមារកម្ពុជា-យុវជនកម្ពុជា លោកគ្រូ អ្នកគ្រូ នៃក្រសួងអប់រំ យុវជន និងកីឡារាជធានីភ្នំពេញចំនួន១៥០នាក់ មកស្តាប់បទបង្ហាញអំពីកិច្ចការអភិរក្សនិងអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរពីថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា។

លោក ង៉ែត សុខចាន់ បានឱ្យដឹងថា ដំណើរទស្សនកិច្ចសិក្សានេះ គឺចាប់ពីថ្ងៃទី២៦ដល់២៨ ខែវិច្ឆិកា ឆ្នាំ២០២០ នៅក្នុងតំបន់វប្បធម៌ប្រវត្តិសាស្ត្រនៃខេត្តសៀមរាប ក្នុងបំណងលើកកម្ពស់ការយល់ដឹងបំណិនជីវិត បណ្តុះស្មារតីសាមគ្គីភាព និងគោរពស្រឡាញ់ចំពោះបេតិកភណ្ឌ។ ពិសេសគឺការទទួលបាននូវចំណេះដឹងថ្មីៗតាមរយៈបទបង្ហាញការងារពីអ្នកជំនាញអាជ្ញាធរជាតិអប្សរា ទាក់ទងនឹងកិច្ចការអភិរក្សនិងអភិវឌ្ឍន៍នៅក្នុងរមណីយដ្ឋានអង្គរ។

ក្នុងឱកាសទទួលស្វាគមន៍គណៈប្រតិភូយុវជនទាំង១៥០នាក់នេះ **ឯកឧត្តម គីម សុធិន** អគ្គនាយករងនៃអាជ្ញាធរជាតិអប្សរា ក៏បានធ្វើបទបង្ហាញអំពីកិច្ចការអភិរក្សប្រាសាទក្នុងនិងក្រៅឧទ្យានអង្គរ បញ្ហាប្រឈម កិច្ចសហប្រតិបត្តិការជាតិ-អន្តរជាតិ។ **ឯកឧត្តម សុខ សង្វារ** អគ្គនាយករងក៏បានធ្វើបទបង្ហាញអំពីការគ្រប់គ្រងទេសចរណ៍ក្នុងតំបន់អង្គរ និងលោក ម៉ុក គន្ធី ប្រធានការិយាល័យនៃនាយកដ្ឋានរដ្ឋបាល បុគ្គលិក និងសម្ភារៈ បានបង្ហាញអំពីស្ថាប័នអាជ្ញាធរជាតិអប្សរាដល់យុវជនដើម្បីទទួលបានចំណេះដឹងថ្មី។

ក្រៅពីការស្តាប់បទបង្ហាញពីថ្នាក់ដឹកនាំអាជ្ញាធរជាតិអប្សរា គណៈប្រតិភូក្រុមប្រឹក្សាកុមារកម្ពុជា-យុវជនកម្ពុជា លោកគ្រូ អ្នកគ្រូនៃក្រសួងអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ ក៏បន្តទទួលបានចំណេះដឹងបន្ថែមទៀត នៅតាមការដ្ឋានផ្ទាល់ពីអ្នកជំនាញអាជ្ញាធរជាតិអប្សរាទៀតផង៕

អ្នកជំនាញអាជ្ញាធរជាតិអប្សរាធ្វើកំណាយស្រាវជ្រាវបុរាណវិទ្យារកឃើញឡដុតភាជន៍ នៅខាងជើងខ្លោងទ្វារដីឆ្នាំងនៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០

ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលអន្តរជាតិស្រាវជ្រាវនិងតម្កល់ឯកសារអង្គរនៃអាជ្ញាធរជាតិអប្សរាបានធ្វើកំណាយស្រាវជ្រាវនៅទួលត្រពាំងបុស្ស ស្ថិតក្នុងភូមិនគរក្រៅ សង្កាត់គោកចក ក្រុង/ខេត្តសៀមរាប ដែលមានទីតាំងនៅខាងជើងខ្លោងទ្វារដីឆ្នាំងនៃក្រុងអង្គរធំ បានប្រទះឃើញឡដុតកុលាលភាជន៍បុរាណមួយ ដែលតាមការសន្និដ្ឋានបឋមប្រហែលជាស្ថិតក្នុងសម័យអង្គរ ឬសម័យក្រោយអង្គរ។

លោកបណ្ឌិត ទិន ទីណា អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិនិងតម្កល់ឯកសារអង្គរនិងជាប្រធានក្រុមកំណាយបានឱ្យដឹងថា ការជ្រើសរើសទីតាំងធ្វើកំណាយនៅលើទួលត្រពាំងបុស្ស ដើម្បីឱ្យដឹងច្បាស់ថាទួលនេះជាកន្លែងផលិតភាជន៍សម័យបុរាណមែនឬអត់ ព្រោះកន្លងមកមានអ្នកស្រាវជ្រាវមួយចំនួនប្រទះឃើញសំណល់បំណែកភាជន៍ជាច្រើនរាយប៉ាយលើទួល នៅលើខ្នងទំនប់ ដែលមានទីតាំងនៅផ្នែកខាងលិចក្លោងទ្វារដីឆ្នាំងនៃរាជធានីអង្គរធំ។ ប៉ុន្តែរហូតមកដល់ពេលនេះ ពុំទាន់មានការធ្វើកំណាយស្រាវជ្រាវដើម្បីបញ្ជាក់ថាទីតាំងនេះជាឡដុតភាជន៍សម័យបុរាណនៅឡើយទេ។ ដូច្នេះតាមរយៈបំណែកភាជន៍និងបំណែកដីដុតដែលបន្សល់ទុកនៅលើទួលធំវែងរហូតដល់សព្វថ្ងៃនេះ អ្នកស្រាវជ្រាវមួយចំនួនយល់ស្របគ្នាថា ទីតាំងនេះមានភាគរយខ្ពស់អាចជាឡដុតភាជន៍សម័យបុរាណ។

គម្រោងនេះនឹងបញ្ចប់នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ ហើយតាមរយៈការធ្វើកំណាយ យើងក៏បានឃើញជញ្ជាំងឡនិងភាជន៍ភាគច្រើនជារបស់ប្រើប្រចាំថ្ងៃមាន ឆ្នាំងដី ក្បឿង ចង្ក្រានខូចប៉ុន្តែពុំមានស្រទាប់រលោងទេ។បន្ទាប់ពីកំណាយរួច យើងនឹងសុំគោលការណ៍សិក្សាស្រាវជ្រាវនៅតំបន់នេះបន្តទៀត ដោយចុះបញ្ជីសារពើភណ្ឌទួលទាំងអស់ គូសផែនទី ដាក់ទីនេះជាតំបន់ការពារសម្រាប់ឱ្យភ្ញៀវទេសចរមកទស្សនានិងការសិក្សារបស់អ្នកស្រាវជ្រាវផង។

លោក វិទូ ភិរម្យ បុរាណវិទូនៃអាជ្ញាធរជាតិអប្សរាបានឱ្យដឹងថា ក្រុមការងារបានយកចិត្តទុកដាក់ខ្លាំងទៅលើបច្ចេកទេសកំណាយ ដើម្បីកាត់បន្ថយហានីភ័យដល់សំណង់បុរាណនិងវត្ថុបុរាណដែលប្រទះឃើញនៅក្នុងរណ្តៅ ដោយបែងចែកជាក្រឡាដើម្បីងាយស្រួលប្រមូលទិន្នន័យ ថតរូបរចនាសម្ពន្ធនៃទីតាំងវត្ថុបុរាណ ការប្រើប្រាស់ឧបករណ៍តូចៗ និងអាចគ្រប់គ្រងរចនាសម្ពន្ធឡបានល្អ។ លក្ខណៈរចនាសម្ពន្ធឡដែលរកឃើញនៅពេលនេះ គឺពិសេសណាស់ ព្រោះរូបរាង រចនាសម្ពន្ធឡនេះខុសពីឡភាគច្រើននៅតំបន់អង្គរ ដែលធំៗ វែងៗ។ តាមរយៈវត្ថុដែលប្រទះឃើញនៅទីនេះ ក៏ធ្លាប់ឃើញនៅតាមការដ្ឋានកំណាយលើទីតាំងមនុស្សរស់នៅដែរ តែយើងមិនដឹងថាវាមានប្រភពមកពីឡណាទេ។ ដូច្នេះវានឹងក្លាយជាភស្តុតាងខ្លះៗសម្រាប់ការស្រាវជ្រាវរកប្រភពនៃឡនិងភាជន៍ដែលបានប្រើប្រាស់នាសម័យមុន ថាមានប្រភពមកពីឡមួយណាច្បាស់លាស់។

លោក ឆាយ រចនា ប្រធានការិយាល័យអង្គរភាពកុលាលភាជន៍អង្គរនៃមជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិនិងតម្កល់ឯកសារអង្គរក៏បានបញ្ជាក់ដែរថា ខណៈនេះយើងមិនទាន់ដឹងរូបរាងឡពេញលេញទេ គ្រាន់តែឃើញមានជញ្ជាំងឡ ទំហំឡតូច រាងមូល មានកន្លែងដាក់ឧស មានអង្កត់ផ្ចិតត្រឹម៣ម៉ែត្រការ៉េប៉ុណ្ណោះ ហើយលក្ខណៈពិសេសនៃរចនាសម្ពន្ធឡដីឆ្នាំងនេះពិតជាអស្ចារ្យ ដែលមិនធ្លាប់ឃើញពីមុនមកទេ។ ចំណែកភាជន៍នៅទីនេះក៏គ្មានស្រទាប់រលោងដែរ តែមានក្បាច់លម្អ ហើយភាគច្រើនគឺឆ្នាំងដី និងក្បឿង ដែលខុសពីការផលិតនៅគោកញ្ចៅ និងគោកបី។ តាមរយៈបំណែកក្បឿង យើងអាចសន្និដ្ឋានថា ឡដុតភាជន៍នេះប្រហែលកើតឡើងនៅចុងសម័យអង្គរ ព្រោះក្បឿងប្រភេទនេះមិនសូវឃើញប្រើប្រាស់នៅក្នុងសម័យអង្គរទេ។

ចំពោះឡផលិតភាជន៍នេះ បើតាមការប្រាប់ពីការចងចាំរបស់អ្នកស្រុក ប្រហែលជាអាចជាប់ពាក់ព័ន្ធនឹងការហៅឈ្មោះខ្លោងទ្វារដីឆ្នាំងដែរ ព្រោះជាកន្លែងមានឡផលិតឆ្នាំងដីជាច្រើន៕

អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន ជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរ៣៩១គ្រួសារ

ផ្សាយនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២០

នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថាក្នុងខែវិច្ឆិកាឆ្នាំ២០២០ ក្រុមការងារបានចុះពិនិត្យនិងជួយសម្រួលលក្ខណៈបច្ចេកទេស នៃការសាងសង់លំនៅដ្ឋាននិងសំណង់ឧបសម្ព័ន្ធផ្សេងៗទៀតដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យាននិងក្រៅឧទ្យានអង្គរបានចំនួន៣៩១គ្រួសារ។ ចំពោះប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យានអង្គរមានចំនួន៣៨៣គ្រួសារមាន៖

ក្រុងសៀមរាបចំនួន១១៧គ្រួសារ
ស្រុកប្រាសាទបាគងចំនួន៩៧គ្រួសារ
ស្រុកបន្ទាយស្រីចំនួន៦២គ្រួសារ
ស្រុកពួកចំនួន៥៦គ្រួសារ
និងស្រុកអង្គរធំចំនួន៥១គ្រួសារ។

ចំណែកប្រជាពលរដ្ឋរស់នៅក្រៅឧទ្យានអង្គរចំនួន០៨គ្រួសារ៖ គឺនៅក្រុងសៀមរាបចំនួន០៣គ្រួសារ ស្រុកសូទ្រនិគមចំនួន០២គ្រួសារ និងស្រុកស្វាយលើចំនួន០៣គ្រួសារ។

សូមបញ្ជាក់ថា ក្រុមការងារនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា ដែលតែងចុះពិនិត្យជាប្រចាំ ដើម្បីសម្របសម្រួលករណីសំណើផ្សេងៗ និងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពល

រដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទីនិងភារកិច្ចរបស់ អាជ្ញាធរជាតិអប្សរានោះ គឺមិនតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់ទេ៕

ព្រឹត្តិការណ៍ព័ត៌មាន
ប្រចាំខែធ្នូ

ខែវិច្ឆិកា ឆ្នាំ២០២០ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១៨០ករណី

ផ្សាយនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០

លទ្ធផលការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំខែវិច្ឆិកា ឆ្នាំ២០២០ បានចុះផ្សព្វផ្សាយអប់រំនិងចុះពិនិត្យការស្នើសុំ អនុញ្ញាតការជួសជុល និងសាងសង់តូចតាចទាំង៥គោលដៅស្រុក/ក្រុង ក្នុងតំបន់ឧទ្យានអង្គរ និងក្រៅតំបន់ឧទ្យានអង្គរបានចំនួន២៧១ សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន១៨០សំណើ។

ក្នុងករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងបានចំនួន២០ករណី ស្រុកអង្គរធំបានចំនួន២៩ករណី ស្រុកពួកបានចំនួន៤៤ករណី ក្រុងសៀមរាបបានចំនួន៥៧ករណី និងស្រុកបន្ទាយស្រីបានចំនួន២៣ករណី រួមទាំងក្រុមការងារក្រៅឧទ្យានអង្គរចំនួន៧សំណើសរុប១៨០សំណើ។

ក្រៅពីនោះ ក្រុមការងារសហគមន៍បានចូលរួមក្នុងកិច្ចការមនុស្សធម៌ ជួយឧបត្ថម្ភថវិកាដល់ចាស់ជរា កុមារមានជំងឺជនពិការ គ្រួសារខ្វះខាតមួយចំនួន ចូលរួមក្នុងកិច្ចការសាសនា និងកម្មវិធីផ្សេងៗនៅក្នុងសហគមន៍ ថែមទាំងសំណេះសំណាលដល់ខ្នងផ្ទះប្រជាពលរដ្ឋ ដោះស្រាយសំណើតាមភូមិទាំង១១២ភូមិក្នុងតំបន់អង្គរ។

ជាគោលដៅបន្ត ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរានឹងបន្តផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរឱ្យកាន់តែមានប្រសិទ្ធិភាព ទាន់ពេលវេលា។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ស្ពានឈើចាស់នៅរមណីយដ្ឋានក្បាលស្ពានត្រូវបានរុះរើដើម្បីជួសជុលពង្រឹងសាឡើងវិញ

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០

ពានឈើចាស់នៅរមណីយដ្ឋានក្បាលស្ពាន ដែលរងនូវការទ្រុឌទ្រោម ដោយអាកាសធាតុនិងអាយុកាល ត្រូវបានអាជ្ញាធរជាតិអប្សរារុះរើចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០២០ ដើម្បីជួសជុលពង្រឹងស្ពាននេះឡើងវិញ សម្រាប់ឱ្យភ្ញៀវទេចចរណ៍ឆ្លងកាត់ដោយងាយស្រួល ហើយមានសុវត្ថិភាពក្នុងការទៅលេងកម្សាន្តនៅរមណីយដ្ឋាននេះ។

អំឡុងពេលរុះរើស្ពានចាស់ដើម្បីជួសជុលនេះ អាជ្ញាធរជាតិអប្សរាក៏សូមការអធ្យាស្រ័យពីសំណាក់ភ្ញៀវទេសចរ ធ្វើដំណើរតាមផ្លូវវាងមួយរយៈពេលខ្លីសិន រហូតដល់ស្ពានជួសជុលរួចរាល់៕

ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយ សំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន១ គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយលោក នង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយ ស្ថិតនៅក្នុងភូមិអញ្ចាញ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អគ្គនាយកអាជ្ញាធរជាតិអប្សរាចុះពិនិត្យការងារតាមការដ្ឋានជួសជុលនៅក្នុងរមណីយដ្ឋានអង្គរ

ផ្សាយនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០ **ឯកឧត្តម ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា អមដំណើរដោយថ្នាក់ដឹកនាំនៃនាយដ្ឋានពាក់ព័ន្ធ បានចុះពិនិត្យតាមដានការងារនៅតាមការដ្ឋានជួសជុលប្រាសាទនិងសំណង់ផ្សេងៗនៅក្នុងរមណីយដ្ឋានអង្គរ។

ក្នុងដំណើរត្រួតពិនិត្យការងារថ្ងៃនេះ ឯកឧត្តមអគ្គនាយកបានចុះពិនិត្យគម្រោងជួសជុលស្ពានឈើប្រាសាទតាកែវដែលចាស់ទ្រុឌទ្រោម ដើម្បីជួសជុលពង្រឹងឡើងវិញ។

បន្ទាប់ពីនោះ ឯកឧត្តមអគ្គនាយកនិងសហការី ក៏ទៅកាន់ទីតាំងមួយចំនួននៅប្រាសាទបន្ទាយធំ ប្រាសាទបាយ័ន្ត និងប្រាសាទអង្គរវត្ត ដែលទីតាំងមួយចំនួននោះ ប្រឈមនឹងហានិភ័យខ្ពស់ ដែលចាំបាច់ត្រូវរកវិធីទប់ស្កាត់ឱ្យបានទាន់ពេលវេលា៕



អាជ្ញាធរជាតិអប្សរាបានចេញផ្សាយទស្សនាវដ្ដីឈ្មោះថា «ព្រះនគរ»

ផ្សាយនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរាបានចេញផ្សាយនូវទស្សនាវដ្ដី «ព្រះនគរ» ដែលអត្ថបទទាំងអស់កើតចេញពីការស្រាវស្រាវនៅក្នុងតំបន់ឧទ្យានអង្គរ។ ខ្លឹមសារនៃអត្ថបទទាំងអស់ ពុំស្ថិតនៅក្នុងប្រភេទសំណេរឃោសនាឡើយ ដ្បិតគោលបំណងធំគឺពុំមែននិយាយពីអាជ្ញាធជាតិអប្សរាខ្លួនឯង តែនិយាយពីអតីតរាជធានីយសោធរ ពោលគឺព្រះនគររបស់ខ្មែរ។

យោងតាមបុព្វបទសំណេររបស់ **ឯកឧត្តមបណ្ឌិត ហង់ ពៅ** អគ្គនាយកអាជ្ញាធរជាតិអប្សរា ទស្សនាវដ្ដី «ព្រះនគរ» Journal Of Angkor Studies ផ្ដោតសំខាន់ទៅលើបុរាណវត្ថុរកឃើញថ្មីៗនៅអង្គរ ការអភិរក្សជួសជុលប៉មឥដ្ឋលេខ ៨នៅប្រាសាទបាគង ពិធីឡើងអ្នកតាខែពិសាខនៅវត្តអធ្វា ប្រព័ន្ធធារាសាស្ត្រនៃឧទ្យានអង្គរ និងប្រព័ន្ធធារាសាស្ត្រនៃប្រាសាទព្រះវិហារ។

អត្ថបទទាំងអស់សរសេរដោយអ្នកស្រាវជ្រាវជាតិនិងអន្តរជាតិ។ រីឯប្រភេទប្រធានបទវិញក៏មានច្រើនបែបដូចជាអត្ថបទពិចារណាទូទៅលើការអភិវឌ្ឍរាជធានីអង្គរ អត្ថបទលក្ខណៈបច្ចេកទេសដូចជា ការលម្អិតផែនទីបុរាណស្ថានដោយយោងតាមទិន្នន័យថ្មីៗនៃបច្ចេកវិទ្យាLiDAR ការសិក្សាពិនិត្យសមាសធាតុនៃថ្មដែលខ្មែរបុរាណយកមកសាងប្រាសាទ និងពេងជាងសិតសំរិទ្ធនៅព្រះរាជវាំងអង្គរធំ។ ក៏មានអត្ថបទបច្ចេកទេសដែរ តែទាក់ទងនឹងការថែទាំ ព្រមទាំងការជួសជុលដូចជា ការថែទាំចម្លាក់ថ្មភក់និងចម្លាក់បាយអរកុំឱ្យវិចវិលតាមរយៈបទពិសោធន៍ជាច្រើនឆ្នាំនៅអង្គរ ការជួសជុលសំណង់ធ្វើពីឥដ្ឋ។ អត្ថបទខ្លះទៀតក៏បង្ហាញឱ្យអ្នកអានជ្រាបអំពីវត្ថុបុរាណច្រើនប្រភេទ ដែលអាជ្ញាធរជាតិអប្សរាបានប្រទះឃើញនៅទីនានាហើយយកមករៀបចំទុកដាក់កត់ត្រាចុះបញ្ជីសារពើភណ្ឌ។ អត្ថបទក្នុងពពួកនរវិទ្យាក៏មាននិយាយអំពីបុណ្យទាក់ទងនឹងស្រូវដែលអ្នកស្រុកប្រារព្ធនៅក្នុងបុរាណស្ថានជាទីសក្ការៈរបស់ពួកគាត់។ ឯក្នុងវិស័យធារាសាស្ត្រវិញមានការសិក្សាស្ដីអំពីតំបន់អង្គរ និងទាក់ទងនឹងប្រាសាទព្រះវិហារ។

អាជ្ញាធរជាតិអប្សរាសង្ឃឹមថា ទស្សនាវដ្ដីនេះនឹងក្លាយជាប្រភពនៃចំណេះដឹងថ្មីៗ បន្ថែមទៀតដល់កូនខ្មែរគ្រប់រូបដែល ចង់សិក្សាពីអង្គរ។ ដូច្នេះ លោកអ្នកអាចមករកទស្សនាវដ្ដីព្រះនគរនេះនៅបណ្ណាល័យអាជ្ញាធរជាតិអប្សរាដោយរីករាយ ដើម្បីទទួលបានព័ត៌មានជាចំណេះដឹងអំពីអតីតកាលផង ស្ថានភាពនៃព្រះនគរយើងបច្ចុប្បន្នផង៕

ខែធ្នូ ឆ្នាំ២០២០

សកម្មភាពថែទាំទ្រនល់ឈើការពារសត្វល្អិតនៅប្រាសាទភ្នំក្រោម

ផ្សាយនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០

ក្រុមការងារអភិរក្សប្រាសាទនៃអាជ្ញាធរជាតិអប្សរា នៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២០ បាននាំគ្នាលាបថ្នាំកណ្ដៀរលើទ្រនល់ឈើទ្រប្រាសាទភ្នំក្រោមដែលមានដុំថ្មពុកផុយខ្លាំង ដើម្បីការពារការបំផ្លាញពីសត្វល្អិតទាំងនេះ រួមនឹងប្រឆាំងនឹងការពុកផុយរបស់ឈើដែលបណ្ដាលមកពីបរិយាកាសផង។

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយ សំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី៨ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន១គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយនៅភូមិរំចេក និងភូមិសាលាក្រវ៉ាន់ ឃុំរំចេក។

ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើលំនៅដ្ឋាន និងជួសជុលតូចតាចចំនួន ២៨៤គ្រួសារក្នុងរយៈ៦ខែចុងឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២០

ក្រុមការងារនៃនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនិងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំស្រុកក្រុងទាំង៥ បានអនុញ្ញាតឱ្យប្រជាពលរដ្ឋធ្វើលំនៅដ្ឋាន និងជួសជុលតិចតួចចំនួន២៨៤គ្រួសារ ក្នុងចំណោមពាក្យស្នើសុំទាំងអស់ចំនួន៦២៩គ្រួសារ រយៈពេល៦ខែ ចាប់ពីថ្ងៃ ទី២៥ ខែមិថុនា ដល់ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០២០។

សូមបញ្ជាក់ថា ក្រុមការងារនាយកដ្ឋានរៀបចំដែនដី និងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរ បានចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលករណីសំណើផ្សេងៗ និងជួយណែនាំផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរាការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ និតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និង សាងសង់ផ្ទះក្នុងឧទ្យានអង្គរ។

ប្រភេទសំណើដែលក្រុមការងារទទួលចុះពិនិត្យនិងដោះស្រាយ ការជួសជុលផ្ទះ ប្តូរដំបូល សំយ៉ាប ជញ្ជាំង ប្តូរសសរ ជណ្តើរ របងមានស្រាប់ កបន្ទប់ក្រោមផ្ទះ គូសប្លង់ផ្ទះ និងជួយសម្រួលលក្ខណៈបច្ចេកទេស៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន១ គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយចំនួន នៅក្នុងភូមិបន្ទាយស្រី និងភូមិទួលក្រឡាញ់ ឃុំខ្នារសណ្ដាយ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្ដែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយនៅស្ថិតក្នុងភូមិលាងដៃ ភូមិសំពេង ភូមិត្រពាំងឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិល្បើក ភូមិត្នោតជ្រុំ ភូមិអន្លង់ធ្នន់ ភូមិតាកាំ ភូមិគោកញ្ញៅ ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សរុបមកនៅថ្ងៃទី១១ខែធ្នូឆ្នាំ២០២០ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងពីរគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន៨សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

កិច្ចប្រជុំរបស់គណៈកម្មាធិការអន្តរជាតិអាយស៊ីស៊ី-អង្គរ ត្រូវបានលើកពេល

ផ្សាយនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា សូមជម្រាបជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបថា សម័យប្រជុំបច្ចេកទេសលើកទី៣៤ និងសម័យប្រជុំពេញអង្គលើកទី២៧ នៃគណៈកម្មាធិការអន្តរជាតិដើម្បីសម្របសម្រួល កិច្ចគាំពារនិងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា អាយស៊ីស៊ី-អង្គរ ដែលគ្រោងរៀបចំនៅពាក់កណ្តាលខែធ្នូនេះ ត្រូវបានលើកពេលទៅថ្ងៃក្រោយ។ មូលហេតុនៃការសម្រេចលើកពេលកិច្ចប្រជុំដែលគ្រោងរៀបចំតាមប្រព័ន្ធវីដេអូ នៅថ្ងៃទី១៥ និងទី១៦ ខែធ្នូ នៅសណ្ឋាគារ ស៊ូហ្វីតែល អង្គរភូគីត្រា ខេត្តសៀមរាប គឺស្របតាមការណែនាំពីរាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមទប់ស្កាត់ការរីករាយដាលជំងឺកូវីដ១៩ ដែលក្នុងនោះក៏មានការឯកភាពស្ថាប័នពាក់ព័ន្ធគឺ ពីសហប្រធានទាំងពីរ (បារាំង និងជប៉ុន) ការិយាល័យអង្គការយូណេស្កូប្រចាំរាជធានីភ្នំពេញ និងអាជ្ញាធរជាតិអប្សរា។ ចំពោះកាលបរិច្ឆេទថ្មីសម្រាប់កិច្ចប្រជុំខាងលើនេះ អាជ្ញាធរជាតិអប្សរានឹងជូនដំណឹងជាថ្មីនៅពេលក្រោយ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

លេខ: ៥៦០/២០ រប.សង្វា

សេចក្តីជូនដំណឹង
ស្តីពី
ការផ្អាកសម័យប្រជុំបច្ចេកទេសលើកទី៣៤ និងសម័យប្រជុំពេញអង្គ លើកទី២៧ នៃគណៈកម្មាធិការអន្តរជាតិ «ICC-Angkor»

អាជ្ញាធរជាតិអប្សរា មានកិត្តិយសសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោក លោកស្រី មេត្តាជ្រាបថា យោងតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចូលរួមទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា សហប្រធានទាំងពីរ(បារាំង និងជប៉ុន) ការិយាល័យអង្គការយូណេស្កូប្រចាំរាជធានីភ្នំពេញ និងអាជ្ញាធរជាតិអប្សរា បានសម្រេចផ្អាកការរៀបចំសម័យប្រជុំបច្ចេកទេសលើកទី៣៤ និងសម័យប្រជុំពេញអង្គលើកទី២៧ នៃគណៈកម្មាធិការអន្តរជាតិ ដើម្បីសម្របសម្រួលកិច្ចគាំពារ និងអភិវឌ្ឍន៍រមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ ហៅកាត់ថា «ICC-Angkor» ដែលនឹងគ្រោងរៀបចំនៅថ្ងៃទី១៥ និង១៦ ខែធ្នូ ឆ្នាំ២០២០ នៅសណ្ឋាគារសូហ្វីតែល អង្គរ ភូគីត្រា ខេត្តសៀមរាប។ ចំពោះកាលបរិច្ឆេទថ្មីសម្រាប់ការរៀបចំសម័យប្រជុំខាងលើនេះ អាជ្ញាធរជាតិអប្សរា នឹងជូនដំណឹងជាថ្មីនៅពេលក្រោយ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ មេត្តាជ្រាបជាព័ត៌មានតាមការគួរ៕

ថ្ងៃ...សុក្រ....១១រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
សៀមរាប ថ្ងៃទី....១១.....ខែ...ធ្នូ......ឆ្នាំ ២០២០
អគ្គនាយក

ហង់ ពៅ

អាជ្ញាធរជាតិអប្សរា
អាសយដ្ឋាន៖ ភូមិបង្កោង ឃុំអំពិល
ស្រុកប្រាសាទបាគង ខេត្តសៀមរាប

អាជ្ញាធរដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរ
Website: apsaraauthority.gov.kh Email: info@apsaraauthority.gov.kh
Tel/Fax: (+855-63) 765 577 / 765 576

APSARA National Authority
Address: Bang Korng Village, Ampil Commune,
Prasat Bakong District, Siem Reap Province

អាជ្ញាធរជាតិអប្សរានិងស្ថាប័នពាក់ព័ន្ធចូលរួមបោះបង្គោលព្រំ ការពារបុរាណដ្ឋាននៅស្រុកវ៉ារិន

ផ្សាយនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០២០

កាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារបច្ចេកទេសនៃនាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរ បានសហការជាមួយមន្ទីរវប្បធម៌ស្រុក រដ្ឋបាលស្រុក អាជ្ញាធរភូមិ ឃុំ ដោយមានការចូលរួមពីប្រជាការពារភូមិ និងប្រជាជនមួយចំនួន បានបន្តការងារបោះបង្គោលព្រំការពារបុរាណដ្ឋាននៅក្នុងភូមិល្វា ឃុំស្រែណូយ ស្រុកវ៉ារិន ខេត្តសៀមរាប បានចំនួន៨ទីតាំងហើយ។

បុរាណដ្ឋានទាំង៨ទីតាំងនោះមានដូចជា ប្រាសាទអូរប្រាសាទ ប្រាសាទរលំដូនមោង ប្រាសាទត្រពាំងឈូក គោកពពូល ត្រពាំងបេង ត្រពាំងចង្អុកក្រាំង ត្រពាំងរលំវែង និងត្រពាំងគុម្ពភ្លៀង។

ការបោះបង្គោលព្រំការពារបុរាណដ្ឋានគឺដើម្បីជាប្រយោជន៍ក្នុងការកំណត់ព្រំដីដែលមានបុរាណដ្ឋានត្រូវការពារបានត្រឹមត្រូវ ការពារការកាន់កាប់ដោយខុសច្បាប់ពីឈ្មួញទិញលក់ដីធ្លី និងងាយស្រួលសម្រាប់ប្រជាពលរដ្ឋដឹងកុំឱ្យពួកគាត់វាទទីដីធ្វើកសិកម្មឬរស់នៅលើប្រាសាទ ស្រះទឹក និងរចនាសម្ពន្ធសំណង់បុរាណផ្សេងៗដោយពុំដឹង ព្រោះពួកគាត់ក៏មានបំណងចង់ការពារឱ្យបុរាណដ្ឋានទាំងនោះឱ្យល្អប្រសើរដែរ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិចំបក់ ភូមិបង្គោង ឃុំរលួស។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតទាំង៦សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ លោក ឡុង កុសល បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិប្រិយ៍ចាស់ ភូមិគោកដូង សង្កាត់ទឹកវិល។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងពីរគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន១១សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

សារលិខិតជូនពរ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា

ផ្សាយនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០

ក្នុងឱកាសដ៏មហាប្រពៃថ្លៃថ្លានៃថ្ងៃខួបគម្រប់៦៦ឆ្នាំ ឈានចូល៦៧ឆ្នាំរបស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី ហ៊ុនសែន**ប្រធានកាកបាទក្រហមកម្ពុជាដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអង្គារ ១កើត ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនិងថ្ងៃទី១៥ខែធ្នូឆ្នាំ២០២០នេះយើងខ្ញុំជាថ្នាក់ដឹកនាំ មន្ត្រីរាជការបុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរជាតិអប្សរា មានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង សូមគោរពជូននូវពរសព្ទសាធុការជ័យជូនចំពោះ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា សូមមានសុខភាពបរិបូរណ៍កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ និងមានសុភមង្គលដ៏ត្រចេះត្រចង់។

យើងខ្ញុំទាំងអស់គ្នា សូមគោរពកោតសរសើរដោយស្មោះចំពោះសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ដែលជាកុលធីតាខ្មែរដ៏ឆ្នើមមួយរូប ជាឧត្តមភរិយា សម្តេចតេជោនាយករដ្ឋមន្ត្រី ដ៏ប្រពៃ ជាមាតាដ៏ល្អ ជាជីដូនដែលមានព្រហ្មវិហារធម៌ ដែលមានស្នាដៃដ៏ប៉ិនប្រសប់រាប់មិនអស់ និងគំនិតប្រាជ្ញាដ៏ឧត្តុង្គឧត្តម ឈ្លាសវៃ ក្នុងការដឹកនាំកាកបាទក្រហមកម្ពុជា ដើម្បីបំពេញបេសកម្មមនុស្សធម៌ដ៏ថ្លៃថ្លា ប្រកប ដោយគុណធម៌ សប្បុរសធម៌ និងបានចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការយកចិត្តទុកដាក់ដោះស្រាយទុក្ខលំបាកជូនប្រជាពលរដ្ឋរងគ្រោះគ្រប់រូប គ្រប់ទីកន្លែងទូទាំងប្រទេស និងបានខិតខំលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងតម្លៃគ្រួសារខ្មែរឲ្យបានខ្ពង់ខ្ពស់រុងរឿង ជាពិសេសបានចូលរួមដឹកនាំសកម្មភាពដ៏មានសារសំខាន់ ក្នុងការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ក្នុងបុព្វហេតុការពារអាយុជីវិតប្រជាជនយើង។

ឆ្លៀតក្នុងឱកាសដ៏វិសេសថ្លៃថ្លានេះដែរ យើងខ្ញុំទាំងអស់គ្នា សូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅបំផុតចំពោះ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប្រធានកាកបាទក្រហមកម្ពុជា ដែលបានចូលរួមចំណែកដ៏ថ្លៃថ្លាក្នុងការដាំកូនឈើក្នុងរមណីយដ្ឋានអង្គរ (ឧទ្យានសហស្សវត្សរ៍កាកបាទក្រហម) ដែលបច្ចុប្បន្នដើមឈើទាំងនោះបានធំលូតលាស់ ម្លប់ត្រឈឹងត្រឈៃ បង្កើតបានជាទេសភាពធម្មជាតិ និងវប្បធម៌នៃរមណីយដ្ឋានអង្គរដ៏ស្រស់ត្រកាល ធ្វើឲ្យរមណីយដ្ឋានអង្គរកាន់តែមានភាពទាក់ទាញក្នុងក្រសែភ្នែកភ្ញៀវជាតិ និងអន្តរជាតិ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមឧទ្ទិសបួងសួងដល់គុណព្រះរតនត្រ័យ វត្ថុសក្តិសិទ្ធិក្នុងលោក និងទេវតាដែលរក្សាទឹកដីអង្គរ សូមប្រសិទ្ធពរជ័យបវរសួស្តី សិរីមង្គលវិបុលសុខ មហាប្រសើរ គ្រប់ប្រការជូន សម្តេចកិត្តិព្រឹទ្ធបណ្ឌិតឧត្តមភរិយាដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជានិងក្រុមគ្រួសារជាទីស្រលាញ់សូមបានសមប្រកបនូវសុខភាពបរិបូរណ៍ អាយុយឺនយូរ កម្លាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ ដើម្បីអភិឱ្ឍមាតុភូមិកម្ពុជាក្នុងបេសកម្មដ៏ ឧត្តុង្គឧត្តម ក្នុងការដឹកនាំស្ថាប័ន កាកបាទក្រហមកម្ពុជា និងបម្រើជាតិ ព្រមទាំងប្រជាពលរដ្ឋកម្ពុជាឲ្យកាន់តែរីកចម្រើនឈានឆ្ពោះទៅរកភាពសម្បូរសប្បាយជានិច្ចនិរន្តរ៍។

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍ចំនួន៣គោលដៅដែលបានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិស្ទឹង ភូមិឪឡោក ភូមិលលៃ ភូមិស្ពានក្អែក ឃុំរលួស។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិភ្លង់ ភូមិភ្លង់(គោកគ្រើល) ភូមិសំរោង ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។ គោលដៅទី៣ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយនៅភូមិអូរទទឹង ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

សរុបមក នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងបីគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន១៩សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ខ្លោងទ្វារខាងកើតប្រាសាទតានៃនឹងបញ្ចប់ការជួសជុលជាស្ថាពរពីអ្នកជំនាញខ្មែរនាចុងឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា សហការជាមួយវិទ្យាស្ថានជាតិស្រាវជ្រាវមរតកវប្បធម៌នៃទីក្រុងតូក្យូ (Tokyo) ប្រទេសជប៉ុន ធ្វើការជួសជុលខ្លោងទ្វារខាងកើតរបស់ប្រាសាទតានៃជិតរួចរាល់ជាស្ថាពរហើយ។

លោក ស៊ា សុភារុន បុរាណវិទូនៃនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ និងបុរាណវិទ្យាបង្ការ និងជាប្រធានការដ្ឋានជួសជុលបានឱ្យដឹងថា ការជួសជុលខ្លោងទ្វារខាងកើតប្រាសាទ តានៃដែលចាប់ផ្តើមតាំងពីឆ្នាំ២០១៩មកម្លេះ ពេលនេះ ឈានទៅដល់ការគ្រោងនឹងបញ្ចប់នៅត្រឹមចុងឆ្នាំ២០២០។

លោកមានប្រសាសន៍ទៀតថា ដើមឡើយបញ្ហាប្រឈមខ្លាំងរបស់ខ្លោងទ្វារខាងកើតប្រាសាទតានៃ គឺរចនាសម្ព័ន្ធរបស់ទាំងមូលរបស់ខ្លោងទ្វារតែម្តង ដោយមូលហេតុឫសនិងដើមឈើធ្វើឲ្យគ្រឹះរំកិលចេញពីទីតាំងដើមបណ្តាលឲ្យថ្មជញ្ជាំងហែកចេញពីគ្នានឹងអាចបាក់រលំ។ ឯដំបូលថ្មបានជ្រុះធ្លាក់ស្ទើរទាំងស្រុង។

ហេតុមកដល់ពេលនេះ ខ្លោងទ្វារខាងកើតនៃប្រាសាទតានៃត្រូវបានជួសជុលស្ទើរតែរួចរាល់ និងថ្មដំបូលត្រូវបានរៀបចំតម្លើងឡើងវិញតាមរូបរាងដើមទាំងស្រុង៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍ចំនួន ២គោលដៅដែលបានសហការជាមួយអាជ្ញាធរមូលដ្ឋាន ចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយស្ថិតក្នុងភូមិប្រទ្បាយ ភូមិបឹងខ្នារ ភូមិព្រៃក្មេង ភូមិស្វាយ ឃុំខ្នាត។

ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាប ដឹកនាំដោយ លោក នង សុវណ្ណរិទ្ធ បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិវាល សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សរុបមក នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងបីគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន១២សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

សត្វទោចមកុដ១គូចុងក្រោយ គ្រោងដោះលែងក្នុងព្រៃធម្មជាតិនៃក្រុងអង្គរធំ

ផ្សាយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០

បន្ទាប់ពីគម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ ក្រោមកិច្ចសហការរវាង អាជ្ញាធរជាតិអប្សរា រដ្ឋបាលព្រៃឈើ ភ្នំពេញ និងអង្គការ Wildlife Alliance ទទួលបានជោគជ័យជាបន្តបន្ទាប់រួចមក ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២០ គម្រោងនេះបានដឹកជញ្ជូនសត្វទោចមកុដ១គូទៀត ដែលជាគូចុងក្រោយ ពីមជ្ឈមណ្ឌលថែទាំ និងសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ មកផ្សាំក្នុងទ្រុងនៅជិតបឹងជូនមាក្បែរខ្លោងទ្វារដីឆ្នាំងខាងជើងក្រុងអង្គរធំ។ សត្វទោចមកុដគូចុងក្រោយនេះ គ្រោងនឹងធ្វើការដោះលែងពីទ្រុងចូល ទៅក្នុងព្រៃធម្មជាតិនៅឆាប់ៗខាងមុខ។

សត្វទោចមកុដជាសត្វរស់នៅជាគ្រួសារ មិនចូលជាមួយគ្រួសារ ឬជាមួយហ្វូងដទៃទេ ហើយគ្រួសារនីមួយៗមានដែនគ្រាច់ចររៀងៗខ្លួនពី៥ទៅ១០ហិកតា និងមិនត្រួតដែនព្រៃគ្នាទេ។ ការកំណត់ទីតាំងក្រុមសត្វទោចមកុដទាំង៣គូកន្លងមក គឺមានគម្លាតពីគ្នា២០០០ម៉ែត្រ ឯចំណុះព្រៃនៅក្នុងឧទ្យានអង្គរ អាចសម្រាប់តែ៤គ្រួសារប៉ុណ្ណោះ ចំពោះលំហព្រៃនៅសេសសល់គឺបំរុងសម្រាប់កូនៗបែកពីមេបា។

កន្លងមកគម្រោងនេះបានដោះលែងរួចមកហើយនូវសត្វទោចមកុដចំនួន៣គូមានចំនួន១២ក្បាល (កើតកូនបានចំនួន៦ក្បាល) ដែលមានទីតាំងស្ថិតនៅក្បែរខ្លោងទ្វារតាកាវខ្លោងទ្វារខ្មោចក្បែរប្រាសាទតានៃនិងមួយគូចុងក្រោយនេះក្បែរខ្លោងទ្វារដីឆ្នាំង។ នៅពេលជាមួយគ្នានោះ គម្រោង

ក៏បានដោះលែងសត្វឆ្មាដាវ (Leopard Cat) ចំនួន១គូ និងសត្វកេងកងតូច (Oriental Pied Hornbill) ចំនួន១គូដែរចូលក្នុងព្រៃធម្មជាតិ ក្រោយពីគម្រោងបានផ្សាំក្នុងទ្រុងអស់រយៈពេលជិត៣ខែមក។ ក្រៅពីនោះ កន្លងមកក៏មានការដោះលែងសត្វឈ្លូស៤ក្បាល សត្វស្វាព្រាម១២ក្បាល សត្វសំពោចក្រអូប៥ក្បាលនិងសត្វកេខ្លនរលោង៥ក្បាល ចូលក្នុងព្រៃអភិរក្សក្នុងរមណីយដ្ឋានអង្គរ។

ដើម្បីឲ្យសត្វព្រៃទាំងអស់នោះបន្តវត្តមាននៅក្នុងព្រៃធម្មជាតិនៃរមណីយដ្ឋានអង្គរយើង និងបង្កើនចំនួនបន្ថែមទៀត អាជ្ញាធរជាតិអប្សរា និងគម្រោងដោះលែងសត្វព្រៃក្នុងឧទ្យានអង្គរ សូមអំពាវនាវហើយអំពាវនាវទៀតជូនសាធារណជន ភ្ញៀវជាតិ អន្តរជាតិ ជាពិសេសប្រជាពលរដ្ឋដែលរស់នៅតំបន់នោះ ចូលរួមថែរក្សាសត្វព្រៃទាំងនោះទាំងអស់គ្នា ជៀសវាងពេលប្រទះឃើញមានបំណងមិនល្អ និងសូមកុំផ្តល់ចំណីឲ្យសត្វទាំងនោះ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍ចំនួន ២គោលដៅ ដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ លោកស្រី ម៉ៅ ល្អ បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិថ្នល់ត្រង់ ឃុំបាគង។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំក្រុងស្រុកបន្ទាយស្រីដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិថ្នល់ទទឹង ភូមិថ្នល់បណ្តោយ ភូមិព្រះដាក់ ឃុំព្រះដាក់។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

សរុបមក នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងពីរគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន១២សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាកំពុងកាត់ដកហូតដើមឈើមានហានិភ័យខ្ពស់ នៅប្រាសាទក្រោលរមាស លើភ្នំគូលែន

ផ្សាយនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០

ដើមឈើហានិភ័យខ្ពស់ចំនួន ១៦ដើម ស្ថិតនៅបរិវេណប្រាសាទក្រាលរមាសលើភ្នំគូលែនត្រូវបានក្រុមអ្នកជំនាញផ្នែកព្រៃឈើរបស់អាជ្ញាធរជាតិអប្សរា កំពុងកាត់ដកហូតក្នុងបំណងដើម្បីបង្ការហានិភ័យជាយថាហេតុ។

ការងារនេះធ្វើឡើង ក្រោយពីក្រុមអង្កេតដើមឈើមានហានិភ័យរបស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយផ្នែកពាក់ព័ន្ធ ចុះពិនិត្យមើលស្ថានភាពជាក់ស្តែងនៃដើមឈើទាំងនោះ និងបានរកឃើញមានដើមឈើហានិភ័យខ្ពស់ចំនួន១៦ដើមរួមមាន ដើមសំបួរចំនួន១៤ដើមនិងដើមតាសែងចំនួន២ដើមដែលកំពុងដុះទ្រេតខ្លាំងមកលើតួប្រាសាទ និងដុះជាប់ថ្មប្រាសាទ។

ក្រុមការងារបាននិងកំពុងដំណើរការងារកាត់ដកហូតដើមឈើខាងលើ ចាប់តាំងពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២០មកដើម្បីធានាដល់សុវត្ថិភាពភ្ញៀវទេសចរ ដែលចូលមកទស្សនាប្រាសាទនេះ ជៀសវាងមានគ្រោះថ្នាក់ប៉ះពាល់ដល់អាយុជីវិតនិងរចនាសម្ព័ន្ធប្រាសាទព្រមទាំងធ្វើឲ្យមានសោភ័ណភាពស្រស់ស្អាតផង៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន៤ គោលដៅដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង គោលដៅ១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិសំពេង ភូមិលាងដៃ ភូមិក្លូង់ ឃុំលាងដៃ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន១១សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិពាម ភូមិដូនអុន ភូមិគោកពោធិ ភូមិគោកថ្មី ភូមិដូនកែវ ឃុំខ្នាត។ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

គោលដៅទី៣ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ លោក អ៉ឹម សុខរិទ្ធី បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិអារក្សស្វាយ សង្កាត់នគរធំ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៩សំណើ។

គោលដៅទី៤ ក្រុមការងារប្រចាំក្រៅឧទ្យានដឹកនាំដោយ លោក ឈាន រដ្ឋា បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងឃុំបឹងមាលា និងឃុំបល្ល័ង្ក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៦សំណើ។

សរុបមក នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំង៤គោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន៣៣សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាកំពុងកាត់ដកហូតដើមឈើមានហានិភ័យខ្ពស់ នៅប្រាសាទក្រោលរមាស លើភ្នំគូលែន

ផ្សាយនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

ឯកឧត្តម ហង់ ពៅ អគ្គនាយកនៃអាជ្ញាធរជាតិអប្សរា រួមទាំងសហការី បានចុះពិនិត្យការដ្ឋានកំណាយស្រាវជ្រាវ ដែលមានទីតាំងនៅព្រះរាជរោងសិតលោហៈនាជ្រុងពាយ័ព្យនៃក្រុងអង្គរធំនៅរសៀលថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០២០ ។

គម្រោងនេះមានឈ្មោះ ថាLANGAU - សិតថ្វាយព្រះមហាក្សត្រ៖ ការសិក្សាអំពីលោហកម្មបុរាណនៃរោងជាងសំរឹទ្ធក្នុងព្រះបរមរាជវាំងក្រុងអង្គរធំ កាលពីអំឡុងសតវត្សរ៍ទី១១ ដល់១២នៃគ.ស.។

គោលបំណងសំខាន់របស់គម្រោងនេះ គឺដើម្បីកំណត់ពីប្រភពនៃការផ្គត់ផ្គង់ ជាតុទង់ដែងទាំងនៅក្នុងស្រុកខ្មែរនាសម័យបុរាណ និងនាំចេញទៅកាន់ប្រទេសជិតខាងផង។

កំណាយស្រាវជ្រាវនេះក្រោមកិច្ចសហការរវាងអាជ្ញាធរជាតិអប្សរានិងសាលាបារាំងចុងបូព៌ា (EFEO) ថែមទាំងមានការចូលរួមពីក្រុមស្រាវជ្រាវ អ្នកជំនាញផ្នែកបុរាណវិទ្យា អ្នកជំនាញផ្នែកលោហៈកម្មបុរាណអ្នកជំនាញផ្នែកភូគព្ភបុរាណ អ្នកជំនាញផ្នែកកុលាលភាជន៍ អ្នកជំនាញផ្នែករូបវិទ្យា និងអ្នកជំនាញផ្នែកជួសជុលលោហៈ អន្តរជាតិ ផង ។

សកម្មភាពកំណាយនៅលើទីតាំង ដែលធ្វើឡើងតាំងពីឆ្នាំ២០១៦រហូតមកដល់ពេលនេះបានប្រទះឃើញសំណល់ជាច្រើន រួមមានឡចំហេះធ្យូងថ្មចំនួន២០កន្លែង ឡសិតលោហៈ និងរោងជាងដំលោហៈ ជញ្ជាំងឡ បណ្ដុំឈ្នួលឈ្នួលជើងកាល់ជើងទម្រនិងចង្ក្រានសិតលោហៈជាដើម។ តាមការពិនិត្យរុករកផ្នែកភូគព្ភគីមី នៅផ្ទៃដីប្រមាណ៧៥០០ម៉ែត្រក្រឡា ឱ្យដឹងថាការបំពុលដីដោយលោហៈធ្ងន់ក៏អាចជួយឱ្យក្រុមអ្នកជំនាញដឹងពីវិសាលភាពនៃទីតាំងរបស់ព្រះរាជរោងសិតលោហៈ និងផលប៉ះពាល់បរិវេណក្បែរនោះដែរ។

ទិន្នន័យនៃការវិភាគថ្មីៗ និងលទ្ធផលនៃការសិក្សាបច្ចេកទេសវិទ្យាផ្សេងទៀត ជាពិសេសបដិមាអំពីលោហៈ បង្ហាញពីភាពចម្រុះនៃលក្ខណៈបច្ចេកទេសរបស់ជាងស្ថិតនៅក្នុងព្រះបរមរាជវាំងសម័យបុរាណអាចឱ្យអ្នកស្រាវជ្រាវសម័យថ្មី យល់ដឹងអំពីរបៀបរស់នៅនិងការរៀបចំនៃរោងសិប្បកម្មលោហៈទាំងមូល នៅក្នុងរដ្ឋការខ្មែរនាសម័យអង្គរបាន៕

ប្រាសាទកណ្ដាលស្រះស្រង់មុនជួសជុល

អាជ្ញាធរជាតិអប្សរា គ្រោងនឹងបញ្ចប់គម្រោងជួសជុលប្រាសាទកណ្ដាលស្រះស្រង់ នៅបំណាច់ឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

សំណង់ប្រាសាទកណ្ដាលស្រះស្រង់ ដែលដំណើរការជួសជុលអស់រយៈពេល៩ខែកន្លងមក ដោយអ្នកជំនាញអាជ្ញា

ធរជាតិអប្សរានឹងបញ្ចប់ការជួសជុលជាស្ថាពរនៅបំណាច់ឆ្នាំ២០២០នេះ។

ប្រាសាទកណ្ដាលស្រះស្រង់ពេលកំពុងជួសជុលជិតរួចរាល់

កញ្ញា ម៉េង សុវណ្ណលីលីន បុគ្គលិកបច្ចេកទេសនៃគម្រោងជួសជុលប្រាសាទកណ្ដាលស្រះស្រង់មកពីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរ បញ្ជាក់ថា បច្ចុប្បន្នក្រុមការងារកំពុងរៀបថ្មភក់រួតទី៧និងទី៨នៃប្រាសាទបង្ហើយ និងការរៀបចំកូនទំនប់ដើម្បីទប់ជើងទេរដែលធ្វើពីដីឥដ្ឋជុំវិញគ្រឹះប្រាសាទការពារពេលបញ្ចូលទឹកវិញ មិនធ្វើឱ្យដីឥដ្ឋរលុះ។

អ្នកជំនាញរូបនេះក៏បន្ថែមដែរថា រូបរាងប្រាសាទកណ្ដាលស្រះស្រង់មានរាងដូចជាចេតិយមួយ សង់នៅលើខឿនថ្មបាយក្រៀមនិងលាយថ្មភក់ចំនួន៨រួត។នេះជាសំណង់មួយដែលមានលក្ខណៈប្លែកគេនៅក្នុងតំបន់អង្គរ។

ក្នុងនោះដែរ កញ្ញា លីលីន ក៏បានឱ្យដឹងថា ក្រោយការជួសជុលតួប្រាសាទនិងបិទទំនប់ជើងទេររួចរាល់ អាជ្ញាធរជាតិអប្សរានឹងបើកទឹកបញ្ចូលវិញ។ ដើម្បីធានាសុវត្ថិភាពប្រាសាទពេលក្រោយពេលបញ្ចូលទឹក គឺក្រុមការងារបានរៀបចំគ្រឹះយ៉ាងពិសេសដោយប្រើថ្មបាយក្រៀមទាំងអស់នៅខាងក្នុង ប្រើដែកទាមថ្កក់ភ្ជាប់រចនាសម្ពន្ធថ្មបាយក្រៀមមួយៗឱ្យជាប់មាំបានល្អ៕

ក្រុមជំនាញផ្នែកព្រៃឈើនៃអាជ្ញាធរជាតិអប្សរា បានជួយកាត់ក្រី និងដកហូតដើមឈើ បង្ការគ្រោះថ្នាក់តាមការស្នើសុំពីប្រជាពលរដ្ឋ

ផ្សាយនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២០

ដោយមានការស្នើសុំពីប្រជាពលរដ្ឋរស់នៅភូមិបន្ទាយឈើ សង្កាត់ទឹកវិល ក្រុងសៀមរាប និងដោយមើលឃើញពីហានិភ័យនៃដើមឈើទាំងនោះ ក្រុមជំនាញផ្នែកព្រៃឈើរបស់នាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាននៃអាជ្ញាធរជាតិអប្សរា បានសហការជាមួយផ្នែកពាក់ព័ន្ធ ចុះពិនិត្យមើលស្ថានភាព និងសម្រេចកាត់ដើមត្រាចងាប់១ដើម និងឈើទាលងាប់១ដើម។ រីឯដើមឈើទាល៤ដើមទៀតត្រូវកាត់ក្រីចំនួន១៥មែកដោយសារដើមឈើទាំងនោះដុះជាប់ផ្លូវ និងជាប់ផ្ទះ។

ការជួយសម្រួលការងារនេះដែរ ក៏ដើម្បីធានាសុវត្ថិភាពជូនប្រជាពលរដ្ឋ ដែលតែងតែធ្វើដំណើរឆ្លងកាត់ និងរស់នៅក្បែរនោះ បង្ការគ្រោះថ្នាក់ទុកជាមុន និងការពារកុំឲ្យបាក់រលំមកលើលំនៅដ្ឋាន ព្រមទាំងសម្រាលតួដើមរបស់ដើមឈើទាំងនោះផង។ ក្រុមជំនាញផ្នែកព្រៃឈើនៃអាជ្ញាធរជាតិអប្សរា បានធ្វើការកាត់ដកហូត និងក្រីមែកដើមឈើទាំងនោះ ហើយបានបញ្ចប់ការងាររួចរាល់កាលពីពេលថ្មីៗ៕

ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំ នៃអាជ្ញាធរជាតិអប្សរាបរិច្ចាគថវិកា ជូនសម្តេចតេជោដើម្បីទិញវ៉ាក់សាំងកូវីដ-១៩

ផ្សាយនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០

ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំ នៃអាជ្ញាធរជាតិអប្សរា សរុបមានចំនួន ៦១៥នាក់ បានចូលរួមចំណែកបរិច្ចាគថវិកាចំនួន ២២,០៣៤,៤៨៦ រៀល និង ១,០៣៧ ដុល្លារ ជូន **សម្តេចតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីកម្ពុជា ដើម្បីទិញវ៉ាក់សាំងកូវីដ១៩ សម្រាប់ចាក់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ។

ការចូលរួមបរិច្ចាគនេះធ្វើឡើងបន្ទាប់ពីសម្តេចនាយករដ្ឋមន្ត្រី ប្រកាសពីការត្រៀមថវិកាទិញវ៉ាក់សាំងកូវីដ១៩ មកចាក់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ស្របពេលដែលជំងឺកូវីដ១៩បានឆ្លងចូលដល់សហគមន៍កម្ពុជា៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA
លេខ៖...............

បញ្ជីរាយនាមថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំ អាជ្ញាធរជាតិអប្សរា
បរិច្ចាគថវិកាជូន សម្តេចតេជោ ហ៊ុន សែន
ដើម្បីរួមចំណែកទិញវ៉ាក់សាំងការពារ ជំងឺកូវីដ១៩ (COVID-19)
ដោយបញ្ជូនទឹកប្រាក់ទៅគណនី តាមបណ្តាញធនាគារនិងតាមកម្មវិធី ABA **របស់ឈ្មោះ** TEP SOTHY

ល.រ	ឈ្មោះសប្បុរសជន	តួនាទី	ចំនួនទឹកប្រាក់		តាមរយៈ	អ្នកទទួល
			ដុល្លារ	រៀល		
1	ឯកឧត្តម ហង់ ពៅ	អគ្គនាយក		2,000,000.00	ACLEDA	Tep Sothy
2	ឯកឧត្តម ជុំ សុភមករា	អគ្គនាយករង		1,000,000.00	ACLEDA	Tep Sothy
3	ឯកឧត្តម ឃិត ចាន់ដារដ្ឋ	អគ្គនាយករង		1,000,000.00	ACLEDA	Tep Sothy
4	ឯកឧត្តម គឹម សុធិន	អគ្គនាយករង		600,000.00	ACLEDA	Tep Sothy
5	ឯកឧត្តម ខូយ គីមទូ	ទីប្រឹក្សាក្រសួងវប្បធម៌	$ 300.00		ABA	Tep Sothy
6	ឯកឧត្តម សុខ លក្ខិណា	ទីប្រឹក្សាក្រសួងវប្បធម៌	$ 100.00		ABA	Tep Sothy
7	ឯកឧត្តម ម៉ី ម៉ារ៉ានី	ទីប្រឹក្សាក្រសួងវប្បធម៌		500,000.00	ACLEDA	Tep Sothy
8	លោកស្រី ម៉ៅ ល្អ	ទីប្រឹក្សាក្រសួងវប្បធម៌		200,000.00	WING	Vaccine Covid-19 Fundraising
9	លោក ឃិន សូវ៉ាត	ទីប្រឹក្សាក្រសួងវប្បធម៌	$ 100.00		ACLEDA	Tep Sothy
10	លោក អ៊ឹង តុងអៀង	ទីប្រឹក្សាក្រសួងវប្បធម៌		200,000.00	ABA	Tep Sothy
11	លោក ភ័ន ផល្លា	ប្រធាននាយកដ្ឋាន		200,000.00	ACLEDA	Tep Sothy
12	លោក ឡុង កុសល	ប្រធាននាយកដ្ឋាន		1,000,000.00	ACLEDA	Tep Sothy
13	លោក ធុច បញ្ចបញ្ញា	ប្រធាននាយកដ្ឋាន		1,000,000.00	ACLEDA	Tep Sothy
14	លោក អ៊ុម សុខរិទ្ធី	ប្រធាននាយកដ្ឋាន		100,000.00	WING	Vaccine Covid-19 Fundraising
15	លោក ឈាន រដ្ឋា	ប្រធាននាយកដ្ឋានស្តីទី		200,000.00	ACLEDA	Tep Sothy

អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតការជួសជុលផ្ទះនិងសាងសង់សំណង់តូចតាចបាន ចំនួន៣០៨២គ្រួសារក្នុងឆ្នាំ២០២០

ផ្សាយនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០

គិតត្រឹមពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាបានចុះសំណេះសំណាលដល់ខ្នងផ្ទះ ដើម្បីពិនិត្យ និងដោះស្រាយសំណើ សុំជួសជុលផ្ទះ សាងសង់តូចតាចតាមភូមិក្នុងតំបន់ឧទ្យានអង្គរ សរុបបានចំនួន៤២៨២គ្រួសារ ហើយបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន ៣០៨២គ្រួសារ ។

ករណីអនុញ្ញាតខាងលើបានផ្តល់ជូនប្រជាពលរដ្ឋនៅស្រុកប្រាសាទបាគង ចំនួន៤៤១គ្រួសារ ស្រុកអង្គរធំចំនួន ៥៣១គ្រួសារ ស្រុកពួកចំនួន ៦៣៥គ្រួសារ ស្រុកបន្ទាយស្រីបានចំនួន ៨៤៨គ្រួសារ ក្រុងសៀមរាបចំនួន ៦១០គ្រួសារ និងក្រៅឧទ្យានចំនួន ១២គ្រួសារ។

ក្រៅពីនោះ ក្រុមការងារសហគមន៍បានជួយឧបត្ថម្ភថវិកាដល់ចាស់ព្រឹទ្ធាចារ្យ ចាស់ជរា ជនពិការ ជនទីទ័លក្រ អ្នកជំងឺ កុមារពិការ និងការជួយឧបត្ថម្ភជាសម្ភារដូចជា ស៊ីម៉ង់ត៍ ស័ង្កសី ព្រមទាំងបានជួយឧបត្ថម្ភគាំទ្រដល់វិស័យព្រះពុទ្ធសាសនាផង។

ក្រុមការងារសហគមន៍បានចុះជាប់ជាប្រចាំ ដើម្បីសម្របសម្រួលករណី សំណើផ្សេងៗ និងជួយណែនាំផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី និងភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ និតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរ ប្រភេទសំណើដែលក្រុមការងារសហគមន៍ទទួលចុះពិនិត្យនិងដោះស្រាយ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាជួសជុលផ្លូវវង់ធំ ចាប់ពីចំណុចមុខប្រាសាទប្រែរូប រហូតដល់ខាងលិចប្រាសាទមេបុណ្យខាងកើត

ផ្សាយនៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២០

កាលពីពាក់កណ្ដាលខែវិច្ឆិកា ឆ្នាំ២០២០ នាយកដ្ឋានទ្រទ្រង់បច្ចេកទេស និងអន្តរវិស័យនៃអាជ្ញាធរជាតិអប្សរាបានជួសជុលកំណាត់ផ្លូវវង់ធំចាប់ពីមុខប្រាសាទប្រែរូប រហូតដល់ខាងលិចប្រាសាទមេបុណ្យខាងកើតដែលមានប្រវែង១៨00ម៉ែត្រ។ នេះគឺជាការបន្តការជួសជុលពីឆ្នាំ២០១៩ ដែលអាជ្ញាធរជាតិអប្សរាបានជួសជុលកែលម្អកំណាត់ផ្លូវវង់ធំ ចាប់ពីប្រាសាទនាគព័ន្ធ រហូតដល់ប្រាសាទមេបុណ្យខាងកើតប្រវែង៥គីឡូម៉ែត្រ។

ចំពោះការអនុវត្តការងារជួសជុលកែលម្អផ្លូវពីមុខប្រាសាទប្រែរូប រហូតដល់ខាងលិចប្រាសាទមេបុណ្យខាងកើត មានទទឹង៦ម៉ែត្រ ជាប្រភេទបេតុងកៅស៊ូ(AC)ហើយគ្រោងនឹងបញ្ចប់នៅដើមឆ្នាំ២០២១ខាងមុខ។

សូមបញ្ជាក់ដែរថា កំណាត់ផ្លូវវង់ធំក្នុងតំបន់ឧទ្យានអង្គរមានប្រវែងជាង២០គីឡូម៉ែត្រជាផ្នែកមួយដ៏សំខាន់សម្រាប់ការធ្វើដំណើររបស់អ្នកស្រុកផង និងបម្រើឱ្យវិស័យទេសចរណ៍ផង៕

ខែធ្នូ ឆ្នាំ២០២០

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែងគោលដៅទី១ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយ លោក អឿន សំអុន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិគោកត្រាច ភូមិអំពិលពាម ភូមិព្រៃធ្លក ភូមិទឹកថ្លា ឃុំខ្នាត។ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។ គោលដៅទី២ ក្រុមការងារប្រចាំក្រុងសៀមរាបដឹកនាំដោយ **ឯកឧត្តម ខូយ គីមឆន** បានពិនិត្យ និងដោះស្រាយនៅភូមិត្រពាំងសេះ សង្កាត់គោកចក។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៥សំណើ។

សរុបមក នៅថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងពីរគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន១៣សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី២៤ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានសហការជាមួយអាជ្ញាធរមូលដ្ឋានបានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិគោកស្រុក ភូមិដូនទាវ ឃុំរលួស ភូមិតាប្រាក់ ឃុំមានជ័យ។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្នែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

គោលដៅ២ ក្រុមការងារប្រចាំស្រុកបន្ទាយស្រី ដឹកនាំដោយ **ឯកឧត្តម ម៉ី ម៉ារ៉ាឌី** បានពិនិត្យ និងដោះស្រាយ ស្ថិតនៅ

ក្នុងភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ។ ក្រោយពីពិនិត្យទីតាំង និងឯកសារដាក់ស្នែងក្រុមការងារបានអនុញ្ញាតចំនួន៤សំណើ។

សរុបមក នៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងពីរគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន៨សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាបញ្ចប់ការជួសជុលប្រាសាទដំរីក្រាបនៅលើខ្នងភ្នំគូលែន

ផ្សាយនៅថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០

នាយកដ្ឋានអភិរក្សប្រាសាទក្រៅឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរា បានបញ្ចប់ការជួសជុលប្រាសាទដំរីក្រាបនៅលើភ្នំគូលែនដោយប្រាសាទនេះមានខឿនពុកផុយនិងស្រុតផ្នែកខាងលិច។ រីឯជញ្ជាំងមានប្រេះហែកជាច្រើនកន្លែង ស៊ុមទ្វារខាងកើតបម្រុងជ្រុះធ្លាក់ និងមានការពុកផុយផ្នែកខ្លះនៃដំបូល។

ការខូចខាតទាំងនេះ បណ្ដាលមកពីកត្តាមនុស្ស ធម្មជាតិ និងអាយុកាលដែលជាមូលហេតុចម្បងដូចជា៖ មានជនខិលខូចជីកកកាយគ្រឹះប្រាសាទ ឫសឈើដុះចាក់ហែកខឿន ជញ្ជាំង និងដំបូលប្រាសាទ ហើយដើមឈើខ្លះទៀតរលំសង្កត់លើតួប្រាសាទ។

ក្នុងការងារជួសជុល ក្រុមការងារបានពង្រឹងខឿនដែលពុកផុយនៅជ្រុងទាំង៤ រៀបពង្រឹងខឿនផ្នែកខាងលិចដែលស្រុត ចាក់ថ្នាំសម្លាប់កូនរុក្ខជាតិ និងសម្អាតឫសដើមឈើដែលដុះលើជញ្ជាំងនិងដំបូលប្រាសាទ ដើម្បីបញ្ឈប់ការលូតលាស់របស់ដើមឈើបន្តទៀត។

បន្ថែមពីនោះ ក៏ជួសជុលពង្រឹងដំបូល ស៊ុមទ្វារខាងកើត ជ្រុងប្រាសាទនៅរួតទី១ និងទី២ ដំឡើងសសរពេជ្រចូលទីតាំងដើមវិញ និងរើរៀបពង្រឹងកាំជណ្ដើរខាងមុខ បិទផ្នឹតជញ្ជាំងប្រេះហែក ពុកផុយ រៀបបំពេញក្បាលសសរផ្ដោបខាងកើតនិងខាងលិចឡើងវិញ សម្អាតដីនៅរួតទី១ លុបថ្នក់ទឹក និងធ្វើចង្អូរដោះទឹកភ្លៀង៕

ក្រុមការងារព្រៃឈើនឹងចុះកាត់ដកហូតដើមឈើហានិភ័យ២ដើមនៅប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០

ក្រុមការងារកាត់ក្រីមែកឈើ នៃនាយកដ្ឋានគ្រប់គ្រងព្រៃឈើ ទេសភាពវប្បធម៌ និងបរិស្ថាន នឹងចុះកាត់ដកហូតដើមឈើហានិភ័យចំនួន២ដើម ស្ថិតក្នុងបរិវេណប្រាសាទអង្គរវត្ត។ ការចុះកាត់ នឹងចាប់ផ្តើមនៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០២០ តទៅ។



ដើមឈើហានិភ័យទាំង២ដើមនោះមាន ១) ដើមត្នោត មានស្ថានភាពងាប់ដើម មានកម្ពស់ប្រហែល១២ម៉ែត្រ អង្កត់ផ្ចិតទំហំ ៣០ស.ម និងមានទីតាំងនៅខាងជើងទីសក្ការៈលោកតារាជ្យ ២) ដើមស្នួល មានអង្កត់ផ្ចិតទំហំ ៦០ស.ម កម្ពស់ប្រហែល១៨ម៉ែត្រ ដែលមានស្ថានភាពទ្រេតជាប់ផ្លូវ និងនៅក្បែរខឿនប្រាសាទ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍ចំនួននៃអាជ្ញាធរជាតិអប្សរាចំនួន២គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរ មូលដ្ឋាន បានបចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

គោលដៅទី១ ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយលោក ព្រហ្ម សំអ៊ាន បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិក្ដង់ ភូមិក្ដង់(គោកគ្រើល) ភូមិលាងដៃ ភូមិសំរោង ឃុំលាងដៃ ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៧សំណើ។

គោលដៅទី២ ក្រុមការងារប្រចាំស្រុកពួក ដឹកនាំដោយលោក អឿន សំអុន បានពិនិត្យ និងដោះស្រាយនៅក្នុងភូមិអន្លង់ធ្នង់ ឃុំដូនកែវ។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន១០សំណើ។

សរុបមក នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាទាំងពីរគោលដៅបានពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងតំបន់ឧទ្យានអង្គរបានចំនួន១៧សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

សត្វស្វាទាញទម្លាក់ផ្ទាំងព័ត៌មាននៅប្រាសាទបាយ័ននាពេលកន្លងមក

សត្វស្វាកាចៗមួយចំនួននៅប្រាសាទបាយ័ននឹងត្រូវយកចេញទៅព្រលែង នៅក្នុងព្រៃក្រៅឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០

ហ្វូងសត្វស្វាកាចៗ មួយចំនួនដែលមានភាពសាំទៅនឹងមនុស្ស និងការផ្តល់នំចំណីដោយមនុស្សបានប្រែពីប្រភេទសត្វព្រៃមកជាសត្វចិញ្ចឹម។ តាមរយៈនេះសត្វស្វាទាំងនោះបានចេញចូលរកចំណីក្នុងតំបន់ប្រាសាទផងដែរ។ ក្នុងការស្វែងរកចំណីនោះ សត្វស្វាបានដណ្តើមចំណីពីមនុស្ស បង្កការរំខាន និងពេលខ្លះប៉ះពាល់ដល់ភ្ញៀវទេសចរដោយផ្ទាល់តែម្តង។ លើសពីនេះសត្វស្វាក៏បានបង្កហានិភ័យដល់ប្រាង្គប្រាសាទដូចជា រុញឲ្យជ្រុះនូវថ្មប្រាសាទ និងធ្វើឲ្យខូចខាតនូវផ្ទាំងបដាព័ត៌មានផ្សេងៗទៀតផង។ ប្រការនេះចាំបាច់ត្រូវយកចេញដើម្បីបញ្ចៀសបញ្ហាផ្សេងៗ នាពេលអនាគត។

ក្នុងន័យនេះ អាជ្ញាធរជាតិអប្សរា សហការជាមួយរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងធ្វើការចាប់យកសត្វស្វាកាចៗទាំងនោះចេញពីតំបន់អង្គរទៅធ្វើចត្តាឡីស័កមុននឹងព្រលែងចូលព្រៃធម្មជាតិផ្សេងទៀតក្រៅពីឧទ្យានអង្គរ។ តាមគម្រោង ការងារនេះនឹងចាប់ផ្តើមពីរសៀលថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ នាប្រាសាទបាយ័ន។

លោក ជូរ៉ា ឌីណា អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រៃឈើទេសភាពវប្បធម៌ និងបរិស្ថាន នៃអាជ្ញាធរជាតិអប្សរា ប្រាប់ថា លោកមិនទាន់ដឹងពីចំនួនពិតប្រាកដនៃចំនួនសត្វស្វាដែលត្រូវនាំចេញនៅឡើយទេ។ លោកបន្ថែមថា ការងារនេះមានកិច្ចសហការជាមួយរដ្ឋបាលព្រៃឈើ ដែលមានមន្ត្រីជំនាញក្នុងការធានាថា ការចាប់សត្វស្វាចេញពីតំបន់អង្គរមានសុវត្ថិភាពខ្ពស់។

សត្វស្វាខាំជើងភ្ញៀវទេសចរនាពេលកន្លងមក

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុល ផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាចំនួន១ គោលដៅដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះរបស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកប្រាសាទបាគង ដឹកនាំដោយ **ឯកឧត្តម សុខ លក្ខិណា** បានពិនិត្យ និងដោះស្រាយស្ថិតនៅក្នុងភូមិមមាញ ភូមិដូនទាវ ភូមិរលួសខាងលិច ឃុំរលួស។ ក្រោយពីពិនិត្យទីតាំង និងឯកសារជាក់ស្តែងក្រុមការងារបានអនុញ្ញាតចំនួន៨សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

អាជ្ញាធរជាតិអប្សរាបានចុះពិនិត្យលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាន ជូនប្រជាពលរដ្ឋក្នុងតំបន់អង្គរចំនួន៨២៣គ្រួសារ

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

នាយកដ្ឋានរៀបចំដែនដីនិងគ្រប់គ្រងលំនៅដ្ឋានក្នុងឧទ្យានអង្គរនៃអាជ្ញាធរជាតិអប្សរាឱ្យដឹងថា ក្នុងឆ្នាំ២០២០ ក្រុមការងារបានចុះពិនិត្យនិងជួយសម្រួលលក្ខណៈបច្ចេកទេសនៃការសាងសង់លំនៅដ្ឋាននិងសំណង់ឧបសម្ពន្ធផ្សេងៗទៀតដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងឧទ្យាន និងក្រៅឧទ្យានអង្គរបានចំនួន៨២៣គ្រួសារ។

គ្រួសារទាំង៨២៣មាន ក្រុងសៀមរាបចំនួន២១៨គ្រួសារ ស្រុកប្រាសាទបាគងចំនួន២១៤គ្រួសារ ស្រុកបន្ទាយស្រីចំនួន១៥៤គ្រួសារ ស្រុកពួកចំនួន១១២គ្រួសារ និងស្រុកអង្គរធំចំនួន១១៤គ្រួសារ។ ចំណែកប្រជាពលរដ្ឋរស់នៅក្រៅឧទ្យានអង្គរចំនួន១១គ្រួសារ៖ គឺនៅក្រុងសៀមរាបចំនួន០៥គ្រួសារ ស្រុកសូទ្រនិគមចំនួន០២គ្រួសារ និងស្រុកស្វាយលើចំនួន០៤គ្រួសារ។

សូមបញ្ជាក់ថា រាល់ការអនុញ្ញាតនិងដាក់ពាក្យសាងសង់ស្នើសុំ គឺមិនតម្រូវឱ្យប្រជាពលរដ្ឋបង់ប្រាក់នោះឡើយ៕

ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បណ្តុះបណ្តាលអ្នកជំនាញអាជ្ញាធរជាតិអប្សរា ទាក់ទងនឹងការពង្រឹងសមត្ថភាពព្យាបាលនិងជួសជុលវត្ថុបុរាណតាមបែបវិទ្យាសាស្ត្រ

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

មូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េនៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ (KOICA) បានបើកវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាពព្យាបាលនិងជួសជុលវត្ថុបុរាណតាមបែបវិទ្យាសាស្ត្រ រយៈពេល៥ថ្ងៃ ពីថ្ងៃទី២១ដល់២៥ ខែធ្នូ ឆ្នាំ២០២០ ដល់មន្ត្រី-បុគ្គលិកជំនាញជួសជុលនិងអភិរក្សប្រាសាទនៃអាជ្ញាធរជាតិអប្សរាចំនួន១៥នាក់។

លោក ផាក សងធល់ អ្នកស្រាវជ្រាវនិងអភិរក្សនៃមូលនិធិបេតិកភណ្ឌវប្បធម៌កូរ៉េជាគ្រូបង្គោលនៃវគ្គបណ្តុះបណ្តាល បានបង្រៀនពីរបៀបប្រើប្រាស់ និងទទួលទិន្នន័យពីឧបករណ៍វិភាគលើ ថ្មរបៀបមើលពីសមាសធាតុនៃថ្មនីមួយៗ បញ្ហាខូចខាត ជំងឺថ្ម ប្រភពថ្ម ប្រភេទថ្ម ដែលជួយពន្លឿននៅក្នុងកិច្ចការជួសជុលអភិរក្សថ្មបានល្អ លឿន និងមានវិធីសាស្ត្រច្រើនក្នុងការជួសជុល។

លោក សងធល់ ក៏បានបញ្ជាក់ថា ប្រាសាទនៅខ្មែរភាគច្រើនធ្វើពីថ្មភក់ ងាយរងផលប៉ះពាល់ពីអាកាសធាតុក្តៅហើយសើម ជួនមានភ្លៀងធ្លាក់ខ្លាំង ជួនក្តៅខ្លាំង ហើយនឹងការដុះឡើងនៃរុក្ខជាតិលើប្រាសា ទបំផ្លាញរចនាសម្ពន្ធប្រាសាទ។លោករំពឹងទុកថាក្រោយបញ្ចប់វគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមទាំង១៥នាក់នឹងអាចរៀបចំការអភិរក្សប្រាសាទទៅតាមលំដាប់លំដោយយ៉ាងមានប្រសិទ្ធភាពខ្ពស់ក្នុងការអភិរក្សថ្ម។ ក្រុមការងារនឹងបន្តធ្វើវគ្គបណ្តុះបណ្តាលនេះទៀត ដើម្បីផ្តល់ចំណេះដឹងបន្ថែមផ្នែកអភិរក្សបែបវិទ្យាសាស្ត្រដល់អ្នកជំនាញអាជ្ញាធរជាតិអប្សរា ពិសេសខាងកូរ៉េចង់ឱ្យមន្ទីរពិសោធន៍នេះ មានមុខងារកាន់តែសំខាន់នៅក្នុងកិច្ចការអភិរក្សប្រាសាទនៅក្នុងតំបន់អង្គរតាមរយៈកិច្ចសហប្រតិបត្តិការកូរ៉េ-អាជ្ញាធរជាតិអប្សរា។

លោក សាន ចន្ទសុខា មន្ត្រីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានឱ្យដឹងថា នេះជាលើកទី១ ដែលបានរៀនពីរបៀបមើលមីក្រូទស្សន៍និងប្រើអ៊ុលត្រាសោន ដែលឱ្យយើងដឹងពីការខូចខាតនៅខាងក្នុងថ្មដែលយើងមិនអាចមើលដោយភ្នែកទទេបាន។ វគ្គបណ្តុះបណ្តាលនេះបានពង្រឹងសមត្ថភាពពាក់ព័ន្ធនឹងការពិសោធដោយប្រើប្រាស់ឧបករណ៍វិទ្យាសាស្ត្រជំនួយដល់ការជួសជុល ដែលកន្លងមករាល់ការពិសោធភាពខូចខាតនៃថ្មនិងសំណល់បុរាណវិទ្យាផ្សេងៗនៅក្នុងតំបន់អង្គរនិងប្រទេសកម្ពុជា ច្រើនពឹងលើការវិភាគនៅក្រៅប្រទេសប៉ុណ្ណោះ។

លោក អាត សុខចាន់ មន្ត្រីមកពីនាយកដ្ឋានអភិរក្សប្រាសាទក្នុងឧទ្យានអង្គរនិងបុរាណវិទ្យាបង្ការ បានលើកឡើងថា ការរៀនលើកនេះគឺមានសម្ភារគ្រប់គ្រាន់។ យើងមានវិធីច្រើនសម្រាប់សិក្សាស្វែងរកភាពខូចខាតនៃថ្ម តែវិធីរៀននេះមានភាពងាយស្រួលជាងមុនព្រោះយើងប្រើម៉ាស៊ីនអាចវិភាគដឹងច្រើនលឿនរហ័សក្នុងការបំពេញការងារបានប្រសើរជាងមុន។ លោកសង្ឃឹមថានឹងមានការបណ្តុះបណ្តាលបែបនេះបន្តទៀតព្រោះយើងបានរៀនតែទ្រឹស្តីច្រើនជាងអនុវត្ត៕

អាជ្ញាធរជាតិអប្សរាដាក់ឱ្យដំណើរការនូវប្រព័ន្ធស្រោចស្រពស្មៅនៅបរិវេណប្រាសាទអង្គរវត្ត

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

នៅព្រឹកថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ នេះ អាជ្ញាធរជាតិអប្សរាបានដាក់ឱ្យដំណើរការនូវប្រព័ន្ធស្រោចស្រពស្មៅនៅបរិវេណប្រាសាទអង្គរវត្ត ដែលប្រព័ន្ធនេះ នឹងធ្វើឱ្យវាលស្មៅទាំងអស់ មានភាពបៃតងខ្ជួបប្រាំងខ្ជួបវស្សា។ នេះជាសមិទ្ធផលថ្មីមួយទៀតរបស់អាជ្ញាធរជាតិអប្សរានៅចុងឆ្នាំ២០២០នេះ បើទោះបីជាកម្ពុជាពើបប្រទះវិបត្តិជំងឺកូវីដ១៩ យ៉ាងណាក្តី។

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា ថ្លែងឱ្យដឹងថា ក្រោយការរៀបចំ និងខិតខំប្រឹងប្រែងពីក្រុមអ្នកជំនាញទឹកនៃអាជ្ញាធរជាតិអប្សរារយៈពេលមួយឆ្នាំរួចមក ប្រព័ន្ធស្រោចស្រពស្មៅដើរដោយស្វ័យប្រវត្តិ បានដាក់ឱ្យដំណើរការជាផ្លូវការ ហើយចំណុចនេះនឹងជួយឱ្យវាលស្មៅទាំងអស់ក្នុងបរិវេណប្រាសាទអង្គរវត្តដែលមានទំហំជាង ១១ហិកតា នឹងមានភាពបៃតង ស្រស់ស្អាត ទាក់ទាញភ្ញៀវទេសចរថែមមួយកម្រិតទៀត។ ឯកឧត្តមបន្តថា ការរៀបចំនេះ គឺបានទាញទឹកពីក្នុងកសិន្ធុអង្គរវត្ត ដែលមានការធានានូវនិរន្តរភាពសម្រាប់ការទាញទឹកមកប្រើប្រាស់ដោយមិនមានការបារម្ភពីការខ្វះទឹកឡើយ។

អគ្គនាយកអាជ្ញាធរជាតិអប្សរា និងជាអ្នកជំនាញទឹកមួយរូប **ឯកឧត្តម ហង់ ពៅ** ពន្យល់បន្ថែមថា មុននឹងឈានដល់ការអនុវត្តគម្រោងនេះ គឺក្រុមអ្នកជំនាញបានសិក្សានិងគុណគូររួចជាមុន អំពីបរិមាណទឹកក្នុងកសិន្ធុ ហើយការទាញទឹកពីប្រព័ន្ធបុរាណនេះ អាចធានាការស្រោចស្រពទាំងមូលបាន ពិសេសនារដូវប្រាំងនេះ។

ជាមួយគ្នានេះដែរ តាមការបញ្ជាក់ពីឯកឧត្តមអគ្គនាយកអាជ្ញាធរជាតិអប្សរា ការកំណត់ទឹកដើរដោយប្រព័ន្ធស្វ័យប្រវត្តិនេះ ក៏មិនមានផលប៉ះពាល់ដល់ថ្មប្រាសាទនោះដែរ។ ផ្ទុយទៅវិញ ទឹកនេះនឹងជួយដល់ភាពរឹងមាំប្រាសាទទៅវិញ៕

ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាចុះពិនិត្យ និងដោះស្រាយសំណើសុំជួសជុលផ្ទះ របស់ប្រជាពលរដ្ឋក្នុងឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០

ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរាដែលមានការចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន បានចុះពិនិត្យ និងដោះស្រាយសំណើស្នើសុំជួសជុលតូចតាចរបស់ ប្រជាពលរដ្ឋនៅក្នុងតំបន់ឧទ្យានអង្គរ។

ជាក់ស្តែង ក្រុមការងារប្រចាំស្រុកអង្គរធំ ដឹកនាំដោយ លោក ព្រហ្ម សំអ៊ាន បានចុះពិនិត្យសំណើសុំជួសជុលប្តូរដំបូលផ្ទះរបស់ប្រជាជននៅក្នុងភូមិសំរោង ភូមិភ្លង់ ភូមិលាងដៃ ភូមិតាប្រុក ភូមិដូនឪ ស្ថិតនៅឃុំលាងដៃ។ ក្រោយពីចុះពិនិត្យដល់ទីតាំងជាក់ស្តែង អនុញ្ញាតបាន២៧សំណើ។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

ទិដ្ឋភាពផ្លូវមុខប្រាសាទអង្គរវត្ត ក្រោយស្ថាបនារួច

ផ្សាយនៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២០

អាជ្ញាធរជាតិអប្សរា បានរៀបចំចាក់កៅស៊ូអ៊ុតផ្លូវមុខប្រាសាទអង្គរវត្ត រួចរាល់ជាស្ថាពរហើយ ដែលការណ៍នេះធ្វើឱ្យសោភ័ណភាពបរិស្ថាននៅតំបន់នេះកាន់តែមានភាពស្រស់ស្អាត និងទាក់ទាញជាខ្លាំង។

នារយៈពេលចុងក្រោយនាឆ្នាំ២០២០នេះ បើទោះបីជាមានការរំខានដោយសារជំងឺកូវីដ១៩យ៉ាងណាក្តី តែការអភិវឌ្ឍក្នុងតំបន់រមណីយដ្ឋានអង្គរ ពិសេសនៅបរិវេណខាងមុខប្រាសាទអង្គរវត្ត មានការរីកចម្រើនទៅមុខជានិច្ច ដូចជាការរៀបចំចំណតរថយន្តថ្មី ទីលានបដិសណ្ឋារកិច្ច តូបលក់ដូរ ការដាំដើមឈើចម្រុះនិងដាំស្មៅលម្អដែលបង្កើតឱ្យបរិស្ថានខាងមុខនេះ មានភាពបៃតងគួរជាទីទស្សនាសម្រាប់ទេសចរគ្រប់រូប៕

សេចក្តីប្រកាសព័ត៌មានស្តីពីករណីចាប់សត្វស្វាកាចមួយចំនួនចេញពីតំបន់ឧទ្យានអង្គរ យកទៅព្រលែងឲ្យរស់នៅបែបធម្មជាតិនៅតំបន់ក្រៅឧទ្យានអង្គរ

ផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិអប្សរា
APSARA

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
ករណីចាប់សត្វស្វាកាចមួយចំនួនចេញពីតំបន់ឧទ្យានអង្គរ
យកទៅព្រលែងឱ្យរស់នៅបែបធម្មជាតិនៅតំបន់ក្រៅឧទ្យានអង្គរ

ពាក់ព័ន្ធនឹងករណីនេះ អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ជូនសាធារណជនទាំងអស់មេត្តាជ្រាបថា បច្ចុប្បន្នចំនួនសត្វស្វានៅតំបន់ឧទ្យានអង្គរមានការកើនឡើងជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ប៉ុន្តែមួយរយៈចុងក្រោយនេះមានបុគ្គលមួយចំនួនតូចចាប់ផ្តើមផ្តល់ចំណីរហូតសត្វស្វាផ្លាស់ប្តូរទម្លាប់ និងបានថតជាវីដេអូសកម្មភាពសត្វស្វាទាំងនោះមកបង្ហោះក្នុងបណ្តាញសង្គម ដើម្បីស្វែងរកប្រាក់ចំណេញផ្ទាល់ខ្លួន។ សកម្មភាពផ្តល់ចំណី និងថតវីដេអូនេះ ក្រៅពីបង្កនូវភាពអនាធិបតេយ្យក៏បណ្តាលឱ្យសត្វស្វាមួយចំនួនផ្លាស់ប្តូរនូវធម្មជាតិរបស់ខ្លួនក្លាយទៅជាសត្វកាច ចេះដណ្តើមចំណី និងបង្ករបួសស្នាមដល់ភ្ញៀវទេសចរជាតិ-អន្តរជាតិ ប៉ះពាល់ដល់បដាព័ត៌មាន និងបានធ្វើឱ្យជ្រុះនូវថ្មប្រាសាទជាយថាហេតុ (រូបភាពភ្ជាប់ជូន)។ *សកម្មភាពកេងប្រវ័ញ្ចលើសត្វស្វានេះ ក៏ធ្លាប់ត្រូវបានក្រុមអង្គការការពារសិទ្ធិសត្វប្តឹងមករាជរដ្ឋាភិបាលកម្ពុជាឱ្យចេញវិធានការទប់ស្កាត់ផងដែរ។* ដើម្បីដោះស្រាយ ករណីចំពោះមុខ អាជ្ញាធរជាតិអប្សរា បានពិភាក្សាស្វែងរកដំណោះស្រាយសមស្របជាមួយដៃគូសហការពាក់ព័ន្ធ ដូចជារដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានសម្រេចឯកភាពកំណត់អត្តសញ្ញាណសត្វស្វាកាចមួយចំនួនទាំងនោះ ដើម្បីចាប់ចេញពីតំបន់ឧទ្យានអង្គរ យកទៅព្រលែងឱ្យរស់នៅតាមបែបធម្មជាតិនៅតំបន់ក្រៅឧទ្យានអង្គរ ក្រោមការចាត់ចែងផ្ទាល់ដោយរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលជាស្ថាប័នជំនាញផ្នែកសត្វព្រៃ។ ក្រុមការងារបានសម្រេចប្រើប្រាស់កាំភ្លើងបាញ់ដាក់ថ្នាំសណ្តំដើម្បីចាប់សត្វស្វាកាចទាំងនោះ ដែលបច្ចេកទេសនេះមិនមានហានិភ័យបណ្តាលឱ្យសត្វស្វាស្លាប់ ដូចដែលបណ្តាញទំនាក់ទំនងសង្គមមួយចំនួនបានលើកឡើងនោះឡើយ សូមពិនិត្យមើលបណ្តាញភ្ជាប់មកជាមួយ (https://m.facebook.com/story.php ?story_fbid=1312141449147562&id=289461581415559)។ ក្នុងពេលបច្ចុប្បន្ន សត្វស្វាទាំងនោះកំពុងត្រូវធ្វើចត្តាឡីស័កនៅឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅមុនយកទៅព្រលែងក្នុងព្រៃធម្មជាតិដូចមានបណ្តាញភ្ជាប់មកជាមួយ (https://www.facebook.com/412441342188097/posts/340456525297 5676/? d=n)។

Email: info@apsaraauthority.gov.kh
Website: http://www.apsaraauthority.gov.kh

ឆ្លៀតឱកាសនេះ អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ជូនបន្ថែមថា *នៅក្នុងប្រតិបត្តិការចាប់សត្វស្វាកាចកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២០ គឺបានចាប់តែសត្វស្វាកាចចំនួន១៦ក្បាលប៉ុណ្ណោះ រីឯសត្វស្វាស្លូតដទៃទៀតដែលរស់នៅជុំវិញប្រាសាទបាយ័ន្តគឺពុំមានការចាប់យកចេញនោះទេ។ ក្នុងនោះក៏ពុំបណ្តាលឱ្យមានសត្វស្វាពីក្បាលស្លាប់ដូចការលើកឡើងក្នុងបណ្តាញទំនាក់ទំនងសង្គមមួយចំនួនឡើយ។ អាជ្ញាធរជាតិអប្សរាសូមបញ្ជាក់ជូនថារាល់សត្វស្វា ដែលបានចាប់នោះសុទ្ធតែត្រូវបានអ្នកជំនាញ និងមន្ត្រី បុគ្គលិក អាជ្ញាធរជាតិអប្សរាប្រចាំទីតាំងផ្ទាល់បានបញ្ជាក់ថាជាសត្វស្វាកាចពិតប្រាកដមែន។* ដោយឡែក អាជ្ញាធរជាតិអប្សរាក៏បានធ្វើសេចក្តីជូនដំណឹងដល់សាធារណជនឱ្យបានជ្រាបផងដែរ អំពីការចាប់សត្វស្វាកាចមួយចំនួនចេញពីតំបន់អង្គរកាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០។ ក្នុងន័យនេះ សូមបងប្អូនប្រជាពលរដ្ឋមេត្តាជ្រាប និងសូមមេត្តាកុំបន្តចែកចាយព័ត៌មានមិនពិតដែលនាំឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងការរៀបចំគ្រប់គ្រងតំបន់អង្គរ ឱ្យមានភាពល្អប្រសើរ និងមានសុវត្ថិភាពដល់អ្នកទស្សនាគ្រប់ៗរូប។ ការបញ្ឈប់ចែកចាយព័ត៌មានមិនពិត ក៏ជាសកម្មភាពមួយចូលរួមដោយផ្ទាល់ក្នុងការលុបបំបាត់សកម្មភាពកេងចំណេញលើរូបភាពសត្វស្វាក្នុងតំបន់ឧទ្យានអង្គរផងដែរ។ អាជ្ញាធរជាតិអប្សរាសូមអំពាវនាវដល់ម្ចាស់នៃបណ្តាញទំនាក់ទំនងសង្គមមួយចំនួនឱ្យបញ្ឈប់នូវសកម្មភាពផ្សព្វផ្សាយព័ត៌មានវាយប្រហារអាជ្ញាធរមានសមត្ថកិច្ចដើម្បីផលចំណេញផ្ទាល់ខ្លួនតទៅទៀត និងងាកមកចូលរួមការពារនូវអ្វីដែលជាតម្លៃនៃអត្តសញ្ញាណជាតិវិញ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន និងចូលរួមសហការទាំងអស់គ្នា។

ថ្ងៃព្រហស្បតិ៍ ២រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
សៀមរាប ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

រូបភាពភ្ញៀវទេសចររងរបួសដោយសារសត្វស្វាកាចខាំ នៅប្រាសាទបាយ័ន

ខែធ្នូ ឆ្នាំ២០២០ ក្រុមការងារសហគមន៍អាជ្ញាធរជាតិអប្សរាបានអនុញ្ញាតឱ្យពលរដ្ឋក្នុងតំបន់អង្គរជួសជុលផ្ទះ និងសាងសង់សំណង់ស្រាលចំនួន១៩១ករណី

ផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

លទ្ធផលការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំខែធ្នូ ឆ្នាំ២០២០ បានចុះផ្សព្វផ្សាយអប់រំ និងចុះពិនិត្យការស្នើសុំ អនុញ្ញាតការជួសជុល និងសាងសង់តូចតាចទាំង៦គោលដៅស្រុក/ក្រុង ក្នុងតំបន់ឧទ្យានអង្គរ និងក្រៅតំបន់ឧទ្យានអង្គរបានចំនួន២៩៧ សំណើ ដែលក្នុងនោះបានអនុញ្ញាតជូនប្រជាពលរដ្ឋចំនួន១៩១សំណើ។

ក្នុងករណីអនុញ្ញាតជូនប្រជាពលរដ្ឋខាងលើ រួមមាននៅស្រុកប្រាសាទបាគងបានចំនួន២១ករណី ស្រុកអង្គរធំបានចំនួន៣៧ករណី ស្រុកពួកបានចំនួន៤៧ករណី ក្រុងសៀមរាបបានចំនួន៤៦ករណី និងស្រុកបន្ទាយស្រីបានចំនួន៣៤ករណី រួមទាំងក្រុមការងារក្រៅឧទ្យានអង្គរចំនួន៦សំណើ សរុប១៩១សំណើ។

ក្រៅពីនោះ ក្រុមការងារសហគមន៍បានចូលរួមក្នុងកិច្ចការមនុស្សធម៌ ជួយឧបត្ថម្ភថវិកាដល់ចាស់ជរា កុមារមានជំងឺជនពិការ គ្រួសារខ្វះខាតមួយចំនួន ចូលរួមក្នុងកិច្ចការសាសនា និងកម្មវិធីផ្សេងៗនៅក្នុងសហគមន៍ ថែមទាំងសំណេះសំណាលដល់ខ្នងផ្ទះប្រជាពលរដ្ឋ ដោះស្រាយសំណើតាមភូមិទាំង១១២ភូមិក្នុងតំបន់អង្គរ។

ជាគោលដៅបន្ត ក្រុមការងារសហគមន៍នៃអាជ្ញាធរជាតិអប្សរានឹងបន្តផ្សព្វផ្សាយ អប់រំប្រជាពលរដ្ឋឱ្យយល់កាន់តែច្បាស់ពីតួនាទី ភារកិច្ចរបស់អាជ្ញាធរជាតិអប្សរា ការប្រើប្រាស់ដីធ្លីក្នុងតំបន់ការពារនៃរមណីយដ្ឋានអង្គរ នីតិវិធីនៃការដាក់ពាក្យស្នើសុំជួសជុល និងសាងសង់ផ្ទះក្នុងឧទ្យានអង្គរឱ្យកាន់តែមានប្រសិទ្ធិភាព ទាន់ពេលវេលា។

សូមបញ្ជាក់ថា រាល់ការស្នើសុំច្បាប់ជួសជុល គឺពុំមានការបង់ប្រាក់ទេ៕

សារលិខិតថ្វាយព្រះពរ ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល

ផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

សារលិខិតថ្វាយព្រះពរ

សូមក្រាបបង្គំទូលថ្វាយ

ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងឱកាសដ៏នក្ខត្តឫក្សថ្លៃថ្លានៃឱកាសចូលឆ្នាំថ្មី ឆ្នាំសកល ដែលនឹងឈានមកដល់នៅថ្ងៃ៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែមករា គ.ស ២០២១

ទូលព្រះបង្គំយើងខ្ញុំទាំងអស់គ្នា សូមអភិវន្ទលើកហត្ថប្រណម្យបួងសួងដល់ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រិយានីខ្មែរគ្រប់ព្រះអង្គ ជាពិសេសឫទ្ធិបារមីនៃដួងព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** សូមព្រះអង្គតាមជួយបីបាច់ថែរក្សាអភិបាលប្រោះព្រំព្រះសព្ទសាធុការពរជ័យគ្រប់ប្រការ ថ្វាយចំពោះ **ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និងសម្តេចម៉ែ** សូមព្រះអង្គទាំងទ្វេទ្រង់ប្រកបដោយព្រះពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ដើម្បីគង់ប្រថាប់ជាម្លប់ដ៏ត្រជាក់ត្រជុំសម្រាប់ប្រជានុរាស្ត្រខ្មែរ ជានិច្ចនិរន្តរ៍។

សូមក្រាបបង្គំទូលថ្វាយពី

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា

ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក កម្មករ និងឆ្មាំទាំងអស់

សារលិខិតជូនពរ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល

ផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

សារលិខិតជូនពរ

សូមគោរពជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុនសែន

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ក្នុងឱកាសដ៏មហានក្ខត្តឫក្សថ្លៃថ្លានៃថ្ងៃចូលឆ្នាំថ្មី ឆ្នាំសកល ដែលនឹងឈានមកដល់នៅថ្ងៃ៣រោច ខែបុស្ស ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី០១ ខែមករា គ.ស ២០២១

យើងខ្ញុំទាំងអស់គ្នា សូមគោរពកោតសរសើរយ៉ាងស្មោះអស់ពីចិត្តចំពោះគំរូវីរភាពដ៏អង់អាចក្លាហាន ការលះបង់ និងពលិកម្មគ្រប់បែបយ៉ាង យកអស់កម្លាំងកាយចិត្តដឹកនាំនាវាកម្ពុជាប្រកបដោយគតិបណ្ឌិត និងដោយពុំចេះនឿយហត់ក្នុងការបំពេញនូវបេសកកម្មជាប្រវត្តិសាស្ត្រ ដើម្បីជាតិមាតុភូមិ និងប្រជាជន ជាពិសេសការផ្សះផ្សាបង្រួបបង្រួមជាតិ នាំមកនូវឯកភាពជាតិ ស្ថេរភាពនយោបាយ និងការអភិវឌ្ឍលើគ្រប់វិស័យ។

យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវកតញ្ញុតាធម៌ សូមលំឱនកាយបួងសួង ដល់គុណបុណ្យព្រះរតនត្រ័យវត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា សូមព្រះអង្គតាមជួយបីបាច់ថែរក្សា អភិបាលប្រោះព្រំ សព្ទសាធុការពរ បវរសួស្តី សិរីមង្គល វិបុលសុខមហាប្រសើរជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ព្រមទាំងក្រុមគ្រួសារ សូមបានប្រកប ដោយពុទ្ធពរបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមគោរពជូនពរពី

ឯកឧត្តម ហង់ ពៅ អគ្គនាយកអាជ្ញាធរជាតិអប្សរា

ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិក ភ្នាក់ងារ ពលករ និងឆ្មាំទាំងអស់

លិខិតជូនពរ លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលនៃអាជ្ញាធរជាតិអប្សរា ក្នុងឱកាសចូលឆ្នាំថ្មី ឆ្នាំសកល

ផ្សាយនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

ទីស្នាក់ការអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

មជ្ឈមណ្ឌលសេវាកម្មត្រូវបានបង្កើតឡើងដើម្បីកែលម្អការផ្ដល់សេវាសាធារណៈតាមយន្តការច្រកចេញ-ចូលតែមួយដោយគ្មានធ្វើប្រតិភូកម្មអំណាចក្នុងគោលដៅបម្រើប្រជាជនឱ្យបានប្រសើរជាងមុនតាមរយៈការប្រមូលផ្តុំសេវាកម្មរដ្ឋបាលឱ្យនៅកន្លែងតែមួយ និងកំណត់យ៉ាងច្បាស់លាស់នូវគុណភាព នីតិវិធី ពេលវេលាប្រគល់ឯកសារ និងថ្លៃសេវា។

ទីតាំងមជ្ឈមណ្ឌលសេវាកម្មនៃអាជ្ញាធរជាតិអប្សរា

១- ស្នាក់ការកណ្ដាលអាជ្ញាធរជាតិអប្សរា ស្ថិតនៅភូមិបង្កោង ឃុំអំពិល ស្រុកប្រាសាទបាគងខេត្តសៀមរាប
២- ភូមិមណ្ឌលបី សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប (តាមបណ្ដោយផ្លូវហ្សាលដឺហ្គោលឆ្ពោះទៅប្រាសាទអង្គរវត្ត)
៣- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលក្រុងសៀមរាប
៤- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកពួក
៥- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកអង្គរធំ
៦- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកបន្ទាយស្រី
៧- ច្រកចេញ-ចូលតែមួយរបស់រដ្ឋបាលស្រុកប្រាសាទបាគង
៨- និងតាមរយៈក្រុមការងារសហគមន៍របស់អាជ្ញាធរជាតិអប្សរាប្រចាំក្រុង-ស្រុកទាំង៥ (ចំពោះការស្នើសុំជួសជុលតូចតាច)

លេខទំនាក់ទំនង

សារអេឡិចត្រូនិច
sca_apsara@yahoo.com
លេខទូរស័ព្ទ
+៨៥៥ ៦៣ ៧៦ ៥៥ ៧៧

ម៉ោងបំពេញការងារ

ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ
ពេលព្រឹក ៖ ម៉ោង ៨:០០ព្រឹក - ម៉ោង ១២:០០ថ្ងៃត្រង់
ពេលរសៀល ៖ ម៉ោង ១៣:០០រសៀល - ម៉ោង ១៦:០០រសៀល

ផលិតដោយនាយកដ្ឋានផ្សព្វផ្សាយ
ឆ្នាំ២០២១